# អដ្ឋកថា បបញ្ចសូទនី

## នៃព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសក

## នវមភាគ

## លេខ ២៨

ពុទ្ធសករាជ ២៥៥៤

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសក

## នវមភាគ

## ភាគ ២៨

ឈ្មោះ

# បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៤

អធិប្បាយ

**វិភង្គវគ្គ - សឡាយតនវគ្គ**

រួមមាន ២០ សូត្រ

A

# ស្រៈនិងសៀរ្យ

# Signes et accents:



# ស្រៈពេញតួ
# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក | ខ | គ | ឃ | ង |
| ឡូប Romain | k | kh | g | gh | ṅ |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| សិង្ហ Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

# D

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |


Cambodgien
Romain
t ṭh ḍ ḍh ṇ
Siamois
Laotien
Cinghalais
Birman

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| រូម<br>Romain | *t* | *th* | *d* | *dh* | *n* |
| សៀម<br>Siamois | ต | ถ | ท | ธ | น |
| លាវ<br>Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| លង្កា<br>Cinghalais | ත | ථ | ද | ධ | න |
| ភូមា<br>Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຠ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ | រ | ល | វ | ស | ហ | ឡ | ំ | ៗ |
| រ៉ូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ° | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ° | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ° | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ° | ၊ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

**១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

**២ ទ្រង់សម្ដែងធម៌មានហេតុផល** ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍ សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធនុះក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្បាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញុំាញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្ពាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថាសង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ្ទ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធ: ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋ: ) ខ្លះ ( សិរិកូដ្ឋ: ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡ្ទ: និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធ: ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណ:សង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

| | |
|---|---|
| ឧបាសក ភ្លាត ហ៊ន | ឧបាសក នាក់ ម៉ៅ |
| ឧបាសក ឡុំ ឡូន | ឧបាសក ហុក សឹងហួត |
| ឧបាសក ជឹម ជំនិត | ឧបាសក កើត ឆិត្យ |
| ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន |
| ឧបាសក អ៊ឹម រ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត |
| ឧបាសក សំ ឆាយ | ឧបាសក ម៉ៅ ផុន |
| ឧបាសក ជា ស៊ីបាន | ឧបាសិកា ថាប់ លឿម |
| ឧបាសិកា ហាយ សារ៉ាត់ | ឧបាសិកា ប៊ុត សុម៉ាលី |
| ឧបាសិកា យស សម្បត្តិ | ឧបាសិកា ពូ ហ៊ាង |
| ឧបាសិកា ប៊ុត សេដាដួង | ឧបាសិកា មុំ |

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នូវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក ហុក សឹងហួត | ឧបាសក អ៊ឹម រ៉ៃយ៉ា |
| ឧបាសក ឈួន សំណាង | ឧបាសក ឃឿម សារ៉េន |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវិរក្សត្រ និងមហាវិរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

*ឈ្មោះធម៌* | *ទំព័រ*

## វិភង្គវគ្គ


| | |
|---|---|
| អដ្ឋកថា ភទ្ទេករត្តសូត្រ ទី ១ | ១ |
| អដ្ឋកថា អានន្ទភទ្ទេករត្តសូត្រ ទី ២ | ៧ |
| អដ្ឋកថា មហាកច្ចានភទ្ទេករត្តសូត្រ ទី ៣ | ៨ |
| *ស្រះតបោទា* | *៨* |
| អដ្ឋកថា លោមសកង្គិយភទ្ទេករត្តសូត្រ ទី ៤ | ១២ |
| *បណ្ឌុកម្ពលសិលាសនៈ* | *១២* |
| អដ្ឋកថា សុភសូត្រ ទី ៥ | ១៥ |
| *សុភមាណព បុត្តតោទេយ្យព្រាហ្មណ៍* | *១៥* |
| *អធិប្បាយ កម្មស្សកា ជាដើម* | *១៩* |
| *កម្ម ៤ ប្រភេទ* | *២១* |
| អដ្ឋកថា មហាកម្មវិភង្គសូត្រ ទី ៦ | ២៩ |
| *ការឲ្យផលរបស់កម្ម* | *៣២* |
| *អធិប្បាយបទ អភព្វំ* | *៣៧* |
| អដ្ឋកថា សឡាយតនវិភង្គសូត្រ ទី ៧ | ៣៩ |
| *បទថា អនិច្ចតំ* | *៤២* |

| | |
|---|---|
| បទថា អតីតំ | ៤៣ |
| អធិប្បាយ វេទនាអាស្រ័យផ្ទះ និងនេក្ខម្ម: | ៤៤ |
| បទថា នានត្តា | ៤៨ |
| **អដ្ឋកថា ឧទ្ទេសវិភង្គសូត្រ ទី ៨** | **៥២** |
| សេចក្តីតក់ស្លុត និងមិនតក់ស្លុត..... | ៥៣ |
| **អដ្ឋកថា អរណវិភង្គសូត្រ ទី ៩** | **៥៦** |
| បទថា សន្ទុក្ខោ | ៥៧ |
| បទថា សុភូតិ ច បន ភិក្ខវេ | ៥៩ |
| **អដ្ឋកថា ធាតុវិភង្គសូត្រ ទី ១០** | **៦១** |
| មិត្តភាពរវាងព្រះរាជាពិម្ពិសារ និងព្រះរាជាបុក្កុសាតិ | ៦២ |
| ព្រះរាជបណ្ណាការរបស់ព្រះរាជាបុក្កុសាតិ | ៦៥ |
| ព្រះរាជបណ្ណាការរបស់ព្រះរាជាពិម្ពិសារ | ៦៨ |
| ការទទួលរាជបណ្ណាការនៃព្រះរាជាបុក្កុសាតិ | ៧៦ |
| ព្រះរាជាបុក្កុសាតិទ្រង់ព្រះផ្នួស | ៧៩ |
| វត្តបដិបត្តិរបស់កុលបុត្តបុក្កុសាតិ | ៨១ |
| ការត្រាស់សម្តែងព្រះធម៌ដល់កុលបុត្តបុក្កុសាតិ | ៨៤ |
| ការត្រាស់សម្តែងព្រះធម៌របស់ព្រះមានព្រះភាគ | ៩២ |
| ការប្រៀបឧបមា | ១០៩ |
| ការស្វែងរកបរិក្ខាររបស់ព្រះបុក្កុសាតិ | ១១៣ |
| មរណកាលរបស់ព្រះបុក្កុសាតិ | ១១៦ |
| **អដ្ឋកថា សច្ចវិភង្គសូត្រ ទី ១១** | **១១៩** |
| ការសង្គ្រោះ ២ យ៉ាង | ១១៩ |

កពបី ប្រៀបដូចលាមក ១២១

**អដ្ឋកថា ទក្ខិណាវិភង្គសូត្រ ទី ១២** **១២៣**
ប្រវត្តិទក្ខិណារបស់ព្រះនាងមហាបជាបតិ ១២៣

បទថា ទុតិយម្បិ ខោ ១២៦
ការហាមរបស់ព្រះមានព្រះភាគ ១២៨
ទក្ខិណាដ៏ប្រសើរជាង....... ១២៩
ការធ្វើតបរបស់សិស្សចំពោះអាចារ្យ ១៣២
ទក្ខិណា ១៤ ប្រការ ១៣៣
បទថា ពុទ្ធប្បមុខេ ឧភតោសង្ឃេ ១៣៧
បទថា គោត្រភុនោ ១៣៩
សង្ឃគតាទក្ខិណាមានផលច្រើន ១៤១
បទថា ទាយកតោ វិសុជ្ឈតិ ១៤២
ទក្ខិណាដ៏ប្រសើរជាង....... ១២៩


## សឡាយតនវគ្គ


**អដ្ឋកថា អនាថបិណ្ឌិកោវាទសូត្រ ទី ១** **១៤៦**
អាយតនៈខាងក្នុង ១៤៧
លោកនេះ និងលោកខាងមុខ ១៤៨
អនាថបិណ្ឌិកទេវបុត្រចូលទៅគាល់ព្រះសាស្តា ១៥១
កម្ម វិជ្ជា និងជីវិតដ៏ឧត្តម ១៥២

**អដ្ឋកថា ឆន្នោវាទសូត្រ ទី ២** **១៥៥**
វេទនាដ៏ខ្លាំងក្លា ១៥៦

| | |
|---|---|
| **អដ្ឋកថា បុណ្ណោវាទសូត្រ ទី ៣** | ១៥៩ |
| ពាក្យថា ទូន្មានចិត្ត | ១៦១ |
| ប្រវត្តិរបស់ព្រះបុណ្ណៈ | ១៦២ |
| ភ្នំសច្ចពន្ធ | ១៧០ |
| ហេតុទ្រង់ប្រតិស្ឋានស្នាមព្រះបាទនៅឆ្នេរស្ទឹងនិម្មទា | ១៧១ |
| ទ្រង់ប្រតិស្ឋានស្នាមព្រះបាទត្រង់ភ្នំសច្ចពន្ធ | ១៧២ |
| **អដ្ឋកថា នន្ទកោវាទសូត្រ ទី ៤** | ១៧៤ |
| ប្រវត្តិព្រះនន្ទកៈ | ១៧៥ |
| ឧបមាបញ្ហា | ១៨២ |
| **អដ្ឋកថា ចូឡរាហុលោវាទសូត្រ ទី ៥** | ១៨៤ |
| សេចក្តីបរិសុទ្ធិនៃឥន្ទ្រិយ..... | ១៨៤ |
| ការតាំងសេចក្តីប្រាថ្នារបស់ព្រះរាហុល | ១៨៦ |
| **អដ្ឋកថា ឆឆក្កសូត្រ ទី ៦** | ១៨៨ |
| ក្នុងពាក្យថា ភិក្ខុប្រមាណ ៦០ រូប | ១៩១ |
| ការសម្តែងធម៌របស់ព្រះមាលេយ្យទេវត្ថេរ | ១៩២ |
| **អដ្ឋកថា មហាសឡាយតនសូត្រ ទី ៧** | ១៩៥ |
| បទថា សុខផ្លូវកាយ ផ្លូវចិត្ត | ១៩៦ |
| អធិប្បាយ អង្គរបស់មគ្គ | ១៩៦ |
| ពាក្យថា យុគនទ្ធា | ១៩៨ |
| **អដ្ឋកថា នគរវិន្ទេយ្យសូត្រ ទី ៨** | ១៩៩ |
| **អដ្ឋកថា បិណ្ឌបាតបារិសុទ្ធិសូត្រ ទី ៩** | ២០១ |

អដ្ឋកថា ឥន្ទ្រិយភាវនាសូត្រ ទី ១០ ២០៤
វិបស្សនូបេក្ខា ២០៥
ជាអ្នកសម្គាល់ក្នុងវត្ថុគួរខ្ពើម.... ២០៦

អវសាន្តកថា ២០៩

# អដ្ឋកថា សុត្តន្តបិដក មជ្ឈិមនិកាយ

## ឧបរិបណ្ណាសក

## ឈ្មោះ បបញ្ចសូទនី

## លេខ ២៨

# វិភង្គវគ្គ

## អ ដ្ឋ ក ថា

### ភទ្ទេករត្តសូត្រទី ១

**[១]** *ភទ្ទេករត្តសូត្រ មានពាក្យដើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖*

*ក្នុងភទ្ទេករត្តសូត្រនោះ បទថា **ភទ្ទេករត្តស្ស** សេចក្តីថា ឈ្មោះថាអ្នកមានរាត្រីមួយចម្រើន ព្រោះគេជាអ្នកដល់ព្រមដោយការតាម ប្រកបវិបស្សនា ។*

*បទថា **ឧទ្ទេសំ** បានដល់ មាតិកា ។ បទថា **វិភង្គំ** បានដល់ បទដែលគប្បីចែកឲ្យពិស្តារ ។*

**[២]** បទថា **អតីតំ** បានដល់ ក្ខន្ធ ៥ ដែលកន្លងហើយ ។ បទថា **នាន្វាគមេយ្យ** សេចក្ដីថា មិនគួរនឹកដល់ ដោយតណ្ហា និងទិដ្ឋិទាំងឡាយ ។ បទថា **នប្បដិកង្ខេ** សេចក្ដីថា មិនគប្បីប្រាថ្នាដោយតណ្ហា និងទិដ្ឋិទាំងឡាយ ។ បទថា **យទតីតំ** នេះ ក្នុងគាថានេះ ជាការពោលដល់ហេតុ ។ ព្រោះវត្ថុណាកន្លងទៅហើយ វត្ថុនោះក៏លះបង់ទៅហើយ រលត់ទៅហើយ ដល់ការតាំងនៅមិនបាន ព្រោះដូច្នោះ បុគ្គលមិនគួរនឹកគិតដល់វត្ថុដែលកន្លងទៅហើយនោះទៀត ។ មួយទៀត ព្រោះវត្ថុណានៅមិនទាន់មកដល់ វត្ថុនោះក៏នៅមិនទាន់មកដល់ នៅមិនទាន់កើត នៅមិនទាន់កើតឡើង ព្រោះដូច្នោះ បុគ្គលមិនគប្បីប្រាថ្នាវត្ថុដែលនៅមិនទាន់មកដល់សូម្បីនោះ ។ បទថា **តត្ថ តត្ថ** សេចក្ដីថា បុគ្គលអ្នកចូលដល់ធម្មៈសូម្បីបច្ចុប្បន្ន ក្នុងធម្មៈណាៗ ឃើញច្បាស់នូវធម្មៈនោះ ដោយអនុបស្សនា ៧ យ៉ាង មានអនិច្ចានុបស្សនាជាដើម ក្នុងធម្មៈនោះៗ តែម្យ៉ាង ។ ម្យ៉ាងទៀត បុគ្គលឃើញច្បាស់ក្នុងធម្មៈនោះៗ ក្នុងទីទាំងឡាយមានព្រៃជាដើម ។

បទថា **អសំហិរំ អសង្កុប្បំ** នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដើម្បីសម្ដែងវិបស្សនា និងបដិវិបស្សនា ។ ពិតហើយ វិបស្សនា រមែងមិនរសេមរសាម

រមែងមិនញាប់ញ័រដោយកិលេសទាំងឡាយ មានរាគៈជាដើម ព្រោះដូច្នោះ វិ-
បស្សនានោះឈ្មោះថា **អសំហិរំ អសំកុប្បំ** ។ លោកពោលអធិប្បាយថា បុគ្គល
គប្បីចម្រើនឲ្យរឿយៗ គប្បីធ្វើឲ្យច្រើន គប្បីឃើញច្បាស់ចំពោះវិបស្សនានោះ ។
មយ៉ាងទៀត **និព្វាន** រមែងមិនរសេមរសាម រមែងមិនញាប់ញ័រ ដោយកិលេស
ទាំងឡាយ មានរាគៈជាដើម ព្រោះដូច្នោះ និព្វាននោះ ទើបឈ្មោះថា **អសំហិរំ
អសំកុប្បំ** ប្រែថា មិនរសេមរសាម មិនញាប់ញ័រ ។ អធិប្បាយថា ភិក្ខុជា
បណ្ឌិតដឹងច្បាស់ហើយ គប្បីចម្រើនឲ្យរឿយៗ នូវនិព្វាននោះ គឺ កាលនៅ
មិនទាន់សម្រេចផលសមាបត្តិដែលមានព្រះនិព្វាននោះជាអារម្មណ៍ ក៏គប្បីចម្រើន
រឿយៗ ។ ដើម្បីប្រយោជន៍ដល់ភិក្ខុអ្នកចម្រើននោះ ។ បទថា **អជ្ជេវ កិច្ចំ
អាតប្បំ** សេចក្ដីថា សេចក្ដីព្យាយាមដែលបានឈ្មោះថា អាតប្បៈ ព្រោះដុត
កិលេសទាំងឡាយ ឬញុំាងកិលេសទាំងឡាយឲ្យក្ដៅសព្វ គប្បីធ្វើក្នុងថ្ងៃនេះ
ឯង ។ បាទគាថាថា **កោ ជញ្ញា មរណំ សុវេ** សេចក្ដីថា នរណាហ្ន៎ នឹងដឹងថា
ការរស់នៅ ឬសេចក្ដីស្លាប់មានក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងថា
គប្បីធ្វើសេចក្ដីព្យាយាមយ៉ាងនេះថា ក៏សេចក្ដីឃឹតយូរ រមែងមានក្នុងថ្ងៃនេះ
ប៉ុណ្ណោះថា យើងនឹងធ្វើទាន ឬនឹងរក្សាសីល ក៏ឬនឹងធ្វើកុសលយ៉ាងណាមួយ

ក្នុងថ្ងៃនេះឯង យើងមិនញុំាងចិត្តឲ្យកើតឡើងថា យើងនឹងដឹងក្នុងថ្ងៃស្អែក ឬក្នុងថ្ងៃខានស្អែក នឹងធ្វើក្នុងថ្ងៃនេះឯង ។ បទថា **មហាសេនេន** សេចក្តីថា ក៏ហេតុនៃសេចក្តីស្លាប់ មានច្រើនយ៉ាង មានភ្លើង ថ្នាំពិស និងសស្ត្រាជាដើម គឺ ជាសេនារបស់មច្ចុរាជនោះ ការពន្យាពេល ពោលគឺ ការចងមេត្រីភាពយ៉ាងនេះថា លោកចូររង់ចាំពីរ-បីថ្ងៃសិន រហូតដល់ខ្ញុំនឹងធ្វើកម្មជាទីពឹងរបស់ខ្លួន មានការបូជាព្រះពុទ្ធជាដើម ឬពោលគឺ ការឲ្យថ្លៃឈ្នួលយ៉ាងនេះថា លោកចូរកាន់យកមួយរយ ឬមួយពាន់នេះហើយ រង់ចាំពីរ-បីថ្ងៃ ឬពោលគឺ កងពលយ៉ាងនេះថា យើងនឹងច្បាំងតបតដោយកងពលនេះ ដូច្នេះ នឹងមច្ចុរាជបែបនេះដែលមានសេនាធំ ដោយអំណាចនៃសេនាដ៏ធំនោះ រមែងមិនមាន ។ ក៏បទថា **សង្គរោ** ការពន្យាពេលនោះ ជាឈ្មោះនៃការចងមេត្រីភាព ការឲ្យថ្លៃឈ្នួល និងកងពល ។ ព្រោះដូច្នោះ សេចក្តីនេះបានពោលហើយ ។

បទថា **អតន្ទិតំ** បានដល់ អ្នកមិនខ្ជិលច្រអូស គឺ ឧស្សាហ៍ ។ បុគ្គលនោះឈ្មោះថា អ្នកមានរាត្រីមួយដ៏ចម្រើន ព្រោះបុគ្គលនោះជាអ្នកបដិបត្តិយ៉ាងនេះ ព្រោះដូច្នោះ បុគ្គលនោះឈ្មោះ **ភទ្ទេករត្តោ** អ្នកមានរាត្រីមួយដ៏ចម្រើន ។ ព្រះមុនី គឺ ព្រះពុទ្ធជាម្ចាស់ ឈ្មោះថា ទ្រង់ស្ងប់ហើយ ព្រោះកិលេសទាំងឡាយ

មានរាគៈជាដើមស្ងប់ហើយ ត្រាស់ហៅបុគ្គលដែលបដិបត្តិយ៉ាងនេះថា បុគ្គលនេះ អ្នកមានរាត្រីមួយដ៏ចម្រើន ដោយប្រការដូច្នេះ ។

[៣] ក្នុងបទទាំងឡាយ មានជាដើមថា **ឯវំ រូបោ** សូម្បីមានរូបខ្មៅមានវណ្ណៈដូចកែវមណីឥន្ទនីល ។ ឬបទថា **អហោសឹ** សេចក្តីថា យើងមានរូបយ៉ាងនេះ ដោយអំណាចនៃរូបដែលគប្បីពេញចិត្តយ៉ាងនេះតែម្យ៉ាង ។ យើងមានវេទនាយ៉ាងនេះ ដោយអំណាចនៃសុខវេទនា និងសោមនស្សវេទនាដែលជាកុសល ។ មានសញ្ញាយ៉ាងនេះ ដោយអំណាចនៃធម៌ទាំងឡាយ មានសញ្ញាជាដើម ដែលប្រកបព្រមដោយវេទនានោះឯង មានសង្ខារយ៉ាងនេះ មានវិញ្ញាណយ៉ាងនេះ ។ បទថា **អតីតមន្វានំ** សេចក្តីថា រំពឹងដល់សេចក្តីរីករាយក្នុងរឿងនោះៗ បានដល់ រំពឹង បណ្តោយតាមតណ្ហាក្នុងរូបជាដើមនោះ ។ រមែងមិនសម្គាល់ថា យើងជាអ្នកមានរូបយ៉ាងនេះ ដោយអំណាចនៃរូបដែលអាក្រក់ជាដើម ។ល។ មានវិញ្ញាណយ៉ាងនេះ ។

[៤] បទថា **នន្ទឹ ន សមន្វានេតិ** សេចក្តីថា តណ្ហា ឬទិដ្ឋិដែលសម្បយុត្តដោយតណ្ហា ដែលបុគ្គលរមែងមិនឲ្យប្រព្រឹត្តទៅ ។

[៥] គប្បីជ្រាបការរំពឹងដល់សេចក្តីត្រេកអរ ពោលគឺ ការប្រព្រឹត្តទៅ

នៃតណ្ហា និងទិដ្ឋិ ដោយអំណាចនៃរូបដ៏ប្រណីត និងគប្បីពេញចិត្តជាដើមនោះឯង សូម្បីក្នុងបទថា **ឯវំ រូបោ សិយំ** ជាដើម ។

**[៧]** បទថា **កថញ្ច ភិក្ខវេ បច្ចុប្បន្នេសុ ធម្មេសុ សហិរតិ** នេះ ទ្រង់ត្រាស់ដើម្បីសម្តែងពង្រីកឧទ្ទេសថា ក៏បុគ្គលឃើញច្បាស់ធម៌បច្ចុប្បន្នក្នុងធម៌នោះៗ ដែលមិនរសេមរសាម មិនញាប់ញ័រ ។ ក៏បទថា **កថញ្ច ភិក្ខវេ បច្ចុប្បន្នំ ធម្មំ ន វិបស្សតិ** ជាដើម ត្រាស់ទុកក្នុងព្រះសូត្រនេះក៏ពិត សូម្បីយ៉ាងនោះ ក៏នៅត្រាស់ដល់វិបស្សនាថា មិនរសេមរសាម មិនញាប់ញ័រ ព្រោះដូច្នោះ ដើម្បីទ្រង់សម្តែងការមាន និងការមិនមាននៃវិបស្សនានោះឯង ទើបទ្រង់តាំងមាតិកាថា បុគ្គលមិនរសេមរសាម មិនញាប់ញ័រ ដូច្នេះ ហើយត្រាស់សេចក្តីពិស្តារ ។ បណ្តាបទទាំងនោះ បទថា **សំហិរតិ** សេចក្តីថា បុគ្គលឈ្មោះថា ត្រូវតណ្ហា និងទិដ្ឋិទាញទៅ ព្រោះមិនមានវិបស្សនា ។ បទថា **ន សំហិរតិ** សេចក្តីថា ឈ្មោះថា មិនត្រូវតណ្ហា និងទិដ្ឋិទាញទៅ ព្រោះមានវិបស្សនា ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ភទ្ទេករត្តសូត្រទី ១

# អ ដ្ឋ ក ថា

## អានន្ទភទ្ទេករត្តសូត្រទី ២

**[១០]** *អានន្ទភទ្ទេករត្តសូត្រ* មានពាក្យដើមថា *ឯវម្មេ សុតំ* ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖

**[១១]** *បណ្តាបទទាំងនោះ បទថា* **បដិសល្លានា វុដ្ឋិតោ** *សេចក្តីថា ទ្រង់ចេញចាកផលសមាបត្តិ ។ បទថា* **កោ នុ ខោ ភិក្ខវេ** *សេចក្តីថា ព្រះមានព្រះភាគទ្រង់ដឹងនោះឯង ទ្រង់ត្រាស់សួរដើម្បីតាំងរឿងឡើង ។*

**[២០]** *បទថា* **សាធុ សាធុ** *សេចក្តីថា ទ្រង់ប្រទានសាធុការដល់ព្រះថេរៈ ។ បទថា* **សាធុ ខោ ត្វំ** *សេចក្តីថា ទ្រង់ត្រាស់សរសើរទេសនាហើយព្រោះទេសនាដែលព្រះថេរៈសម្តែងដោយបទ និងព្យញ្ជនៈទាំងឡាយ មូលក្តី បរិសុទ្ធិល្អ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា អានន្ទភទ្ទេករត្តសូត្រទី ២

# អ ដ្ឋ ក ថា

## មហាកច្ចានភទ្ទេករត្តសូត្រទី ៣

[២៣] មហាកច្ចានភទ្ទេករត្តសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៖

បណ្ដាបទទាំងនោះ បទថា **តបោទារាមេ** សេចក្ដីថា ក្នុងអារាមដែលមានឈ្មោះយ៉ាងនេះ ដោយអំណាចនៃស្រះឈ្មោះ តបោទៈ គឺ មានទឹកក្ដៅ ។ បានឮថា ខាងក្រោមភ្នំវេភារៈ មានពិភពនាគប្រមាណ ៥ រយយោជន៍ របស់នាគដែលនៅក្នុងផែនដីទាំងឡាយ ដូចគ្នានឹងទេវលោក ដល់ព្រមដោយផ្ទៃរាបស្មើ ដែលសម្រេចដោយកែវមណី និងសួនឧទ្យានជាទីមនោរម្យទាំងឡាយ ។ ក្នុងស្ថានទីលេងរបស់នាគទាំងឡាយក្នុងពិភពនាគនោះ មានស្រះទឹកដ៏ធំ ។ ស្ទឹងឈ្មោះ **តបោទា** មានទឹកក្ដៅពុះកញ្ជ្រោលហូរអំពីស្រះនោះ ។ ក៏ព្រោះហេតុអ្វីស្ទឹងនោះ ទើបជាដូច្នេះ ។ បានឮថា លោកនៃប្រេតធំលោមព័ទ្ធក្រុងរាជគ្រឹះ ។ ស្ទឹងតបោទានេះ មកក្នុងចន្លោះមហាលោហកុម្ភីនរកទាំងពីរ ក្នុងមហាប្រេតលោកនោះ ។ ព្រោះដូច្នោះ ស្ទឹងតបោទានោះ ទើបក្ដៅពុះកញ្ជ្រោល

ហូរមក ។ សមពិតដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ស្ទឹងតបោទានេះ រមែងហូរដោយប្រការដែលស្រះនោះមានទឹកថ្លាស្អាត ត្រជាក់ ស មានកំពង់ល្អ រីករាយ មានត្រី និងអណ្តើកច្រើន និងមានបទុមប្រមាណប៉ុនខ្នងកង់រីកស្គុះស្គាយ មួយទៀត ស្ទឹងតបោទានេះ ហូរកន្លងវាំងមហានរកទាំងពីរ ព្រោះហេតុនោះ ស្ទឹងតបោទានេះ ទើបក្តៅពុះកញ្ជ្រោលហូរមក ដូច្នេះ ។ ក៏ស្រះទឹកដ៏ធំ ដែលកើតខាងមុខអារាមនេះ ។ ដោយអំណាចនៃឈ្មោះស្រះទឹកដ៏ធំនោះ អារាមនេះ ទើបហៅថា **តបោទារាម** ។

**[២៤]** បទថា *សមិទ្ធិ* សេចក្តីថា ន័យថា អត្តភាពរបស់ព្រះថេរៈនោះល្អិតល្អន់ មានរូបស្អាត គួរជ្រះថ្លា ព្រោះដូច្នោះ ទើបដល់ការរាប់ថា សមិទ្ធិ ។ បទថា **អាទិព្រហ្មចរិយកោ** បានដល់ ជាខាងដើមនៃមគ្គព្រហ្មចរិយ គឺ ជាវត្ត-បដិបត្តិក្នុងចំណែកខាងដើម ។

**[២៦]** បទថា *ឥទំ វត្វា សុគតោ ឧដ្ឋាយាសនា* ជាដើម គប្បីឲ្យពិស្តារដោយន័យដែលពោលហើយក្នុងមធុបណ្ឌិកសូត្រ ។

**[៣១]** បទថា *ឥតិ មេ ចក្ខុំ* សេចក្តីថា ន័យថា ព្រះមានព្រះភាគទ្រង់តាំងមាតិកាដោយអំណាចនៃអាយតនៈ ១២ ក្នុងសូត្រនេះ ។ ព្រះមានព្រះភាគ

ទ្រង់ធ្វើមាតិកា និងវិភង្គ ដោយអំណាចនៃខន្ធ ៥ ក្នុងបីសូត្រនេះ គឺ ក្នុងខាងក្រោយពីរសូត្រ និងក្នុងខាងមុខមួយសូត្រដែលជាសូត្រទីបួន តែក្នុងសូត្រនេះ ចំណែកព្រះថេរៈបានចែកន័យថា **មាតិកាវ បឋិតា** ទើបពោលយ៉ាងនេះ ដើម្បីចែកអាយតនៈ ១២ ។ ក៏ព្រះថេរៈកាលបានន័យនេះ បានធ្វើការៈធ្ងន់ ។ គឺ សម្តែងស្នាមជើងក្នុងទីមិនមានស្នាមជើង ធ្វើស្នាមជើងក្នុងអាកាស ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅដល់ព្រះសូត្រនេះតែម្យ៉ាង ទើបទ្រង់តាំងព្រះថេរៈនោះទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ មហាកច្ចាយនៈជាអ្នកកំពូលលើសភិក្ខុទាំងឡាយ អ្នកជាសាវករបស់តថាគត ដែលចែកសេចក្តីនៃភាសិតដោយសង្ខេប ឲ្យពិស្តារបាន ។

ក៏ក្នុងសូត្រនេះ បទថា **ចក្ខុំ** បានដល់ ចក្ខុបសាទ ។ បទថា **រូបា** បានដល់ រូបទាំងឡាយដែលមានសមុដ្ឋានបួន ។ គប្បីជ្រាបសូម្បីអាយតនៈដ៏សេសដោយន័យនេះ ។ បទថា **វិញ្ញាណំ** បានដល់ វិញ្ញាណដែលកើតរួមជាមួយតណ្ហា ។ បទថា **តទភិនន្ទតិ** សេចក្តីថា រីករាយក្នុងចក្ខុ និងរូបនោះ ដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ បទថា **អន្វាគមេតិ** សេចក្តីថា ទៅតាមដោយអំណាចតណ្ហា និងទិដ្ឋិទាំងឡាយ ។ ក៏ក្នុងបទថា **ឥតិ មេ មនោ អហោសិ ឥតិ ធម្មា**

*នោះ បទថា **មនោ** បានដល់ ភវង្គចិត្ត ។ បទថា **ធម្មា** បានដល់ ធម្មារម្មណ៍ ដែលប្រព្រឹត្តទៅក្នុងភូមិបី ។*

**[៣៣]** *បទថា **បណិទហតិ** គឺ តាំងទុកដោយអំណាចនៃសេចក្តីប្រាថ្នា ។ បទថា **បណិធានបច្ចយា** បានដល់ ព្រោះតាំងសេចក្តីប្រាថ្នាទុក គឺ ព្រោះហេតុ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា មហាកច្ចានភទ្ទេករត្តសូត្រទី ៣

# អ ដ្ឋ ក ថា

## លោមសកង្គិយភទ្ទេករត្តសូត្រទី ៤

[៤០] *លោមសកង្គិយភទ្ទេករត្តសូត្រ មានពាក្យជាដើមថា* ***ឯវម្មេ សុតំ*** *ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖*

*បណ្តាបទទាំងនោះ បទថា* ***លោមសកង្គិយោ*** *គឺ បានឮថា លោមស-កង្គិយៈនោះ ជាឈ្មោះព្រះត្ថេរៈអង្គនោះ ។ ក៏ព្រះថេរៈនោះ ប្រាកដឈ្មោះថា លោមសកង្គិយៈ ព្រោះអាការនៃកាយមានរោមតិចតួច ។ បទថា* ***ចន្ទនោ ទេវ-បុត្តោ*** *សេចក្តីថា បានឮថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា កស្សបៈ ឧបាសកឈ្មោះថា ចន្ទនៈ ជាអ្នកស្តុកស្តម មានទ្រព្យច្រើន បូជាព្រះរតនៈទាំងបីដោយបច្ច័យបួន ស្លាប់ហើយទៅកើតក្នុងទេវលោក ដែលរាប់បានថា ចន្ទនទេវបុត្រ ដោយឈ្មោះដែលមានក្នុងជាតិមុន ។*

[៤២] *បទថា* ***បណ្ឌុកម្ពលសិលាយំ*** *បានដល់ ក្នុងកម្ពលសិលាសនៈពណ៌ក្រហម ។ បានឮថា ពណ៌របស់កម្ពលសិលាសនៈពណ៌ក្រហមនោះ មានពណ៌ដូចគំនរផ្កាចម្បា ព្រោះដូច្នោះ ទើបហៅថា* ***បណ្ឌុកម្ពលសិលាសនៈ*** *។*

សួរថា ព្រះមានព្រះភាគស្ដេចប្រថាប់លើបណ្ឌុកម្ពលសិលាសនៈនោះ ក្នុងកាលណា ។ ឆ្លើយថា ក្នុងវស្សាទី ៧ បន្ទាប់ពីការត្រាស់ដឹង ទ្រង់ធ្វើយមកបាដិហារ្យក្នុងកណ្ដាលនៃបរិស័ទប្រមាណ ១២ យោជន៍ ក្នុងថ្ងៃពេញ-បូណ៌មីខែអាសាឍ ជិតក្រុងសាវត្ថី ស្ដេចប្រថាប់អង្គុយលើពុទ្ធាសនៈដែលក្រាលទុកហើយជិតគល់ដើមគណ្ឌម្ព ទ្រង់ញ៉ាំងមហាជនឲ្យចេញចាកទុក្ខធំដោយព្រះធម៌ទេសនា ព្រោះធម្មតាព្រះពុទ្ធទាំងឡាយ លុះទ្រង់ធ្វើបាដិហារ្យហើយនឹងមិនប្រថាប់នៅក្នុងដែនដីមនុស្ស ព្រោះដូច្នោះ ទើបទ្រង់ធ្វើឲ្យផុតពីជនមកគាល់ ស្ដេចទៅចាំព្រះវស្សាក្នុងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិចត្តក្នុងភពតាវត្តិង្ស ប្រថាប់នៅក្នុងសម័យនោះ ។

បទថា **តត្រ ភគវា** សេចក្ដីថា ព្រះមានព្រះភាគ កាលប្រថាប់នៅក្នុងភពតាវត្តិង្សនោះ ដែលទេវតាម៉ឺនចក្រវាឡមកប្រជុំហែហមហើយ ទ្រង់សម្ដែងព្រះអភិធម្មបិដកដល់ព្រះមាតាឲ្យជាកាយសក្ខី បានត្រាស់ ឧទ្ទេស និងវិភង្គ នៃបុគ្គលដែលមានរាត្រីមួយដ៏ចម្រើនតាមលំដាប់ ដើម្បីឲ្យកើតសេចក្ដីសង្វេគដល់ពួកទេវតា ដែលមិនអាចចាក់ធ្លុះនូវកថា ដែលកំណត់រូប និងអរូប ដ៏ជ្រាលជ្រៅល្អិតល្អន់ប្រកបដោយត្រៃលក្ខណ៍ ។

ក្នុងទីនោះ ទេវបុត្រនេះ កាលនឹងរៀន បានរៀនគាថាទាំងនេះ ព្រមទាំងវិភង្គ តែព្រោះទេវបុត្រនោះតាំងនៅក្នុងសេចក្តីប្រមាទ ត្រូវអារម្មណ៍ដែលជាទិព្វទាំងឡាយគ្របសង្កត់ ទើបភ្លេចព្រះសូត្រដោយលំដាប់ ចាំបានត្រឹមតែគាថាប៉ុណ្ណោះ ។ ដោយហេតុនោះ ទេវបុត្រទើបពោលថា ម្នាលភិក្ខុ ខ្ញុំទ្រទ្រង់ចាំគាថា រាត្រីតែមួយដ៏ចម្រើនយ៉ាងនេះឯង ។

[៤៣] ក្នុងបទថា ឧគ្គណ្ហាហិ ត្វំ ជាដើម ជាអ្នកស្ដៀម អន្ទ្រយស្ដាប់ ឈ្មោះថា រៀន ។ កាលធ្វើការស្វាធ្យាយដោយវាចា ឈ្មោះថា រៀនសូត្រ ។ កាលប្រាប់ដល់បុគ្គលពួកដទៃ ឈ្មោះថា ទ្រទ្រង់ចាំ ។ បទដសេសក្នុងសូត្រនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា លោមសកង្គិយភទ្ទេករត្តសូត្រទី ៨

# អ ដ្ឋ ក ថា

## សុភសូត្រទី ៥[១]

**[៥៤]** *សុភសូត្រ* មានពាក្យផ្ដើមថា *ឯវម្មេ សុតំ* ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៖

ក្នុងសូត្រនោះ បទថា **សុភោ** សេចក្ដីថា បានឮថា គេជាអ្នកគួរមើលគួរជ្រះថ្លា ។ ដោយហេតុនោះ ញាតិទាំងឡាយទើបតាំងឈ្មោះគេថា **សុភៈ** ព្រោះគេមានអវយវៈល្អស្អាត ។ តែបានហៅគេថា មាណពក្នុងកាលជាកម្លោះ ។ គេត្រូវហៅដោយវោហារនោះឯង សូម្បីក្នុងកាលជាមនុស្សចាស់ ។ បទថា **តោទេយ្យបុត្តោ** បានដល់ បុត្ររបស់ព្រាហ្មណ៍បុរោហិត របស់ព្រះបាទបសេនទិកោសល ឈ្មោះថា **តោទេយ្យៈ** ។ បានឮថា គេដល់ការរាប់ថា តោទេយ្យៈ ព្រោះគេជាធំនៃស្រុកឈ្មោះថា តុទិគ្រាម ដែលនៅជិតក្រុងសាវត្ថី ។ ក៏គេជាអ្នកមានទ្រព្យច្រើន មានសម្បត្តិដល់ ៨៧ កោដិ តែមានសេចក្ដីកំណាញ់ ។

កាលនីងឲ្យក៏គិតថា ដែលឈ្មោះថា ការបំណាយភោគៈទាំងឡាយមិន

---

១-ក្នុងបិដកជា ចូឡកម្មវិភង្គសូត្រ ។

អស់មិនមាន ទើបមិនឲ្យអ្វីដល់អ្នកណាៗ ។ សមដូចពាក្យដែលលោកពោលទុកថា ៖

បណ្ឌិតឃើញការអស់ទៅនៃថ្នាំបន្តក់ភ្នែកទាំងឡាយ ការសន្សំរបស់សត្វកណ្ដៀរទាំងឡាយ និងការរួបរួមរបស់ឃ្មុំទាំងឡាយហើយ គប្បីនៅគ្រប់គ្រងផ្ទះ ។

គេឲ្យសម្គាល់យ៉ាងនេះ រហូតអស់កាលយូរនោះឯង ។ គេមិនឲ្យវត្ថុត្រឹមតែយាគូមួយវែក ឬកត្តមួយវែក ចំពោះព្រះសម្មាសម្ពុទ្ធ ដែលប្រថាប់នៅក្នុងវិហារជិត ធ្វើកាលកិរិយាដោយសេចក្ដីលោភក្នុងទ្រព្យ ទៅកើតជាសុនខក្នុងផ្ទះនោះឯង ។ សុកៈ ស្រឡាញ់សុនខនោះណាស់ ឲ្យស៊ីភត្តដែលខ្លួនបរិភោគនោះឯង លើកឲ្យដេកក្នុងទីដេកដ៏ប្រសើរ ។

ថ្ងៃមួយ ព្រះមានព្រះភាគទ្រង់ត្រួតមើលលោក ក្នុងសម័យជិតភ្លឺ ទ្រង់ឃើញសុនខនោះហើយ ទ្រង់ត្រិះរិះថា "តោទេយ្យព្រាហ្មណ៍ស្លាប់ទៅកើតជាសុនខក្នុងផ្ទះរបស់ខ្លួននោះឯង ព្រោះសេចក្ដីលោភក្នុងទ្រព្យ ថ្ងៃនេះ កាលតថាគតទៅកាន់ផ្ទះរបស់សុកៈ សុនខឃើញតថាគតហើយ នឹងធ្វើការព្រុស លំដាប់នោះតថាគតនឹងពោលពាក្យមួយដល់សុនខនោះ សុនខនោះនឹងដឹងតថាគតថា ជា

សមណគោតម ហើយទៅដេកក្នុងចង្ក្រានភ្លើង ព្រោះប្រការនោះជាហេតុ សុភៈនឹងមានការសន្ទនាមួយនឹងតថាគត សុភៈនោះស្តាប់ធម៌ហើយ នឹងតាំងនៅក្នុងសរណៈទាំងឡាយ ចំណែកសុនខស្លាប់ទៅហើយ នឹងកើតក្នុងនរក” ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីដែលមាណពនឹងតាំងនៅក្នុងសរណៈទាំងឡាយនេះហើយ ក្នុងថ្ងៃនោះទ្រង់បដិបត្តិព្រះសរីរៈ ស្តេចទៅកាន់ផ្ទះនោះ ដើម្បីបិណ្ឌបាត ដោយខណៈជាមួយគ្នានឹងមាណពចេញទៅកាន់ស្រុក ។ សុនខឃើញព្រះមានព្រះភាគហើយ ធ្វើការព្រុស ទៅជិតព្រះមានព្រះភាគ ។ បន្ទាប់ពីនោះព្រះមានព្រះភាគ បានត្រាស់ពាក្យនេះចំពោះសុនខនោះថា នែ៎តោទេយ្យៈ អ្នកធ្លាប់ពោលចំពោះតថាគតថា លោកដ៏ចម្រើនៗ ទៅកើតជាសុនខ សូម្បីឥឡូវនេះ ធ្វើការព្រុសហើយ នឹងទៅកាន់អវិចីនរក ដូច្នេះ ។ សុនខស្តាប់ព្រះតម្រាស់នោះហើយ ដឹងថា ជាសមណគោតម មានសេចក្តីក្តៅក្រហាយ ឱនកទៅដេកក្នុងកម្មេចផេះក្នុងចន្លោះចង្ក្រានភ្លើង ។ មនុស្សមិនអាចនឹងលើកឲ្យដេកលើទីដេកដ៏ប្រសើរបាន ។ សុភៈមក ហើយនិយាយថា អ្នកណាលើកសុនខនេះចុះពីទីដេកហ្ន៎ ។ មនុស្សនិយាយថា មិនមានអ្នកណាលើកសុនខនេះចុះទេ ហើយប្រាប់រឿងរ៉ាវនោះ ។ មាណពស្តាប់ហើយក្រោធថា បិតារបស់យើងទៅកើត

ក្នុងព្រហ្មលោក មិនមានសុនខឈ្មោះតោទេយ្យៈ តែព្រះសមណគោតម ទ្រង់ធ្វើបិតាឲ្យជាសុនខ ព្រះសមណគោតមនោះ និយាយមើលងាយ ដូច្នេះ ជាអ្នកប្រាថ្នានឹងគ្របសង្កត់ព្រះមានព្រះភាគ ដោយពាក្យកុហក ទើបទៅកាន់វត្តទូលសួរប្រវត្តិនោះ ។

សូម្បីព្រះមានព្រះភាគ ក៏ត្រាស់យ៉ាងនោះឯង ដល់សុភមាណពនោះ ដើម្បីមិនឲ្យប្រកែក ទើបត្រាស់ថា ម្នាលមាណព ក៏ទ្រព្យដែលបិតារបស់អ្នកមានទុក មិនបានប្រាប់ទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មានមួកមាសតម្លៃមួយសែន ស្បែកជើងមាសតម្លៃមួយសែន និងកហាបណៈមួយសែន ។ អ្នកឯងចូរទៅ ចូរសួរសុនខនោះក្នុងវេលាឲ្យស៊ីបាយបាយាសមានទឹកតិច ហើយលើកឡើងក្នុងទីដេក ពេលលក់បន្តិច វានឹងប្រាប់ទ្រព្យទាំងអស់ដល់អ្នក លំដាប់នោះ អ្នកនឹងដឹងសុនខនោះថា គេជាបិតារបស់អ្នក ។ មាណពសប្បាយចិត្តដោយហេតុ ២ ប្រការ គឺ បើជាការពិត យើងនឹងបានទ្រព្យ បើមិនជាការពិត យើងនឹងគ្របសង្កត់ព្រះសមណគោតម ដោយពាក្យកុហក ដូច្នេះ ហើយទៅធ្វើយ៉ាងនោះ ។ សុនខដឹងថា យើងដែលមាណពនេះដឹងហើយ ក៏ធ្វើសំឡេងស្រែក វូស វូស ទៅកាន់ទីកប់ទ្រព្យ កកាយផែនដីដោយជើង ហើយឲ្យសញ្ញា ។

មាណពកាន់យកទ្រព្យហើយ មានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគថា ធម្មតាទីដែលបិទបាំងទ្រព្យប្រាកដជារបស់ល្អិត នៅក្នុងចន្លោះបដិសន្ធិយ៉ាងនេះ នោះជាសព្វញ្ញុរបស់ព្រះសមណគោតមពិតប្រាកដ ។ ទើបរួបរួមបញ្ហា ១៤ បញ្ហា ។ន័យថា មាណពនោះជាអ្នកសម្ដែងរៀនក្នុងវិជ្ជាផ្លូវកាយ ។ ដោយហេតុនោះមាណពនោះ ទើបមានការគិតថា យើងកាន់ធម្មបណ្ណាការនេះហើយ នឹងទូលសួរបញ្ហាចំពោះព្រះសមណគោតម ។ ដោយការទៅលើកទីពីរ ទើបចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

**[៥៦]** តែព្រះមានព្រះភាគ ទ្រង់ដោះស្រាយបញ្ហាទាំងឡាយ ដែលមាណពនោះទូលសួរ ត្រឹមតែម្ដងប៉ុណ្ណោះ ទើបត្រាស់ថា **កម្មស្សកា** ជាដើម ។

ក្នុងបទនោះ កម្មជារបស់សត្វទាំងនោះ គឺ ជាភណ្ឌៈរបស់ខ្លួន ព្រោះដូច្នោះ សត្វទាំងនោះឈ្មោះថា មានកម្មជារបស់ខ្លួន ។ សត្វទាំងឡាយជាទាយាទនៃកម្ម ព្រោះដូច្នោះ សត្វទាំងនោះឈ្មោះថា ជាទាយាទនៃកម្ម អធិប្បាយថាកម្មជាទាយាទ គឺ ជាភណ្ឌៈរបស់សត្វទាំងនោះ ។ កម្មជាកំណើត គឺ ជាហេតុរបស់សត្វទាំងនោះ ព្រោះដូច្នោះ សត្វទាំងនោះឈ្មោះថា មានកម្មជាកំណើត ។កម្មជាផៅពង្សរបស់សត្វទាំងនោះ ព្រោះដូច្នោះ សត្វទាំងនោះឈ្មោះថា មានកម្ម

ជាផៅពន្ធុ អធិប្បាយថា មានកម្មជាញាតិ ។ កម្មជាទីពឹងអាស្រ័យ គឺ ជាទីតាំងរបស់សត្វទាំងនោះ ព្រោះដូច្នោះ សត្វទាំងនោះឈ្មោះថា មានកម្មជាទីពឹងអាស្រ័យ ។ បទថា **យទិទំ ហីនប្បណីតតាយ** សេចក្ដីថា កម្មណាចែកឲ្យថោកទាប និងប្រណីត យ៉ាងនេះថា បុគ្គលថោកទាប បុគ្គលប្រណីត អ្នកមានអាយុតិច អ្នកមានអាយុវែង អ្នកមិនមានបញ្ញា អ្នកមានបញ្ញា ដូច្នេះ អ្នកដទៃណាមិនធ្វើកម្មនោះ កម្មនោះឯង រមែងចែកសត្វទាំងឡាយយ៉ាងនេះ ។ មាណពមិនដឹងសេចក្ដីនៃឧទ្ទេសដែលទ្រង់សម្ដែង ។ ដូចជាចងមាត់របស់មាណពនោះដោយសំពត់សាច់ក្រាស់ ហើយដាក់របស់ផ្អែមទុកខាងមុខ ។ បានឮថា មាណពនោះអាស្រ័យមានះ ប្រកាន់ខ្លួនថាជាបណ្ឌិត រមែងពិចារណាឃើញខ្លួន ។

លំដាប់នោះ ព្រះមានព្រះភាគ ដើម្បីទ្រង់កាច់បំបាក់មានះរបស់មាណពនោះថា មានះនេះថា ព្រះសមណគោតមត្រាស់អ្វី យើងរមែងដឹងវត្ថុដែលត្រាស់នោះឯង កុំបានមានដូច្នេះ ទើបត្រាស់ធ្វើឲ្យយល់បានដោយលំបាក តថាគតនឹងសម្ដែងធ្វើឲ្យយល់បានលំបាកតាំងពីខាងដើមនោះឯង បន្ទាប់ពីនោះ មាណពនឹងសូមតថាគតថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹង សូមព្រះអង្គទ្រង់សម្ដែងធ្វើឲ្យប្រាកដដល់ខ្ញុំព្រះអង្គដោយពិស្ដារ លំដាប់នោះ តថាគតនឹងសម្ដែង

ដល់គេក្នុងវេលាសូមអង្វរ កាលដូច្នេះ ក៏នឹងជាប្រយោជន៍ដល់មាណពនោះ ដូច្នេះ ។ ឥឡូវនេះ មាណពនោះកាលនឹងប្រកាសសេចក្ដីដែលខ្លួនជាអ្នកមិនយល់ ទើបទូលថា **ន ខោ អហំ** ដូច្នេះជាដើម ។

**[៥៧]** បទថា **សមត្តេន** បានដល់ បរិបូណ៌ ។ បទថា **សមាទិន្នេន** បានដល់ កាន់យកហើយ គឺ ស្ទាបអង្អែលហើយ ។

បទថា **អប្បាយុកសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ បាណាតិបាតី** សេចក្ដីថា កម្មក្នុងការញ៉ាំងជីវិតសត្វឲ្យធ្លាក់ចុះនេះណា នោះបដិបទាប្រព្រឹត្តទៅដើម្បីមានអាយុខ្លី ។

ក៏បដិបទានោះ រមែងធ្វើឲ្យមានអាយុខ្លីយ៉ាងណា ។ ក៏កម្មមាន ៤ ប្រភេទ គឺ ឧបបីឡកកម្ម ឧបច្ឆេទកកម្ម ជនកកម្ម ឧបត្ថម្ភកកម្ម ។ ក៏ឧបបីឡកកម្មក្នុងប្រវត្តិដែលកើតដោយកម្មដែលមានកម្លាំង មកនិយាយដោយសេចក្ដីយ៉ាងនេះថា បើយើងដឹងមុន មិនគប្បីឲ្យកម្មនោះកើតក្នុងទីនេះ គប្បីឲ្យវាកើតក្នុងអបាយទាំងបួន ចូរលើកទុក អ្នកឯងកើតក្នុងទីណាមួយ យើងបៀតបៀនកម្មដែលឈ្មោះថា ឧបបីឡកកម្មនោះ នឹងធ្វើឲ្យប្រាសចាកអំពីរស ប្រាសចាកជ័រស្អិត ឲ្យគ្មានតម្លៃ ចាប់ផ្ដើមតាំងពីនោះ នឹងធ្វើវាឲ្យជាដូច្នោះ ។ ធ្វើយ៉ាងណា

គឺ នាំអន្តរាយចូលមក ញ៉ាំងភោគៈឲ្យវិនាស ។ ព្រោះកម្មនោះ ចាប់ផ្ដើមពីកាលដែលទារកកើតក្នុងផ្ទៃមាតា មាតារមែងមិនមានសេចក្ដីធូរចិត្ត ឬមិនមានសេចក្ដីសុខ និងសេចក្ដីបៀតបៀន រមែងកើតដល់បិតាមាតា រមែងនាំអន្តរាយចូលមកយ៉ាងនេះ ។ ក៏ចាប់ផ្ដើមពីកាលដែលទារកកើតក្នុងផ្ទៃមាតា ភោគៈទាំងឡាយក្នុងផ្ទះ រមែងវិនាសដោយអំណាចនៃព្រះរាជាជាដើម ដូចអំបិលត្រូវទឹក ។ មេគោទាំងឡាយដែលប្របាច់ទឹកដោះដាក់ក្នុងភាជន៍ ក៏មិនចេញទឹកដោះ ហ្វូងគោទីងខ្លាំងក្លាប្រទូសរ៉ាយ មានភ្នែកខ្វាក់ពិការ រោគទីងរាតត្បាត (ធ្លង) ក្នុងក្រោលគោ បរិវារជនមានទាសៈជាដើម មិនស្ដាប់បង្គាប់ ស្រូវដែលសាបព្រោះទុកក៏មិនកើត ស្រូវដែលនៅក្នុងផ្ទះរមែងវិនាសក្នុងផ្ទះ ស្រូវដែលនៅក្នុងព្រៃក៏វិនាសក្នុងព្រៃ វត្ថុត្រឹមតែថាបំបាត់សេចក្ដីស្រេកឃ្លាន ក៏រកបានលំបាកដោយលំដាប់ ។ គ្រឿងរក្សាគភ៌ក៏មិនមាន ។ វេលាទារកប្រសូតហើយ ទឹកដោះរបស់មាតាក៏ទីងអស់ ។ ទារកកាលមិនបានរក្សា ក៏ត្រូវបៀតបៀន ប្រាសចាករសស្និតស្រពោន គ្មានតម្លៃ នេះឈ្មោះថា **ឧបបីឡកកម្ម** ។ ចំណែកកាលបុគ្គលកើតហើយ ដោយកម្មដែលធ្វើឲ្យមានអាយុវែង ឧបច្ឆេទកកម្មក៏មកកាត់បង់នូវអាយុ ។ ដូចបុរសធ្វើការដោយគោឈ្មោល ៨ ក្បាល បាញ់កូនសរ ម្នាក់ទៀត

ក៏វាយកូនសរនោះ ត្រឹមតែថា របូតចេញពីធ្នូ ដោយឈើញញួរឲ្យធ្លាក់ចុះក្នុងទីនោះ យ៉ាងណា ឧបច្ឆេទកកម្ម រមែងកាត់បង់នូវអាយុរបស់ខ្លួនដែលកើតហើយដោយកម្មដែលធ្វើឲ្យមានអាយុវែង ដូច្នោះ ។ ធ្វើយ៉ាងណា ។ ចោរឲ្យបុគ្គលនោះចូលទៅកាន់ព្រៃ ឲ្យលុយទឹកដែលមានត្រីកាច ។ ក៏ឬនាំចូលកាន់ស្ថានទីអន្តរាយដទៃ ។ នេះឈ្មោះថា **ឧបច្ឆេទកកម្ម** ។ ឧបច្ឆេទកកម្មនោះឯង មានឈ្មោះថា **ឧបឃាតកកម្ម** ដូច្នេះខ្លះ ។ ចំណែកកម្មដែលឲ្យបដិសន្ធិ ឈ្មោះថា **ជនកកម្ម** ។ កម្មដែលជួយឧបត្ថម្ភ ដោយការធ្វើឲ្យដល់ព្រមដោយភោគៈជាដើម ដល់បុគ្គលដែលកើតក្នុងត្រកូលទាំងឡាយ មានត្រកូលមានភោគៈតិចជាដើម ឈ្មោះថា **ឧបត្ថម្ភកកម្ម** ។

ក្នុងកម្ម ៤ ប្រភេទនេះ កម្ម ២ ប្រភេទខាងដើម ជាអកុសលតែម្យ៉ាង ។ ក្នុងកម្មទាំងនោះ បាណាតិបាតកម្ម រមែងប្រព្រឹត្តទៅដើម្បីមានអាយុខ្លី ដោយសភាពជាឧបច្ឆេទកកម្ម ។ ឬកុសលកម្ម ដែលបុគ្គលមានប្រក្រតីញុំាងជីវិតសត្វឲ្យធ្លាក់ចុះ រមែងមិនឱឡារ ។ រមែងមិនអាចដើម្បីញុំាងបដិសន្ធិដែលមានអាយុវែងកើតឡើង ។ បាណាតិបាត រមែងប្រព្រឹត្តទៅដើម្បីឲ្យអាយុខ្លី ដោយប្រការដូច្នេះ ។ ឬកំណត់បដិសន្ធិប៉ុណ្ណោះ ធ្វើឲ្យមានអាយុខ្លី ។ ឬរមែងកើត

ក្នុងនរកដោយសន្និដ្ឋានចេតនា ។ ជាហេតុឲ្យមានអាយុខ្លី ដោយន័យពោលហើយ ដោយបុព្វចេតនា និងអបរចេតនា ។

[៥៨] ក្នុងបទថា **ទីឃាយុកសំវត្តនិកា ឯសា មាណវ បដិបទា** នេះ កម្មដែលវៀរចាកបាណាតិបាតយ៉ាងនេះ ក្នុងប្រវត្តិ ដែលកើតដោយកម្មបន្តិចបន្តួច មកពោលយ៉ាងនេះ ដោយសេចក្ដីថា បើយើងដឹងមុន មិនគប្បីឲ្យអ្នកឯងកើតក្នុងទីនេះ នឹងគប្បីឲ្យអ្នកឯងកើតក្នុងទេវលោកប៉ុណ្ណោះ ណ្ហើយចុះ អ្នកឯងនឹងកើតក្នុងទីណាក៏ដោយ យើងនឹងធ្វើការឧបត្ថម្ភ ។ ធ្វើយ៉ាងណា ។ គឺញុំាងអន្តរាយឲ្យវិនាស ញុំាងភោគៈទាំងឡាយឲ្យកើតឡើង ។ ព្រោះឧបត្ថម្ភកកម្មនោះ បិតាមាតារមែងមានសេចក្ដីសុខតែម្យ៉ាង រមែងជួរស្រោលចិត្តតែម្យ៉ាងចាប់តាំងពីកាលដែលទារកកើតក្នុងផ្ទៃមាតា ។ អន្តរាយពីមនុស្ស និងអមនុស្សដោយប្រក្រតីពួកណា អន្តរាយទាំងអស់នោះ រមែងប្រាសទៅ ។ រមែងញុំាងអន្តរាយឲ្យវិនាសយ៉ាងនេះ ។ ប្រមាណនៃភោគៈទាំងឡាយក្នុងផ្ទះ ដែលមិនមាន ចាប់ផ្ដើមពីកាលដែលទារកកើតក្នុងផ្ទៃមាតា ។ រណ្ដៅទ្រព្យទាំងឡាយរមែងមករួមនៅក្នុងផ្ទះ ទាំងខាងមុខទាំងខាងក្រោយ ។ បិតាមាតា រមែងព្រមចំពោះមុខនូវទ្រព្យដែលបុគ្គលទាំងនោះនាំមកឲ្យ ។ មេគោទាំងឡាយ រមែងមាន

ទឹកដោះច្រើន ។ ហ្វូងគោរមែងនៅជាសុខ ។ ស្រូវទាំងឡាយក្នុងទីសាបព្រោះ រមែងសម្បូរណ៍ ។ បុគ្គលទាំងឡាយដែលមិនមានអ្នកណាជាស់តឿន រមែងនាំទ្រព្យដែលប្រកបដោយសេចក្ដីចម្រើន ឬទ្រព្យដែលគេឲ្យមួយរយៈមកឲ្យឯង ។ បរិវារជនទាំងឡាយ មានទាសៈជាដើម ក៏នឹងជាអ្នកប្រដៅងាយ ។ ការងារទាំងឡាយក៏មិនសាបសូន្យ ។ ទារក រមែងបានរក្សាចាប់តាំងពីនៅក្នុងគភ៌ ។ ពេទ្យជាប់ទាក់ទងនឹងក្មេងទាំងឡាយក៏នឹងមកជួបជុំ ។ ទារកដែលកើតក្នុងត្រកូលគហបតីនឹងបានតំណែងសេដ្ឋី ដែលកើតក្នុងត្រកូលទាំងឡាយ មានត្រកូលអាមាត្យជាដើម ក៏នឹងបានតំណែងទាំងឡាយ មានតំណែងសេនាបតីជាដើម ។ រមែងឲ្យភោគៈទាំងឡាយកើតឡើងដោយប្រការដូច្នេះ ។ គេមិនមានអន្តរាយ មានភោគៈ រមែងមានអាយុវែង ។ កម្ម គឺ ការមិនសម្លាប់សត្វ រមែងប្រព្រឹត្តទៅដើម្បីឲ្យមានអាយុវែង យ៉ាងនេះ ។ ឬកុសលសូម្បីដទៃរបស់បុគ្គលដែលមិនសម្លាប់សត្វធ្វើទុក រមែងឱឡារ ។ រមែងអាចដើម្បីញ៉ាំងបដិសន្ធិ ដែលឲ្យមានអាយុវែងកើតឡើង ។ រមែងប្រព្រឹត្តទៅឲ្យមានអាយុវែង សូម្បីយ៉ាងនេះ ។ ឬកំណត់បដិសន្ធិប៉ុណ្ណោះ ធ្វើឲ្យមានអាយុវែង ។ ឬរមែងកើតក្នុងទេវលោកដោយសន្និដ្ឋានចេតនា ។ រមែងឲ្យមានអាយុវែង ដោយន័យពោលហើយ ដោយ

បុព្វចេតនា និងអបរចេតនា ។ គប្បីជ្រាបសេចក្តីក្នុងការដោះស្រាយបញ្ហាទាំងពួង ដោយន័យនេះ ។

ក៏កម្មទាំងឡាយ សូម្បីមានការបៀតបៀនជាដើម មកក្នុងបវត្តិកាលហើយ ដូចពោលយ៉ាងនេះ ដោយអត្ថ រមែងធ្វើកិច្ចទាំងឡាយ មានការអាពាធច្រើនជាដើម ដោយហេតុទាំងឡាយ មានការញុំាងរោគឲ្យកើតឡើងជាដើម ដល់បុគ្គលដែលប្រាសចាករោគៈ ដោយការបៀតបៀន មិនមានការបដិបត្តិ ឬដោយសភាពនៃកុសលដែលបុគ្គលបៀតបៀនជាដើមធ្វើហើយ ជាធម្មជាតិមិនឱឡារ ឬដោយការកំណត់បដិសន្ធិតាំងពីខាងដើមនោះឯង ឬដោយអំណាចនៃបុព្វចេតនា និងអបរចេតនា ដោយន័យពោលហើយនោះឯង កម្មទាំងឡាយមានការមិនបៀតបៀនជាដើម រមែងធ្វើសូម្បីជាអ្នកមានអាពាធតិចទាំងឡាយ ដូចការមិនសម្លាប់សត្វ ដូច្នោះ ។

**[៦៣]** ក៏ក្នុងបទទាំងនោះ បទថា **ឥស្សាមនកោ** បានដល់ មានចិត្តប្រកបដោយសេចក្តីច្រណែន ។ បទថា **ឧបទុស្សតិ** សេចក្តីថា ជេរដោយអំណាចនៃសេចក្តីច្រណែននោះឯង ប្រទូសរ៉ាយ ។ បទថា **ឥស្សំ ពន្ធតិ** សេចក្តីថា រមែងចងឥស្សាទុក ដូចក្តាប់បាយ ដូចក្តាប់ដោយប្រការមិនឲ្យសាបសូន្យ ។

បទថា **អប្បេសក្ខោ** សេចក្តីថា មានបរិវារតិច គឺ មិនប្រាកដដូចកូនសរដែលបាញ់ក្នុងពេលយប់ ។ មានដៃស្មោកគ្រោកអគ្គិយហើយ រមែងមិនបានសូម្បីអ្នកឲ្យទឹក ។

**[៦៥]** បទថា **ន ទាតា ហោតិ** សេចក្តីថា ជាអ្នកមិនឲ្យ ដោយអំណាចនៃសេចក្តីកំណាញ់ ។ បទថា **តេន កម្មេន** បានដល់ កម្ម គឺ សេចក្តីកំណាញ់នោះ ។

**[៦៧]** បទថា **អភិវាទេ តព្វំ** គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬព្រះអរិយ-សាវក អ្នកសមគួរដល់ការអភិវាទ ។

ក្នុងបទទាំងឡាយ សូម្បីមានអ្នកគួរក្រោកឡើងទទួលជាដើម ក៏ន័យនេះដូចគ្នា ។ មិនគួរកាន់យកឧបបីឡកកម្ម និងឧបគ្គកកម្មក្នុងការដោះស្រាយបញ្ហានេះ ។ ព្រោះមិនអាចធ្វើឲ្យដល់អ្នកមានត្រកូលថោកទាប អ្នកមានត្រកូលខ្ពង់ខ្ពស់ក្នុងបវត្តិកាល ។ តែកម្មរបស់អ្នកកើតក្នុងត្រកូលថោកទាប កំណត់បដិសន្ធិនោះឯង ឲ្យកើតក្នុងត្រកូលថោកទាប កម្មដែលជំនួយឲ្យកើតក្នុងត្រកូលខ្ពង់ខ្ពស់ រមែងឲ្យកើតក្នុងត្រកូលខ្ពង់ខ្ពស់ ។

**[៦៩]** រមែងកើតក្នុងនរក ដោយការមិនបានដេញដោលសួរ ក្នុងបទ

*នេះថា **ន បរិបុច្ឆិតា ហោតិ** ។ ក៏អ្នកមិនដេញដោលសួរ រមែងមិនដឹងថា នេះគួរធ្វើ នេះមិនគួរធ្វើ ។ កាលមិនដឹង រមែងមិនធ្វើវត្ថុដែលគួរធ្វើ រមែងធ្វើវត្ថុដែលមិនគួរ រមែងកើតក្នុងនរកដោយកម្មនោះ ។ បុគ្គលក្រៅពីនេះ រមែងកើតក្នុងសួគ៌ ។*

**[៧១]** *បទថា **ឥតិ ខោ មាណវ ។បេ។ យទិទំ ហីនប្បណីតតាយ** សេចក្តីថា ព្រះសាស្តាទ្រង់ញុំាងទេសនាឲ្យចប់តាមអនុសន្ធិ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សុភសូត្រ ទី៩

# អ ដ្ឋ ក ថា

## មហាកម្មវិភង្គសូត្រទី ៦

**[៧៣]** មហាកម្មវិភង្គសូត្រ មានពាក្យចាប់ផ្តើមថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖

**[៧៤]** ក្នុងសូត្រនោះ បទថា **មោឃំ** បានដល់ ទទេ មិនមានផល ។ បទថា **សច្ចំ** បានដល់ ពិត មានពិត ។ ក៏សេចក្តីនេះ ដែលបរិព្វាជកបោតលិបុត្រនោះ មិនបានស្តាប់មកចំពោះព្រះភក្ត្រ ។ តែមនោកម្មដែលមានទោសច្រើនជាង បានបញ្ញត្តិទុកហើយក្នុងឧបាលិសូត្រ ។ ពាក្យនេះថា កាយកម្មមិនជាយ៉ាងនោះ វចីកម្មមិនជាយ៉ាងនោះ នៃការធ្វើកម្មអាក្រក់ នៃការប្រព្រឹត្តទៅរបស់កម្មអាក្រក់ ដែលព្រះមានព្រះភាគត្រាស់ហើយ ។ កថានោះកើតប្រាកដក្នុងចន្លោះតិរ្ថិយទាំងឡាយ ។ បរិព្វាជកបោតលិបុត្រ គឺ យកកថានោះពោល ។ ពោលពាក្យនេះថា ក៏សមាបត្តិនោះមាន ដូច្នេះ សំដៅដល់ **អភិសញ្ញានិរោធកថា** ដែលកើតហើយក្នុងបោដ្ឋបទសូត្រថា ម្នាលអ្នកដ៏ចម្រើន អភិសញ្ញានិរោធមានយ៉ាងណាហ្ន៎ ។ បទថា **ន កិញ្ចិ វេទិយតិ** សេចក្តីថា មិនសោយសូម្បីវេទនា

ណាមួយ ។ បទថា **អត្ថិ ច ខោ** សេចក្តីថា ព្រះថេរៈរមែងទទួលដឹង សំដៅដល់និរោធសមាបត្តិ ។ បទថា **បរិរក្ខិតព្វំ** សេចក្តីថា គប្បីរក្សាដោយការដោះពីពាក្យតិះដៀល ។ សេចក្តីផ្គងចិត្តនៃកម្មនោះមាន ព្រោះដូច្នោះ កម្មនោះឈ្មោះថា **សពេ្វតនិកំ** ប្រែថា ប្រកបដោយសេចក្តីផ្គងចិត្ត ដែលមានសេចក្តីបំណងប្រាថ្នា ។ បទថា **ទុក្ខំ** សេចក្តីថា ព្រះថេរៈសំដៅដល់អកុសលប៉ុណ្ណោះទើបពោលយ៉ាងនេះ ដោយសម្គាល់ថា បរិព្វាជកនឹងសួរ ។

**[៧៦]** បទថា **ទស្សនម្បិ ខោ អហំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ឃើញសន្ធារស្មូម្បីត្រឹមតែប៉ុនគ្រាប់ល្ង ក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញក្នុងទីងងឹតសូម្បីមានអង្គប្អូន ដោយមំសចក្ខុនោះឯង ។ ក៏បរិព្វាជកនេះ នៅក្នុងទីមិនឆ្ងាយ ខាងក្នុងប្រមាណមួយគាវុត ។ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ ឆ្លើយថា ព្រោះត្រាស់បំណងដល់ការឃើញសមាគមនោះឯង ។

**[៧៧]** បទថា **ឧទាយិ** គឺ ព្រះលោឡុទាយី ។ បទថា **តំ ទុក្ខស្មឹ** បានដល់ ទុក្ខទាំងអស់នោះឯង ។ ពោលថា ប្រសិនបើព្រះមានព្រះភាគ គប្បីមានភាសិតដូច្នេះ សំដៅដល់វដ្តទុក្ខ កិលេសទុក្ខ និងសង្ខារទុក្ខនេះ ដោយប្រការ

ដូច្នេះ ។

បទថា **ឧម្មង្គំ** បានដល់ ការប្រាកដចេញមកនៃបញ្ញា ។ បទថា **ឧម្មុជ្ជ-មានោ** បានដល់ ងើបសីសៈ ។ បទថា **អយោនិសោ ឧម្មុជ្ជិស្សតិ** បានដល់ ងើបសីសៈឡើងដោយមិនមានឧបាយ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ដឹងរឿងនេះ មិនមែនទ្រង់ដឹងដោយទិព្វចក្ខុ ចេតោបរិយញ្ញាណ និងសព្វញ្ញុតញ្ញាណ ។ តែទ្រង់ដឹងដោយអធិប្បាយប៉ុណ្ណោះ ។ ក៏កាលពោលធម្មតា អធិប្បាយក៏ដឹងបានដោយងាយ អ្នកប្រាថ្នានឹងពោល រមែងដកក ញ័រចង្កា មាត់របស់គេក៏អេចអូច មិនអាចនៅស្ងៀមបាន ។ ព្រះមានព្រះភាគទ្រង់ឃើញអាការនោះ របស់ព្រះឧទាយីនោះហើយ ទ្រង់មើលហើយថា ឧទាយីនេះ មិនអាចនឹងស្ងប់ស្ងៀមបាន នឹងពោលពាក្យដែលមិនពិតនោះឯង ទ្រង់បានដឹងហើយ ។ បទថា **អាទីយេវ** គឺ ក្នុងខាងដើមនោះឯង ។ បទថា **តិស្សោ វេទនា** សេចក្ដីថា បរិព្វាជកបោតលិបុត្រ កាលនឹងសួរថា បុគ្គលនោះនឹងសោយអ្វី ក៏កំណត់យ៉ាងនេះថា យើងនឹងសួរវេទនាបី ដូច្នេះ ហើយទើបសួរវេទនាបី ។ បទថា **សុខវេទនីយំ** បានដល់ ជាបច្ច័យនៃសុខវេទនា ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

ក៏ក្នុងទីនេះ ឈ្មោះថា កម្មដែលឲ្យផលជាសុខ ព្រោះកើតសុខវេទនាក្នុងខណៈបដិសន្ធិ និងបវត្តិកាល យ៉ាងនេះគឺ ចេតនា ៤ ដែលសម្បយុត្តដោយចិត្តដែលសហគតដោយសោមនស្ស ដោយកាមាវចរកុសល ចេតនាក្នុងឈានពួក ៣ ខាងក្រោម ។

ក៏ក្នុងទីនេះ **កាមាវចរ** រមែងញ៉ាំងសុខដោយចំណែកមួយឲ្យកើតឡើងក្នុងខណៈបដិសន្ធិនោះឯង ។ រមែងញ៉ាំងអទុក្ខមសុខឲ្យកើតឡើង ក្នុងមជ្ឈត្តារម្មណ៍ ដែលគួរប្រាថ្នាដែលប្រព្រឹត្តទៅហើយ ។ អកុសលចេតនា ឈ្មោះថាឲ្យផលជាទុក្ខ ព្រោះកើតទុក្ខប៉ុណ្ណោះ ក្នុងខណៈបដិសន្ធិ និងបវត្តិកាល ។

លុះកាយទ្វារប្រព្រឹត្តទៅហើយ ក៏ញ៉ាំងទុក្ខដោយចំណែកមួយនោះឲ្យកើតឡើង ។ រមែងញ៉ាំងអទុក្ខមសុខឲ្យកើតឡើងក្នុងវារៈដទៃ ។ ក៏វេទនានោះ ដល់ការរាប់ថា ទុក្ខនោះឯង ព្រោះកើតឡើងក្នុងអារម្មណ៍ទាំងឡាយដែលជាកណ្តាល ដែលមិនគួរប្រាថ្នានោះឯង ។ ក៏ឈ្មោះថា កម្មឲ្យផលជាអទុក្ខមសុខ ព្រោះកើតវេទនាទីបីក្នុងខណៈបដិសន្ធិ និងបវត្តិកាលយ៉ាងនេះ គឺ វេទនា ៤ ដែលសម្បយុត្តដោយចិត្ត ដែលសហគតដោយឧបេក្ខា ដោយកាមាវចរកុសល វេទនាក្នុងចតុត្ថជ្ឈានដោយរូបាវចរកុសល ។ ក៏ញ៉ាំងអទុក្ខមសុខដោយ

ចំណែកមួយ ឲ្យកើតក្នុងកាមាវចរបដិសន្ធិនោះឯង ។ ញ៉ាំងសូម្បីសុខឲ្យកើតក្នុងឥដ្ឋារម្មណ៍ដែលប្រព្រឹត្តទៅហើយ ។ មួយទៀត កម្មដែលឲ្យផលជាសុខរមែងប្រព្រឹត្តទៅដោយអំណាចនៃការប្រព្រឹត្តទៅនៃបដិសន្ធិ ។ កម្មដែលឲ្យផលជាអទុក្ខមសុខ រមែងប្រព្រឹត្តទៅដូចគ្នា កម្មដែលឲ្យផលជាទុក្ខ រមែងប្រព្រឹត្តទៅដោយអំណាចនៃការប្រព្រឹត្តទៅដូចគ្នា ។ ក៏ដោយអំណាចនៃទុក្ខវេទនីយកម្មនោះ កម្មទាំងអស់ រមែងប្រព្រឹត្តទៅដោយអំណាចនៃការប្រព្រឹត្តទៅនោះឯង ។

បទថា **ឯតស្ស ភគវា** សេចក្តីថា ព្រះតថាគតទ្រង់សម្តែងអាល័យ ដើម្បីទ្រង់សម្តែងមហាកម្មវិភង្គ យើងទូលសូមព្រះតថាគតហើយ នឹងធ្វើមហាវិភង្គញ្ញាណឲ្យប្រាកដដល់ព្រះភិក្ខុសង្ឃ ដូច្នេះ ហើយពោលយ៉ាងនេះ ព្រោះការដែលខ្លួនធ្លាតក្នុងការភ្ជាប់សេចក្តី ។ បណ្តាបទទាំងនោះ បទថា **មហាកម្មវិភង្គំ** បានដល់ ការចែកមហាកម្ម ។

**[៧៨]** ពាក្យថា បុគ្គលបួនពួក តើដូចម្តេច ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ។បេ។ រមែងចូលដល់នរក នេះជាមហាកម្មវិភង្គញ្ញាណភាជនៈ តែក៏ជាមាតិកាឋបនៈ ដើម្បីប្រយោជន៍ដល់មហាកម្មវិភង្គញ្ញាណភាជនៈ ។

**[៧៩]** ពាក្យថា **ម្នាលអានន្ទ សមណៈពួកខ្លះក្នុងលោកនេះ** តែមួយពាក្យ ជាអនុសន្ធិ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ប្រារព្ធដល់អនុសន្ធិនេះ ដើម្បីទ្រង់ប្រកាសថា សមណៈឬ ព្រាហ្មណ៍ទាំងឡាយអ្នកមានចក្ខុត្រឹមតែជួចទិព្វ ធ្វើអនុសន្ធិនេះជាអារម្មណ៍បាន បច្ច័យនេះ គឺ កាន់យកទស្សនៈនេះ ។ បណ្ដាបទទាំងនោះ បទថា **អាតប្បំ** ជាដើម ជាឈ្មោះរបស់សេចក្ដីព្យាយាម ៥ ប្រការនោះឯង ។ បទថា **ចេតោ សមាធឹ** បានដល់ ទិព្វចក្ខុសមាធិ ។

បទថា **បស្សតិ** សេចក្ដីថា រមែងសម្លឹងឃើញថា សត្វនោះកើតហើយសូម្បីក្នុងទីណា ។ បទថា **យេ អញ្ញថា** សេចក្ដីថា រមែងពោលថា ពួកជនណារមែងដឹងថា បុគ្គលនោះចូលដល់នរក ព្រោះកុសលកម្មបថ ១០ ដែលខ្លួនប្រព្រឹត្តហើយ ការដឹងរបស់ជនទាំងនោះ ខុស ។ គប្បីជ្រាបសេចក្ដីក្នុងវារៈទាំងពួងដោយន័យនេះ ។ បទថា **វិទិតំ** បានដល់ ប្រាកដ ។ បទថា **ថាមសា** បានដល់ ដោយកម្លាំងទិដ្ឋិ ។ បទថា **បរាមាសា** បានដល់ ស្ទាបអង្អែលដោយទិដ្ឋិ ។ បទថា **អភិនិវិស្ស វោហរតិ** សេចក្ដីថា អធិដ្ឋានហើយ ចាប់ប្រកាន់ហើយ ទើបនិយាយ ។

**[៨៣]** ក៏បទថា **តត្រានន្ទ** នេះ ជាបទចែកមហាកម្មវិភង្គញាណសូម្បី

នោះ ក៏នៅជាបទតាំងមាតិកាផង ។ ក៏ក្នុងទីនេះ ព្រះមានព្រះភាគទ្រង់សម្តែង បទនេះថា វាទៈមានប្រមាណប៉ុណ្ណេះ តថាគតអនុមតិ វាទៈមានប្រមាណប៉ុណ្ណេះ តថាគតមិនអនុមតិតាមពាក្យរបស់សមណៈ ឬព្រាហ្មណ៍ទាំងនោះ អ្នកមានចក្ខុត្រឹមតែដូចជាទិព្វ ។ បទថា **តត្រ តត្រ** គឺ ក្នុងសមណៈ ឬព្រាហ្មណ៍ទាំងបួននេះ ។ បទថា **ឥទមស្ស** កាត់បទជា **ឥទំ វចនំ អស្ស** ប្រែថា ពាក្យនេះនឹងគប្បីមាន ។ បទថា **អញ្ញថា** គឺ ដោយអាការដទៃ ។ គប្បីជ្រាបវាទៈដែលទ្រង់អនុមតិ ទ្រង់មិនអនុមតិ ក្នុងបទទាំងពួងយ៉ាងនេះថា ទ្រង់អនុមតិក្នុងឋានៈ ២ យ៉ាង ទ្រង់មិនអនុមតិក្នុងឋានៈ ៣ យ៉ាង ក្នុងវាទៈរបស់សមណៈ ឬព្រាហ្មណ៍ទាំងនេះ ដោយប្រការដូច្នេះ ។

**[៨៧]** ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងអនុមតិ និងមិនមែនជាអនុមតិតាមពាក្យរបស់សមណៈ ឬព្រាហ្មណ៍ទាំងឡាយអ្នកមានចក្ខុត្រឹមតែដូចជាទិព្វយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់ចែកញាណក្នុងមហាកម្មវិភង្គ ទើបត្រាស់ថា **តត្រានន្ទ យាយំ បុគ្គលោ** ដូច្នេះជាដើម ។ បទថា **បុព្វេ វាស្សតំ កតំ ហោតិ** សេចក្តីថា បុគ្គលដែលធ្វើកម្មណា ដែលសមណៈ ឬព្រាហ្មណ៍នេះ អ្នកមានចក្ខុត្រឹមតែដូចជាទិព្វឃើញហើយ ។ ក៏កម្មដែលបុគ្គលធ្វើហើយក្នុងកាល

មុន បន្ទាប់ពីនោះ បុគ្គលរមែងកើតក្នុងនរកដោយកម្មដែលខ្លួនធ្វើហើយ ក្នុងកាលមុនខ្លះ រមែងកើតដោយកម្មដែលខ្លួនធ្វើក្នុងខាងក្រោយខ្លះ ។ ក៏ឯក្នុងមរណកាលក៏រមែងកើតដូចគ្នា សូម្បីដោយការឃើញខុសជាដើមថា ព្រះខន្ធដ៏ប្រសើរ ព្រះសិវៈដ៏ប្រសើរ ព្រះព្រហ្មដ៏ប្រសើរ ឬលោកដ៏ប្រសើរពិសេសដោយឥស្សរៈជាដើម ។ បទថា **ទិដ្ឋេវ ធម្មេ** សេចក្តីថា កម្មណាគប្បីឲ្យផលក្នុងបច្ចុប្បន្ននោះ បុគ្គលរមែងបានសោយផលរបស់កម្មនោះ ក្នុងបច្ចុប្បន្ននោះឯង កម្មណាឲ្យផលកាលឧប្បត្តិ បុគ្គលឧប្បត្តិហើយ រមែងបានសោយផលរបស់កម្មនោះ កម្មណាឲ្យផលក្នុងលំដាប់បន្ទាប់ទៅ រមែងបានសោយផលរបស់កម្មនោះក្នុងលំដាប់បន្ទាប់ទៅ ។ សមណៈ ឬព្រាហ្មណ៍នេះបានឃើញគំនរនៃកម្ម ១ យ៉ាង និងគំនរនៃវិបាក ១ យ៉ាង ដោយប្រការដូច្នេះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃើញគំនរនៃកម្ម ៣ យ៉ាង និងគំនរនៃវិបាក ២ យ៉ាង ដែលសមណៈ ឬព្រាហ្មណ៍នេះមិនឃើញ តែទ្រង់ឃើញគំនរនៃកម្ម ៤ យ៉ាង និងគំនរនៃវិបាក ៣ យ៉ាង ដែលសមណៈ ឬព្រាហ្មណ៍នេះឃើញហើយ ។ ញាណក្នុងការដឹងឋានៈទាំង ៧ យ៉ាងនេះ ឈ្មោះថា ញាណក្នុងមហាកម្មវិភង្គរបស់ព្រះតថាគត ។ សមណៈ ឬព្រាហ្មណ៍ អ្នកមានចក្ខុត្រឹមតែដូចទិព្វ មិនឃើញអ្វីក្នុងវារៈទីពីរ ។ ក៏ញាណក្នុងឋានៈ ៥ យ៉ាងសូម្បីនេះ គឺ គំនរនៃកម្ម ៣ យ៉ាង គំនរនៃវិបាក

២ យ៉ាង ដែលព្រះតថាគតទ្រង់ឃើញហើយ ដូច្នេះ ឈ្មោះថា ញាណក្នុងមហាកម្មវិភង្គរបស់ព្រះតថាគត ។ សូម្បីក្នុងវារៈ ២ យ៉ាងដ៏សេស ក៏មានន័យនេះដូចគ្នា ។

[៩១] បទថា **អភព្វំ** បានដល់ វៀរចាកសេចក្តីពិត គឺ ជាអកុសល ។ បទថា **អភព្វាភាសំ** សេចក្តីថា កម្មមិនគួរ គឺ រមែងគ្របសង្កត់ អធិប្បាយថា រមែងហាមឃាត់ ។ ក៏កាលអកុសលកម្មមានច្រើន ដែលបុគ្គលធ្វើទុកហើយ កម្មដែលមានកម្លាំងហាមឃាត់វិបាករបស់កម្មដែលមិនមានកម្លាំង រមែងនឹងធ្វើឱកាសឲ្យដល់វិបាករបស់ខ្លួន កម្មនេះ ឈ្មោះថា កម្មមិនគួរហាមកម្មមិនគួរ ។ ចំណែកបុគ្គលធ្វើកុសលកម្មហើយ ធ្វើអកុសលកម្មក្នុងវេលាជិតស្លាប់ ។ អកុសលកម្មនោះ ហាមវិបាករបស់កុសលកម្ម ធ្វើឱកាសឲ្យដល់វិបាករបស់ខ្លួន កម្មនេះឈ្មោះថា កម្មមិនគួរហាមកម្មដែលគួរ ។ ក៏កាលកុសលដែលបុគ្គលធ្វើទុកច្រើនហើយ កម្មមានកម្លាំង ហាមវិបាករបស់កម្មដែលមិនមានកម្លាំង រមែងធ្វើឱកាសដល់វិបាការបស់ខ្លួន កម្មនេះ ឈ្មោះថា កម្មគួរហាមកម្មដែលគួរ ។ ចំណែកបុគ្គលធ្វើអកុសលហើយ ធ្វើកុសលក្នុងវេលាជិតស្លាប់ កុសលកម្មនោះ ហាមវិបាករបស់អកុសលកម្ម ធ្វើឱកាសឲ្យដល់វិបាករបស់ខ្លួន កម្មនេះ ឈ្មោះថា កម្មគួរហាមកម្មមិនគួរ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងទីនេះ ដោយអាការដែលប្រាកដ ។ ក៏មានអធិប្បាយដូច្នេះ កម្មណារមែងឃាត់ គឺ រមែងប្រាកដដោយកម្មមិនគួរ ព្រោះដូច្នោះ កម្មនោះ ឈ្មោះថា ឃាត់កម្មមិនគួរ ។ ព្រះមានព្រះភាគត្រាស់បុគ្គល ៤ ពួក ដោយន័យជាដើមថា ក្នុងបុគ្គល ៤ នោះ បុគ្គលណាក្នុងលោកនេះ អ្នកប្រាថ្នាធ្វើជីវិតសត្វឲ្យធ្លាក់ចុះ ដូច្នេះ ។ ក្នុងបុគ្គល ៤ នោះ កម្មរបស់បុគ្គលពួកទីមួយ ឈ្មោះថា កម្មមិនគួរឃាត់កម្មមិនគួរ ។ ក៏កម្មនេះ ឈ្មោះថា មិនគួរ ព្រោះជាអកុសល ។ កម្មដែលជាហេតុឲ្យកើតក្នុងនរកនោះ ឈ្មោះថា ជាអកុសលដោយពិត ព្រោះបុគ្គលពួកទីមួយនោះកើតក្នុងនរក ។ កម្មរបស់បុគ្គលពួកទីពីរ ឈ្មោះថា កម្មមិនគួរឃាត់កម្មដែលគួរ ។ ក៏កម្មនោះ ឈ្មោះថា មិនគួរ ព្រោះជាអកុសល ។ ក៏កម្មដែលជាហេតុឲ្យកើតក្នុងសួគ៌របស់អន្យតិរ្ថិយទាំងឡាយ ឈ្មោះថា ជាកុសលពិត ព្រោះបុគ្គលពួកទីពីរកើតក្នុងសួគ៌ ។ កម្ម ២ យ៉ាង សូម្បីក្រៅពីនេះ ក៏មានន័យដូចគ្នា ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា មហាកម្មវិភង្គសូត្រទី ៦

# អ ដ្ឋ ក ថា

## សឡាយតនវិភង្គសូត្រទី ៧

[៩២] *សឡាយតនវិភង្គសូត្រ* មានពាក្យផ្តើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្តាប់មកយ៉ាងនេះ ៖

[៩៣] បណ្តាបទទាំងនោះ បទថា **វេទិតព្វានិ** សេចក្តីថា គប្បីដឹងដោយ មគ្គព្រមទាំងវិបស្សនា ។ បទថា **មនោបវិចារា** បានដល់ វិតក្ក និងវិចារ ។ ពិតណាស់ មនៈដែលញ៉ាំងវិតក្កឲ្យកើតឡើង លោកប្រាថ្នាថា មនៈ ក្នុងទីនេះ ។ ឈ្មោះថា **មនោបវិចារា** ព្រោះអត្ថថា ជាសេចក្តីពិចារណារបស់ចិត្ត ។ បទថា **សត្តបទា** បានដល់ ដំណើរផ្លូវរបស់សត្វទាំងឡាយ ដែលអាស្រ័យវដ្តៈ និង វិវដ្តៈ ។ ក៏ក្នុងទីនេះ ដំណើរផ្លូវកាន់វដ្តៈ មាន ១៨ ប្រការ ដំណើរផ្លូវទៅកាន់ វិវដ្តៈ មាន ១៨ ប្រការ ។ ដំណើរផ្លូវសូម្បីទាំងនោះ គប្បីដឹងដោយមគ្គព្រម ទាំងវិបស្សនានោះឯង ។ បទថា **យោគាចរិយានំ** សេចក្តីថា អ្នកឲ្យសិក្សា អាចារៈ មានហត្ថិយោគៈជាដើម បានដល់ អ្នកទូន្មានបុគ្គលដែលគួរទូន្មាន ។ បទដ៏សេសនឹងជាក់ច្បាស់ក្នុងវិភង្គនោះឯង ។ បទថា **អយមុទ្ទេសោ** នេះ ជាបទ

តាំងមាតិកា ។

**[៩៤]** អាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម មានពិស្ដារហើយក្នុងវិសុទ្ធិមគ្គ ។

**[៩៥]** បទថា **ចក្ខុវិញ្ញាណំ** បានដល់ ចក្ខុវិញ្ញាណទាំងពីរជាវិបាករបស់កម្មដែលជាកុសល និងអកុសល ។ សូម្បីក្នុងបសាទវិញ្ញាណដ៏សេសទាំងឡាយក៏មានន័យនេះដូចគ្នា ។ ក៏វិញ្ញាណដ៏សេស វៀរវិញ្ញាណ ៥ ប្រការនេះ ឈ្មោះថា មនោវិញ្ញាណក្នុងទីនេះ ។

**[៩៧]** បទថា **ចក្ខុសម្ផស្សោ** បានដល់ សម្ផស្សក្នុងចក្ខុ ។ នោះជាឈ្មោះរបស់សម្ផស្សៈដែលប្រកបជាមួយនឹងចក្ខុវិញ្ញាណ ។ ក្នុងសម្ផស្សទាំងឡាយសូម្បីដ៏សេស ក៏ន័យនេះដូចគ្នា ។

**[៩៨]** បទថា **ចក្ខុនា រូបំ ទិស្វា** សេចក្ដីថា ព្រោះឃើញរូបដោយចក្ខុវិញ្ញាណ ។ ក្នុងបទទាំងពួង ក៏ន័យនេះដូចគ្នា ។

បទថា **សោមនស្សដ្ឋានីយំ** បានដល់ ជាហេតុដោយអំណាចនៃអារម្មណ៍របស់សោមនស្ស ។

បទថា **ឧបវិចរតិ** សេចក្ដីថា ចិត្តរមែងពិចារណា ដោយការប្រព្រឹត្ត

ទៅរបស់វិតក្ក ក្នុងការពិចារណារបស់ចិត្តនោះ ។ គប្បីជ្រាបការពិចារណារបស់ចិត្ត ពោលគឺ វិតក្កវិចារ ១៨ ប្រការ ដោយន័យនេះថា **វិតក្កោ តំ សម្បយុត្តោ ច** ។ ក៏ឈ្មោះថា **សោមនស្សូបវិចារ** ព្រោះអត្ថថា ពិចារណាដោយសោមនស្សក្នុងបទថា **ឆសោមនស្សូបវិចារា** នេះ ។ សូម្បីក្នុងបទទាំងពីរដ៏សេសក៏ន័យនេះដូចគ្នា ។

[៩៩] បទថា **គេហសិតានិ** បានដល់ អាស្រ័យកាមគុណ ។ បទថា **នេក្ខម្មសិតានិ** បានដល់ អាស្រ័យវិបស្សនា ។

[១០០] បទថា **ឥដ្ឋានំ** បានដល់ ដែលស្វែងរកហើយ ។ បទថា **កន្តានំ** បានដល់ ឲ្យប្រាថ្នា ។ បទថា **មនោរមានំ** សេចក្តីថា ចិត្ត រមែងត្រេកអរក្នុងធម្មារម្មណ៍ទាំងនោះ ព្រោះដូច្នោះ ធម្មារម្មណ៍ទាំងនោះ ទើបឈ្មោះថា ជាទីមកត្រេកអររបស់ចិត្ត ធម្មារម្មណ៍ទាំងនោះ ជាទីរីករាយនៃចិត្ត ។ បទថា **លោកាមិសបដិសំយុត្តានំ** គឺ ប្រកបដោយតណ្ហា ។ បទថា **អតីតំ** គឺ ដែលបានចំពោះហើយ ។

សួរថា សោមនស្ស ប្រារព្ធបច្ចុប្បន្នកើតឡើងមុន នឹងកើតឡើងក្នុងអតីតយ៉ាងណា ។ ឆ្លើយថា សោមនស្សដែលមានកម្លាំង រមែងកើតដល់បុគ្គល

ដែលត្រឡប់ពេកសូម្បីក្នុងអតីតថា យើងសោយឥដ្ឋារម្មណ៍ក្នុងកាលឥឡូវនេះ យ៉ាងណា យើងសោយហើយសូម្បីក្នុងកាលមុន ដូច្នោះ ។

[១០១] បទថា **អនិច្ចតំ** បានដល់ អាការដែលមិនទៀង ។ បទថា **វិបរិណាមវិរាគនិរោធំ** សេចក្តីថា ឈ្មោះថា សេចក្តីប្រែប្រួល ព្រោះលះបង់ប្រក្រតី , ឈ្មោះថា ការប្រាសចាករាគៈ ព្រោះទៅប្រាសហើយ , ឈ្មោះថា ការរលត់ ព្រោះរលត់ទៅហើយ ។ បទថា **សម្មប្បញ្ញាយ** បានដល់ វិបស្សនាបញ្ញា ។ បទថា **ឥទំ វុច្ចតិ នេក្ខម្មសិតសោមនស្សំ** សេចក្តីថា សោមនស្សនេះ កើតឡើងហើយដល់បុគ្គលដែលអង្គុយចម្រើនវិបស្សនា ឃើញការរលត់របស់សង្ខារទាំងឡាយ ដូចព្រះរាជាទ្រង់ឃើញសិរីសម្បត្តិរបស់ព្រះអង្គដូច្នោះ ក្នុងកាលវិបស្សនាញាណដែលមានកម្លាំងខ្លាំងក្លា សូម្បីសង្ខារនាំទៅហើយ តថាគតហៅថា សោមនស្សអាស្រ័យនេក្ខម្មៈ ។ សមដូចគាថាព័ន្ធដែលត្រាស់ទុកដូច្នេះថា ៖

សេចក្តីត្រេកអរដែលមិនមែនរបស់មនុស្ស រមែងមានដល់
ភិក្ខុអ្នកចូលកាន់ផ្ទះស្ងាត់ មានចិត្តស្ងប់ហើយ ឃើញច្បាស់
ធម៌ដោយប្រពៃហើយ ភិក្ខុឃើញការកើត និងការរលត់របស់

ខន្ធទាំងឡាយក្នុងកាលណាៗ រមែងបានបីតិ និងបាមោជ្ជៈ ក្នុងកាលនោះៗ អមតៈនោះ ភិក្ខុនោះដឹងហើយ ។

បទថា **ឥមានិ** សេចក្តីថា ទាំងនេះ សោមនស្សអាស្រ័យនេក្ខម្មៈ ៥ យ៉ាងកើតហើយ ដល់បុគ្គលដែលអង្គុយចម្រើនវិបស្សនា ដោយអំណាចនៃការមិនទៀងជាដើម ក្នុងកាលឥដ្ឋារម្មណ៍មកកាន់គន្លងក្នុងទ្វារ ៦ ។

**[១០៣]** បទថា **អតីតំ** សេចក្តីថា ទោមនស្សចូរកើតដល់បុគ្គលដែលប្រាថ្នាមិនបាននូវឥដ្ឋារម្មណ៍បច្ចុប្បន្នមុន នឹងកើតក្នុងអតីតយ៉ាងណា ។ ទោ-មនស្សដែលមានកម្លាំង រមែងកើតដល់បុគ្គលដែលត្រឡប់រឭកសម្បត្តិក្នុងអតីតថា យើងប្រាថ្នាហើយមិនបានឥដ្ឋារម្មណ៍ក្នុងកាលឥឡូវនេះយ៉ាងណា យើងប្រាថ្នាហើយ មិនបានសម្បត្តិក្នុងកាលមុនក៏ដូច្នោះ ។ បទថា **អនុត្តរេសុ វិមោក្ខេសុ** គឺ អរហត្ត ឈ្មោះថា អនុត្តរវិមោក្ខ ។ អធិប្បាយថា តាំងសេចក្តីប្រាថ្នាក្នុងអរហត្ត ។ បទថា **អាយតនំ** បានដល់ អាយតនៈ គឺ អរហត្ត ។ បទថា **បិហំ ឧបដ្ឋាបយតោ** សេចក្តីថា តាំងសេចក្តីប្រាថ្នា ។ ក៏អាយតនៈនោះ រមែងកើតដល់បុគ្គលដែលតាំងសេចក្តីប្រាថ្នានោះ ។ អធិប្បាយថា អ្នកចូលទៅតាំងសេចក្តីប្រាថ្នា ព្រោះអាយតនៈជាឫសគល់របស់សេចក្តីប្រាថ្នា ដោយប្រការដូច្នេះ ។

បទថា **ឥមានិ ច នេក្ខម្មសិតានិទោមនស្សានិ** សេចក្តីថា ទោមនស្សដែលកើតដល់បុគ្គលដែលតាំងសេចក្តីប្រាថ្នាក្នុងអរហត្ត ក្នុងកាលឥដ្ឋារម្មណ៍មកកាន់គន្លងក្នុងទ្វារ ៦ នេះ មិនអាចដើម្បីនឹងតាំងវិបស្សនាឲ្យចម្រើនឡើង ដោយអំណាចនៃសេចក្តីមិនទៀងជាដើម ដើម្បីសម្រេចអរហត្តនោះ ដូចព្រះមហាសិវត្ថេរអ្នកនៅក្នុងញកក្នុំជិតស្រុក សោកសៅថា យើងមិនអាចនឹងសម្រេចអរហត្តរហូតអស់បក្ខនេះខ្លះ រហូតអស់ខែនេះខ្លះ រហូតអស់ឆ្នាំនេះខ្លះ ដោយអំណាចការប្រព្រឹត្តទៅនៃទឹកភ្នែកទាំងនេះ គប្បីជ្រាបថា ទោមនស្សអាស្រ័យនេក្ខម្មៈ ៦ ។

ក៏រឿងរ៉ាវ បានឲ្យពិស្តារហើយក្នុងសក្កបញ្ហវណ្ណនា ក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ។ បណ្ឌិតគប្បីកាន់យកអំពីអដ្ឋកថានោះចុះ ។

**[១០៨]** បទថា **ឧប្បជ្ជតិ ឧបេក្ខា** សេចក្តីថា ឈ្មោះថា ឧបេក្ខា បានដល់ ឧបេក្ខាក្នុងអញ្ញាណ ក្នុងបទនេះ ។ បទថា **អនោធិជិនស្ស** សេចក្តីថា ព្រះខីណាស្រព ឈ្មោះថា **ឱធិជិន** ព្រោះព្រះខីណាស្រពឈ្នះសត្រូវ គឺ កិលេសហើយតាំងនៅ ព្រោះដូច្នោះ បទនេះ បានដល់ បុថុជ្ជនទៅមានអាសវៈ ។ ព្រះខីណាស្រពនោះឯង ឈ្មោះថា **វិបាកជិន** ព្រោះព្រះខីណាស្រពឈ្នះវិបាកហើយតាំងនៅ សូម្បីក្នុងបទនេះថា **អវិបាកជិនស្ស** ព្រោះដូច្នោះ អ្នកនៅមានអាសវៈ

នោះឯង ។

បទថា អនោធិជិនោ អវិទ្វា បានដល់ អ្នកមិនឃើញដោយ សេចក្តីជាទោស ។ បទថា **ឥមា ឆ គេហសិតា ឧបេក្ខា** សេចក្តីថា ឧបេក្ខាដែលមិនត្រឡប់មកកាន់រូបជាដើម ដូចសត្វរុយដែលជាប់នឹងដុំស្ករអំពៅ កាលឥដ្ឋារម្មណ៍មកកាន់គន្លងក្នុងទ្វារ ៦ នេះ ជាប់នៅក្នុងរូបជាដើមនោះកើតឡើង នេះគប្បីជ្រាបថា ឧបេក្ខាអាស្រ័យផ្ទះ ៦ ។ បទថា **រូបំ សា នាតិវត្តតិ** សេចក្តីថា ឧបេក្ខានោះមិនកន្លងហួសរូបឡើយ ។ មិនតាំងនៅដោយអំណាចសេចក្តីនឿយណាយក្នុងរូបនោះ ។

**[១០៥]** បទថា **ឥមា ឆ នេក្ខម្មសិតា ឧបេក្ខា** សេចក្តីថា ឧបេក្ខាកើតឡើងដល់បុគ្គលដែលមិនត្រេកអរក្នុងឥដ្ឋារម្មណ៍ មិនប្រទូសរ៉ាយក្នុងអនិដ្ឋារម្មណ៍ កាលអារម្មណ៍ដែលគួរប្រាថ្នាជាដើមមកកាន់គន្លងក្នុងទ្វារ ៦ នេះ ដោយការពិចារណាល្អិតល្អន់ មិនវង្វេង ប្រកបដោយឧបេក្ខាវិបស្សនាញាណទាំងនេះគប្បីជ្រាបថា ឧបេក្ខាអាស្រ័យនេក្ខម្មៈ ៦ ។

**[១០៦]** បទថា **តត្រិទំ និស្សាយ ឥទំ បជហថ** សេចក្តីថា ក្នុងដំណើរផ្លូវរបស់សត្វ ៣៦ ប្រការនោះ ពួកអ្នកចូរអាស្រ័យដំណើរផ្លូវ ១៨ ប្រការ លះ

បង់ដំណើរផ្លូវ ១៨ ប្រការ ។ ដោយហេតុនោះឯង ព្រះមានព្រះភាគ ទើបត្រាស់ថា **តត្រ ភិក្ខវេ យានិ ឆ នេក្ខម្មសិតានិ** ដូច្នេះជាដើម ។ បទថា **និស្សាយ អាគម្ម** បានដល់ ទីអាស្រ័យ និងទីពឹង ដោយអំណាចការប្រព្រឹត្តទៅ ។ បទថា **ឯវមេតេសំ សមតិក្កមោ ហោតិ** សេចក្ដីថា ឈ្មោះថា កន្លងហួសឧបេក្ខាអាស្រ័យផ្ទះ ព្រោះការប្រព្រឹត្តទៅនៃឧបេក្ខាអាស្រ័យនេក្ខម្មៈនេះ ។

ព្រះមានព្រះភាគ ទ្រង់ឲ្យលះបង់ធម៌ដែលស្រដៀងគ្នា ដោយធម៌ដែលស្រដៀងគ្នាយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់ឲ្យលះបង់ធម៌ដែលមិនមានកម្លាំង ដោយធម៌ដែលមានកម្លាំង ទើបត្រាស់ទៀតថា **តត្រ ភិក្ខវេ យានិ ឆ នេក្ខម្ម-សិតានិ សោមនស្សានិ** ដូច្នេះជាដើម ។

ព្រះមានព្រះភាគ ទ្រង់ឲ្យលះបង់ទោមនស្សអាស្រ័យនេក្ខម្មៈ ដោយសោមនស្សអាស្រ័យនេក្ខម្មៈ និងសោមនស្សអាស្រ័យនេក្ខម្មៈ ដោយឧបេក្ខាអាស្រ័យនេក្ខម្មៈ ដូច្នេះ ។ ទើបត្រាស់ការលះបង់ធម៌ដែលមិនមានកម្លាំង ដោយធម៌ដែលមានកម្លាំង ។ ក៏បណ្ឌិតតាំងនៅក្នុងការលះបង់នោះ គប្បីពោលឧបេក្ខា ។ ក៏បុព្វភាគវិបស្សនារបស់ភិក្ខុ ៤ រូប ដែលប្រារព្ធវិបស្សនា ធ្វើឈាន ៣ មានបឋមជ្ឈានជាដើម ក្នុងសមាបត្តិ ៨ និងសង្ខារបរិសុទ្ធិទាំងឡាយឲ្យជាបាទ រមែង

សហគតដោយសោមនស្ស ឬសហគតដោយឧបេក្ខា ។ ចំណែកវុដ្ឋានគាមិនី សហគតដោយសោមនស្សតែម្យ៉ាង ។ បុព្វភាគវិបស្សនារបស់ភិក្ខុ ៥ រូប ដែលប្រារព្ធវិបស្សនា ធ្វើឈានទាំងឡាយ មានចតុត្ថជ្ឈានជាដើមឲ្យជាបាទ ក៏តែមួយដូចន័យមុន ។ ក៏វុដ្ឋានគាមិនីសហគតដោយឧបេក្ខា ។ ទ្រង់សំដៅដល់បទនេះ ទើបត្រាស់ថា ឧបេក្ខាអាស្រ័យនេក្ខម្មៈ ៦ ណា ពួកអ្នកអាស្រ័យឧបេក្ខាទាំងនោះ ពីងឧបេក្ខាទាំងនោះ ចូរលះបង់សោមនស្សអាស្រ័យនេក្ខម្មៈ ៦ ដូច្នេះ ។ ក៏ភិក្ខុដែលបដិបត្តិយ៉ាងនេះ រមែងមានគុណវិសេសដោយអំណាចនៃវេទនា ដោយវិបស្សនានេះតែម្យ៉ាងក៏មិនមែន ។ គុណវិសេស សូម្បីអង្គរបស់ឈាន ពោជ្ឈង្គៈ និងអង្គរបស់មគ្គ រមែងមានសូម្បីក្នុងអរិយមគ្គ ។ ក៏អ្វីកំណត់គុណវិសេសនោះ ។ ព្រះថេរៈពួកខ្លះពោលមុនថា ឈានដែលមានវិបស្សនាជាបាទរមែងកំណត់ ។ ពួកខ្លះពោលថា ខន្ធទាំងឡាយដែលជាអារម្មណ៍របស់វិបស្សនារមែងកំណត់ ។ ពួកខ្លះថា អជ្ឈាស្រ័យរបស់បុគ្គលរមែងកំណត់ ។ ក្នុងវាទៈរបស់ព្រះថេរៈទាំងនោះ វិបស្សនាដែលជាវុដ្ឋានគាមិនី ក្នុងបុព្វភាគនេះឯង គប្បីជ្រាបថា រមែងកំណត់ ។ ចំណែកវិនិច្ឆ័យកថាក្នុងសេចក្តីនេះ បានពោលហើយក្នុងសង្ខារុបេក្ខានិទ្ទេសក្នុងវិសុទ្ធិមគ្គនោះឯង ។

[១០៧] បទថា **នានត្តា** បានដល់ ផ្សេងៗ ច្រើន មានប្រមាណអនេក ។ បទថា **នានត្តសិតា** បានដល់ អាស្រ័យអារម្មណ៍ផ្សេងៗ ។ បទថា **ឯកត្តា** បានដល់ មួយ ។ បទថា **ឯកត្តសិតា** បានដល់ អាស្រ័យអារម្មណ៍មួយ ។ សួរថា ក៏ឧបេក្ខានេះដូចជាម្តេច ។ ឆ្លើយថា បានត្រាស់ អញ្ញាណុបេក្ខា ទុកក្នុងកាលមុន ។ នឹងត្រាស់ធម្មក្តុបេក្ខាក្នុងខាងមុខ ។ ទ្រង់កាន់យកឧបេក្ខា ២ យ៉ាង គឺ សមថុបេក្ខា វិបស្សនូបេក្ខា សូម្បីក្នុងទីនេះ ។ ក្នុងឧបេក្ខា ២ យ៉ាងនោះ ព្រោះឧបេក្ខាក្នុងរូបម្យ៉ាង ឧបេក្ខាក្នុងសំឡេងជាដើមម្យ៉ាង ។

ក៏ឧបេក្ខាក្នុងរូប រមែងមិនមានក្នុងសំឡេងជាដើម ។ ឧបេក្ខាក្នុងរូបប៉ុណ្ណោះ ធ្វើរូបប៉ុណ្ណោះឲ្យជាអារម្មណ៍ ។ សំឡេងជាដើម រមែងមិនធ្វើរូបនិងជាឧបេក្ខាឲ្យជាអារម្មណ៍ ។ សមថុបេក្ខាដទៃៗ ក៏គឺ ឧបេក្ខាដែលធ្វើបឋវីកសិណឲ្យជាអារម្មណ៍កើតឡើង ។ ឧបេក្ខាដទៃៗ គឺ ឧបេក្ខាដែលកើតឡើងព្រោះធ្វើអាបោកសិណជាដើមឲ្យជាអារម្មណ៍ ។ ព្រោះដូច្នោះ កាលទ្រង់ចែកសេចក្តីផ្សេងៗ និងអាស្រ័យអារម្មណ៍ផ្សេងៗ ទើបត្រាស់ថា **អត្ថិ ភិក្ខវេ ឧបេក្ខា រូបេ** ជាដើម ក៏ព្រោះអាកាសានញ្ចាយតនៈ ឬវិញ្ញាណញ្ចាយតនៈជាដើម មិនមានពីរ ឬបី ។ ព្រោះដូច្នោះ កាលទ្រង់ ចែកអាស្រ័យអារម្មណ៍មួយ ទើបត្រាស់

ថា *អត្ថិ ភិក្ខវេ ឧបេក្ខា អាកាសានញ្ចាយតននិស្សិតា* ដូច្នេះជាដើម ។ បណ្ដាឧបេក្ខាទាំងនោះ អាកាសានញ្ចាយតនូបេក្ខា អាស្រ័យអាកាសានញ្ចាយតនៈដោយអំណាចសម្បយុត្ត ។ វិបស្សនូបេក្ខារបស់ភិក្ខុដែលឃើញច្បាស់អាកាសានញ្ចាយតនខន្ធ អាស្រ័យអាកាសានញ្ចាយតនៈ ដោយអំណាចនៃអារម្មណ៍ ។ ក្នុងឧបេក្ខាដ៏សេស ក៏ន័យនេះដូចគ្នា ។ ទ្រង់ឲ្យលះបង់រូបាវចរកុសលសមាបត្តិឧបេក្ខា ដោយអរូបាវចរសមាបត្តិឧបេក្ខា ទ្រង់ឲ្យលះបង់រូបាវចរវិបស្សនូបេក្ខា ដោយអរូបាវចរវិបស្សនូបេក្ខា ក្នុងបទនេះថា **តំ បជហថ** ដូច្នេះ ។ តណ្ហា ឈ្មោះថា **តម្មយតា** ក្នុងបទនេះថា **អតម្មយតំ** ។ វិបស្សនាដែលឲ្យដល់ការចេញចាកការរួបរឹតរបស់តណ្ហានោះ ហៅថា **អតម្មយតា** ។ រមែងលះបង់អរូបាវចរសមាបត្តិឧបេក្ខា និងវិបស្សនូបេក្ខា ដោយវុដ្ឋានគាមិនីវិបស្សនា ក្នុងបទនេះថា **តំ បជហថ** ។

**[១០៨]** បទថា **យទរិយោ** សេចក្ដីថា ព្រះសម្មាសម្ពុទ្ធ ដែលជាអរិយៈ ទ្រង់រមែងសេពសតិប្បដ្ឋានពួកណា ។ ទ្រង់តាំងព្រះសតិក្នុងឋានៈ ៣ យ៉ាងនោះ គប្បីជ្រាបថា ទ្រង់សេពសតិប្បដ្ឋាន ។

**[១០៩]** បទថា **ន សុស្សូសន្តិ** សេចក្ដីថា មិនប្រាថ្នាដើម្បីជឿស្ដាប់ ។

បទថា **ន អញ្ញា** សេចក្តីថា មិនតាំងចិត្តដើម្បីប្រយោជន៍ដល់ការដឹង ។ បទថា **វោ កម្ម** បានដល់ ឈានកន្ទង ។ បទថា **សត្ថុ សាសនំ** សេចក្តីថា មិនសម្គាល់នូវឱវាទរបស់ព្រះសាស្តាដែលគួរកាន់យក គួរឲ្យពេញ ។ បទថា **ន ច អត្តមនោ** គឺ មិនមានចិត្តជារបស់ខ្លួន ។ តែក្នុងទីនេះ មិនគួរឃើញសេចក្តីយ៉ាងនេះថា មិនក្តៅក្រហាយ ដោយអំណាចទោមនស្សអាស្រ័យផ្ទះ ។ តែត្រាស់បទនោះ ព្រោះមិនមានហេតុនៃសេចក្តីសរសើរ ក្នុងពួកសាវកអ្នកមិនបដិបត្តិ ។ បទថា **អនវស្សុតោ** គឺ មិនខ្វល់ខ្វាយដោយអំណាចសេចក្តីខ្វល់ខ្វាយ សេចក្តីចង្អៀតចង្អល់ចិត្ត ។ បទថា **សតោ សម្បជានោ** សេចក្តីថា ដល់ព្រមដោយសតិ និងញាណ ។

**[១១០]** បទថា **ឧបេក្ខកោ** សេចក្តីថា ព្រងើយដោយឆឡង្គុបេក្ខា ។ មិនគួរជ្រាបសេចក្តីយ៉ាងនេះថា មានសេចក្តីសប្បាយចិត្ត ដោយអំណាចសោមនស្សអាស្រ័យផ្ទះ ក្នុងបទសូម្បីនេះថា **អត្តមនោ** ។ បទនោះត្រាស់ហើយដោយមានហេតុនៃសេចក្តីសរសើរក្នុងពួកសាវកអ្នកបដិបត្តិ ។

**[១១១]** បទថា **អនវស្សុតោ** បានដល់ មិនខ្វល់ខ្វាយ ដោយអំណាចសេចក្តីខ្វល់ខ្វាយដោយរាគៈ ។

**[១១២]** បទថា ***សារិតោ*** បានដល់ ទូន្មានហើយ ។ បទថា ***ឯកំយេវ ទិសំ ធាវតិ*** សេចក្តីថា កាលមិនឲ្យស្ទុះទៅ ឈ្មោះថា ស្ទុះទៅកាន់ទិសតែមួយប៉ុណ្ណោះ ។ តែរមែងឲ្យស្ទុះទៅកាន់ទិសដទៃ ។ បទថា ***អដ្ឋទិសា វិធាវតិ*** សេចក្តីថា អង្គុយដោយបល្ល័ង្កមួយ មិនស្ទុះទៅដោយកាយ ស្ទុះទៅកាន់ទិសទាំង ៨ ក្នុងគ្រាតែមួយនោះឯង ដោយអំណាចនៃវិមោក្ខ ។ អធិប្បាយថា ទ្រង់ប្រាថ្នាព្រះភ័ក្ត្រទៅទិសខាងកើត ឬទិសត្បូងជាដើម ទិសណាមួយ ប្រថាប់អង្គុយចូលសមាបត្តិទាំង ៨ នោះឯង ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សឡាយតនវិភង្គសូត្រទី ៧

# អ ដ្ឋ ក ថា

## ឧទ្ទេសវិភង្គសូត្រទី ៨

[១១៣] *ឧទ្ទេសវិភង្គសូត្រ ចាប់ផ្តើមថា* ***ឯវម្មេ សុតំ*** *ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖*

*បណ្តាបទទាំងនោះ បទថា* ***ឧទ្ទេសវិភង្គំ*** *បានដល់ ឧទ្ទេស និងវិភង្គ ។ អធិប្បាយថា មាតិកា និងការចែក ។*

[១១៤] *បទថា* ***ឧបបរិក្ខេយ្យ*** *សេចក្តីថា គប្បីប្រៀបផ្ទឹម គប្បីពិចារណា គប្បីកាន់យក គប្បីកំណត់ ។ បទថា* ***ពហិទ្ធា*** *បានដល់ ក្នុងអារម្មណ៍ខាងក្រៅទាំងឡាយ ។ បទថា* ***អវិក្ខិត្តំ អវិសដំ*** *សេចក្តីថា ការតាំងមាំក្នុងអារម្មណ៍ ដោយអំណាចសេចក្តីប្រាថ្នា រាយមាយ ឈ្មោះថា ខ្ចាត់ខ្ចាយទៅ ។ កាលទ្រង់បដិសេធសេចក្តីដឹងខ្ចាត់ខ្ចាយទៅនោះ ទើបត្រាស់យ៉ាងនេះ ។ បទថា* ***អជ្ឈត្តំ អសណ្ឋិតំ*** *សេចក្តីថា មិនស្ងប់ដោយអំណាចនៃការប្រាថ្នាក្នុងអារម្មណ៍ខាងក្នុង ។ បទថា* ***អនុបាទាយ ន បរិតស្សេយ្យ*** *មានអធិប្បាយថា សេចក្តីដឹងនោះ មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ គឺ មិនកាន់យកសេចក្តីដឹង មិន*

ភាយមាយ មិនខ្ចាត់ខ្ចាយទៅក្នុងខាងក្រៅ មិនស្ងប់ខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ យ៉ាងណា ភិក្ខុគប្បីពិចារណាដូច្នោះ ។ បទថា **ជាតិជរា មរណ-ទុក្ខសមុទយសម្ភវោ** សេចក្តីថា រមែងមិនមានការកើតនៃជាតិ ជរាមរណៈ និងទុក្ខដ៏សេស ។

**[១១៩]** បទថា **រូបនិមិត្តានុសារី** បានដល់ ឈ្មោះថា ស្ទុះទៅតាមនិមិត្ត គឺ រូប ព្រោះអត្ថថា ស្ទុះទៅ ត្រាច់ទៅតាមនិមិត្ត គឺ រូប ។

**[១២២]** បទថា **ឯវំ ខោ អាវុសោ អជ្ឈត្តំ ចិត្តំ អសណ្ឋិតំ** សេចក្តីថា មិនស្ងប់ ដោយអំណាចនៃសេចក្តីប្រាថ្នា ។ ក៏ចិត្តមិនតាំងមាំ ដោយអំណាចនៃសេចក្តីប្រាថ្នា រមែងមិនជាចំណែកក្នុងការលះបង់ តែជាចំណែកក្នុងគុណវិសេសតែម្យ៉ាង ។

**[១២៣]** បទថា **អនុបាទា បរិតស្សនា** សេចក្តីថា ព្រះសាស្តាទ្រង់សម្តែងសេចក្តីតក់ស្លុត ព្រោះប្រកាន់មាំ និងសេចក្តីមិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ក្នុងខន្ធិយវគ្គយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងសេចក្តីតក់-ស្លុតព្រោះប្រកាន់មាំ និងសេចក្តីមិនតក់ស្លុតព្រោះមិនប្រកាន់មាំ ។ ព្រះមហាថេរៈកាលនឹងសម្តែងសេចក្តីតក់ស្លុតនោះ ធ្វើសេចក្តីតក់ស្លុត ព្រោះការប្រកាន់មាំ ឲ្យជាសេចក្តីតក់ស្លុតព្រោះមិនប្រកាន់មាំ ទើបពោលយ៉ាងនេះថា ម្នាល

អាវុសោទាំងឡាយ ក៏សេចក្តីតក់ស្លុត ព្រោះមិនប្រកាន់មាំ តើដូចម្តេច ។ ព្រោះមិនមានសង្ខារដែលគប្បីប្រកាន់មាំ ប្រសិនបើថា សង្ខារណាៗ ជារបស់ទៀង ឬឋិតថេរ ក៏នឹងជារបស់គួរប្រកាន់មាំថា ជាខ្លួន ឬជារបស់ខ្លួន ។ សេចក្តីតក់ស្លុតនេះ ជាសេចក្តីតក់ស្លុតព្រោះការប្រកាន់មាំ ។ ក៏ធម្មតា សង្ខារដែលគួរប្រកាន់មាំយ៉ាងនេះ មិនមាន ព្រោះដូច្នោះ សង្ខារទាំងឡាយសូម្បីមានចិត្តគ្រប់គ្រង មានរូបជាដើម ដោយន័យមានជាដើមថា រូប អត្តា ក៏ជារបស់មិនគួរប្រកាន់មាំដោយពិត ។ សេចក្តីតក់ស្លុតនោះ សូម្បីជាសេចក្តីតក់ស្លុតព្រោះប្រកាន់មាំយ៉ាងនេះឯង ដោយសេចក្តីគប្បីជ្រាបថា សេចក្តីតក់ស្លុតព្រោះមិនប្រកាន់មាំ ។

បទថា **អញ្ញថា ហោតិ** សេចក្តីថា រូបប្រែប្រួលទៅ ។ តែក៏វិនាសទៅ ព្រោះការលះប្រក្រតី ។ បទថា **រូបវិបរិណាមានុបរិវត្តិ** សេចក្តីថា កម្មវិញ្ញាណរមែងប្រែប្រួលទៅតាមការបែកធ្លាយរបស់រូប ដោយន័យមានជាដើមថា រូបរបស់យើងប្រែប្រួលទៅហើយ ឬថា រូបណាមានហើយ រូបនោះឯងជារបស់យើងមិនមាន ដូច្នេះ ។ បទថា **វិបរិណាមានុបរិវត្តជា** សេចក្តីថា ដែលកើតពីសេចក្តីប្រែប្រួល ទៅតាមសេចក្តីប្រែប្រួល គឺ តែចិត្តដែលមានអារម្មណ៍ មានសេចក្តីប្រែប្រួល ។ បទថា **បរិតស្សនា ធម្មសមុប្បាទា** បានដល់ សេចក្តីតក់ស្លុត

ព្រោះតណ្ហា និងការកើតឡើងនៃអកុសលធម៌ ។ បទថា **ចិត្តំ បរិយាទាយ តិដ្ឋតិ** សេចក្តីថា រមែងគ្របសង្កត់ គឺ កាន់យកឲ្យអស់ទៅនូវអកុសលចិត្ត ។ បទថា **ឧត្តាសវា** សេចក្តីថា គេមានសេចក្តីភ័យខ្លាច ព្រោះសេចក្តីតក់ស្លុតពីភ័យខ្លះ មានសេចក្តីភ័យខ្លាច ព្រោះសេចក្តីតក់ស្លុតពីតណ្ហាខ្លះ ។ បទថា **វិឃាតវា** បានដល់ មានសេចក្តីចង្អៀតចង្អល់ មានទុក្ខ ។ បទថា **អបេក្ខវា** បានដល់ មានអាល័យ មានសេចក្តីស្រឡាញ់ ។ បទថា **ឯវំ ខោ អាវុសោ អនុបាទា បរិតស្សនា ហោតិ** សេចក្តីថា សេចក្តីតក់ស្លុតព្រោះមិនប្រកាន់មាំ រមែងមានដល់គេ ដូចកាន់ប្រអប់ទទេដោយសម្គាល់ថា ប្រអប់កែវមណីយ៉ាងនេះ កាលប្រអប់នោះវិនាសហើយ ទើបដល់សេចក្តីចង្អៀតចង្អល់ក្នុងខាងក្រោយ ដូច្នោះ ។

**[១២៤]** បទថា **ន រូបវិបរិណាមានុបរិវត្តិ** សេចក្តីថា កម្មវិញ្ញាណរបស់ទីណាស្រេចនោះឯង រមែងមិនមាន ។ ព្រោះដូច្នោះ ទើបសមគួរដើម្បីពោលថា សេចក្តីប្រែប្រួល ទៅតាមសេចក្តីបែកធ្លាយរបស់រូបមិនមាន ដូច្នេះ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ឧទ្ទេសវិភង្គសូត្រទី ៨

# អ ដ្ឋ ក ថា

## អរណវិភង្គសូត្រទី ៩

[១២៨] *អរណវិភង្គសូត្រ* មានពាក្យផ្ដើមថា *ឯវម្មេ សុតំ* ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៖

[១២៩] ក្នុងបទទាំងនោះ បទថា **នេវុស្សាទេយ្យ ន អបសាទេយ្យ** សេចក្ដីថា មិនលើកតម្កើង មិនគប្បីបន្ទុះបង្អាប់បុគ្គលណា ដោយអំណាចអាស្រ័យផ្ទះ ។ បទថា **ធម្មមេវ ទេសេយ្យ** គឺ គប្បីនិយាយតែសេចក្ដីពិតប៉ុណ្ណោះ ។ បទថា **សុខវិនិច្ឆយំ** បានដល់ សុខដែលកាត់ក្ដីហើយ បទថា **រហោ វាទំ** បានដល់ ពោលទោសកំបាំងមុខ អធិប្បាយថា ពោលពាក្យញុះញង់ ។ បទថា **សម្មុខា នាតិខីណំ** សេចក្ដីថា មិនគប្បីពោលពាក្យកន្ទងលើស ពាក្យខ្ជីខ្ជាពាក្យស្មោកគ្រោកចំពោះមុខ ។ បទថា **នាភិនិវេសេយ្យ** សេចក្ដីថា មិនគប្បីនិយាយប្រញាប់ប្រញាល់យកតែបាន ។ បទថា **សមញ្ញំ** បានដល់ លោកសមញ្ញា គឺ លោកបញ្ញត្តិ ។

បទថា **នាតិធាវេយ្យំ** គឺ មិនគប្បីកន្ទងល្មើស ។

[១៣០] បទថា **កាមបដិសន្ធិសុខិនោ** សេចក្តីថា អ្នកមានសេចក្តីសុខដោយសេចក្តីសុខជាប់ដោយកាម គឺ ប្រកបដោយកាម ។

បទថា **សទុក្ខោ** បានដល់ មានទុក្ខ ដោយវិបាកទុក្ខខះ ដោយកិលេស-ទុក្ខខះ ។ បទថា **សឧបឃាតោ** បានដល់ មានសេចក្តីចង្អៀតចង្អល់ចិត្ត ដោយសេចក្តីចង្អៀតចង្អល់ចិត្តក្នុងវិបាក និងសេចក្តីចង្អៀតចិត្តក្នុងកិលេសនោះឯងមានសេចក្តីក្តៅក្រហាយ ដូច្នោះ ។ បទថា **មិច្ឆាបដិបទា** បានដល់ ការបដិ-បត្តិមិនត្រូវ គឺ ការបដិបត្តិដែលជាអកុសល ។

[១៣២] បទថា **ឥត្ថេកេ អបសាទេតិ** សេចក្តីថា តិះដៀលបុគ្គលពួកខះ ដោយអំណាចអាស្រ័យផ្ទះយ៉ាងនេះ ។

សូម្បីក្នុងការបញ្ចោរ ក៏មានន័យនេះដូចគ្នា ។ បទថា **ភវសំយោជនំ** បានដល់ គ្រឿងចងក្នុងភព ។ នោះជាឈ្មោះរបស់តណ្ហា ។

បានឮថា ព្រះសុភូតិត្ថេរ អាស្រ័យចតុក:នេះ តាំងនៅក្នុងតំណែងឯត-ទគ្គ: ។ ពិតហើយ កាលព្រះមានព្រះភាគទ្រង់សម្តែងធម៌ ការលើកសរសើរនិងការបន្តុះបង្អាប់ រមែងប្រាកដដល់បុគ្គលទាំងឡាយ ។ កាលព្រះថេរ:ទាំងឡាយ មានព្រះសារីបុត្តត្ថេរជាដើម សម្តែងធម៌ សេចក្តីលើកសរសើរ និងការ

តិះដៀលក៏ប្រាកដយ៉ាងនោះ ។ តែធម្មទេសនារបស់សុភូតិត្ថេរ មិនមានថា បុគ្គលនេះមិនបដិបត្តិ បដិបត្តិខុស ឬថា បុគ្គលនេះមានសីល មានគុណ មានការអៀនខ្មាស មានសីលជាទីស្រឡាញ់ ដល់ព្រមដោយមារយាទ ដូច្នេះ ។ ក៏ធម្មទេសនារបស់ព្រះសុភូតិត្ថេរនោះ រមែងប្រាកដថា នេះជាការបដិបត្តិខុស នេះជាការបដិបត្តិត្រូវ ដូច្នេះប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សុភូតិជាកំពូលលើសនៃភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត អ្នកមានប្រក្រតីនៅដោយសេចក្ដីស្ងប់ ។

**[១៣៥]** បទថា **កាលញ្ញូ អស្ស** សេចក្ដីថា មិនពោលក្នុងកាលដែលមិនទាន់ដល់ និងដែលកន្លងហើយ និងពោលដល់កាលដែលគួរប្រកបសេចក្ដីព្យាយាម ដែលគួរពោលក្នុងកាលឥឡូវនេះថា មហាជននឹងកាន់យក មិនគប្បីពោលវាទៈកំបាំងមុខ ។ សូម្បីក្នុងវីណាវាទៈក៏មានន័យដូចគ្នា ។

**[១៣៦]** បទថា **ឧបហញ្ញតិ** បានដល់ ការប៉ះទង្គិច ។ បទថា **សរោបិ ឧបហញ្ញតិ** គឺ សូម្បីសំឡេង រមែងបែកៗ ។ បទថា **អាតុរិយតិ** បានដល់ ជាអ្នកក្ដៅក្រហាយ ។ ដល់ភាពជាអ្នកឈឺចាប់ព្រោះអាពាធ ។ បទថា **អវិសដ្ឋំ** បានដល់ ពាក្យមិនស្អាតរៀបរយ គឺ មិនច្បាស់លាស់ ។

**[១៣៧]** បទថា **តទេវ** បានដល់ ភាជនៈនោះឯង ។ បទថា **អភិនិវិស្ស វោហរតិ** សេចក្ដីថា បុថុជ្ជនអ្នកល្ងង់ខ្លៅ ទៅកាន់ជនបទដែលបានចាំថា **បត្ត** ស្ដាប់ថា ពួកអ្នកឯងចូរនាំមក ចូរលាងបត្តៈ ប្រញាប់និយាយថា នេះមិនមែនបត្តៈ នោះឈ្មោះថា **បាតី** អ្នកឯងចូរនិយាយយ៉ាងនេះ ។ គប្បីប្រកបដោយបទទាំងឡាយ ក្នុងទីទាំងពួងយ៉ាងនេះ ។ បទថា **អតិសារោ** បានដល់ ថ្វាយបង្គំ ។ បទថា **តថា តថា វោហរតិ អបរាមសំ** សេចក្ដីថា ភាជនៈក្នុងជនបទរបស់ពួកយើងហៅថា **បាតី** ។ ចំណែកជនទាំងនេះពោលភាជនៈនោះថា **បត្ត** ។ ចាប់តាំងពីនោះ ដោះស្រាយពាក្យនិយាយរបស់ជនបទពោលរឿយៗ ថា បត្តៈ បត្តៈ ដូច្នេះឯង ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

**[១៣៨]** ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់ធ្វើបទមរិយាទភាជនីយ៍ ទើបត្រាស់ថា **តត្រ ភិក្ខវេ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **សរណោ** បានដល់ មានធូលី មានកិលេស ។ បទថា **អរណោ** បានដល់ មិនមានធូលី ប្រាសចាកកិលេស ។

**[១៤៧]** បទថា **សុភូតិ ច បន ភិក្ខវេ** សេចក្ដីថា ព្រះថេរៈនេះ ឡើងកាន់តំណែងឯតទគ្គៈ ២ យ៉ាង គឺ សុភូតិ កំពូលលើសក្នុងផ្នែកអរណវិហារី

និងកំពូលលើសក្នុងផ្នែកទក្ខិណេយ្យ ។ បានឮថា ព្រះធម្មសេនាបតី ញ៉ាំងវត្ថុឲ្យបរិសុទ្ធិ ។ សុភូតិត្ថេរញ៉ាំងទក្ខិណាឲ្យបរិសុទ្ធិ ។ ពិតដូច្នោះ ព្រះធម្មសេ-នាបតីត្រាច់បិណ្ឌបាត ឈរជិតទ្វារផ្ទះ កំណត់ក្នុងបុព្វភាគហើយ ចូលនិរោធ ដរាបដល់បុគ្គលទាំងឡាយនាំភិក្ខាមកថ្វាយ ។ ចេញចាកនិរោធហើយ ទទួលទេយ្យធម៌ ។ ព្រះសុភូតិត្ថេរ ចូលមេត្តាឈាន ។ ចេញចាកមេត្តាឈានហើយ ទទួលទេយ្យធម៌ ។ សួរថា ក៏ព្រះថេរៈអាចធ្វើយ៉ាងនេះឬ ។ ឆ្លើយថា អើ! អាច ។ ការដែលព្រះសាវកទាំងឡាយអ្នកដល់មហាភិញ្ញា គប្បីធ្វើយ៉ាងនេះ នោះមិនគួរអស្ចារ្យឡើយ ។ ពិតហើយ ក្នុងកាលនៃបុរាណករាជ ក្នុងតម្ពបណ្ណិទ្វីបនោះ ព្រះថេរៈឈ្មោះបិង្គលពុទ្ធរក្ខិត នៅអាស្រ័យឧត្តរគ្រាម ។ ក្នុងឧត្តរ-គ្រាមនោះ មានត្រកូល ៧០០ ត្រកូល ។ ព្រះថេរៈមិនធ្លាប់ចូលសមាបត្តិត្រង់ទ្វារនៃត្រកូលណា ទ្វារនៃត្រកូលនោះសូម្បីតែមួយក៏មិនមាន ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា អរណវិភង្គសូត្រទី ៩

# អដ្ឋកថា

## ធាតុវិភង្គសូត្រទី ១០

[១៤៨] ធាតុវិភង្គសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់យ៉ាងនេះ ៖

ក្នុងបទទាំងនោះ បទថា **ចារិកំ** បានដល់ ចារិកទៅដោយប្រញាប់ប្រញាល់ ។ បទថា **សចេ តេ អគរុ** សេចក្ដីថា បើមិនធ្ងន់ចិត្ត គឺ មិនមានសេចក្ដីសប្បាយដល់លោក ។

បទថា **សចេ សោ អនុជានាតិ** សេចក្ដីថា បានឮថា ភគ្គវៈ មានការគិតយ៉ាងនេះថា ធម្មតាបព្វជិតទាំងឡាយ រមែងមានអធ្យាស្រ័យផ្សេងគ្នា ភិក្ខុពួកខ្លះជាអ្នកត្រេកអរក្នុងពួក ភិក្ខុពួកខ្លះមិនត្រេកអរក្នុងពួក បើភិក្ខុនោះត្រេកអរក្នុងការនៅម្នាក់ឯង នឹងពោលថា ម្នាលអ្នកមានអាយុ លោកកុំចូលមក ខ្ញុំបានសាលាហើយ បើភិក្ខុនេះត្រេកអរក្នុងការនៅតែម្នាក់ឯង ក៏នឹងនិយាយថា ម្នាលអ្នកមានអាយុ លោកចូរចេញទៅ ខ្ញុំបានសាលាហើយ បើដូច្នេះ យើងក៏នឹងជាហេតុឲ្យអ្នកទាំងពីរធ្វើការឈ្លោះគ្នា ធម្មតាវត្ថុដែលឲ្យហើយ ក៏គួរជាការឲ្យ

ហើយនោះឯង វត្ថុដែលធ្វើហើយ ក៏គួរជាការធ្វើហើយនោះឯង ។ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។

**[១៤៩]** បទថា **កុលបុត្តោ** បានដល់ កុលបុត្រដោយជាតិខ្លះ កុលបុត្រដោយមារយាទខ្លះ ។ បទថា **វាសូបគតោ** បានដល់ ចូលទៅនៅហើយ ។ សួរថា កុលបុត្រនោះមកពីណា ។ ឆ្លើយថា មកពីនគរតក្កសិលា ។ ក្នុងរឿងនោះ មានការពណ៌នាដោយលំដាប់ដូច្នេះ ។

បានឮថា កាលព្រះបាទពិម្ពិសារសោយរាជសម្បត្តិក្នុងព្រះនគររាជគ្រឹះ ក្នុងមជ្ឈិមប្រទេស ព្រះបាទបុក្កុសាតិសោយរាជសម្បត្តិក្នុងព្រះនគរតក្កសិលា ក្នុងបច្ចន្តប្រទេស ។ គ្រានោះ ឈ្មួញទាំងឡាយយកទំនិញអំពីព្រះនគរតក្កសិលា មកកាន់ព្រះនគររាជគ្រឹះ នាំបណ្ណាការទៅថ្វាយចំពោះព្រះរាជា ។ ព្រះរាជាត្រាស់សួរឈ្មួញទាំងនោះ ដែលថ្វាយបង្គំថា ពួកលោកនៅទីណា ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គនៅព្រះនគរតក្កសិលា ។ លំដាប់នោះ ព្រះរាជាត្រាស់សួរដល់សេចក្តីក្សេម និងការរកភិក្ខាហារបានដោយងាយជាដើម របស់ជនបទ និងប្រវត្តិនៃព្រះនគរចំពោះឈ្មួញទាំងនោះ ហើយត្រាស់សួរថា ព្រះរាជារបស់ពួកលោកមានព្រះនាមអ្វី ។ ព្រះរាជាអង្គនោះ ព្រះនាមថា **បុក្កុសាតិ** ។ ទ្រង់តាំង

នៅក្នុងធម៌ឬ ។ យ៉ាងនោះហើយព្រះអង្គ ទ្រង់តាំងនៅក្នុងធម៌ ទ្រង់សង្គ្រោះជន ដោយសង្គហវត្ថុបួន ទ្រង់តាំងនៅក្នុងឋានៈជាមាតាបិតារបស់ប្រជារាស្ត្រ ទ្រង់ញ៉ាំងជនដូចទារកដែលដេកលើភ្លៅឲ្យត្រេកអរ ។ ទ្រង់មានវ័យប៉ុណ្ណា ។ លំដាប់នោះ ពួកឈ្មួញទូលប្រាប់វ័យចំពោះព្រះរាជានោះ ។ ទ្រង់មានវ័យប្រហែលនឹងព្រះអង្គ ។ គ្រានោះព្រះរាជាត្រាស់ចំពោះឈ្មួញទាំងនោះថា ម្នាលបាទាំងឡាយ ព្រះរាជារបស់ពួកលោកតាំងនៅក្នុងធម៌ និងទ្រង់មានវ័យស្មើនឹងយើង តើពួកអ្នកអាចធ្វើព្រះរាជារបស់ពួកអ្នកឲ្យជាមិត្តនឹងយើងបានឬ ។ អាច ព្រះអង្គ ។ ព្រះរាជាទ្រង់លះបង់ភាស៊ី (ការបង់ពន្ធ) ដល់ឈ្មួញទាំងនោះ ទ្រង់ព្រះរាជទានផ្ទះ ហើយត្រាស់ថា ពួកអ្នកកាលបើលក់ទំនិញអស់ហើយ ប្រាថ្នានឹងត្រឡប់ទៅ ពួកអ្នកគប្បីមកជួបយើងហើយសឹមត្រឡប់ទៅ ដូច្នេះ ។ ពួកឈ្មួញទាំងនោះធ្វើការលក់ដូរហើយ ក៏ចូលទៅគាល់ព្រះរាជាក្នុងវេលាត្រឡប់ ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរត្រឡប់ទៅ ពួកអ្នកចូរទូលសួរដល់ការមិនមានព្រះរោគរឿយៗ តាមពាក្យរបស់យើង ហើយទូលថា ព្រះរាជាទ្រង់មានព្រះបំណងចងមិត្តភាពនឹងព្រះអង្គ ។ ឈ្មួញទាំងនោះទូលទទួលព្រះរាជឱង្ការហើយ ទៅប្រមូលទំនិញ ទទួលប្រទានអាហារព្រឹក ហើយចេញទៅ លុះដល់នគរតក្កសិលាហើយ ទទួល

ទានអាហារពេលព្រឹករួច ក៏ចូលទៅថ្វាយបង្គំព្រះរាជា ។ ព្រះរាជាត្រាស់សួរថា នែ៎នាយ ពួកអ្នកទៅណាមិនឃើញច្រើនថ្ងៃហើយ ។ ពួកឈ្មួញទូលប្រាប់រឿងរ៉ាវទាំងអស់ចំពោះព្រះរាជា ។ ព្រះរាជាទ្រង់មានព្រះហឫទ័យត្រេកអរថា ម្នាលបាទាំងឡាយ ជាការល្អ ដែលមានព្រះរាជាមានសភាពដូចជាយើង ព្រះរាជាក្នុងមជ្ឈិមប្រទេសបានមិត្តហើយ ព្រោះអាស្រ័យពួកអ្នក ។

ក្នុងវេលាតមក ឈ្មួញទាំងឡាយសូម្បីនៅក្នុងនគររាជគ្រឹះ ក៏ទៅកាន់នគរតក្កសិលា ។ ព្រះរាជាបុក្កុសាតិ ត្រាស់សួរឈ្មួញទាំងនោះ ដែលកាន់បណ្ណាការមកថា ពួកអ្នកមកពីណា ។ ព្រះរាជាទ្រង់ស្តាប់ថា មកអំពីនគររាជគ្រឹះ ទើបត្រាស់ថា ពួកអ្នកមកពីនគររបស់សម្លាញ់យើង ។ យ៉ាងនោះហើយព្រះអង្គ ។ ព្រះរាជាត្រាស់សួរដល់ការមិនមានព្រះរោគថា សម្លាញ់របស់យើងមិនមានព្រះរោគឬ ហើយទ្រង់ឲ្យវាយស្គរប្រកាសថា ចាប់តាំងពីថ្ងៃនេះ ពួកឈ្មួញថ្មើរជើង ឬពួករទេះ ពួកណាមកពីនគររបស់សម្លាញ់យើង ចាប់តាំងពីថ្ងៃនេះទៅ ឈ្មួញទាំងពួងដែលចូលមកកាន់ព្រំប្រទល់របស់យើង ចូរឲ្យផ្ទះជាទីសម្រាកអាស្រ័យ និងស្បៀងអំពីព្រះឃ្លាំង ចូរលះបង់ការស៊ី កុំធ្វើអន្តរាយណាៗ ដល់ឈ្មួញទាំងនោះ ដូច្នេះ ។ ចំណែកព្រះបាទពិម្ពិសារ ក៏ទ្រង់ឲ្យគេវាយស្គរប្រកាស

ដូច្នេះ ដូចគ្នានឹងនគរសម្លាញ់របស់ព្រះអង្គ ។ លំដាប់នោះ ព្រះបាទពិម្ពិសារ ទ្រង់បានបញ្ជូនបណ្ណាការដល់ព្រះបាទបុក្កុសាតិថា រតនៈទាំងឡាយ មានកែវមណី និងមុក្តាជាដើម រមែងកើតក្នុងបច្ចន្តប្រទេស រតនៈណាដែលគួរឃើញ ឬគួរស្តាប់ កើតឡើងក្នុងរាជសម្បត្តិនៃសម្លាញ់ សូមសម្លាញ់ ចូរទ្រង់កុំកំណាញ់ក្នុងរតនៈនោះ ។ ចំណែកព្រះបាទបុក្កុសាតិ ក៏ទ្រង់បញ្ជូនព្រះរាជបណ្ណាការតបទៅថា ធម្មតាមជ្ឈិមប្រទេសជាមហាជនបទ រតនៈបែបណា រមែងកើតក្នុងមហាជនបទនោះ សូមសម្លាញ់ទ្រង់កុំកំណាញ់ក្នុងរតនៈនោះ ។ កាលកន្លងទៅៗយ៉ាងនេះ ព្រះរាជាទាំងនោះ សូម្បីទ្រង់មិនឃើញគ្នា ក៏ជាមិត្តដ៏ល្អនឹងគ្នា ។ កាលព្រះរាជាទាំងពីរព្រះអង្គនោះ ទ្រង់ធ្វើការត្រាស់យ៉ាងនេះ បណ្ណាការរមែងកើតដល់ព្រះបាទបុក្កុសាតិមុន ។ បានឮថា ព្រះរាជាទ្រង់បានសំពត់កម្ពល ៨ ផ្ទាំង ដែលកាត់ថ្លៃមិនបាន មានប្រាំពណ៌ ។ ព្រះរាជានោះ ទ្រង់ព្រះតម្រិះថា សំពត់កម្ពលទាំងនេះល្អយ៉ាងក្រៃលែង យើងនឹងបញ្ជូនឲ្យសម្លាញ់របស់យើង ។ ទ្រង់បញ្ជូនអាមាត្រទាំងឡាយ ដោយព្រះតម្រាស់ថា ពួកលោកចូរឲ្យធ្វើប្រអប់ដ៏រឹង ៨ ប្រអប់ ប៉ុនដុំល័ក្ខ ដាក់សំពត់កម្ពលទាំងនោះក្នុងប្រអប់ទាំងនោះ ឲ្យលាបដោយល័ក្ខ រុំដោយសំពត់ស ដាក់ក្នុងហិប រុំដោយសំពត់ ប្រថាប់ត្រា

ព្រះរាជលញ្ចករហើយ ថ្វាយដល់សម្លាញ់របស់យើង និងបានព្រះទានព្រះរាជ-
សាសន៍ថា បណ្ណាការនេះ ដែលយើងនឹងអាមាត្រជាដើមហែហមហើយ ឃើញ
ត្រង់កណ្តាលព្រះនគរ ។ អាមាត្រទាំងនោះទៅទូលថ្វាយ ចំពោះព្រះបាទពិម្ពិ-
សារ ។ ព្រះបាទពិម្ពិសារ ទ្រង់ស្តាប់ព្រះរាជសាសន៍ ទ្រង់ឲ្យវាយស្គរប្រកាស
ថា ជនទាំងឡាយ មានអាមាត្រជាដើមចូរប្រជុំគ្នា ដូច្នេះ ដែលអាមាត្រជាដើម
ហែហមហើយត្រង់កណ្តាលព្រះនគរ ទ្រង់មានសេ្វតឆត្របាំង ប្រថាប់អង្គុយលើ
ព្រះរាជបល្ល័ង្កដ៏ប្រសើរ ទ្រង់ទម្លាយត្រាដែលប្រថាប់ បើកសំពត់ចេញ បើក
ប្រអប់ ស្រាយគ្រឿងខាងក្នុង ទ្រង់ឃើញដុំល័ក្ខ ទ្រង់មានព្រះតម្រិះថា ព្រះបាទ
បុក្កុសាតិសម្លាញ់របស់យើង គង់សម្គាល់ថា សម្លាញ់របស់យើងមានព្រះរាជ-
ហឫទ័យទូលាយ ទើបទ្រង់បញ្ជូនព្រះរាជបណ្ណាការនេះមកឲ្យ ដូច្នេះ ។ ទ្រង់ចាប់
ដុំល័ក្ខ ហើយទ្រង់បន្ទិលដោយព្រះហស្ត ពិចារណាមើល ក៏ទ្រង់មិនជ្រាបថា
ខាងក្នុងមានគ្រឿងសំពត់ ។ លំដាប់នោះ ទ្រង់វាយដុំនោះត្រង់ជើងព្រះរាជ-
បល្ល័ង្ក ។ ក្នាមនោះ ល័ក្ខក៏បែកចេញ ។ ព្រះអង្គទ្រង់បើកប្រអប់ដោយព្រះនខា
ទ្រង់ឃើញកម្ពលរតនៈខាងក្នុង ហើយទ្រង់ឲ្យបើកប្រអប់ទាំងឡាយ សូម្បីក្រៅ
ពីនេះ ។ សូម្បីទាំងអស់ក៏ជាសំពត់កម្ពល ។ លំដាប់នោះ ទ្រង់ឲ្យលាតសំពត់

កម្ពលទាំងនោះ ។ សំពត់កម្ពលទាំងនោះដល់ព្រមដោយពណ៌ ដល់ព្រមដោយសម្ផស្ស ប្រវែង ១៦ ហត្ថ ទទឹង ៨ ហត្ថ ។ មហាជនទាំងឡាយឃើញហើយក៏ចាប់លើកសំពត់តូចៗ ឡើង នាំគ្នាសប្បាយចិត្តថា ព្រះរាជាបុក្កុសាតិ មិនធ្លាប់ជួប ឬឃើញព្រះរាជានៃពួកយើង ទ្រង់មិនឃើញគ្នាឡើយ នៅតែទ្រង់បញ្ជូនព្រះរាជបណ្ណាការបែបនេះ សមគួរពិតដើម្បីធ្វើព្រះរាជាមានសភាពបែបនេះឲ្យជាមិត្ត ។ ព្រះរាជាទ្រង់ឲ្យវាយតម្លៃសំពត់កម្ពលមួយផ្ទាំងៗ ។ សំពត់កម្ពលគ្រប់ផ្ទាំងកាត់ថ្លៃមិនបាន ។ ក្នុងសំពត់កម្ពល ៨ ផ្ទាំងនោះ ទ្រង់ថ្វាយបួនផ្ទាំងចំពោះព្រះសម្មាសម្ពុទ្ធ ។ ទ្រង់ទុកប្រើបួនផ្ទាំងក្នុងព្រះរាជវាំងរបស់ព្រះអង្គ ។ តពីនោះ ទ្រង់មានព្រះរាជតម្រិះថា ការដែលយើងនឹងបញ្ជូនបណ្ណាការជាខាងក្រោយ ក៏គួរបញ្ជូនបណ្ណាការល្អជាងបណ្ណាការដែលបញ្ជូនមកហើយនេះក៏សម្លាញ់បានបញ្ជូនបណ្ណាការដែលកាត់ថ្លៃមិនបានដល់យើង យើងនឹងបញ្ជូនអ្វីល្អហ្ន៎ ។ ក៏ក្នុងក្រុងរាជគ្រឹះមិនមានវត្ថុដែលល្អក្រៃលែងជាងនោះឬ ។ មិនមានមិនមែន ព្រះរាជាទ្រង់មានបុណ្យច្រើនប្រការមួយ ម្យ៉ាងទៀត ចាប់តាំងពីកាលដែលព្រះអង្គទ្រង់ជាព្រះសោតាបន្នហើយ វៀរចាកព្រះរតនត្រ័យហើយមិនមានវត្ថុដទៃណាដែលឈ្មោះថា អាចដើម្បីញ៉ាំងព្រះសោមនស្សឲ្យកើតឡើង

បាន ។ ព្រះអង្គទើបទ្រង់ប្រារព្ធដើម្បីទ្រង់ជ្រើសរើសរតនៈ ។ ធម្មតារតនៈមាន ២ យ៉ាង គឺ មានវិញ្ញាណ មិនមានវិញ្ញាណ ។ ក្នុងរតនៈ ២ យ៉ាងនោះ រតនៈដែលមិនមានវិញ្ញាណ បានដល់ មាស និងប្រាក់ជាដើម ដែលមានវិញ្ញាណ បានដល់វត្ថុដែលជាប់ទីឥន្ទ្រិយ ។ រតនៈដែលមិនមានវិញ្ញាណ ជាគ្រឿងប្រើប្រាស់ដែលជាគ្រឿងប្រដាប់ជាដើម នៃរតនៈដែលមានវិញ្ញាណនោះឯង ។ ក្នុងរតនៈ ២ យ៉ាងនេះ រតនៈដែលមានវិញ្ញាណប្រសើរជាទីបំផុត ។ រតនៈសូម្បីមានវិញ្ញាណ មាន ២ យ៉ាង គឺ តិរច្ឆានរតនៈ មនុស្សរតនៈ ។ ក្នុងរតនៈ ២ យ៉ាងនោះ តិរច្ឆានរតនៈ បានដល់ ដំរីកែវ និងសេះកែវ ។ តិរច្ឆានរតនៈសូម្បីនោះ កើតឡើងដើម្បីជាគ្រឿងប្រើរបស់មនុស្សទាំងឡាយនោះឯង ។ ក្នុងរតនៈ ២ យ៉ាងនោះ មនុស្សរតនៈ ប្រសើរជាទីបំផុត ដោយប្រការដូច្នេះ ។ សូម្បីមនុស្សរតនៈ ក៏មាន ២ យ៉ាង គឺ ឥត្ថីរតនៈ បុរិសរតនៈ ។ ក្នុងរតនៈ ២ យ៉ាងនោះ សូម្បីឥត្ថីរតនៈ ដែលកើតដល់ស្តេចចក្រពត្តិ រមែងជាឧបភោគរបស់បុរសនោះឯង ។ ក្នុងរតនៈ ២ យ៉ាងនេះ បុរិសរតនៈ ប្រសើរជាទីបំផុត ដោយប្រការដូច្នេះ ។

សូម្បីបុរិសរតនៈ ក៏មាន ២ យ៉ាង គឺ អាគារិករតនៈ ១ អនាគារិក-

រតនៈ ១ ។ សូម្បីក្នុងអាគារិករតនៈនោះ ស្តេចចក្រពត្តិទ្រង់រមែងនមស្ការសាមណេរដែលបួសក្នុងថ្ងៃនេះដោយព្រះបញ្ចង្គប្រតិស្ឋាន ។ ក្នុងរតនៈទាំង ២ យ៉ាងនេះ អនាគារិករតនៈប៉ុណ្ណោះប្រសើរជាទីបំផុត ។ សូម្បីអនាគារិករតនៈក៏មាន ២ យ៉ាង គឺ សេក្ខរតនៈ ១ អសេក្ខរតនៈ ១ ។

ក្នុងអនាគារិករតនៈ ២ យ៉ាងនោះ ព្រះសេក្ខៈទាំងសែន រមែងមិនដល់ចំណែកនៃព្រះអសេក្ខៈ ។

ក្នុងរតនៈ ២ យ៉ាងសូម្បីនេះ អសេក្ខរតនៈប៉ុណ្ណោះ ប្រសើរជាទីបំផុត ។ អសេក្ខរតនៈសូម្បីនោះ ក៏មាន ២ យ៉ាង គឺ ពុទ្ធរតនៈ សាវករតនៈ ។ ក្នុងអសេក្ខរតនៈនោះ សាវករតនៈសូម្បីទាំងសែន ក៏មិនដល់ចំណែកនៃពុទ្ធរតនៈ ។ ក្នុងរតនៈ ២ យ៉ាងសូម្បីនេះ ពុទ្ធរតនៈប៉ុណ្ណោះ ប្រសើរទីបំផុត ដោយប្រការដូច្នេះ ។ សូម្បីពុទ្ធរតនៈក៏មាន ២ យ៉ាង គឺ បច្ចេកពុទ្ធរតនៈ និងសព្វញ្ញុពុទ្ធ-រតនៈ ។ ក្នុងពុទ្ធរតនៈនោះ បច្ចេកពុទ្ធរតនៈសូម្បីទាំងសែន ក៏មិនដល់ចំណែកនៃសព្វញ្ញុពុទ្ធ ។ ក្នុងរតនៈ ២ យ៉ាងនេះ សព្វញ្ញុពុទ្ធរតនៈប៉ុណ្ណោះ ប្រសើរជាទីបំផុត ដោយប្រការដូច្នេះ ។ ដែលឈ្មោះថា រតនៈ ដែលស្មើដោយពុទ្ធ-រតនៈរមែងមិនមាន ក្នុងលោកព្រមទាំងទេវលោក ។ ព្រោះដូច្នោះ ទើបទ្រង់

មានព្រះតម្រិះថា យើងនឹងបញ្ជូនរតនៈដែលមិនមានអ្វីស្មើប៉ុណ្ណោះ ដល់សម្លាញ់របស់យើង ទើបត្រាស់សួរពួកឈ្មួញអ្នកនគរតក្កសិលាថា ម្នាលបាទាំងឡាយ រតនៈ ៣ យ៉ាងនេះ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រមែងប្រាកដក្នុងជនបទរបស់ពួកអ្នកឬ ។ បពិត្រមហារាជ សូម្បីសំឡេងក៏មិនមានក្នុងជនបទនោះ ក៏ការឃើញនឹងមានមកអំពីណា ។ ព្រះរាជាទ្រង់ត្រេកអរហើយ ទ្រង់ព្រះតម្រិះថា យើងអាចនឹងបញ្ជូនព្រះសម្មាសម្ពុទ្ធទៅកាន់ស្ថានទីជាទីនៅរបស់សម្លាញ់យើង ដើម្បីប្រយោជន៍ដល់ការសង្គ្រោះជន តែព្រះពុទ្ធទាំងឡាយ ទ្រង់មិនស្នាក់នៅមួយយប់ក្នុងបច្ចន្តជនបទទាំងឡាយ ព្រោះដូច្នោះ ព្រះសាស្ដាស្ដេចនឹងមិនអាចទៅ គប្បីអាចបញ្ជូនព្រះមហាសាវក មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម តែយើងស្ដាប់មកថា ព្រះថេរៈទាំងឡាយនៅក្នុងបច្ចន្តជនបទ ជនអ្នកមានសទ្ធាទាំងឡាយ តែងបញ្ជូនមនុស្សទាំងឡាយ ទៅនាំព្រះថេរៈទាំងនោះមកកាន់ទីជិតខ្លួន ហើយទំនុកបម្រុងតែម្ដង ព្រោះដូច្នោះ សូម្បីព្រះថេរៈទាំងឡាយក៏មិនអាចទៅ កាលបញ្ជូនសាសន៍ទៅហើយ ដោយបណ្ណាការណា ព្រះសាស្ដា និងព្រះមហាសាវកទាំងឡាយ ក៏ដូចជាទៅហើយ យើងនឹងបញ្ជូនសាសន៍ដោយបណ្ណាការនោះ ដូច្នេះ ទ្រង់ព្រះតម្រិះទៀតថា យើងឲ្យធ្វើផែនមាសប្រវែងបួន

ហត្ថ ទទឹងប្រមាណមួយចំអាម កម្រាស់ល្មមសមគួរ មិនក្រាស់ពេកស្តើងពេក ហើយទើងចារអក្សរចុះក្នុងផែនមាសនោះក្នុងថ្ងៃនេះ ទ្រង់ស្រោចស្រប់ព្រះសិរសា តាំងពីព្រឹកព្រលឹម ទ្រង់អធិដ្ឋានអដ្ឋឧបោសថ ទ្រង់សោយព្រះក្រយាហារពេលព្រឹក ទ្រង់ដោះព្រះសុគន្ធមាលា និងអាភរណៈចេញ ទ្រង់កាន់ជាតពណ៌ក្រហមដោយផ្តិលមាស ទ្រង់បិទទ្វារទាំងឡាយតាំងពីជាន់ក្រោម ស្តេចទ្រង់ឡើងកាន់ប្រាសាទ ទ្រង់បើកព្រះសីហបញ្ជរផ្នែកទិសខាងកើត ទ្រង់ប្រថាប់អង្គុយលើផ្ទៃអាកាស ទ្រង់ចារអក្សរចុះក្នុងផែនមាស ទ្រង់ចារព្រះពុទ្ធគុណដោយឯកទេសមុនថា ព្រះតថាគត ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ដល់ព្រមដោយវិជ្ជា និងចរណៈ ស្តេចទៅល្អហើយ ទ្រង់ដឹងច្បាស់នូវលោក ទ្រង់ជាសារថី ទូន្មានទៅបុរស ជាព្រះសាស្តារបស់ទេវតា និងមនុស្សទាំងឡាយ ទ្រង់ភ្ញាក់ហើយ ទ្រង់ចែកព្រះធម៌ ស្តេចឧប្បត្តិក្នុងលោកនេះ ដូច្នេះ ។ តអំពីនោះ ទ្រង់លិខិតថា ព្រះពុទ្ធទ្រង់បំពេញបារមី ១០ យ៉ាងនេះ ទ្រង់ចុតិអំពីតុសិត ទ្រង់បដិសន្ធិក្នុងព្រះគភ៌ព្រះមាតា ការបើកលោកបានមានហើយយ៉ាងនេះ កាលទ្រង់នៅក្នុងព្រះគភ៌មាតា ឈ្មោះនេះបានមានហើយ កាលទ្រង់នៅគ្រប់គ្រងផ្ទះ ឈ្មោះនេះបានមានហើយ កាលស្តេចចេញព្រះមហាភិនេស្ក្រម៍យ៉ាងនេះ ទ្រង់ផ្តើមតាំង

សេចក្តីព្យាយាមដ៏ធំក្រៃលែងយ៉ាងនេះ ទ្រង់បំពេញទុក្ករកិរិយាយ៉ាងនេះ ស្តេចឡើងកាន់មណ្ឌលមហាពោធិ ប្រថាប់អង្គុយលើអបរាជិតបល្ល័ង្ក ទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណ កាលទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណ ជាការបើកលោកហើយយ៉ាងនេះ ដែលឈ្មោះថា រតនៈបែបនេះ មិនមានក្នុងលោកព្រមនឹងទេវលោក ដូច្នេះ ទ្រង់លិខិតព្រះពុទ្ធគុណទាំងឡាយដោយឯកទេសយ៉ាងនេះថា ទ្រព្យជាគ្រឿងរីករាយចិត្តណាមួយក្នុងលោកនេះ ឬលោកដទៃ ឬរតនៈណាដែលប្រណីតក្នុងសួគ៌ ទ្រព្យ និងរតនៈនោះ ស្មើដោយព្រះតថាគតមិនមាន ពុទ្ធរតនៈសូម្បីនេះជារតនៈដែលប្រណីត ដោយពាក្យសច្ចនេះ សូមសិរីសួស្តីចូរមាន ដូច្នេះ កាលនឹងទ្រង់សរសើរព្រះធម្មរតនៈ ជារតនៈទីពីរថា ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ។ល។ ដែលវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន ដូច្នេះហើយ ទ្រង់លិខិតពោធិបក្ខិយធម៌ ៣៧ ប្រការ ដោយឯកទេសថា សតិប្បដ្ឋានបួន ។ល។ មគ្គមានអង្គ ៨ ដ៏ប្រសើរ ឈ្មោះថា ព្រះធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយបែបនេះ និងបែបនេះ ដូច្នេះ ហើយទ្រង់លិខិតព្រះធម្មគុណទាំងឡាយ ដោយឯកទេសថា ព្រះពុទ្ធ ជាបុគ្គលប្រសើរបំផុត ទ្រង់សរសើរហើយនូវសមាធិណាថា ជាធម៌ដ៏ស្អាត បណ្ឌិតទាំងឡាយពោលនៅសមាធិឯណាថា ជាធម៌ឲ្យ

ផលក្នុងលំដាប់ សមាធិដទៃស្មើដោយសមាធិនោះ រមែងមិនមាន ធម្មរតនៈ សូម្បីនេះ ជារតនៈដ៏ប្រណីត ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីចូរមាន ដូច្នេះ តអំពីនោះ កាលនឹងទ្រង់សរសើរព្រះសង្ឃរតនៈ ដែលជារតនៈទីបីថា ព្រះសង្ឃ-សាវករបស់ព្រះមានព្រះភាគ ជាអ្នកបដិបត្តិល្អ ។ល។ ជាស្រែបុណ្យរបស់សត្វលោក ដូច្នេះ ទ្រង់លិខិតចូឡសីល មជ្ឈិមសីល និងមហាសីល ដោយឯក-ទេសថា ធម្មតាកុលបុត្រទាំងឡាយ ស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ ចេញបួសយ៉ាងនេះ ពួកខ្លះលះបង់ស្វេតឆត្របួស ពួកខ្លះលះបង់ភាពជាឧបរាជបួស ពួកខ្លះលះបង់តំណែងទាំងឡាយ មានតំណែងសេនាបតីជាដើមបួស កាលបួសហើយ ក៏បំពេញវត្តបដិបត្តិនេះ ទ្រង់លិខិតការសង្រួមក្នុងទ្វារ ៦ សតិសម្បជញ្ញៈ សេចក្តីត្រេកអរក្នុងការចម្រើនសេចក្តីសន្តោសដោយបច្ច័យបួន ការលះនីវរណៈ បរិកម្មឈាន និងអភិញ្ញា កម្មដ្ឋាន ៣៨ ប្រការ ដរាបដល់ការអស់ទៅនៃអាសវៈដោយឯកទេស ទ្រង់លិខិតអានាបានស្សតិកម្មដ្ឋាន ១៦ ប្រការ ដោយពិស្តារ ទ្រង់លិខិតព្រះសង្ឃគុណទាំងឡាយដោយឯកទេសថា ឈ្មោះថា ព្រះសង្ឃសាវករបស់ព្រះសាស្តាដល់ព្រមដោយគុណទាំងឡាយដូច្នេះ និងបែបនេះ បុគ្គលពួកណា ៨ ពួក ៤ គូ ដែលសប្បុរសទាំងឡាយសរសើរហើយ បុគ្គលទាំង

នោះ គួរដល់ទក្ខិណាទាន ជាសាវករបស់ព្រះសុគត ទានទាំងឡាយដែលបុគ្គលថ្វាយហើយក្នុងលោកទាំងនោះ រមែងមានផលច្រើន សង្ឃរតនៈសូម្បីនេះ ជារតនៈដ៏ប្រណីត ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីចូរមាន ទ្រង់លិខិតថាសាសនារបស់ព្រះមានព្រះភាគ ត្រាស់ល្អហើយ ជាសាសនានាំសត្វចេញចាកទុក្ខ បើសម្លាញ់របស់យើងនឹងអាចសោត សូមស្តេចចេញព្រះផ្នួសចុះ ដូច្នេះទ្រង់មូរផែនមាស រុំដោយសំពត់កម្ពលសាច់ល្អិត ទ្រង់ដាក់ក្នុងហិបដ៏រឹង ទ្រង់ដាក់ហិបនោះក្នុងហិបមាស ទ្រង់ដាក់ហិបមាសចុះក្នុងហិបប្រាក់ ទ្រង់ដាក់ហិបប្រាក់ចុះក្នុងហិបកែវមណី ទ្រង់ដាក់ហិបកែវមណីចុះក្នុងហិបកែវប្រវាឡ ទ្រង់ដាក់ហិបកែវប្រវាឡចុះក្នុងហិបកែវទទ្ទឹម ទ្រង់ដាក់ហិបកែវទទ្ទឹមចុះក្នុងហិបកែវមរកត ទ្រង់ដាក់ហិបកែវមរកតចុះក្នុងហិបកែវផលឹក ទ្រង់ដាក់ហិបកែវផលឹកចុះក្នុងហិបភ្លុក ទ្រង់ដាក់ហិបភ្លុកចុះក្នុងហិបរតនៈគ្រប់យ៉ាង ទ្រង់ដាក់ហិបរតនៈគ្រប់យ៉ាងចុះក្នុងហិបឫស្សី ទ្រង់ដាក់ហិបឫស្សីចុះក្នុងប្រអប់រឹង ទ្រង់ដាក់ប្រអប់រឹងចុះក្នុងប្រអប់មាសទៀត ទ្រង់នាំទៅដោយន័យមុននោះឯង ទ្រង់ដាក់ប្រអប់ដែលធ្វើដោយរតនៈគ្រប់យ៉ាងចុះក្នុងប្រអប់ដែលធ្វើដោយឫស្សី ។ បន្ទាប់ពីនោះទ្រង់ដាក់ប្រអប់ដែលធ្វើដោយឫស្សចុះក្នុងហិបដែលធ្វើដោយឈើខ្លឹម ខាងក្រៅ

ទ្រង់រំដោយសំពត់ប្រថាប់ត្រាព្រះរាជលញ្ចករ ត្រាស់បង្គាប់អាមាត្រទាំងឡាយថា អ្នកទាំងឡាយចូរតាក់តែងផ្លូវក្នុងស្ថានទីដែលនៅក្នុងអំណាចរបស់យើង ធ្វើឲ្យមានទទឹង ៨ ឧសភៈ , ស្ថានទី ៤ ឧសភៈ ត្រូវឲ្យស្មើល្អ អ្នកទាំងឡាយចូរតាក់តែងស្ថានទី ៤ ឧសភៈ ត្រង់កណ្តាលដោយអានុភាពរបស់ព្រះរាជ ។ បន្ទាប់ពីនោះ ទ្រង់បញ្ជូនទូតដល់អ្នករាជការខាងក្នុងថា ចូរប្រដាប់ដំរីមង្គល ចាត់បល្ល័ង្កលើដំរីនោះ លើកស្វេតឆត្រ ធ្វើថ្នល់ព្រះនគរឲ្យស្អាតល្អ តុបតែងលម្អដោយទង់បដាដែលស្រស់ល្អ ដើមចេក ធ្នាំងទឹកដែលពេញដោយរបស់ក្រអូប ធូបនិងផ្កាឈើជាដើម ចូរធ្វើបូជាបែបនេះ ក្នុងស្ថានទីគ្រប់គ្រងរៀងៗ ខ្លួន ដូច្នេះ ចំណែកព្រះអង្គទ្រង់ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ដែលមានកងកម្លាំងព្រមទាំងតន្ត្រីគ្រប់ប្រភេទហែហម ទ្រង់ត្រិះរិះថា យើងនឹងបញ្ជូនបណ្ណាការទៅដូច្នេះ ស្តេចទៅដរាបដល់ទីបំផុតព្រះរាជអាណាខេត្តរបស់ព្រះអង្គ ហើយបានព្រះរាជទានព្រះរាជសាសន៍ដ៏សំខាន់ដល់អាមាត្រ ហើយត្រាស់ថា ម្នាលបា! ព្រះរាជាបុក្កុសាតិព្រះសម្លាញ់របស់យើង កាលទ្រង់ទទួលបណ្ណាការនេះ កុំទទួលត្រង់កណ្តាលដំណាក់នាងស្នំកំណាន់ ចូរស្តេចឡើងព្រះប្រាសាទ ហើយទ្រង់ទទួលចុះ ។ លុះព្រះរាជទានព្រះរាជសាសន៍នេះហើយ ទ្រង់ត្រិះរិះថា

ព្រះសាស្ដាស្ដេចទៅកាន់បច្ចន្តប្រទេស ទ្រង់នមស្សការដោយព្រះបញ្ចង្គប្រតិ-ស្ឋាន ហើយស្ដេចត្រឡប់ ។ ចំណែកអ្នករាជការខាងក្នុងទាំងឡាយ តាក់តែងផ្លូវដោយទំនងនោះឯង នាំទៅនូវព្រះរាជបណ្ណាការ ។

ចំណែកព្រះបាទបុក្កុសាតិ ទ្រង់តាក់តែងផ្លូវដោយទំនងនោះ តាំងពីរាជសីមារបស់ព្រះអង្គ ទ្រង់ឲ្យតាក់តែងព្រះនគរ ទើបទ្រង់ធ្វើការទទួលព្រះ-រាជបណ្ណាការ ។ ព្រះរាជបណ្ណាការ កាលដល់ព្រះនគរតក្កសិលា បានដល់ក្នុងថ្ងៃឧបោសថ ។ ចំណែកអាមាត្រអ្នកទទួលព្រះរាជបណ្ណាការ ទៅក្រាបទូលប្រាប់ព្រះរាជសាសន៍ចំពោះព្រះរាជា ។ ព្រះរាជាទ្រង់ស្ដាប់ព្រះរាជសាសន៍នោះហើយ ទ្រង់ពិចារណាកិច្ចដែលគួរធ្វើដល់អាមាត្រទាំងឡាយអ្នកមក ព្រមទាំងព្រះរាជបណ្ណាការ ទ្រង់កាន់ព្រះរាជបណ្ណាការ ស្ដេចឡើងកាន់ព្រះប្រាសាទហើយត្រាស់ថា នរណាៗ កុំចូលមកក្នុងទីនេះ ទ្រង់ឲ្យធ្វើការរក្សាត្រង់ទ្វារ ទ្រង់បើកព្រះសីហបញ្ជរ ទ្រង់ដាក់ព្រះរាជបណ្ណាការ លើទីខ្ពស់ ចំណែកព្រះអង្គប្រថាប់អង្គុយលើអាសនៈក្រោម ទ្រង់ទម្លាយស្នាមប្រថាប់ ទ្រង់ដោះគ្រឿងគ្របដណ្ដប់កាលទ្រង់បើកដោយលំដាប់ផ្ដើមតាំងពីហិបធ្វើដោយឫស្សី ទ្រង់ឃើញហិបដែលធ្វើដោយខ្លឹមចន្ទន៍ ទ្រង់ត្រិះរិះថា ឈ្មោះថា មហាបរិវារនេះ នឹងមិនមានដល់រតនៈ

ដទៃ រតនៈដែលគួរស្តាប់បានកើតឡើងហើយ ក្នុងមជ្ឈិមប្រទេសពិតប្រាកដ ។ លំដាប់នោះ ទ្រង់បើកហិបនោះហើយ ទ្រង់ទម្លាយស្នាមប្រថាប់ព្រះរាជលញ្ចករ ទ្រង់បើកសំពត់កម្ពលដែលមានសាច់ល្អិតទាំងពីរខាង ទ្រង់ឃើញផែនមាស ។ ព្រះអង្គទ្រង់លាតផែនមាសនោះចេញ ទ្រង់ត្រិះរិះថា "អក្សរទាំងឡាយគួរពេញចិត្តណាស់ហ្ន៎ មានទំហំប៉ុនគ្នា មានរបៀបរៀបរយ មានជ្រុងបួន" ដូច្នេះ ទ្រង់ប្រារព្ធដើម្បីនឹងទ្រង់អានផ្តើមតាំងអំពីដើម ។ ព្រះសោមនស្សដែលមានកម្លាំងបានកើតឡើងដល់ព្រះអង្គ ទ្រង់អានហើយអានទៀតនូវព្រះពុទ្ធគុណទាំងឡាយថា ព្រះតថាគតទ្រង់ឧប្បត្តិឡើងហើយក្នុងលោកនេះ ។ រណ្តៅព្រះលោមា ៩ ម៉ឺនរណ្តៅ ក៏មានចុងព្រះលោមងឡើង ។ ព្រះអង្គទ្រង់មិនជ្រាបដល់សេចក្តីដែលព្រះអង្គប្រថាប់ឈរ ឬប្រថាប់អង្គុយ ។ លំដាប់នោះ បីតិដ៏មានកម្លាំងយ៉ាងក្រៃលែងបានកើតឡើងដល់ព្រះអង្គថា យើងបានស្តាប់ព្រះសាសនាដែលរកបានដោយលំបាកនេះ សូម្បីដោយសែនកោដិកប្ប ព្រោះអាស្រ័យសម្លាញ់ ។ ព្រះអង្គកាលមិនអាចដើម្បីទ្រង់អានតទៅ ក៏ប្រថាប់អង្គុយរហូតដល់កម្លាំងបីតិស្ងប់រម្ងាប់ ហើយទ្រង់ប្រារព្ធព្រះធម្មគុណទាំងឡាយតទៅថា ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ដូច្នេះ ។ ព្រះអង្គក៏ទ្រង់មានបីតិយ៉ាងនោះ

សូម្បីក្នុងព្រះធម្មគុណនោះឯង ។ ព្រះអង្គប្រថាប់អង្គុយទៀត ដរាបដល់សេចក្តីស្ងប់នៃកម្លាំងបីតិ ទ្រង់ប្រារព្ធព្រះសង្ឃគុណទាំងឡាយតទៅថា ព្រះសង្ឃសាវកជាអ្នកបដិបត្តិល្អ ។ ក្នុងព្រះសង្ឃគុណសូម្បីនោះ ព្រះអង្គក៏ទ្រង់មានបីតិយ៉ាងនោះ ដូចគ្នា ។ លំដាប់នោះ ទ្រង់អានអានាបានស្សតិកម្មដ្ឋាន ក្នុងលំដាប់ចុងក្រោយបង្អស់ ទ្រង់ញ៉ាំងឈានពួក ៤ និងពួក ៥ ឲ្យកើតឡើង ។ ព្រះអង្គទ្រង់ញ៉ាំងវេលាឲ្យកន្លងទៅ ដោយសេចក្តីសុខក្នុងឈាននោះឯង ។ អ្នកដទៃណារមែងមិនបានដើម្បីឃើញ ។ មហាប្ញឹកប្រចាំព្រះអង្គមួយនាក់ប៉ុណ្ណោះ រមែងចូលទៅបាន ។ ទ្រង់ញ៉ាំង វេលាប្រមាណកន្លះខែឲ្យកន្លងទៅ ដោយប្រការដូច្នេះ ។ អ្នកព្រះនគរទាំងឡាយប្រជុំគ្នាក្នុងព្រះរាជវាំង បានធ្វើការស្រែកថា ចាប់តាំងពីថ្ងៃដែលព្រះរាជាទ្រង់ទទួលព្រះរាជបណ្ណាការហើយ មិនមានការទតព្រះនេត្រដល់ព្រះនគរ ឬការទតមើលស្រីស្នំ មិនមានការព្រះរាជវិនិច្ឆ័យ ព្រះរាជាចូរទ្រង់ព្រះរាជទានព្រះរាជបណ្ណាការដែលព្រះរាជាសម្លាញ់បញ្ជូនមក ឲ្យដល់អ្នកទទួលទៅចុះ ធម្មតាព្រះរាជាទាំងឡាយ រមែងទ្រង់ព្យាយាមដើម្បីបន្លំសូម្បីដោយគ្រឿងបណ្ណាការ កាន់យកព្រះរាជសម្បត្តិរបស់ព្រះរាជាអង្គខ្លះដែលឲ្យដល់ខ្លួន ព្រះរាជារបស់ពួកយើងទ្រង់ធ្វើអ្វីហ្ន៎ ដូច្នេះ ។ ព្រះរាជាទ្រង់ស្តាប់សំឡេងស្រែក

ហើយ ទ្រង់ព្រះតម្រិះថា យើងនឹងរក្សារាជសម្បត្តិ ឬត្រូវរក្សាព្រះសាស្តា ។ លំដាប់នោះ ព្រះអង្គទ្រង់មានព្រះតម្រិះថា ប្រធាន និងមហាមាត្ររបស់ប្រធានរមែងមិនអាចដើម្បីនឹងរក្សាយើងក្នុងរាជសម្បត្តិបាន យើងនឹងទ្រទ្រង់ទុកនូវព្រះសាសនារបស់ព្រះសាស្តា ដូច្នេះ ។ ទ្រង់ចាប់ព្រះខាន់ដែលទ្រង់ទុកលើក្រឡាបន្ទំកាត់ព្រះកេសា ហើយទ្រង់បើកព្រះសីហបញ្ជរ ទ្រង់ញាំងបាច់ព្រះកេសា ព្រមទាំងព្រះចុឌាមណីឲ្យធ្លាក់ចុះត្រង់កណ្តាលបរិស័ទត្រាស់ថា "អ្នកទាំងឡាយ កាន់យកបាច់កេសានេះ ហើយគ្រប់គ្រងរាជសម្បត្តិចុះ" ។ មហាជនលើកបាច់ព្រះកេសានោះឡើង ហើយស្រែកជាសំឡេងតែមួយថា "បពិត្រព្រះសម្មតិទេព ព្រះរាជាទាំងឡាយឈ្មោះថា បានព្រះរាជបណ្ណាការអំពីសម្នាក់ព្រះរាជាសម្លាញ់ហើយ រមែងដូចព្រះអង្គ ។ ព្រះកេសា និងព្រះមស្សុប្រមាណពីរអង្គុលីរបស់ព្រះរាជាបានមានហើយ ។ បានឮថា ព្រះកេសា និងព្រះមស្សុប្រាកដដូចគ្នានឹងការបព្វជ្ជារបស់ព្រះពោធិសត្វនោះឯង" ។ លំដាប់នោះ ទ្រង់បញ្ជូនមហាថ្លឹកប្រចាំព្រះអង្គឲ្យនាំសំពត់កាសាវពស្ត្រពីរផ្ទាំង និងបាត្រដីអំពីទីផ្សារទ្រង់ឧទ្ទិសចំពោះព្រះសាស្តាថា "ព្រះអរហន្តពួកណាក្នុងលោក យើងបួសឧទ្ទិសព្រះអរហន្តទាំងនោះ" ដូច្នេះ ហើយទ្រង់ស្លៀកសំពត់កាសាវៈមួយផ្ទាំង ទ្រង់

ដណ្តប់សំពត់កាសាវៈមួយផ្ទាំង ទ្រង់ស្ពាយបាត្រ ទ្រង់កាន់ឈើច្រត់ ទ្រង់ព្រះចង្ក្រមទៅមកពីរ-បីជុំ ក្នុងប្រាសាទធំដោយព្រះតម្រិះថា "បព្វជ្ជារបស់យើងល្អឬទេ" ដូច្នេះ ទ្រង់ជ្រាបថា "បព្វជ្ជារបស់យើងល្អ" ដូច្នេះហើយទ្រង់បើកទ្វារ ស្តេចចុះចាកព្រះប្រាសាទ ។ ក៏ប្រជាជនទាំងឡាយឃើញស្រីស្នំត្រង់ទ្វារទាំងបីជាដើម តែចាំព្រះរាជានោះដែលស្តេចចុះមកមិនបាន ។ បានឮថា ប្រជាជននាំគ្នាគិតថា ព្រះបច្ចេកពុទ្ធមួយអង្គមកដើម្បីសម្តែងធម្មកថា ដល់ព្រះរាជារបស់ពួកយើង ។ តែគ្រាឡើងលើព្រះប្រាសាទហើយ ឃើញតែទីប្រថាប់ឈរ និងទីប្រថាប់អង្គុយជាដើមរបស់ព្រះរាជា ទើបដឹងថា ព្រះរាជាស្តេចចេញទៅហើយ ទើបនាំគ្នាស្រែកព្រមគ្នាតែម្តង ដូចជនក្នុងទូកកំពុងក្រឡាប់លិចក្នុងកណ្តាលសមុទ្រ ដូច្នោះ ។ សេនាទាំងដប់ប្រាំបីនាក់ អ្នកនគរទាំងអស់ និងពលកាយទាំងឡាយ នាំគ្នាហែហាមកុលបុត្រ ដែលត្រឹមតែស្តេចចុះកាន់ផ្ទៃផែនដីហើយស្រែកសំឡេងខ្លាំង ។

ចំណែកអាមាត្រទាំងឡាយ ក្រាបទូលចំពោះកុលបុត្រនោះថា "បពិត្រទេវៈ ធម្មតាព្រះរាជាទាំងឡាយក្នុងមជ្ឈិមប្រទេស ទ្រង់មានមាយាច្រើន សូមព្រះអង្គមេត្តាបញ្ជូនព្រះរាជសាសន៍ទៅថា ដែលឈ្មោះថា ពុទ្ធរតនៈបានកើតឡើងក្នុង

លោកហើយឬ ពេលទ្រង់ជ្រាបហើយសឹមស្ដេចយាងទៅ សូមព្រះអង្គស្ដេចត្រឡប់ចុះ” ។ “យើងជឿសម្លាញ់របស់យើង យើងនឹងសម្លាញ់នោះ មិនមានសេចក្ដីផ្សេងគ្នា ពួកអ្នកចូរឈប់ចុះ” ។ អាមាត្រទាំងនោះ ក៏ជាប់តាមស្ដេចនោះឯង ។ កុលបុត្រទ្រង់យកឈើច្រត់សរសេរជាអក្សរ ត្រាស់ថា “រាជសម្បត្តិនេះ ជារបស់អ្នកណា” ។ “របស់ព្រះអង្គ” ។ “អ្នកណាធ្វើអក្សរនេះក្នុងចន្លោះ (ដោះប្រស្នា) បុគ្គលនោះ គប្បីឲ្យសោយរាជ” ។ ក្នុងព្រះមហាជនកជាតកព្រះទេវីព្រះនាមថា សីវលី កាលទ្រង់មិនអាចធ្វើអក្សរដែលព្រះពោធិសត្វធ្វើហើយឲ្យមានចន្លោះ ក៏ស្ដេចត្រឡប់ទៅ ។ មហាជនក៏បានទៅតាមផ្លូវដែលព្រះទេវីស្ដេចទៅ ។ ក៏មហាជនមិនអាចធ្វើអក្សរនោះឲ្យមានក្នុងចន្លោះ ។ អ្នកនគរធ្វើព្រះអក្សរនេះទុកលើសីសៈហើយ ព្រមដោយការស្រែក ។ មហាជនគិតថា “កុលបុត្រនេះ នឹងឲ្យឈើស្ងួន ឬទឹកខ្ទរមាត់ក្នុងស្ថានទីយើងទៅហើយ” ដូច្នេះ កាលមិនបានអ្វី ដោយហោចទៅសូម្បីសំណល់សំពត់ក៏ចៀសទៅ ។ បានឮថា កុលបុត្រនោះ មានសេចក្ដីគិតយ៉ាងនេះថា “ព្រះសាស្ដារបស់យើងស្ដេចចេញមហាភិនេស្រ្កម៍ ទ្រង់បព្វជ្ជាតែមួយព្រះអង្គឯង ស្ដេចទៅតែមួយព្រះអង្គឯង យើងខ្មាសចំពោះព្រះសាស្ដា បានឮថា ព្រះសាស្ដារបស់យើងទ្រង់បព្វជ្ជាហើយ

មិនស្តេចឡើងយាន និងទ្រង់មិនពាក់ស្បែកព្រះបាទ ដោយហោចទៅសូម្បីតែមួយជាន់ ទ្រង់មិនបាំងឆត្រ” ។ មហាជនឡើងដើម ឈើកំពែង និងប៉មជាដើមក្រឡេកមើលថា “ព្រះរាជារបស់យើងស្តេចទៅ” ដូច្នេះ ។ កុលបុត្រគិតថា “យើងដើរផ្លូវឆ្ងាយ មិនអាចដើម្បីនឹងទៅផ្លូវមួយបាន ទើបស្តេចជាប់តាមឈ្មួញមួយពួក” ។ កាលកុលបុត្រជាអ្នកសុខុមមាល ទៅក្នុងផែនដីដែលក្តៅគគុកផ្ទៃព្រះបាទទាំងសងខាងក៏ពង ហើយមានខ្លះបែកជាដំបៅ ។ ទុក្ខវេទនាក៏កើតឡើង ។ កាលពួកឈ្មួញតាំងទីសម្រាកហើយ កុលបុត្រក៏ចុះអំពីផ្លូវ អង្គុយក្បែរគល់ឈើមួយ ។ ឈ្មោះថា អ្នកធ្វើបរិកម្មជើង ឬគក់ខ្នងក្នុងទីអង្គុយមិនមាន ។ កុលបុត្រចូលអានាបានចតុត្ថជ្ឈាន គ្របសង្កត់សេចក្តីលំបាកក្នុងផ្លូវ សេចក្តីនឿយហត់ និងសេចក្តីឈឺផ្សា ញ៉ាំងវេលាឲ្យកន្លងទៅដោយសេចក្តីត្រេកអរក្នុងឈាន ។ ក្នុងថ្ងៃស្អែក កាលអរុណរះហើយ ធ្វើការបដិបត្តិសរីរៈ ដើរជាប់តាមពួកឈ្មួញទៀត ។ ក្នុងវេលាអាហារព្រឹក ពួកឈ្មួញទទួលបាត្ររបស់កុលបុត្រហើយដាក់ខាទនិយៈ និងភោជនីយៈចុះក្នុងបាត្រថ្វាយ ។ ខាទនិយៈ និងភោជនីយៈនោះ ជាបាយឆៅខ្លះ សៅហ្មងខ្លះ ។ រឹងស្មើនឹងដុំគ្រួសខ្លះ សាប និងប្រៃខ្លះ ។ កុលបុត្រពិចារណាស្ថានទីសម្រាក បរិភោគខាទនិយៈ និងភោជនីយៈ

នោះ ដូចបរិភោគទឹកអម្រឹត ។ ដោយទំនងនោះ ដើរទៅអស់ផ្លូវ ២០០ យោជន៍ ខ្វះ ៨ យោជន៍ (១៩២ យោជន៍) សូម្បីនឹងដើរទៅជិតខ្លោងទ្វារវត្តជេតពនក៏ដោយ តែក៏មិនសួរថា "ព្រះសាស្ដាប្រថាប់នៅក្នុងទីណា" ។ ព្រោះហេតុអ្វី ។ ព្រោះគោរពក្នុងព្រះសាស្ដា និងព្រោះអំណាចនៃព្រះរាជសាសន៍ ដែលព្រះរាជាទ្រង់បញ្ជូនទៅ ។ ក៏ព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ទៅ ទ្រង់ធ្វើដូចជាព្រះសាស្ដាទ្រង់ឧប្បត្តិក្នុងក្រុងរាជគ្រឹះថា ព្រះតថាគតទ្រង់ឧប្បត្តិក្នុងលោកនេះ ។ ព្រោះដូច្នោះ ទើបមិនសួរ ធ្វើដំណើរទៅអស់ ៤៥ យោជន៍ ។ ក្នុងវេលាព្រះអាទិត្យលិច កុលបុត្រនោះទៅដល់ក្រុងរាជគ្រឹះ ទើបសួរថា "ព្រះសាស្ដាទ្រង់ប្រថាប់ក្នុងទីណា" ។ "លោកម្ចាស់និមន្តមកពីទីណា" ។ "អាត្មាមកអំពីឧត្តរប្រទេសនេះ" ។ "ព្រះនគរឈ្មោះថា សាវត្ថី មាននៅក្នុងផ្លូវដែលលោកមកចម្ងាយពីនគររាជគ្រឹះនេះប្រមាណ ៤៥ យោជន៍ ព្រះសាស្ដាប្រថាប់នៅក្នុងក្រុងសាវត្ថីនោះ" ។ កុលបុត្រនោះគិតថា "ឥឡូវនេះមិនមែនកាល ដែលយើងមិនអាចត្រឡប់ថ្ងៃនេះ យើងនឹងសម្រាកក្នុងទីនេះសិន ស្អែកនឹងទៅកាន់សម្នាក់ព្រះសាស្ដា" ។ បន្ទាប់ពីនោះ ទើបសួរថា "ពួកបព្វជិតដែលមកដល់ក្នុងយាមវិកាល សម្រាកក្នុងទីណា" ។ "សម្រាកក្នុងរោងជាងឆ្នាំងនេះ លោកម្ចាស់" ។

លំដាប់នោះ កុលបុត្រនោះសូមជាងឆ្នាំងនោះសម្រាក ហើយចូលទៅអង្គុយដើម្បីប្រយោជន៍ដល់ការសម្រាកអាស្រ័យក្នុងរោងរបស់ជាងឆ្នាំងនោះ ។

ក្នុងវេលាជិតភ្លឺថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ត្រួតមើលលោក ទ្រង់ឃើញកុលបុត្រឈ្មោះថា បុក្កុសាតិ ទ្រង់មានព្រះតម្រិះថា "កុលបុត្រនេះ អានត្រឹមតែសាសន៍ដែលព្រះរាជាសម្លាញ់បញ្ជូនទៅ លះបង់រាជសម្បត្តិធំ ច្រើនជាងរយយោជន៍ បួសឧទ្ទិសចំពោះតថាគត ធ្វើដំណើរអស់ ១៩២ យោជន៍ ដល់ក្រុងរាជគ្រឹះ ក៏កាលតថាគតមិនទៅ នឹងមិនអាចចាក់ធ្លុះសាមញ្ញផល ៣ នឹងធ្វើកាលកិរិយាគ្មានទីពឹង ដោយការសម្រាកតែមួយយប់ តែបើតថាគតទៅហើយ នឹងចាក់ធ្លុះសាមញ្ញផល ៣ ក៏តថាគតបំពេញបារមីទាំងឡាយអស់ ៤ អសង្ខេយ្យ ក្រៃលែងដោយសែនកប្ប ដើម្បីប្រយោជន៍ដល់ការសង្គ្រោះជនប៉ុណ្ណោះ តថាគតនឹងធ្វើការសង្គ្រោះដល់កុលបុត្របុក្កុសាតិនោះ" ដូច្នេះ ទ្រង់ធ្វើការបដិបត្តិព្រះសរីរៈពីព្រឹកព្រលឹម មានព្រះភិក្ខុសង្ឃហែហម ស្តេចចារិកបិណ្ឌបាតក្នុងក្រុងសាវត្ថី ខាងក្រោយភត្ត ស្តេចត្រឡប់អំពីបិណ្ឌបាត ស្តេចចូលព្រះគន្ធកុដិ ទ្រង់រម្ងាប់សេចក្តីលំបាកក្នុងការធ្វើដំណើរមួយភ្លែត ទ្រង់ព្រះតម្រិះថា "កុលបុត្របានធ្វើកិច្ចដែលធ្វើបានលំបាក ព្រោះសេចក្តីគោរពក្នុងតថាគត លះរាជសម្បត្តិ

ដ៏ប្រសើរ ធ្វើដំណើរមួយរយយោជន៍ មិនកាន់សំណល់សំពត់ ដោយហោច ទៅសូម្បីអ្នកឲ្យទឹកខ្ពុរមាត់ ចេញទៅត្រឹមតែម្នាក់” ដូច្នេះ ទ្រង់មិនត្រាស់អ្វី ក្នុងព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានៈជាដើម ព្រះអង្គ ឯងទ្រង់កាន់បាត្រ និងចីវរ ស្ដេចចេញទៅត្រឹមតែមួយព្រះអង្គឯង និងកាល ស្ដេចទៅ ក៏មិនបានទ្រង់ហោះទៅ ទ្រង់មិនបំព្រួញផែនដី ។ ទ្រង់ព្រះតម្រិះ ទៀតថា “កុលបុត្រខ្វាសចំពោះតថាគត មិនអង្គុយសូម្បីក្នុងយានមួយ ក្នុងបណ្ដា ដំរី សេះ រថ និងអង្រឹងមាសជាដើម ដោយទីបំផុត មិនពាក់ស្បែកជើងសូម្បី មួយជាន់ មិនបាំងឆត្រ ចេញទៅ សូម្បីតថាគតក៏គួរទៅដោយជើងប៉ុណ្ណោះ” ដូច្នេះ ទើបស្ដេចទៅដោយព្រះបាទ ។ ព្រះអង្គទ្រង់បិទបាំងព្រះពុទ្ធសិរីនេះ គឺ អនុព្យញ្ជនៈ ៨០ រស្មី ១ ព្យាម មហាបុរិសលក្ខណៈ ៣២ ប្រការ ស្ដេចទៅ ដោយភេទដូចភិក្ខុមួយរូប ដូចព្រះចន្ទពេញវង់ដែលអ័ព្ទពពកបិទបាំងទុក ដូច្នោះ ដោយបច្ឆាភត្តតែមួយប៉ុណ្ណោះ ក៏ស្ដេចទៅបាន ៤៥ យោជន៍ ក្នុងវេលាព្រះ-អាទិត្យលិច ស្ដេចក៏ដល់រោងរបស់ជាងឆ្នាំងនោះ ក្នុងខណៈដែលកុលបុត្រចូល ទៅហើយនោះឯង ។ លោកសំដៅដល់រោងរបស់ជាងឆ្នាំងនោះ ទើបពោលថា ក៏ដោយសម័យនោះឯង កុលបុត្រឈ្មោះថា បុក្កុសាតិ មានសទ្ធាចេញចាកផ្ទះ

បួសជាបព្វជិត ឧទ្ទិសដល់ព្រះមានព្រះភាគ គេចូលទៅសម្រាកក្នុងនិវេសន៍របស់ជាងឆ្នាំងនោះមុន ដូច្នេះ ។

ក៏ព្រះមានព្រះភាគ សូម្បីត្រាស់ចទៅយ៉ាងនេះហើយ ក៏ទ្រង់មិនគម្រាមថា "យើងជាព្រះសម្មាសម្ពុទ្ធ" ស្ដេចទៅកាន់រោងរបស់ជាងឆ្នាំង ប្រថាប់ឈរត្រង់ទ្វារនោះឯង កាលនឹងឲ្យកុលបុត្រធ្វើឱកាស ទើបត្រាស់ថា **សចេ តេ ភិក្ខុ** ដូច្នេះជាដើម ។ បទថា **ឧរុទ្ធំ** បានដល់ ស្វាត់ មិនចង្អៀត ។ បទថា **វិហរតាយស្មា យថាសុខំ** សេចក្ដីថា កុលបុត្រធ្វើឱកាសថា សូមលោកម្ចាស់ចូរនៅជាសុខតាមឥរិយាបថដែលសប្បាយចុះ ។ ក៏កុលបុត្រលះបង់រាជសម្បត្តិដ៏ប្រសើរធ្វើដំណើរមួយរយយោជន៍ហើយបួស នឹងកំណាញ់រោងរបស់ជាងឆ្នាំង ដែលអ្នកដទៃលះបង់ចោល ដើម្បីប្រព្រឹត្តនូវធម៌ដទៃឬ ។

ក៏មោឃបុរសពួកខ្លះ បួសក្នុងសាសនាហើយ ត្រូវសេចក្ដីកំណាញ់ទាំងឡាយ មានសេចក្ដីកំណាញ់ ព្រោះអាវាសជាដើមគ្របសង្កត់ រមែងហួងហែងព្រោះអាវាសរបស់បុគ្គលពួកដទៃថា ស្ថានទីនៅរបស់ខ្លួន ជាកុដិរបស់យើងជាបរិវេណរបស់យើង ដូច្នេះ ។

**[១៥០]** បទថា **និសីទិ** សេចក្ដីថា ព្រះលោកនាថទ្រង់ជាសុខុមាលជាតិ

យ៉ាងក្រៃលែង ទ្រង់លះព្រះគន្ធកុដិដូចទេវវិមាន ទ្រង់ក្រាលសន្ថត គឺ កម្រាលស្មៅក្នុងរោងជាងឆ្នាំង ដែលមានកម្ទេចផេះរាត់រាយពាសពេញ ស្មោកគ្រោកដោយកាជនៈបែក ស្មៅស្ងួត អាចម៍មាន់ និងអាចម៍ជ្រូកជាដើម ដូចទីចោលសម្រាម ទ្រង់ក្រាលបង្សុកូលចីវរប្រថាប់អង្គុយ ដូចស្តេចចូលព្រះមហាគន្ធកុដិដែលមានក្លិនទិព្វដូចជាទេវវិមាន ហើយប្រថាប់អង្គុយ ដូច្នោះ ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់ឧប្បត្តិក្នុងព្រះមហាសម្មតវង្សដែលមិនលាយឡំ សូម្បីកុលបុត្រ ក៏ចម្រើនហើយក្នុងខត្តិយគភ៌ ។ សូម្បីព្រះមានព្រះភាគ ក៏ទ្រង់ដល់ព្រមដោយព្រះអភិនិហារ សូម្បីកុលបុត្រ ក៏ដល់ព្រមដោយអភិនិហារ ។ ព្រះមានព្រះភាគក្តី កុលបុត្រក្តី ទ្រង់ក៏លះបង់រាជសម្បត្តិទ្រង់ព្រះផ្នួស ។ សូម្បីព្រះមានព្រះភាគទ្រង់មានព្រះវណ្ណៈដូចមាស សូម្បីកុលបុត្រ ក៏មានវណ្ណៈដូចមាស ព្រះមានព្រះភាគក្តី កុលបុត្រក្តី ទ្រង់មានលាភ គឺ សមាបត្តិ ។ ទាំងពីរអង្គក៏ទ្រង់ជាក្សត្រិយ៍ ទាំងពីរអង្គក៏ទ្រង់ដល់ព្រមដោយព្រះអភិនិហារ ទាំងពីរអង្គក៏ទ្រង់ព្រះផ្នួសអំពីរាជត្រកូល ទាំងពីរអង្គទ្រង់មានព្រះវណ្ណៈដូចមាស ទាំងពីរអង្គទ្រង់មានលាភ គឺ សមាបត្តិ ស្តេចចូល កាន់រោងរបស់ជាងឆ្នាំង ហើយប្រថាប់អង្គុយ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ រោងជាងឆ្នាំង ទើប

ស្រស់ល្អយ៉ាងក្រៃលែង ។ គប្បីនាំស្ពានទីទាំងឡាយជាដើមថា ល្អានដែល ស្តេចបក្សីទាំងពីរ មានសីហៈជាដើម ចូលមកសម្តែងប្រៀបធៀបចុះ ។

ក៏ក្នុងបុគ្គលទាំងពីរនោះ ព្រះមានព្រះភាគទ្រង់មិនញុំាងសូម្បីព្រះហឫទ័យឲ្យកើតឡើងថា តថាគតជាបុគ្គលសុខុមាល ធ្វើដំណើរមកអស់ ៤៥ យោជន៍ ដោយវេលាក្រោយភត្តនោះឯង គួរសម្រេចសីហសេយ្យាត្រឹមតែមួយភ្លេតឲ្យបាត់នឿយហត់អំពីការធ្វើដំណើរ ដូច្នេះ ប្រថាប់អង្គុយចូលផលសមាបត្តិតែម្តង ។ ចំណែកកុលបុត្រ ក៏មិនញុំាងចិត្តឲ្យកើតឡើងថា យើងធ្វើដំណើរមកអស់ ១៩២ យោជន៍ គួរដេកសម្រាកបន្ទោបង់សេចក្តីនឿយហត់ក្នុងការធ្វើដំណើរត្រឹមតែមួយរយៈ ក៏អង្គុយចូលអានាបានចតុត្ថជ្ឈាននោះឯង ។ លោកសំដៅដល់ការចូលសមាបត្តិនោះ ទើបពោលថា **អថខោ ភគវា ពហុទេវ រត្តឹ** ជាដើម ។ សួរថា ព្រះមានព្រះភាគ ស្តេចមកដោយព្រះតម្រិះថា តថាគតនឹងសម្តែងធម៌ដល់កុលបុត្រមិនមែនឬ ព្រោះហេតុអ្វី ទើបទ្រង់មិនសម្តែងហ្ន៎ ។ ឆ្លើយថា ទ្រង់មិនសម្តែង ព្រោះហេតុថា កុលបុត្រមានសេចក្តីនឿយហត់ក្នុងការធ្វើដំណើរមិនទាន់ស្ងប់រម្ងាប់ មិនអាចនឹងទទួលព្រះធម៌ទេសនាបាន សូមឲ្យសេចក្តីនឿយហត់ក្នុងការធ្វើដំណើរនោះរបស់កុលបុត្រស្ងប់រម្ងាប់សិន ។ អាចារ្យពួកខ្លះពោល

ថា ធម្មតានគររាជគ្រឹះពោរពេញដោយមនុស្ស មិនស្ងាត់អំពីសំឡេង ១០ យ៉ាង សំឡេងនោះ នឹងស្ងប់ដោយប្រមាណពីរយាមកន្លះ ព្រះអង្គទ្រង់រង់ចាំការស្ងប់សំឡេងនោះ ទើបទ្រង់មិនសម្ដែង ។ នោះមិនមែនហេតុ ។ ព្រោះព្រះមាន-ព្រះភាគអាចដើម្បីញ៉ាំងសំឡេងសូម្បីព្រហ្មលោកឲ្យស្ងប់រម្ងាប់បាន ដោយអានុ-ភាពរបស់ព្រះអង្គ ។ ព្រះអង្គទ្រង់រង់ចាំសេចក្ដីស្ងប់រម្ងាប់អំពីសេចក្ដីនឿយហត់ក្នុងការធ្វើដំណើរសិន ទើបទ្រង់មិនសម្ដែង ។ បណ្ដាបទទាំងនោះ បទថា **ពហុទេវ រត្តឹ** បានដល់ ប្រមាណពីរយាមកន្លះ ។ បទថា **ឯតទហោសិ** សេចក្ដីថា ព្រះមានព្រះភាគ ស្ដេចចេញចាកផលសមាបត្តិហើយ ទ្រង់ធ្មេចព្រះនេត្រដែលប្រដាប់ប្រដាដោយប្រសាទ ៥ យ៉ាង ទ្រង់ក្រឡេកមើល ដូចទ្រង់បើកសីហបញ្ជរកែវមណីក្នុងវិមានមាស ដូច្នោះ ។

លំដាប់នោះ ព្រះអង្គទ្រង់ឃើញកុលបុត្រប្រាសចាកការឃ្នើសឃ្នងដៃ ការឃ្នើសឃ្នងជើង និងការញ័ររន្ធត់សីសៈ អង្គុយដូចសសរខឿនដែលកប់ទុកយ៉ាងល្អ ដូចព្រះពុទ្ធរូបមាស មិនញាប់ញ័រ ទើបត្រាស់ថា **ឯតំ បាសាទិកំ នុខោ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **បាសាទិកោ** គឺ នាំមកនូវសេចក្ដីជ្រះថ្លា ។

ក៏ពាក្យនោះជាការនៃបុំសកលិង្គ ។ ក្នុងពាក្យនោះ មានសេចក្ដីដូច្នេះថា កុលបុត្រ រមែងប្រព្រឹត្តទៅដោយឥរិយាបថដែលគួរជ្រះថ្លា ព្រោះដូច្នោះ ឥរិយាបថជាកិរិយាដែលគួរជ្រះថ្លាដោយប្រការណា ក៏រមែងប្រព្រឹត្តទៅដោយប្រការនោះ ។ ក្នុងឥរិយាបថទាំង ៤ យ៉ាង ឥរិយាបថបីយ៉ាង រមែងមិនល្អ ។ ពិតហើយ ភិក្ខុដើរទៅ ដៃទាំងឡាយរមែងយោល ជើងទាំងឡាយរមែងឃ្លាតទៅ សីសៈរមែងញ័រ ។ កាយរបស់ភិក្ខុដែលឈររមែងរឹង ។ ឥរិយាបថសូម្បីរបស់ភិក្ខុដែលសឹងរមែងមិនគួរពេញចិត្ត ។ តែកាលភិក្ខុបោសសំអាតត្រង់ទីសម្រាកពេលថ្ងៃ ក្នុងបច្ឆាភត្ត ក្រាលកម្រាល មានដៃ និងជើងលាងល្អហើយ អង្គុយចម្រើនសមាធិ ដែលប្រកបដោយសមាធិបួននោះ ឥរិយាបថ រមែងល្អ ។ ក៏កុលបុត្រនេះ ចម្រើនសមាធិ អង្គុយចូលអានាបានចតុត្ថជ្ឈាន ។ កុលបុត្រប្រកបដោយឥរិយាបថដោយប្រការដូច្នេះឯង ។ ព្រះមានព្រះភាគទ្រង់បរិវិត្តកថាកុលបុត្រគួរជ្រះថ្លាហ្ន៎ ។ សួរថា ព្រះមានព្រះភាគទ្រង់បរិវិតក្កថា ណ្ហើយចុះតថាគតគួរនឹងសួរមើលខ្វះ ហើយត្រាស់សួរ ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់មិនដឹងសេចក្ដីដែលកុលបុត្រនោះ ជាអ្នកបួសឧទ្ទិសព្រះអង្គឬ ។ ឆ្លើយថា ទ្រង់មិនដឹងមិនមែន តែកាលមិនត្រាស់សួរ ពាក្យក៏មិនតាំងឡើង កាលពាក្យ

មិនតាំងឡើងហើយ ការសម្តែងរមែងមិនកើតឡើង ព្រោះដូច្នោះ ទើបត្រាស់សួរដើម្បីផ្តើមតាំងពាក្យឡើង ។ បទថា **ទិស្វាបាហំ ន ជានេយ្យំ** សេចក្តីថា ជនទាំងអស់ រមែងដឹងព្រះតថាគតអ្នករុងរោចន៍ដោយពុទ្ធសិរីថា នេះព្រះពុទ្ធ ។ ការដឹងនោះមិនគួរអស្ចារ្យ ។ តែព្រះមានព្រះភាគទ្រង់បិទបាំង ព្រះពុទ្ធរស្មីស្តេចទៅដោយការៈដូចជារបស់ភិក្ខុដែលត្រាច់បិណ្ឌបាតមួយរូប ទើបដឹងបានលំបាក ។ កុលបុត្តបុក្កុសាតិ ពោលតាមសេចក្តីពិតថា យើងមិនដឹងដោយប្រការដូច្នេះ ។ សេចក្តីពិតគឺដូច្នោះ កុលបុត្តបុក្កុសាតិ មិនស្គាល់ព្រះមានព្រះភាគនោះ សូម្បីប្រថាប់អង្គុយក្នុងរោងជាងឆ្នាំងជាមួយគ្នា ។

**[១៥២]** បទថា **ឯតទហោសិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនៀយហត់ក្នុងការធ្វើដំណើរស្ងប់រម្ងាប់ហើយ ទ្រង់មានព្រះតម្រិះ ។ បទថា **ឯវមាវុសោ** សេចក្តីថា កុលបុត្របានអានត្រឹមតែសាសន៍ដែលសម្លាញ់បញ្ជូនទៅ លះបង់រាជសម្បត្តិចេញបួសដោយគិតថា "យើង បានស្តាប់ព្រះធម្ម-ទេសនាដ៏ពីរោះរបស់ព្រះទសពល" លុះបព្វជ្ជាហើយ ក៏ដើរផ្លូវឆ្ងាយប្រមាណប៉ុណ្ណេះ ក៏មិនបានព្រះសាស្តា ត្រាស់ត្រឹមតែបទថា ម្នាលភិក្ខុតថាគតនឹងសម្តែងធម៌ដល់អ្នក កុលបុត្រនោះ នឹងមិនស្តាប់ពាក្យដែលត្រាស់ថា ម្នាលភិក្ខុ តថាគត

នឹងសម្តែងធម៌ដល់អ្នក ដោយគោរពឬ ។ កុលបុត្រនេះ ដូចជាអ្នកលេងសុរា ដែលក្តៅក្រហាយ និងដូចដំរីដែលចុះប្រេង ដូច្នោះ ។ ព្រោះដូច្នោះ កុលបុត្រ កាលប្តេជ្ញាដល់ការស្តាប់ដោយសេចក្តីគោរព ទើបទូលថា **ឯវមាវុសោ** ដូច្នេះ ។

**[១៥៣]** បទថា **ឆធាតុរោ អយំ** សេចក្តីថា ព្រះមានព្រះភាគមិនត្រាស់វត្តបដិបត្តិចំណែកខាងដើមដល់កុលបុត្រ តែទ្រង់ប្រារព្ធដើម្បីត្រាស់ប្រាប់វិបស្សនាលក្ខណៈប៉ុណ្ណោះ ដែលមានសភាពសូន្យទទេយ៉ាងក្រៃលែង ដែលជាបទដ្ឋាននៃព្រះអរហត្ត អំពីខាងដើម ។ ពិតហើយ បុព្វភាគបដិបទារបស់បុគ្គលណាមិនទាន់បរិសុទ្ធិ ព្រះមានព្រះភាគ ក៏ត្រាស់ប្រាប់បុព្វភាគបដិបទានេះ គឺសីលសំវរៈ ការឃុំគ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីព្យាយាមជាគ្រឿងភ្ញាក់ សទ្ធម្ម ៧ ឈាន ៤ ដល់បុគ្គលនោះមុន ។ តែបុព្វភាគបដិបទានោះ របស់បុគ្គលណាបរិសុទ្ធិ ព្រះមានព្រះភាគទ្រង់មិនត្រាស់បុព្វភាគបដិបទានោះ តែត្រាស់ប្រាប់វិបស្សនានោះឯង ដែលជាបទដ្ឋាននៃព្រះអរហត្តដល់បុគ្គលនោះ ។ ក៏បុព្វភាគបដិបទារបស់កុលបុត្របរិសុទ្ធិហើយ ។ ពិតយ៉ាងនោះ កុលបុត្រនោះអានព្រះសាសន៍ហើយ ឡើងកាន់ប្រាសាទដ៏ប្រសើរ ញ៉ាំងអានាបានចតុត្ថជ្ឈានឲ្យកើតឡើងហើយ

ទើបធ្វើដំណើររហូតដល់អស់ ១៩២ យោជន៍ ញុំាងកិច្ចក្នុងយានឲ្យសម្រេច ។ សូម្បីសាមណេរសីលរបស់កុលបុត្រនោះ ក៏បរិបូណ៌ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគទើបមិនត្រាស់បុព្វភាគបដិបទា តែទ្រង់ប្រារព្ធដើម្បីត្រាស់ប្រាប់វិបស្សនា-លក្ខណៈ ដែលមានសភាពសូន្យទទេយ៉ាងក្រៃលែង ដែលជាបទដ្ឋាននៃព្រះ-អរហត្តប៉ុណ្ណោះ ដល់កុលបុត្រនោះ ។ បណ្តាបទទាំងនោះ បទថា **ឆធាតុរោ** បានដល់ ធាតុ ៦ មាន តែបុរសមិនមាន ។

ក៏ព្រះមានព្រះភាគ ទ្រង់សម្តែងវត្ថុដែលមិនមាន ដោយវត្ថុដែលមាន ក្នុងទីណា ទ្រង់សម្តែងវត្ថុដែលមានដោយវត្ថុដែលមិនមានក្នុងទីណា ទ្រង់សម្តែងវត្ថុដែលមានដោយវត្ថុដែលមានក្នុងទីណា ទ្រង់សម្តែងវត្ថុដែលមិនមានដោយវត្ថុដែលមិនមានក្នុងទីណា ពាក្យដូចពោលមកនេះ គប្បីឲ្យពិស្តារដោយន័យដែលពោលហើយក្នុងសព្វាសវសូត្រនោះឯង ។ តែក្នុងធាតុវិភង្គសូត្រនេះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងវត្ថុដែលមានដោយវត្ថុដែលមិនមាន ទើបទ្រង់ត្រាស់យ៉ាងនោះ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់លះបង់បញ្ញត្តិថា បុរស ត្រាស់ថា ធាតុប៉ុណ្ណោះ ហើយទ្រង់ដាក់ព្រះហឫទ័យ កុលបុត្រក៏គប្បីដល់នូវសេចក្តីភាំងស្មារតី មិនអាចទទួលព្រះទេសនាបាន ។ ព្រោះដូច្នោះ ព្រះតថាគត

ទើបទ្រង់លះបញ្ញត្តិថា បុរសដោយលំដាប់ ត្រាស់ត្រឹមតែថា បញ្ញត្តិថា សត្វ ឬបុរស ឬបុគ្គលប៉ុណ្ណោះ ដោយបរមត្ថ ឈ្មោះថា សត្វមិនមាន ទ្រង់ដាក់ព្រះទ័យក្នុងធម៌ត្រឹមតែថា ធាតុប៉ុណ្ណោះ ត្រាស់ទុកក្នុងអនង្គណសូត្រថា តថាគតនឹងឲ្យចាក់ធ្លុះផលបី ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដូចអាចារ្យឲ្យរៀនសិល្បៈដោយភាសានោះ ព្រោះជាអ្នកឆ្លាតក្នុងភាសាដទៃ ។ ក្នុងធាតុវិភង្គ-សូត្រនោះ ធាតុ ៦ របស់បុគ្គលនោះ ព្រោះដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា មានធាតុ ៦ ។ មានអធិប្បាយថា លោករមែងចាំបុគ្គលណាថា បុរស បុគ្គលនោះមានធាតុ ៦ ក៏ក្នុងទីនេះ ដោយបរមត្ថក៏មានត្រឹមតែធាតុប៉ុណ្ណោះ ។ ក៏បទថា **បុរិសោ** គឺ មានត្រឹមតែបញ្ញត្តិ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ **បតិដ្ឋាន** ហៅថា អធិដ្ឋាន ក្នុងបទនេះថា **ចតុរាធិដ្ឋានោ** សេចក្តីថា មានអធិដ្ឋានបួន ។ មានអធិប្បាយថា ម្នាលភិក្ខុ បុរសនេះមានធាតុ ៦ មានផស្សាយតនៈ ៦ មានមនោបវិចារៈ ១៨ ដូច្នេះ ។ កុលបុត្រនោះ ត្រឡប់អំពីធាតុនោះឯង កាន់យកអរហត្តដែលជាដ៏ខ្ពង់ខ្ពស់បំផុត តាំងនៅក្នុងឋានៈ ៤ នេះ កាន់យកព្រះអរហត្ត ព្រោះដូច្នោះទើបឈ្មោះថា មានអធិដ្ឋាន ៤ ។ បទថា **យត្ថដ្ឋិតំ** បានដល់ តាំងនៅក្នុងអធិដ្ឋានពួកណា ។ បទថា **មញ្ញស្សវា នប្បវត្តន្តិ**

បានដល់ មិនមានកិលេសជាគ្រឿងសម្គាល់ប្រព្រឹត្តទៅ ។ បទថា **មុនិ សន្តោតិ វុច្ចតិ** បានដល់ មុនី ជាព្រះខីណាស្រព ហៅថា ស្ងប់ហើយ រលត់ហើយ ។

បទថា **បញ្ញំ នប្បមជ្ជេយ្យ** សេចក្ដីថា មិនគប្បីប្រមាទ សមាធិ បញ្ញា និងវិបស្សនាបញ្ញា តាំងជាខាងដើម ដើម្បីចាក់ធ្លុះអរហត្តផលប្បញ្ញា ។ បទថា **សច្ចមនុរក្ខេយ្យ** សេចក្ដីថា គប្បីរក្សាវចីសច្ចៈតាំងពីដើម ដើម្បីធ្វើឲ្យច្បាស់នូវបរមត្ថសច្ចៈ គឺ និព្វាន ។ បទថា **ចាគមនុព្រូហេយ្យ** សេចក្ដីថា គប្បីចម្រើនការលះបង់កិលេសអំពីខាងដើមនោះឯង ដើម្បីធ្វើការលះបង់កិលេសទាំងពួងដោយអរហត្តមគ្គ ។

បទថា **សន្តិមេវ សោ សិក្ខេយ្យ** សេចក្ដីថា គប្បីសិក្សាការស្ងប់រម្ងាប់កិលេសតាំងអំពីខាងដើមនោះឯង ដើម្បីស្ងប់រម្ងាប់កិលេសទាំងអស់ ដោយអរហត្តមគ្គ ។ ព្រះមានព្រះភាគត្រាស់បុព្វភាគាធិដ្ឋានទាំងឡាយ មានសមថៈ វិបស្សនាបញ្ញាជាដើមនេះ ដើម្បីប្រយោជន៍ដល់ការសម្រេចអធិដ្ឋានទាំងឡាយ មានបញ្ញាធិដ្ឋានជាដើម ដោយប្រការដូច្នេះ ។

**[១៥៥]** បទថា **ផស្សាយតនំ** សេចក្ដីថា អាយតនៈ គឺ អាការរបស់ផស្សៈ ។

**[១៥៧]** បទថា **បញ្ញាធិដ្ឋានោ** ជាដើម គប្បីជ្រាបដោយអំណាចនៃបញ្ញាទាំងឡាយ មានអរហត្តផលប្បញ្ញាជាដើម ដែលបានពោលហើយក្នុងបទមុន ។ ឥឡូវនេះ ជាការពោលដល់បទថា ដែលជាធម៌ដែលបុគ្គលតាំងនៅហើយមិនមាន កិលេសជាគ្រឿងសម្គាល់ខ្លួន និងកិលេសជាគ្រឿងប្រឡាក់ បព្រឹត្តទៅដោយអំណាចនៃមាតិកាដែលតាំងទុកហើយ ។ តែត្រាសម្រេចអរហត្តហើយកិច្ចដោយពាក្យថា មិនគប្បីប្រមាទក្នុងបញ្ញាជាដើម រមែងមិនមានទៀត ។ ព្រះមានព្រះភាគទ្រង់តាំងមាតិកា ដែលមានធាតុជាលំដាប់គ្នាហើយ កាលនឹងទ្រង់ចែកវិភង្គដោយអំណាចតាមធម៌ប៉ុណ្ណោះ ទើបត្រាស់ពាក្យថា មិនគប្បីប្រមាទក្នុងបញ្ញាដូច្នេះជាដើម ដោយប្រការដូច្នេះ ។

សួរថា ក្នុងបាទគាថានោះ អ្នកណាប្រមាទក្នុងបញ្ញា អ្នកណាមិនប្រមាទក្នុងបញ្ញា ។

ឆ្លើយថា បុគ្គលណាបួសក្នុងសាសនានេះហើយ ចិញ្ចឹមជីវិតដោយអនេសនា ២១ វិធី ដោយអំណាចកម្ម មានវេជ្ជកម្មជាដើម មិនអាចដើម្បីតាំងចិត្តប្បាទដោយសមគួរដល់បព្វជ្ជា បុគ្គលនេះឈ្មោះថា ប្រមាទក្នុងបញ្ញា ។ ចំណែកបុគ្គលណាបួសក្នុងសាសនាហើយ តាំងនៅក្នុងសីល រៀនសូត្រព្រះពុទ្ធវចនៈ

សមាទានធុតង្គដែលជាទីសប្បាយ រៀនកម្មដ្ឋានដែលពេញចិត្ត អាស្រ័យសេនាសនៈដែលស្ងាត់ ធ្វើកសិណបរិកម្ម ញុំាងសមាបត្តិឲ្យកើតឡើង ចម្រើនវិបស្សនាថា ក្នុងថ្ងៃនេះឯង យើងនឹងសម្រេចព្រះអរហត្ត ដូច្នេះ ត្រាច់ទៅ បុគ្គលនេះឈ្មោះថា មិនប្រមាទក្នុងបញ្ញា ។ តែក្នុងសូត្រនេះ បានត្រាស់ដល់សេចក្ដីមិនប្រមាទក្នុងបញ្ញានោះ ដោយអំណាចនៃធាតុកម្មដ្ឋាន ។ ចំណែកពាក្យណាគប្បីពោលក្នុងធាតុកម្មដ្ឋាននោះ ពាក្យនោះបានពោលទុកហើយក្នុងសូត្រទាំងឡាយ មានហត្ថិបទោបមសូត្រជាដើម ក្នុងកាលមុននោះឯង ។

ក្នុងសូត្រនេះ មានអនុសន្ធិដោយចំពោះថា តអំពីនោះ វត្ថុដែលនឹងនៅសល់ទៀត គឺ វិញ្ញាណ ដូច្នេះ ។ ព្រោះបានត្រាស់រូបកម្មដ្ឋានក្នុងកាលមុនហើយ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីនឹងទ្រង់ផ្លាស់សម្ដែងអរូបកម្មដ្ឋានដោយអំណាចវេទនា ទើបទ្រង់ប្រារព្ធទេសនានេះ ។ អរូបកម្មដ្ឋាននេះណាដែលជាវិញ្ញាណធ្វើនូវកម្ម ដោយអំណាចវិបស្សនា ដែលភិក្ខុនេះគប្បីដល់ក្នុងធាតុទាំងឡាយ មានបឋវីធាតុជាដើម ព្រះមានព្រះភាគសូម្បីទ្រង់សម្ដែងចែកអរូបកម្មដ្ឋាននោះ ដោយអំណាចវិញ្ញាណធាតុ ទើបទ្រង់ប្រារព្ធទេសនានេះ ។

[១៦៣] បណ្ដាបទទាំងនោះ បទថា **អវសិស្សតិ** សេចក្ដីថា នឹងនៅសល់ដើម្បីប្រយោជន៍អ្វី ។ នឹងនៅសល់ដើម្បីប្រយោជន៍ដល់ការសម្ដែងរបស់ព្រះសាស្ដា និងដើម្បីប្រយោជន៍ដល់ការចាក់ធ្លុះរបស់កុលបុត្រ ។ បទថា **បរិសុទ្ធំ** បានដល់ ប្រាសចាកឧបក្កិលេស ។ បទថា **បរិយោទាតំ** បានដល់ **បភស្សរ** គឺ ផូរផង់ ។

បទថា **សុខន្តិបិ បជានាតិ** សេចក្ដីថា រមែងដឹងច្បាស់ថា កាលយើងសោយសុខ ឈ្មោះថា សោយសុខវេទនា ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏ន័យនេះដូចគ្នា ។ ក៏បើវេទនាកថានេះ មិនបានត្រាស់ទុកក្នុងកាលមុនសោត ក៏គួរប្រព្រឹត្តទៅដើម្បីត្រាស់ទុកក្នុងសូត្រនេះ ។ ក៏វេទនាកថានោះ បានត្រាស់ទុកហើយក្នុងសតិប្បដ្ឋាននោះឯង ព្រោះដូច្នោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងសតិប្បដ្ឋាននោះចុះ ។ បទជាដើមយ៉ាងនេះថា **សុខវេទនីយំ** បានពោលទុកហើយ ដើម្បីសម្ដែងការកើតឡើង និងសេចក្ដីរលត់ ដោយអំណាចបច្ច័យ ។

[១៦៤] បណ្ដាបទទាំង នោះបទថា **សុខវេទនីយំ** គឺ ជាបច្ច័យនៃសុខវេទនា ។ សូម្បីក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។

[១៦៦] បទថា **ឧបេក្ខាយេវ អវសិស្សតិ** សេចក្ដីថា ក៏សិស្សប្រាប់

កែវមុក្តាដែលអាចារ្យជាអ្នកឆ្លាតក្នុងការធ្វើកែវមណី ក្រងពេជ្រដោយម្ជុលយក មកដាក់ពីលើបន្ថែមទៀតក្នុងបន្ទះស្បែក កាលធ្វើការក្រងដោយអំបោះ ឈ្មោះថា ធ្វើគ្រឿងប្រដាប់ មានក្រវិលត្រចៀកដោយកែវមុក្តា និងសំណាញ់កែវមុក្តាជាដើម យ៉ាងណា កុលបុត្រនេះកាលមនសិការនូវកម្មដ្ឋាន ដែលព្រះមានព្រះភាគត្រាស់ហើយ ឈ្មោះថា ធ្វើឲ្យជំនាញដូច្នោះដែរ ព្រោះដូច្នោះ រូបកម្មដ្ឋានក្តី អរូបកម្មដ្ឋានក្តី បានកើតឡើងរហ័ស ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគទើបត្រាស់ថា តអំពីនោះវត្ថុដែលនៅសល់គឺ ឧបេក្ខា ដូច្នេះ ។ សួរថា នៅសល់ដើម្បីអ្វី ។ ឆ្លើយថា ដើម្បីទ្រង់សម្តែងដោយព្រះអង្គឯង ។ អាចារ្យពួកខ្លះពោលថា ដើម្បីការសម្រេចរបស់កុលបុត្រដូច្នេះខ្លះ ។ ពាក្យនោះមិនគួរកាន់យក ។

កុលបុត្របានអានរាជសាសន៍របស់សម្លាញ់ បានឈរលើផ្ទៃដីប្រាសាទញ៉ាំងអានាបានចតុត្ថជ្ឈានឲ្យកើតហើយ ក៏អានាបានចតុត្ថជ្ឈាននោះ រមែងញ៉ាំងយានកិច្ចរបស់កុលបុត្រនោះ ដែលធ្វើដំណើរមកប្រមាណប៉ុណ្ណេះ ឲ្យសម្រេច ព្រោះដូច្នោះ ទើបនៅសល់តែការត្រាស់របស់ព្រះសាស្តាប៉ុណ្ណោះ ។ ក៏ក្នុងឋានៈនេះ ព្រះសាស្តាត្រាស់គុណក្នុងរូបាវចរឈានដល់កុលបុត្រ ។ ព្រោះបាន

ត្រាស់ថា ម្នាលភិក្ខុ រូបាវចរចតុត្ថជ្ឈាននេះ ជំនាញ ដូច្នេះ ។ បទថា **បរិសុទ្ធា** ជាដើម ជាការសម្តែងគុណនៃឧបេក្ខានោះឯង ។ បទថា **ឧក្កំ ពន្ធេយ្យ** គឺ ដាក់រងើកភ្លើងលើក្បៀង ។ បទថា **អាលិមបេយ្យ** សេចក្តីថា ដាក់រងើកភ្លើងចុះក្នុងក្បៀងនោះហើយ ដុតភ្លើង សប់ដោយស្នប់ឲ្យភ្លើងឆេះសន្ធោសន្ធៅ ។

បទថា **ឧក្កាមុខេ បក្ខិបេយ្យ** សេចក្តីថា ថៀបរងើកភ្លើងដាក់លើរងើកភ្លើង ឬដាក់រងើកភ្លើងលើរងើកភ្លើងនោះ ។ បទថា **នីហតំ** គឺ មានមន្ទិលដែលនាំចេញហើយ ។ បទថា **និន្និតកសាវំ** បានដល់ មានទឹកអម្ចត់ហូរចេញហើយ ។ បទថា **ឯវមេវ ខោ** សេចក្តីថា ទ្រង់សម្តែងគុណថា ចតុត្ថជ្ឈានូបេក្ខានេះ រមែងមានដើម្បីប្រយោជន៍ដល់ធម៌ដែលអ្នកប្រាថ្នា ក្នុងបណ្តាធម៌នេះ គឺ វិបស្សនា អភិញ្ញា និរោធ ភវោកកន្តិ ។ ដូចមាសនោះ រមែងប្រព្រឹត្តទៅដើម្បីជាគ្រឿងប្រដាប់ដែលគួរប្រាថ្នា និងត្រូវការហើយ ដូច្នោះ ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបមិនត្រាស់ទោស ដើម្បីសេចក្តីបរិសុទ្ធចាកសេចក្តីប្រាថ្នាក្នុងរូបាវចរចតុត្ថជ្ឈាននេះ តែត្រាស់ពីគុណប៉ុណ្ណោះ ។ ឆ្លើយថា ព្រោះការប្រកាន់មាំ សេចក្តីប្រាថ្នាក្នុងចតុត្ថជ្ឈានរបស់កុលបុត្រមានកម្លាំង ។ បើនឹងគប្បីត្រាស់ទោសសោត កុលបុត្រក៏នឹងគប្បីដល់សេចក្តីសង្ស័យ សេចក្តីភាំង

ស្មារតីថា កាលយើងបួសហើយ ធ្វើដំណើរមករហូតដល់អស់ ១៩២ យោជន៍ ចតុត្ថជ្ឈាននេះ ញុំាងយានកិច្ចឲ្យសម្រេចបាន យើងមកកាន់ផ្លូវប្រមាណប៉ុណ្ណោះ ក៏មកហើយដើម្បីសេចក្តីត្រេកអរក្នុងឈានសុខ ដោយឈានសុខ ព្រះមានព្រះ-ភាគត្រាស់ទោសនៃធម៌ដែលប្រណីតបែបនេះ ទ្រង់ជ្រាបទើបត្រាស់ ឬទ្រង់មិនជ្រាបទើបត្រាស់ ដូច្នេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ពីគុណ ។ ក្នុងបទនេះថា **តទនុធម្មំ** ដូច្នេះ អរូបាវចរឈាន ឈ្មោះថា ធម៌ ។ រូបាវចរ-ឈាន ហៅថា អនុធម៌ ព្រោះជាធម៌បណ្តោយតាមអរូបាវចរឈាននោះ ម្យ៉ាងទៀត វិបាកឈាន ឈ្មោះថា ធម៌ , កុសលឈាន ឈ្មោះថា អនុធម៌ ។

បទថា **តទុបាទានា** គឺ ការកាន់យកធម៌នោះ ។

បទថា **ចិរំ ទីឃមទ្ធានំ** បានដល់ រហូតដល់អស់ ២០,០០០ កប្ប ។ ក៏ពាក្យនោះ ត្រាស់ដោយអំណាចនៃវិបាក ។

សូម្បីក្រៅអំពីនេះ ក៏មានន័យដូចគ្នា ។ ។

ព្រះមានព្រះភាគ ត្រាត្រាស់គុណរបស់អរូបាវចរឈាន ដោយវារៈ ៤ យ៉ាងនេះហើយ ឥឡូវនេះ កាលទឹងទ្រង់សម្តែងទោសនៃអរូបាវចរឈាននោះ ទើបត្រាស់ថា លោកដឹងច្បាស់យ៉ាងនេះជាដើម ។ បណ្តាបទទាំងនោះ បទថា

*សន្តមេតំ សេចក្តីថា ក្នុងបឋមព្រហ្មលោកនោះ (អរូបព្រហ្មទី ១) មានអាយុ ២០,០០០ កប្បក៏ពិត តែព្រះមានព្រះភាគកាលទ្រង់ធ្វើចិត្តនោះឲ្យជាការតាក់តែង គឺ សេចក្តីសម្រេច ដោយប្រមូលមក ក៏ទ្រង់រមែងធ្វើ ។ អាយុនោះមិនទៀង មិនយឺនយូរ មិនពិតប្រាកដ មួយរយៈ មានការឃ្លាតទៅ បែកធ្លាយ និងរលត់ទៅជាធម្មតា បណ្តោយតាមការកើត ត្រូវជរាញាំញី ដែលមរណៈគ្របសង្កត់ តាំងនៅក្នុងទុក្ខ មិនមានអ្វីតតាំង មិនមានទីពួនសម្ងំ មិនមានទីពឹង មិនមានទីពំនាក់អាស្រ័យ ។ សូម្បីក្នុងវិញ្ញាណញ្ចាយតនៈជាដើម ក៏ន័យនេះដូចគ្នា ។*

*ឥឡូវនេះ កាលទឹងទ្រង់កាន់យកទេសនាដ៏កំពូល គឺ អរហត្ត ទើបត្រាស់ថា បុគ្គលនោះនឹងមិនរំពឹងគិត ដូច្នេះជាដើម ។ ដូចពេទ្យដែលឆ្លាត ឃើញការប្រែប្រួលនៃពិសហើយ ធ្វើឲ្យពិសឃ្លាតចាកទី ឲ្យឡើងខាងលើ មិនឲ្យពិសជ្រាបត្រង់ក ឬសីសៈ ញាំងពិសធ្លាក់ចុះក្នុងផែនដី យ៉ាងណា ព្រះមានព្រះភាគទ្រង់សម្តែងគុណក្នុងអរូបាវចរឈានដល់កុលបុត្រ ដូច្នោះដែរ ។ កុលបុត្រ លុះស្តាប់អរូបាវចរឈាននោះហើយ គ្របសង្កត់សេចក្តីប្រាថ្នាក្នុងរូបាវចរឈាន តាំងសេចក្តីប្រាថ្នាក្នុងអរូបាវចរឈាន ។ ក៏ព្រះមានព្រះភាគ ទ្រង់ជ្រាបដល់កុលបុត្រនោះ*

គ្រប់សង្កត់សេចក្តីប្រាថ្នាក្នុងរូបាវចរឈានហើយ ទើបទ្រង់សម្តែងទោសនោះទាំងអស់ ដោយបទតែមួយប៉ុណ្ណោះថា **សង្ខតមេតំ** ដូច្នេះ ដល់ភិក្ខុអ្នកមិនទាន់សម្រេច មិនទាន់បានអរូបាវចរឈាននោះថា ឈ្មោះថា សម្បត្តិក្នុងអាកាសានញ្ចាយតនៈជាដើមនោះមាន ក៏អាយុរបស់អ្នកបានអាកាសានញ្ចាយតនៈជាដើមនោះ ក្នុងព្រហ្មលោក (អរូបព្រហ្ម) ទីមួយមាន ២០,០០០ កប្ប ក្នុងព្រហ្មលោកទីពីរមាន ៤០,០០០ កប្ប ក្នុងព្រហ្មលោកទីបីមាន ៦០,០០០ កប្ប ក្នុងព្រហ្មលោកទីបួនមាន ៨៤,០០០ កប្ប តែអាយុនោះ មិនទៀង មិនយឺនយូរ មិនពិតប្រាកដ ប្រព្រឹត្តទៅមួយរយៈ មានការឃ្លាតទៅ បែកធ្លាយ និងរលត់ទៅជាធម្មតា បណ្តោយតាមការកើត ត្រូវជរាញាំញី ដែលមរណៈគ្របសង្កត់ តាំងនៅក្នុងទុក្ខ មិនមានអ្វីតតាំង មិនមានទីពួនសម្ងំ មិនមានទីពឹង មិនមានទីពំនាក់អាស្រ័យ សូម្បីបានសោយសម្បត្តិក្នុងព្រហ្មលោកនោះ រហូតដល់អស់កាលប្រមាណប៉ុណ្ណោះ ធ្វើកាលកិរិយាដោយភាពជាបុថុជ្ជនហើយ គប្បីធ្លាក់ក្នុងអបាយភូមិបួនទៀត ។ កុលបុត្របានស្តាប់ព្រះពុទ្ធវចននោះហើយ មានសេចក្តីប្រាថ្នាក្នុងអរូបាវចរឈាន ។

ព្រះមានព្រះភាគត្រា ទ្រង់ជ្រាបដល់កុលបុត្រនោះ ជាអ្នកមានសេចក្តី

ប្រាថ្នាក្នុងរូបាវចរឈាន និងអរូបាវចរឈានហើយ កាលនឹងទ្រង់លើកយកនូវកំពូលនៃធម៌ គឺ អរហត្ត ទើបត្រាស់ថា បុគ្គលនោះនឹងមិនរំពឹងគិត ដូច្នេះជាដើម ។ ក៏ឬថា **មហាយោធ** (នាយទាហានជាធំ) ម្នាក់ ញុំាងព្រះរាជាមួយអង្គឲ្យពេញព្រះរាជហឫទ័យហើយ ទើបបានស្រុកសួយ ដែលមានចំណូលមួយសែន ។ ព្រះរាជាទ្រង់ព្រួកដល់អានុភាពរបស់មេទ័ពនោះថា មេទ័ពមានអានុភាពច្រើន គេបានទ្រព្យតិច ដូច្នេះ ទើបព្រះរាជទានទៀតថា ម្នាលបា ស្រុកនេះមិនសមគួរដល់លោក លោកចូរទទួលយកស្រុកដទៃ ដែលមានចំណូលបួនសែន ។ គេទទួលព្រះបរមរាជឱង្ការថា ករុណាព្រះអង្គ លះបង់ស្រុកនោះហើយ ទទួលយកស្រុកនេះ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យហៅមេទ័ពនោះ អ្នកមិនទាន់ដល់ស្រុកនោះឯង ទ្រង់ត្រាស់ទៅថា លោកនិងមានប្រយោជន៍អ្វីដោយស្រុកនោះ **អហិវាតករោគ** កំពុងកើតក្នុងស្រុកនោះ តែក្នុងទីឯណោះ មាននគរធំ លោកគប្បីលើកឆត្រសោយរាជ្យក្នុងនគរនោះចុះ ដូច្នេះ ។

មេទ័ពនោះ គប្បីសោយរាជ្យយ៉ាងនោះ ។ ក្នុងសេចក្តីនោះ គប្បីឃើញព្រះសម្មាសម្ពុទ្ធ ដូចជាព្រះរាជា ។ បុក្កុសាតិកុលបុត្រ ដូចជាមេទ័ព ។ អានាបានចតុត្ថជ្ឈាន ដូចស្រុកដែលបានគ្រាដំបូង ។ ការប្រកាន់មាំចំពោះសេចក្តី

ប្រាថ្នាក្នុងអានាបានឈាន ហើយត្រាស់អរូបជ្ឈាន ដូចកាលឲ្យមេទ័ពលះបង់ស្រុកនោះ ហើយត្រាស់ថា អ្នកចូរកាន់យកស្រុកនេះ ។ ការដែលឲ្យកុលបុត្រនោះផ្លាស់ការប្រាថ្នាក្នុងសមាបត្តិទាំងនោះ ដែលនៅមិនទាន់បានដល់ ដោយទ្រង់សម្តែងទោសក្នុងអរូបជ្ឈានថា **សង្ខតមេតំ** ហើយទ្រង់កាន់យកទេសនាដល់កំពូល គឺ អរហត្តក្នុងខាងលើ ដូចកាលដែលត្រាស់បង្គាប់ឲ្យហៅមេទ័ពដែលមិនទាន់បានដល់ស្រុកនោះ ហើយត្រាស់ថា លោកនឹងមានប្រយោជន៍អ្វីដោយស្រុកនោះ អហិវាតករោគកំពុងកើតក្នុងស្រុកនោះ ក្នុងទីឯណោះមាននគរលោកចូរលើកឆត្រ សោយរាជ្យក្នុងនគរនោះចុះ ។

បណ្តាបទទាំងនោះ បទថា **នេវ អភិសង្ខរោតិ** គឺ មិនសន្សំ បានដល់មិនធ្វើឲ្យជាគំនរ ។ បទថា **ន អភិសញ្ចេតយតិ** គឺ មិនឲ្យសម្រេច ។ បទថា **ភវាយ វា វិភវាយ វា** បានដល់ ដើម្បីសេចក្តីចម្រើន ឬដើម្បីសេចក្តីសាបសូន្យ ។ គប្បីប្រកបសូម្បីដោយអំណាចនៃសស្សតៈ និងឧច្ឆេទៈ ។

បទថា **ន កិញ្ចិ លោកេ ឧបាទិយតិ** សេចក្តីថា មិនកាន់យក មិនស្ទាបអង្អែល សូម្បីធម៌អ្វីៗ នីមួយ ក្នុងធម៌ទាំងឡាយ មានរូបជាដើមក្នុងលោកដោយតណ្ហា ។ បទថា **នាបរំ ឥត្ថត្តាយាតិ បជានាតិ** សេចក្តីថា ព្រះមានព្រះ

កាគទ្រង់តាំងនៅក្នុងពុទ្ធវិស័យរបស់ព្រះអង្គ ទ្រង់កាន់យកនូវធម៌ដ៏កំពូល គឺ អរហត្ត ដោយទេសនា ។ ចំណែកកុលបុត្រចាក់ធ្លុះសាមញ្ញផល ៣ តាមឧបនិស្ស័យរបស់ខ្លួន ។ ព្រះរាជាសោយភោជនមានរសផ្សេងៗ ដោយភាជនៈមាស ទ្រង់ធ្វើដុំបាយដោយប្រមាណរបស់ព្រះអង្គ កាលព្រះរាជកុមារប្រថាប់អង្គុយលើភ្លៅ សម្តែងសេចក្តីអាល័យក្នុងដុំបាយ ទ្រង់គប្បីបង្អោនដុំបាយនោះ ។ ព្រះកុមារទ្រង់ធ្វើដុំបាយ ដោយប្រមាណព្រះឱស្ឋរបស់ព្រះអង្គ ព្រះរាជាទ្រង់សោយដុំបាយដែលសល់ដោយព្រះអង្គឯង ឬទ្រង់ដាក់ក្នុងចាន យ៉ាងណា ព្រះតថាគតទ្រង់ជាធម្មរាជាក៏ដូច្នោះ កាលទ្រង់កាន់យកនូវធម៌ដ៏កំពូល គឺ ព្រះអរហត្ត ដោយប្រមាណព្រះអង្គ ទើបទ្រង់សម្តែងទេសនា ។ កុលបុត្រចាក់ធ្លុះសាមញ្ញផល ៣ តាមឧបនិស្ស័យរបស់ខ្លួន ។ ក៏ក្នុងកាលមុនពីនេះ កុលបុត្រនោះ សម្តែងកថាដែលប្រកបដោយត្រៃលក្ខណ៍ ដែលមានភាពសូន្យទទេយ៉ាងក្រៃលែង យ៉ាងនេះថា ខន្ធ ធាតុ អាយតនៈទាំងឡាយ រមែងមិនកន្ធារ រមែងមិនសង្ស័យថា ន័យថា មិនជាយ៉ាងនោះ ប្រការនោះ អាចារ្យរបស់យើងពោលហើយយ៉ាងនេះ ជ្រាបថា ភាពជាអ្នកល្ងង់ខ្លៅ ភាពជាអ្នកយល់ខុស មិនមានដោយប្រការដូច្នេះ ។ បានឮថា ក្នុងឋានៈយ៉ាងណាមួយ ព្រះពុទ្ធទាំងឡាយ

ស្ដេចទៅដោយភេទដែលបុគ្គលដឹងមិនបាន ។ បានមានសេចក្ដីសង្ស័យ មានសេចក្ដីជឿងឆ្ងល់ថា នោះជាព្រះសម្មាសម្ពុទ្ធឬហ្ន៎ ។ ព្រោះកុលបុត្រ នេះចាក់ធ្លុះអនាគាមិផលហើយ ក្នុងកាលនោះ ទើបដល់ការធ្លាក់ចុះ (គឺដឹងច្បាស់) ថា បុគ្គលនេះ គឺ ព្រះសាស្ដារបស់យើង ។ សួរថា បើដូច្នោះ ព្រោះហេតុអ្វីកុល-បុត្រ ទើបមិនសម្ដែងទោសដែលកន្លងហ្ន៎ ។ ឆ្លើយថា ព្រោះមិនមានឱកាស ។ ក៏ព្រះមានព្រះភាគ ទ្រង់ធ្វើវារៈដែលមិនសន្ធែបដោយមាតិកា តាមដែលទ្រង់លើកឡើងហើយ ទើបទ្រង់សម្ដែងព្រះទេសនា ដូចទ្រង់ឲ្យធ្លារទឹកក្នុងអាកាសធ្លាក់ចុះដូច្នោះឯង ។

បទថា **សោ** គឺ ព្រះអរហន្តនោះ ។ បទថា **អនជ្ឈោសិតា** សេចក្ដីថា ដឹងច្បាស់ថា មិនគួរដើម្បីលេប ជាប់ចិត្ត កាន់យក ។ បទថា **អនភិនន្ទិតា** គឺ ដឹងច្បាស់ថា មិនគួរដើម្បីត្រេកត្រអាលដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ បទថា **វិសំយុត្តោ ន វេទិយតិ** សេចក្ដីថា ប្រសិនបើថា រាគានុស័យ ព្រោះប្រារព្ធសុខវេទនា បដិឃានុស័យ ព្រោះប្រារព្ធទុក្ខវេទនា អវិជ្ជានុស័យ ព្រោះប្រារព្ធវេទនាក្រៅពីនេះ គប្បីកើតដល់បុគ្គលនោះសោត បុគ្គលនោះក៏ឈ្មោះថា ប្រកបព្រមហើយសោយ ។ តែព្រោះមិនកើត ទើបឈ្មោះថា មិនប្រកប ហើយសោយ

គឺ រលាស់ចេញហើយ រួចផុតវិសេសហើយ ។

បទថា **កាយបរិយន្តិកំ** សេចក្ដីថា វេទនាដែលកើតឡើង មានកាយជាទីបំផុត ដរាបដល់ការប្រព្រឹត្តទៅនៃកាយ តអំពីនោះក៏មិនកើត ។ សូម្បីក្នុងបទទីពីរ ក៏ន័យនេះដូចគ្នា ។

បទថា **អនភិនន្ទិតានិ សីតិភវិស្សន្តិ** សេចក្ដីថា ការសោយអារម្មណ៍ទាំងអស់ ដែលឈ្មោះថា មិនត្រេកអរហើយ ព្រោះកិលេសទាំងឡាយមិនមានសេសសល់ក្នុងអាយតនៈ ១២ និងរលត់ក្នុងអាយតនៈ ១២ នេះឯង ។ ក៏កិលេសទាំងឡាយសូម្បីរលត់ហើយ ព្រោះមកដល់និព្វាន រមែងមិនមានក្នុងទីណា ហៅថា រលត់ហើយក្នុងទីនោះ ។ សេចក្ដីនេះ គប្បីសម្ដែងដោយសមុទយបញ្ហាថា តណ្ហានោះ កាលនឹងរលត់រមែងរលត់ក្នុងទីនោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ថា ការសោយអារម្មណ៍ទាំងអស់ សូម្បីជាធម្មជាតិស្ងប់ហើយព្រោះអាស្រ័យនិព្វាន នឹងជារបស់ស្ងប់ក្នុងលោកនេះឯង ។ សួរថា ក៏ព្រះមានព្រះភាគ ត្រាស់ការសោយអារម្មណ៍ទាំងឡាយក្នុងទីនេះមិនមែនឬ ហេតុដូចម្ដេចទើបមិនត្រាស់កិលេសទាំងឡាយហ្ន៎ ។ ឆ្លើយថា ព្រោះសូម្បីការសោយអារម្មណ៍ទាំងឡាយ នឹងជាធម្មជាតិស្ងប់ ព្រោះមិនមានកិលេសនោះឯង ។ ធម្មតាការ

សោយអារម្មណ៍ទាំងឡាយជាធម្មជាតិស្ងប់ មិនមានក្នុងឋានៈក្រៅនេះ ព្រោះដូច្នោះ ពាក្យនោះពោលល្អហើយ ។

**[១៦៧]** នេះជាការប្រៀបធៀបឧបមាក្នុងបទនេះថា *ឯវមេវ ខោ* ។ ដូចបុរសម្នាក់ កាលប្រទីបប្រេងឆេះ លុះប្រេងអស់ហើយ ក៏ថែមប្រេងទាំងនោះ កាលប្រឆេះអស់ ក៏ដាក់ប្រឆេះ បើដូច្នោះ អណ្តាតប្រទីបក៏មិនរលត់យ៉ាងណា បុថុជ្ជនក៏ដូច្នោះដែរ តាំងនៅក្នុងភពមួយ រមែងធ្វើកុសល និងអកុសល គេក៏នឹងកើតក្នុងសុគតិ និងក្នុងអបាយទាំងឡាយ ព្រោះកុសល និងអកុសលនោះ បើដូច្នោះ វេទនាទាំងឡាយ ក៏មិនទាន់ដាច់សូន្យនោះឯង ។ មួយវិញទៀត បុគ្គលម្នាក់ខ្វល់ខ្វាយក្នុងអណ្តាតប្រទីប ហើយក៏យកអណ្តាតប្រទីបលាក់ ដោយគិតថា ព្រោះអាស្រ័យបុរសនេះ អណ្តាតប្រទីបទើបមិនរលត់ ដូច្នេះ គប្បីកាត់សីសៈរបស់បុរសនោះ ។ ព្រោះមិនដាក់ប្រឆេះ និងមិនថែមប្រេងយ៉ាងនេះ អណ្តាតប្រទីបដែលអស់គ្រឿងឆេះ ក៏រមែងរលត់ យ៉ាងណា ព្រះយោគាវចរអ្នកខ្វល់ខ្វាយក្នុងបដិបត្តិក៏ដូច្នោះដែរ រមែងលះបង់កុសល និងអកុសល ដោយអរហត្តមគ្គ ។ ព្រោះកុសលនោះ ត្រូវកាត់ផ្តាច់ហើយ ការសោយអារម្មណ៍ទាំងឡាយរមែងមិនកើតឡើងទៀតដល់ភិក្ខុដែលជាខីណាស្រព ព្រោះការបែកធ្លាយនៃកាយ

ដូច្នេះ ។

បទថា **តស្មា** សេចក្តីថា ព្រោះអរហត្តផលប្បញ្ញា ក្រៃលែងជាង សមាធិប្បញ្ញា និងវិបស្សនាបញ្ញាក្នុងខាងដើម ។ បទថា **ឯវំ សមន្នាគតោ** សេចក្តីថា អ្នកប្រកបព្រមដោយអរហត្តផលប្បញ្ញា ដែលជាធម៌គួរតាំងទុកក្នុងចិត្ត ដែលខ្ពស់បំផុតនេះ ។ ញាណក្នុងអរហត្តមគ្គ ឈ្មោះថា ញាណក្នុងការអស់ទៅនូវទុក្ខទាំងពួង ។ តែក្នុងសូត្រនេះ ទ្រង់បំណងយកញាណក្នុងអរហត្ត-ផល ។ ព្រោះហេតុនោះឯង ទើបត្រាស់ថា ការរួចផុតរបស់គេនោះ ចាត់ថាតាំងនៅក្នុងសច្ចៈ ជាគុណមិនកម្រើក ដូច្នេះ ។ ក៏ក្នុងបទទាំងនោះ បទថា **វិមុត្តិ** បានដល់ អរហត្តផលវិមុត្តិ ។ បទថា **សច្ចំ** បានដល់ បរមត្ថសច្ច គឺនិព្វាន ។ ការរួចផុតនោះ ត្រាស់ថា មិនកម្រើក ព្រោះធ្វើអារម្មណ៍ដែលមិនកម្រើក ដោយប្រការដូច្នេះ ។ បទថា **មុសា** បានដល់ មិនពិត ។ បទថា **មោសធម្មំ** បានដល់ សភាពដែលវិនាស ។ បទថា **តំ សច្ចំ** សេចក្តីថា សភាវនៃសច្ចៈនោះ ជារបស់ពិត ។

បទថា **អមោសធម្មំ** បានដល់ ជាសភាវៈមិនវិនាស ។ បទថា **តស្មា** សេចក្តីថា ព្រោះបរមត្ថសច្ចៈ គឺ និព្វាននោះឯង ខ្ពស់ជាងវចីសច្ចៈខ្ទះ ទុក្ខសច្ចៈ

និងសមុទយសច្ចៈខ្លះ ដោយអំណាចនៃសមថៈ និងវិបស្សនាខាងដើម ។

បទថា **ឯវំ សមន្នាគតោ** សេចក្ដីថា អ្នកប្រកបព្រមដោយបរមត្ថ-សច្ចាធិដ្ឋានដែលខ្ពស់បំផុតនេះ ។ បទថា **បុព្វេ** គឺ ក្នុងកាលជាបុថុជ្ជន ។ បទថា **ឧបធី ហោន្តិ** បានដល់ ឧបធិទាំងនេះ គឺ ខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ បញ្ចកាមគុណូបធិ ។ បទថា **សមត្តា សមាទិន្នា** សេចក្ដីថា បរិបូណ៌ គឺ កាន់យកហើយ បានដល់ ស្ទាបអង្អែលហើយ ។ បទថា **តស្មា** សេចក្ដីថា ព្រោះការលះបង់កិលេសដោយអរហត្តមគ្គនោះឯង ល្អជាងការលះបង់កិលេសដោយអំណាចនៃសមថៈ និងវិបស្សនាអំពីខាងដើម និងក្រៃលែងជាងការលះបង់កិលេសដោយសោតាបត្តិមគ្គជាដើម ។ បទថា **ឯវំ សមន្នាគ-តោ** គឺ អ្នកប្រកបព្រមហើយដោយចាគាធិដ្ឋានដែលខ្ពស់បំផុតនេះ ។ ឈ្មោះថា **អាឃាដ** ដោយអំណាចនៃការធ្វើអាឃាដព្យាបាទ ក្នុងពាក្យជាដើមថា **អាឃា-ដោ** ។ ឈ្មោះថា **ព្យាបាទ** ដោយអំណាចនៃការប្រទូសរ៉ាយ ។ ឈ្មោះថា **សម្បទោស** ដោយអំណាចនៃការប្រទូសរ៉ាយគ្រប់យ៉ាង ។ លោកពោលអកុ-សលមូលប៉ុណ្ណោះ ដោយបទទាំង ៣ ។ បទថា **តស្មា** សេចក្ដីថា ព្រោះការស្ងប់រម្ងាប់កិលេសដោយអរហត្តមគ្គនោះឯង ខ្ពស់ជាងការស្ងប់រម្ងាប់កិលេស

ដោយអំណាចនៃសមថៈ និងវិបស្សនាអំពីខាងដើម និងការស្ងប់រម្ងាប់កិលេស ដោយសោតាបត្តិមគ្គជាដើម ។

បទថា **ឯវំ សមន្នាគតោ** សេចក្តីថា អ្នកប្រកបព្រមដោយឧបសមាធិ-ដ្ឋានដ៏ឧត្តមនេះ ។

**[១៦៨]** បទថា **មញ្ញិត មេតំ** សេចក្តីថា សេចក្តីសម្គាល់សូម្បី ៣ យ៉ាង គឺ តណ្ហា មានះ ទិដ្ឋិ រមែងប្រព្រឹត្តទៅ ។ ក៏បទនេះថា **អយមហមស្មី** ក្នុងបទនេះថា **អហមស្មិ** គឺ សេចក្តីសម្គាល់តណ្ហានោះឯងរមែងប្រព្រឹត្តទៅ ។ ឈ្មោះថា **រោគ** ព្រោះអត្ថថា បៀតបៀន ក្នុងបទថា **រោគោ** ជាដើម ។ ឈ្មោះថា **គណ្ឌ** ព្រោះអត្ថថា ប្រទូសរ៉ាយក្នុងខាងក្នុង ។ ឈ្មោះថា **សល្ល** ព្រោះអត្ថថា ចាក់សៀតរឿយៗ ។

បទថា **មុនិ សន្តោតិ វុច្ចតិ** សេចក្តីថា បុគ្គលនោះហៅថា មុនី ដែលជាព្រះខីណាស្រពអ្នកស្ងប់ហើយ គឺ អ្នកស្ងប់រម្ងាប់ហើយ រលត់ទុក្ខហើយ ។ បទថា **យត្ថ ឋិតំ** គឺ តាំងនៅក្នុងឋានៈណា ។ បទថា **សង្ខិត្តេន** សេចក្តីថា ក៏ព្រះធម្មទេសនាសូម្បីទាំងអស់របស់ព្រះពុទ្ធទាំងឡាយ ក៏សង្ខេបហើយនោះឯង ។ ឈ្មោះថា ទេសនាដោយពិស្តារមិនមាន ។ សូម្បីសមន្តបដ្ឋានកថា ក៏

*សន្ធិបហើយនោះឯង ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងទេសនាឲ្យដល់ តាមអនុ-សន្ធិដោយប្រការដូច្នេះ ។ ក៏ក្នុងបុគ្គល ៤ ពួក មានឧគ្ឃដិតញ្ញូជាដើម បុក្កុ-សាតិកុលបុត្រ ជាវិបច្ចិតញ្ញូ ។ ព្រះមានព្រះភាគទ្រង់សម្ដែងធាតុវិភង្គសូត្រនេះ ដោយអំណាចនៃវិបច្ចិតញ្ញូ ដោយប្រការដូច្នេះ ។*

**[១៧១]** *ក្នុងបទថា* **បពិត្រ ព្រះអង្គដ៏ចម្រើន បាត្រ និងចីវរ របស់ខ្ញុំព្រះអង្គ មិនទាន់គ្រប់** *មានពាក្យ សួរថា ព្រោះហេតុអ្វី បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ទើបមិនកើតឡើងដល់កុលបុត្រហ្ន៎ ។ ឆ្លើយថា ព្រោះបរិក្ខារ ៨ យ៉ាង ដែលកុលបុត្រមិនធ្លាប់ឲ្យទានហើយក្នុងកាលមុនមិនមាន ។ កុលបុត្រមានទានធ្លាប់ថ្វាយហើយ មានអភិនិហារបានធ្វើហើយ ទើបមិនគួរពោលថា ព្រោះទានមិនធ្លាប់ឲ្យ ។ ក៏បាត្រ និងចីវរដែលសម្រេចពីឫទ្ធិ រមែងកើតដល់សាវកទាំងឡាយអ្នកមានភពចុងក្រោយបង្អស់ប៉ុណ្ណោះ ។ ចំណែកកុលបុត្រនេះ នៅមានបដិសន្ធិទៀត ។ ព្រោះដូច្នោះ បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ទើបមិនកើតឡើង ។ សួរថា បើដូច្នោះ ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់មិនស្វែងរកដោយព្រះអង្គឯង ឲ្យដល់ព្រមហ្ន៎ ។ ឆ្លើយថា ព្រោះព្រះអង្គមិនមានឱកាស ។ អាយុរបស់កុលបុត្រ ក៏អស់ហើយ ។ មហាព្រហ្មជាអនាគាមីជាន់*

សុទ្ធាវាស ក៏ហាក់បីដូចជាមកកាន់រោងជាងថ្នាំងអន្តុយហើយ ។ ព្រោះដូច្នោះ ទើបទ្រង់មិនស្វែងរកដោយព្រះអង្គឯង ។ បទថា **បត្តចីវរំ បរិយេសនំ បក្កាមិ** សេចក្តីថា កុលបុត្តបុក្កុសាតិចៀសទៅក្នុងវេលានោះ កាលអរុណរះហើយ ។

បានឮថា កាលចប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគ ការរះឡើងនៃអរុណ និងការបញ្ចេញរស្មី បានមានក្នុងខណៈតែមួយជាមួយគ្នា ។ ន័យថា ព្រះមានព្រះភាគទ្រង់បញ្ចប់ព្រះទេសនាហើយ ទ្រង់បញ្ចេញព្រះរស្មីមានពណ៌ ៦ ប្រការ ។ និវេសន៍នៃជាងថ្នាំងទាំងអស់ ក៏រុងរឿងជាតែម្យ៉ាង ។ ព្រះឆព្វ-ណ្ណរស្មី ក៏ផ្សាយទៅជាក្រុមៗ ធ្វើទិសទាំងពួងឲ្យដូចជាគ្របដណ្តប់ដោយផែនមាស និងដូចរុងរឿងដូចកម្រងផ្ការតនៈរីកដ៏ប្រសើរប្រកបដោយពណ៌ផ្សេងៗ ។ ព្រោះព្រះមានព្រះភាគ ទ្រង់អធិដ្ឋានថា សូមឲ្យអ្នកនគរទាំងឡាយចូរបានឃើញតថាគត ដូច្នេះ ។ អ្នកព្រះនគរទាំងឡាយ ឃើញព្រះមានព្រះភាគហើយ ខ្លះក៏ប្រាប់តៗ គ្នាថា បានឮថា ព្រះសាស្តាស្តេចមកហើយ ន័យថា ទ្រង់ប្រថាប់អន្តុយក្នុងរោងជាងថ្នាំង ហើយក្រាបទូលចំពោះព្រះរាជា ។ ព្រះរាជាស្តេចទៅថ្វាយបង្គំព្រះសាស្តា ហើយត្រាស់សួរថា ព្រះអង្គស្តេចមកហើយកាលណា ។ កាលវេលាព្រះអាទិត្យលិចថ្ងៃម្សិលមិញ មហាបពិត្រ ។ ព្រះមានព្រះភាគស្តេច

មកដោយកម្មអ្វី ។ ព្រះបាទបុក្កុសាតិសម្លាញ់របស់ព្រះអង្គទ្រង់ស្តាប់ព្រះរាជ-សាសន៍ដែលមហាបពិត្របញ្ជូនទៅហើយ ស្តេចចេញបួស ស្តេចមកចំពោះតថាគត កន្លងក្រុងសាវត្ថី ស្តេចមកអស់ ៤៥ យោជន៍ ស្តេចចូលកាន់រោងជាងឆ្នាំងនេះ ហើយប្រថាប់អង្គុយ តថាគតទើបមក ដើម្បីសង្គ្រោះសម្លាញ់របស់មហាបពិត្រ បានសម្តែងធម្មកថា កុលបុត្រទ្រង់ចាក់ធ្លុះផល ៣ មហាបពិត្រ ។ បពិត្រព្រះអង្គដ៏ចម្រើន វេលានេះ សម្លាញ់បុក្កុសាតិប្រថាប់នៅទីណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ព្រះរាជាបុក្កុសាតិកុលបុត្រទ្រង់សូមឧបសម្បទហើយ ស្តេចទៅដើម្បីស្វែងរកបាត្រ និងចីវរ ព្រោះបាត្រ និងចីវរមិនទាន់គ្រប់បរិបូរ ។ ព្រះរាជាស្តេចទៅតាមទិសដែលកុលបុត្រទៅ ។ ចំណែកព្រះមានព្រះភាគ ស្តេចហោះទៅប្រាកដក្នុងព្រះគន្ធកុដិក្នុងវត្តជេតពននោះឯង ។ សូម្បីកុលបុត្រ កាលស្វែងរកបាត្រ និងចីវរ ក៏មិនទៅកាន់សម្នាក់របស់ព្រះបាទពិម្ពិសារ និងរបស់ពួកឈ្មួញថ្មីរជើង អ្នកក្រុងតក្កសិលា ។ បានឮថា កុលបុត្រនោះគិតយ៉ាងនេះថា ការដែលជ្រើសរើសស្វែងរកបាត្រ និងចីវរដែលពេញចិត្ត និងមិនពេញចិត្តក្នុងសម្នាក់នោះៗ ឯង មិនសមគួរដល់យើង ដែលដូចជាសត្វមាន់ ព្រះនគរនេះធំ ណ្ហើយចុះយើងនឹងស្វែងរកត្រង់កំពង់ទឹក ព្រៃជាទីចោលសាកសព គំនរ

សម្រាម និងតាមច្រកផ្លូវ ដូច្នេះ ។ កុលបុត្រប្រារព្ធដើម្បីស្វែងរកសំណល់សំពត់ ត្រង់គំនរសម្រាមក្នុងច្រកផ្លូវមុន ។

បទថា **ជីវិតា វោរោបេសិ** សេចក្តីថា មេគោកូនខ្ចីធ្វើលទៅធ្វើលមកដល់កុលបុត្រនោះ ដែលកំពុងរកមើលសំណល់សំពត់ក្នុងគំនរសម្រាមកន្លែងមួយ ឲ្យដល់សេចក្តីស្លាប់ ។ កុលបុត្រអ្នកត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ដល់ការអស់អាយុក្នុងគ្រានោះឯង ដួលដេកផ្កាប់លើគំនរសម្រាម ដូចជារូបមាសដូច្នោះ ។ កាលធ្វើកាលកិរិយាហើយ ទៅកើតក្នុងព្រហ្មលោកជាន់អវិហា ។ ពេលកើតហើយ ក៏សម្រេចព្រះអរហត្ត ។ បានឮថា ជនដែលកើតហើយភ្លាមក្នុងអវិហាព្រហ្មលោកមាន ៧ នាក់ បានសម្រេចព្រះអរហត្ត ។ សមពិតដូចដែលលោកពោលទុកថា ភិក្ខុ ៧ រូប ចូលដល់អវិហាព្រហ្មលោកហើយ រួចផុតមានរាគៈ និងទោសៈអស់ហើយ ឆ្លងតណ្ហាក្នុងលោក បុគ្គលទាំងនោះឆ្លងចាកភក់ ផុតអំពីអន្ទាក់មច្ចុរាជដែលឆ្លងបានដោយលំបាក បុគ្គលទាំងនោះលះយោគៈរបស់មនុស្សហើយ ចូលដល់យោគៈដែលជាទិព្វ ។ បុគ្គលទាំងនោះ គឺ ឧបកៈ ១ បលគណ្ឌៈ ១ បុក្កុសាតិ ១ រួមជា ៣ , ភទ្ទិយៈ ១ ខណ្ឌទេវៈ ១ ពាហុទត្តិ ១ បិង្គិយៈ ១ លោកទាំងនោះ លះយោគៈរបស់មនុស្សហើយ ចូលដល់យោគៈ

ដែលជាទិព្វ ដូច្នេះ ។

ចំណែកព្រះបាទពិម្ពិសារ ទ្រង់មានព្រះតម្រិះថា "សម្លាញ់របស់យើងបានអានត្រឹមតែសាសន៍ ដែលយើងបញ្ជូនទៅ ទ្រង់លះបង់រាជសម្បត្តិដែលនៅក្នុងកណ្តាប់ព្រះហស្ត ស្តេចមកផ្លូវឆ្ងាយប្រមាណប៉ុណ្ណេះ កិច្ចដែលធ្វើបានដោយលំបាក ដែលកុលបុត្របានធ្វើហើយ យើងនឹងធ្វើសក្ការៈដោយគ្រឿងសក្ការៈរបស់បព្វជិត" ដូច្នេះហើយ ទើបត្រាស់ថា "ពួកលោក ចូរទៅតាមរកសម្លាញ់របស់យើង" ដូច្នេះ ។ រាជបរិវារទាំងឡាយ ដែលត្រូវបញ្ជូនទៅក្នុងទីនោះៗ បានឃើញកុលបុត្រនោះ ។ ឃើញគេដួលចុះលើគំនរសម្រាម ត្រឡប់មកទូលចំពោះព្រះរាជា ។ ព្រះរាជាស្តេចទៅ ទ្រង់ឃើញកុលបុត្រហើយ ទ្រង់ទួញយំថា "អ្នកទាំងឡាយ ពួកយើង មិនបានដើម្បីធ្វើសក្ការៈដល់សម្លាញ់ទេ សម្លាញ់របស់យើងមិនមានទីពឹងហើយ" ត្រាស់បង្គាប់ឲ្យនាំកុលបុត្រដោយគ្រែ ទ្រង់តាំងទុកក្នុងឱកាសដែលសមគួរ ត្រាស់បង្គាប់ឲ្យហៅអ្នកងូតទឹកឲ្យ និងជាងកោរកាត់ជាដើម ដោយឲ្យដឹងដល់ការធ្វើសក្ការៈដល់កុលបុត្រដែលមិនទាន់បានឧបសម្បទា ទ្រង់ឲ្យងូតព្រះសិរសារបស់កុលបុត្រ ទ្រង់ឲ្យស្លៀកសំពត់ដែលបរិសុទ្ធិជាដើម ទ្រង់ឲ្យតាក់តែងដោយភេទរបស់ព្រះរាជា ទ្រង់លើកឡើងកាន់អង្រឹង

មាស ទ្រង់ឲ្យធ្វើការបូជាដោយវត្ថុទាំងឡាយ មានតន្ត្រី មានរបស់ក្រអូប និង មាលាគ្រប់យ៉ាងជាដើម ទ្រង់នាំចេញអំពីព្រះនគរ ទ្រង់ឲ្យធ្វើមហាចិត្តកាធារ ដោយឈើក្រអូបជាច្រើន គ្រាទ្រង់ធ្វើសរីរកិច្ចរបស់កុលបុត្រហើយ ទ្រង់នាំយក ព្រះធាតុមកប្រតិស្ឋានទុកក្នុងព្រះចេតិយ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយ ទាំងអស់នោះឯង ។

ចប់អដ្ឋកថា ធាតុវិភង្គសូត្រទី ១០

# អ ដ្ឋ ក ថា

## សច្ចវិភង្គសូត្រទី ១១

**[១៧៣]** *សច្ចវិភង្គសូត្រ* មានពាក្យផ្ដើមថា *ឯវម្មេ សុតំ* ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៖

**[១៧៤]** បណ្ដាបទទាំងនោះ បទថា **អាចិក្ខនា** សេចក្ដីថា នេះឈ្មោះថា ទុក្ខអរិយសច្ច ។ល។ នេះឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ក្នុងទីនេះ ការតាំងសច្ចៈ មានទុក្ខសច្ចជាដើម ឈ្មោះថា ការបញ្ញត្តិ ។ ក៏បុគ្គលតាំងអាសនៈហៅថា បញ្ញត្តិអាសនៈ ។ បទថា **បដ្ឋបនា** គឺ ការបញ្ញត្តិ ។ បទថា **វិវរណា** គឺ ការធ្វើបើកបង្ហាញ ។ បទថា **វិភជនា** គឺ ធ្វើការចែក ។ បទថា **ឧត្តានីកម្មំ** បានដល់ ធ្វើឲ្យប្រាកដ ។ បទថា **អនុគ្គាហកា** សេចក្ដីថា អនុគ្រោះដោយការសង្គ្រោះសូម្បី ២ យ៉ាង គឺ អាមិសសង្គ្រោះ ធម្មសង្គ្រោះ ។ បទថា **ជនេតា** គឺ មាតាអ្នកឲ្យកើត ។ បទថា **អាបាទេតា** គឺ អ្នកចិញ្ចឹម ទ្រង់សម្ដែងថា មោគ្គល្លានដូចមាតាអ្នកចិញ្ចឹម ។ ក៏មាតាអ្នកឲ្យកើត វៀរចាករបស់ប្រែ និង

របស់ក្មាវជាដើម រហូតអស់ ៩ ខែ ឬ ១០ ខែ ទ្រទ្រង់ទារកទុកក្នុងផ្ទៃ ឲ្យមាតា ចិញ្ចឹម គឺ មេដោះ ទទួលទារកដែលចេញចាកផ្ទៃ ។ មាតានោះ ចិញ្ចឹមទារក ដោយទឹកដោះ និងទឹកដោះស្រស់ជាដើមឲ្យចម្រើន ។ ទារកនោះ អាស្រ័យ សេចក្ដីចម្រើនប្រព្រឹត្តទៅតាមសប្បាយ ។ ព្រះសារីបុត្តត្ថេរក៏ដូច្នោះ សង្គ្រោះ បព្វជិតទាំងឡាយក្នុងសម្នាក់របស់ខ្លួន ឬរបស់ភិក្ខុពួកដទៃ ដោយការសង្គ្រោះ ២ យ៉ាង បដិបត្តិបព្វជិតអ្នកឈឺ ១ បបួលក្នុងកម្មដ្ឋាន ១ ដឹងថាព្រះសោតា- បន្នហើយ ចាប់តាំងពីកាលបព្វជិតទាំងនោះចេញចាកភ័យទាំងឡាយ ឥឡូវនេះ ក៏ជាអ្នកមិនមានការសម្លឹងពិនិត្យក្នុងបព្វជិតទាំងនោះថា ពួកគេនឹងញ៉ាំងមគ្គ ខាងលើឲ្យកើតឡើង ដោយការធ្វើរបស់បុរសចំពោះខ្លួន ហើយពោលប្រៀន ប្រដៅបព្វជិតថ្មីៗ ពួកដទៃ ។ ចំណែកព្រះមហាមោគ្គល្លាន សង្គ្រោះបព្វជិត ទាំងឡាយក្នុងសម្នាក់របស់ខ្លួន ឬរបស់ភិក្ខុពួកដទៃដូច្នោះដែរ បបួលក្នុងកម្មដ្ឋាន រមែងមិនដល់ភាពជាអ្នកមិនមានការសម្លឹងពិនិត្យក្នុងបព្វជិតទាំងឡាយ សូម្បី សម្រេចហើយនូវផល ៣ ក្នុងខាងក្រោម ។ ជ្រាបថា ព្រោះហេតុអ្វី ព្រះមហា មោគ្គល្លាននោះ ទើបមានសេចក្ដីត្រិះរិះយ៉ាងនេះ ។ សមដូចព្រះតម្រាស់ដែល ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ លាមកសូម្បីមានប្រមាណ

តិចក៏មានក្លិនស្អុយ មូត្រ ទឹកមាត់ ទឹកខ្ទុះ ឈាម សូម្បីមានប្រមាណតិច ក៏មានក្លិនស្អុយ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតរមែងមិនសរសើរភពសូម្បីមានប្រមាណតិច ដោយទីបំផុតសូម្បីត្រឹមតែជា ពួកនាងទេពអប្សរ ក៏ដូច្នោះដែរ ដូច្នេះ ។ ព្រោះដូច្នោះ ព្រះមហាមោគ្គល្លាន ទើបមិនដល់ភាពជាអ្នកមិនមានការសម្លឹងពិនិត្យក្នុងបព្វជិតទាំងនោះ រហូតថា ពួកគេមិនទាន់សម្រេចអរហត្ត រមែងដល់ភាពជាអ្នកមិនមានការសម្លឹងពិនិត្យក្នុងបព្វជិតទាំងឡាយ សូម្បីអ្នកសម្រេចអរហត្តហើយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រដូចមាតាបង្កើត មោគ្គល្លានដូចមាតាចិញ្ចឹមទារកដែលកើតហើយ ម្នាលភិក្ខុទាំងឡាយ សារីបុត្ររមែងណែនាំក្នុងសោតាបត្តិផល មោគ្គល្លានរមែងណែនាំក្នុងផលដែលខ្ពស់ឡើងទៅ ដូច្នេះ ។

បទថា **បហោតិ** បានដល់ រមែងអាច ។

**[១៧៩]** បទថា **ទុក្ខេ ញាណំ** បានដល់ ញាណសម្រេចដោយការស្តាប់និងការពិចារណា ។ ក្នុងទុក្ខសមុទ័យ ក៏ដូចច្នោះ ។ បដិវេធញ្ញាណក្នុងការស្តាប់ រមែងគួរក្នុងទុក្ខនិរោធ ។ រមែងគួរក្នុងទុក្ខនិរោធគាមិនីបដិបទាដូចគ្នា ។ ក្នុងសង្កប្បៈទាំងឡាយ មាននេក្ខម្មសង្កប្បៈជាដើម សេចក្តីត្រិះរិះថា សង្កប្បៈ

កើតឡើងហើយដល់អ្នកពិចារណាកាម ដោយអត្ថថា កាមជាសត្រូវ ឬដោយការរលាស់ចេញចាកកាមក្តី សង្កប្បៈធ្វើការកម្ចាត់កាម គឺ ការចូលទៅស្ងប់រម្ងាប់កាមកើតឡើងហើយក្តី សង្កប្បៈកើតឡើងក្នុងទីបំផុតនៃការស្ងប់ចាកកាមក្តី ឈ្មោះថា **នេក្ខម្មសង្កប្បៈ** ។ ក្នុងបទទាំងពីរដ៏សេស ក៏ន័យនេះដូចគ្នា ។ ក៏សង្កប្បៈទាំងអស់នោះ ក្នុងបុព្វភាគ បានក្នុងចិត្តផ្សេងៗ ក្នុងខណៈនៃមគ្គរមែងបានក្នុងចិត្តតែមួយនោះឯង រមែងបានសង្កប្បៈតែមួយប៉ុណ្ណោះ ដែលទម្លាយមិច្ឆាសង្កប្បៈចេតនាក្នុងឯកចិត្តនោះ រមែងមិនបានសង្កប្បៈផ្សេងៗ ។ សូម្បីក្នុងសម្មាវាចាជាដើម ក៏រមែងបានក្នុងចិត្តតែមួយ ក្នុងខណៈនៃមគ្គ ដោយន័យពោលហើយ ក្នុងបណ្តាចិត្តផ្សេងៗ ក្នុងបុព្វភាគ ។

ក្នុងទីនេះ មានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារបានពោលហើយក្នុងសច្ចកថាវិសុទ្ធិមគ្គ និងក្នុងសម្មាទិដ្ឋិសូត្រនោះឯង ។

ចប់អដ្ឋកថា សច្ចវិភង្គសូត្រទី ១១

# អ ដ្ឋ ក ថា

## ទក្ខិណាវិភង្គសូត្រទី ១២

**[១៨១]** *ទក្ខិណាវិភង្គសូត្រ* មានពាក្យផ្ដើមថា *ឯវំមេ សុតំ* ខ្ញុំបានស្ដាប់យ៉ាងនេះ ៖

ក្នុងទក្ខិណាវិភង្គសូត្រនោះ បទថា **មហាបជាបតី គោតមី** បានដល់ព្រះគោត្រថា **គោតមី** ។ ក៏ក្នុងថ្ងៃថ្វាយព្រះនាម ព្រាហ្មណ៍ទាំងឡាយបានទទួលសក្ការៈ ឃើញព្រះលក្ខណសម្បត្តិរបស់ព្រះនាងហើយ បានព្យាករណ៍ថា បើព្រះនាងនេះនឹងបានព្រះធីតា ព្រះធីតានឹងជាអគ្គមហេសីរបស់ស្ដេចចក្រពត្តិ បើនឹងបានព្រះឱរស ព្រះឱរសនឹងជាស្ដេចចក្រពត្តិ ព្រះបជារបស់ព្រះនាងនឹងជាអ្នកធំក្រៃលែង ដោយប្រការសូម្បីទាំងពីរនោះឯង ដូច្នេះ ។ ព្រះញាតិទាំងឡាយទើបបានថ្វាយព្រះនាមរបស់ព្រះនាងថា **បជាបតី** ដោយប្រការដូច្នេះ ។ តែក្នុងសូត្រនេះ លោករួមយកព្រះគោត្រផង ទើបពោលថា **មហាបជាបតីគោតមី** ។ បទថា **នវំ** បានដល់ ថ្មី ។ បទថា **សាមំ វាយិតំ** គឺ ទ្រង់ត្បាញខ្លួនឯងដោយព្រះហស្ត ។ ក៏ក្នុងថ្ងៃនោះ ព្រះនាងមហាបជាបតីគោតមី ដែលពួកកិលៀង

ហែហមហើយ ស្តេចមកកាន់រោងតម្បាញសំពត់របស់ជាងហត្ថករទាំងឡាយ ទ្រង់ចាប់ចុងត្រល់ ទ្រង់បានធ្វើអាការនៃការត្បាញសំពត់ ។ ពាក្យនោះ លោកពោលសំដៅដល់ការត្បាញសំពត់នោះ ។

សួរថា ព្រះនាងគោតមីទ្រង់កើតព្រះទ័យ ដើម្បីថ្វាយសំពត់មួយគូចំពោះព្រះមានព្រះភាគក្នុងកាលណា ។ ឆ្លើយថា ក្នុងកាលដែលព្រះមានព្រះភាគទ្រង់សម្រេចអភិសម្ពោធិញ្ញាណហើយ ស្តេចមកកាន់ក្រុងកបិលវត្ថុ ដោយស្តេចយាងមកគ្រាដំបូង ។ ពិតដូច្នោះ ព្រះបាទសុទ្ធោទនៈមហារាជ ទ្រង់នាំព្រះសាស្តាដែលស្តេចបិណ្ឌបាត ឲ្យស្តេចទៅកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គ ។ គ្រានោះព្រះនាងមហាបជាបតីគោតមី ទ្រង់ឃើញព្រះរូបសោភារបស់ព្រះមានព្រះភាគហើយ ទ្រង់ត្រិះរិះថា ព្រះអត្តភាពរបស់បុត្រយើងស្រស់ល្អហ្ន៎ ដូច្នេះ ។ លំដាប់នោះ ព្រះនាងក៏កើតព្រះសោមនស្សជាខ្លាំង ។ តពីនោះ ទ្រង់ព្រះត្រិះរិះថា កាលបុត្ររបស់យើងនៅកណ្តាលរាជវាំង រហូតអស់ ២៩ ឆ្នាំ វត្ថុដែលយើងឲ្យហើយ ដោយហោចទៅសូម្បីត្រឹមតែថា ផ្លែចេកនោះឯង មិនមានឡើយ តែឥឡូវនេះយើងនឹងថ្វាយសំពត់ចីវរដល់បុត្រនោះ ។ ទ្រង់ញ៉ាំងព្រះហឫទ័យឲ្យកើតឡើងថា ក៏ក្នុងក្រុងរាជគ្រឹះនេះ សំពត់តម្លៃថ្លៃមានច្រើន សំពត់ទាំងនោះ

រមែងមិនញ៉ាំងយើងឲ្យសប្បាយចិត្ត សំពត់ដែលយើងធ្វើខ្លួនឯងនោះឯង រមែងញ៉ាំងយើងឲ្យសប្បាយចិត្តបាន យើងត្រូវធ្វើសំពត់ខ្លួនឯងថ្វាយ ដូច្នេះ ។

គ្រានោះ ព្រះនាងទ្រង់ឲ្យនាំកប្បាសមកពីផ្សារ ទ្រង់ប្របាច់ ទ្រង់ញីដោយព្រះហស្ត ខារអំបោះយ៉ាងល្អិតល្អន់ ទ្រង់ឲ្យសាងរោងត្បាញសំពត់ខាងក្នុងព្រះរាជវាំងនោះឯង ទ្រង់ឲ្យហៅជាងហត្ថករទាំងឡាយ ព្រះរាជទានគ្រឿងបរិភោគខាទនីយៈ និងភោជនីយៈរបស់ព្រះអង្គនោះឯង ឲ្យដល់ជាងសិល្បទាំងឡាយហើយទ្រង់ឲ្យត្បាញសំពត់ ។

ក៏ព្រះនាងដែលពួកកីលៀងហែហាមហើយ ស្តេចទៅចាប់ចុងត្រល់តាមសមគួរដល់កាលវេលា ។ ក្នុងកាលដែលសំពត់នោះត្បាញស្រេចហើយ ទ្រង់ធ្វើសក្ការៈធំដល់ជាងហត្ថករទាំងឡាយ ហើយទ្រង់ដាក់សំពត់មួយគូក្នុងហិបដែលមានក្លិនក្រអូប ទ្រង់ឲ្យកាន់សំពត់ទូលចំពោះព្រះរាជាថា នាងខ្ញុំម្ចាស់នឹងកាន់សំពត់ចីវរទៅថ្វាយដល់បុត្រយើង ។ ព្រះរាជាត្រាស់បង្គាប់ឲ្យត្រៀមផ្លូវស្តេច ។ រាជបរិវារទាំងឡាយបោសសម្អាតថ្នល់ តាំងថ្នាំងទឹក លើកទង់សំពត់ទាំងឡាយ តាក់តែងផ្លូវតាំងពីទ្វារព្រះរាជវាំង រហូតដល់វត្តនិគ្រោធារាម ធ្វើផ្លូវឲ្យពាសពេញដោយផ្កាឈើ ។ ចំណែកព្រះនាងមហាបជាបតី ទ្រង់ប្រដាប់

គ្រឿងអលង្ការគ្រប់យ៉ាង ព្រះនាងដែលពួកគីលៀងហែហមហើយ ទ្រង់ទូលហិបសំពត់ ស្ដេចទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មីគូនេះជារបស់នាងខ្ញុំម្ចាស់ ដូច្នេះជាដើម ។

**[១៨២]** បទថា **ទុតិយម្បិ ខោ** សេចក្ដីថា កាលព្រះមានព្រះភាគត្រាស់ថា ម្នាលគោតមី ព្រះនាងចូរថ្វាយសង្ឃចុះ ព្រះនាងមហាបជាបតីគោតមីបានក្រាបទូលអង្វរថា បពិត្រព្រះអង្គដ៏ចម្រើន នាងខ្ញុំម្ចាស់អាចថ្វាយសំពត់ចីវរទាំងឡាយអំពីឃ្លាំងសំពត់ដល់ភិក្ខុរយរូបខ្លះ ពាន់រូបខ្លះ ឯសំពត់ថ្មីគូនេះ នាងខ្ញុំម្ចាស់ខាអំបោះខ្លួនឯង ត្បាញខ្លួនឯង តាំងចិត្តឧទ្ទិសព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាទទួលសំពត់ថ្មីគូនោះ របស់នាងខ្ញុំម្ចាស់ចុះ ។ ព្រះនាងក្រាបទូលយ៉ាងនេះដល់ ៣ ដង ។ សូម្បីព្រះមានព្រះភាគក៏ត្រាស់ហាមយ៉ាងនោះ ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ឲ្យថ្វាយសំពត់គូថ្មី ដែលព្រះនាងនឹងថ្វាយចំពោះព្រះអង្គ ដល់ព្រះភិក្ខុសង្ឃហ្ន៎ ។ ឆ្លើយថា ព្រោះដើម្បីទ្រង់អនុគ្រោះព្រះមាតា ។ ក៏បានឮថា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់មានព្រះតម្រិះថា ចេតនា ៣ យ៉ាង គឺ បុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនា របស់ព្រះនាងមហាបជាបតីនេះកើតឡើងប្រារព្ធតថាគត

ហើយ ចូរកើតឡើងប្រារព្ធព្រះភិក្ខុសង្ឃខ្លះ កាលដូច្នេះ ចេតនាទាំង ៦ យ៉ាង ក៏នឹងរួមតែមួយយ៉ាង នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ រហូតដល់អស់កាលយូរដល់ព្រះនាងមហាបជាបតីគោតមីនោះ ដូច្នេះ ។ ចំណែក-វិតណ្ឌវាទី (អ្នកពោលជំទាស់) ពោលថា ទានដែលថ្វាយសង្ឃមានផលច្រើន ។ គប្បីក្រើនរំលឹកវិតណ្ឌវាទីនោះថា ព្រោះហេតុអ្វីទើបពោលយ៉ាងនោះ លោករមែងពោលដល់ទានដែលថ្វាយសង្ឃ មានផលច្រើនជាងទានដែលថ្វាយដល់ព្រះសាស្តាឬ ។ អើ! យើងពោល ។ លោកចូរអាងព្រះសូត្រមក ។ វិតណ្ឌ-វាទីអាងព្រះសូត្រថា ម្នាលគោតមី ព្រះនាងថ្វាយសង្ឃចុះ កាលថ្វាយសង្ឃហើយ នឹងជាការដែលព្រះនាងបានបូជាទាំងតថាគត និងសង្ឃ ។ ក៏ព្រះសូត្រនេះ មានសេចក្តីត្រឹមតែប៉ុណ្ណេះឬ ។ អើ! ត្រឹមតែប៉ុណ្ណេះ ។ បើពោលដូច្នោះ ទានដែលឲ្យដល់អ្នកស៊ីរបស់សល់ទាំងឡាយ ក៏គប្បីមានផលច្រើន តាមព្រះតម្រាស់ថា ម្នាលអានន្ទ បើយ៉ាងនោះអ្នកចូរឲ្យនំដល់អ្នកស៊ីរបស់សល់ទាំងឡាយ និងថា ម្នាលកច្ចាន: បើដូច្នោះ អ្នកចូរឲ្យដុំស្ករអំពៅដល់អ្នកស៊ីរបស់សល់ទាំងឡាយ ដូច្នេះ ។ ក៏កាលដូច្នោះ ព្រះសាស្តាទើបទ្រង់ញ៉ាំងសំពត់ ដែលនឹងថ្វាយព្រះអង្គឲ្យដល់សង្ឃហើយ ដូច្នេះ ។ ក៏ជនទាំងឡាយសូម្បីមានព្រះរាជា

និងមហាមាត្ររបស់ព្រះរាជាជាដើម រមែងបង្គាប់ឲ្យបណ្ណាការ ដែលនាំមកដើម្បីខ្ញុំនឲ្យដល់ជនទាំងឡាយ មានអ្នកចិញ្ចឹមដំរីជាដើម ជនទាំងនោះក៏គប្បីជំជាងព្រះរាជាជាដើម ។ ពិតហើយ ទក្ខិណេយ្យបុគ្គលដ៏កំពូលប្រសើរជាងព្រះសាស្ដាមិនមាន តាមព្រះបាលីថា ព្រោះដូច្នោះ អ្នកកុំកាន់យកយ៉ាងនោះ ទក្ខិណេយ្យ-បុគ្គលដែលដល់ភាពជាអ្នកកំពូលនៃអហុនេយ្យបុគ្គលទាំងឡាយ អ្នកត្រូវការបុណ្យ ស្វែងផលបរិបូណ៌ដ៏ប្រសើរ ដូចព្រះពុទ្ធមិនមានក្នុងលោកនេះ ឬក្នុងលោកដទៃ ។ ចេតនា ៦ ប្រការរបស់ព្រះនាងមហាបជាបតីគោតមីនោះ រួមចូលគ្នាហើយ នឹងមានដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ រហូតអស់កាលយូរយ៉ាងនេះ ។

ក៏ព្រះមានព្រះភាគទ្រង់ហាមដល់ ៣ ដល់ហើយ ទ្រង់ឲ្យថ្វាយដល់សង្ឃទ្រង់សំដៅយកអ្វី ។ ត្រាស់យ៉ាងនោះ ដើម្បីជនជំនាន់ក្រោយ និងដើម្បីទ្រង់ឲ្យកើតសេចក្ដីកោតក្រែងក្នុងសង្ឃផង ។ ន័យថា ព្រះមានព្រះភាគទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតតាំងនៅមិនយូរ តែសាសនារបស់តថាគតនឹងតាំងនៅក្នុងព្រះភិក្ខុសង្ឃជំនាន់ក្រោយ ចូរញ៉ាំងសេចក្ដីកោតក្រែងក្នុងសង្ឃឲ្យកើតឡើង ដូច្នេះ ទើបទ្រង់ហាមដល់ ៣ ដង ទើបទ្រង់ឲ្យថ្វាយសង្ឃ ។

ក៏កាលដូច្នោះ ព្រះសាស្តាទើបទ្រង់ឲ្យថ្វាយសំពត់ថ្មីមួយគូ សូម្បីដែលព្រះនាងនឹងថ្វាយចំពោះព្រះអង្គឲ្យដល់សង្ឃ ទក្ខិណេយ្យបុគ្គល ឈ្មោះថា សង្ឃ ព្រោះដូច្នោះ ជនជំនាន់ក្រោយ ញ៉ាំងសេចក្តីកោតក្រែងឲ្យកើតឡើងក្នុងសង្ឃ នឹងសម្គាល់បច្ច័យបួនជាវត្ថុគប្បីថ្វាយ សង្ឃកាលមិនលំបាកដោយបច្ច័យបួន នឹងរៀនព្រះពុទ្ធវចនៈ ធ្វើសមណធម៌ កាលដូច្នោះ សាសនារបស់តថាគតនឹងតាំងនៅដល់ ៥,០០០ ឆ្នាំ ដូច្នេះ ។

ក៏ពាក្យថា ធម្មតាទក្ខិណេយ្យបុគ្គលដ៏ប្រសើរជាងព្រះសាស្តា មិនមាននោះ គួរពោលសូម្បីដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះ-ភាគមេត្តាទទួលចុះ ដូច្នេះ ។ ក៏ព្រះអានន្ទត្ថេរ មិនមានសេចក្តីអាឃាត ឬពៀរវេរាក្នុងព្រះនាងមហាបជាបតី ទាំងព្រះថេរៈមិនត្រូវការថា ទក្ខិណារបស់ព្រះនាងកុំបានមានផលច្រើន ។ ពិតហើយ ព្រះថេរៈជាបណ្ឌិត ពហុស្សូត សម្រេចសេក្ខបដិបទា ។ ព្រះថេរៈនោះ កាលឃើញភាពសំពត់ថ្មីមួយគូ ដែលព្រះនាងថ្វាយព្រះសាស្តានោះមានផលច្រើន ទើបក្រាបទូលសូមដើម្បីទ្រង់ទទួលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាទទួលចុះ ដូច្នេះ ។ វិតណ្ឌវាទីពោលទៀតថា ព្រះសាស្តាទ្រង់រាប់បញ្ចូលនឹងសង្ឃ ព្រោះព្រះតម្រាស់ថា កាល

ថ្វាយសង្ឃហើយ នឹងជាចំណែកដែលព្រះនាងបានបូជាទាំងតថាគត និងសង្ឃ ដូច្នេះ វិតណ្ឌវាទីនោះ គួរត្រូវជំទាស់ថា ក៏លោកដឹងឬថា សរណៈមានប៉ុន្មាន សេចក្តីជ្រះថ្លាពិតប្រាកដមានប៉ុន្មាន ។ វិតណ្ឌវាទីកាលដឹង ក៏នឹងពោលថា សរណៈមាន ៣ សេចក្តីជ្រះថ្លាពិតប្រាកដមាន ៣ ។ បន្ទាប់ពីនោះ ក៏ត្រូវពោលថា តាមលទ្ធិរបស់លោកសរណៈក៏គង់មាន ២ យ៉ាងប៉ុណ្ណោះ ព្រោះព្រះសាស្តារាប់បញ្ចូលនឹងសង្ឃ ។ កាលបើដូច្នោះ បព្វជ្ជាដែលទ្រង់អនុញ្ញាតយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជាឧបសម្បទ ដោយត្រៃសរណគមន៍ ដូច្នេះ សូម្បីឧបសម្បទាក៏មិនចម្រើនឡើង ។ អំពីនោះ លោកក៏នឹងមិនជាបព្វជិត គង់ជាគ្រហស្ថ ។ សូម្បីព្រះសម្មាសម្ពុទ្ធប្រថាប់គង់ក្នុងព្រះគន្ធកុដិ ភិក្ខុទាំងឡាយធ្វើឧបោសថខ្លះ បវារណាខ្លះ សង្ឃកម្មទាំងឡាយខ្លះ កម្មទាំងនោះក៏គប្បីកម្រើក ព្រោះព្រះសាស្តាទ្រង់រាប់បញ្ចូលមួយអន្លើដោយសង្ឃ នឹងមិនមាន ។ ព្រោះដូច្នោះ ទើបមិនគួរពោលពាក្យនេះថា ព្រះសាស្តាទ្រង់រាប់មួយអន្លើដោយសង្ឃ ។

**[១៨៣]** បទថា ***អាបាទិតា*** បានដល់ ទ្រង់ឲ្យចម្រើនព្រមហើយ អធិប្បាយថា គ្រាព្រះហស្ត និងព្រះបាទរបស់ព្រះអង្គមិនញុាំងកិច្ចដោយព្រះហស្ត

និងព្រះបាទឲ្យសម្រេច ព្រះនាងក៏ទ្រង់ឲ្យព្រះហស្ត និងព្រះបាទឲ្យបម្រើន ដោយការប្រណិបត្តិ ។ បទថា **បោសិកា** សេចក្ដីថា ព្រះនាងទ្រង់ចិញ្ចឹមព្រះអង្គ ដោយការផ្ងូតទឹក ទ្រង់ឲ្យសោយ ទ្រង់ឲ្យផឹក មួយថ្ងៃ ២-៣ ដង ។

បទថា **ថញ្ញំ បាយេសិ** សេចក្ដីថា បានឮថា នន្ទកុមារពោធិសត្វ ទ្រង់ជាកម្លោះត្រឹមតែពីរ-បីថ្ងៃប៉ុណ្ណោះ កាលនន្ទកុមារប្រសូតិហើយ ព្រះនាងមហាបជាបតីទ្រង់ឲ្យព្រះឱរសរបស់ព្រះអង្គឲ្យដល់កីលៀងចិញ្ចឹម ព្រះអង្គឯងញុំាងនាទីជាមេដោះឲ្យសម្រេច ប្រទានព្រះខីរសចំពោះព្រះពោធិសត្វ ព្រះថេរៈសំដៅដល់ការប្រទានព្រះខីរសនោះ ទើបក្រាបទូលយ៉ាងនេះ ។

ព្រះថេរៈ គ្រាសម្ដែងសភាពដែលព្រះនាងមហាបជាបតីទ្រង់មានព្រះឧបការៈច្រើន ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលនឹងសម្ដែងសេចក្ដីដែលព្រះតថាគតទ្រង់មានព្រះឧបការៈច្រើន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគ ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ភគវន្តំ ភន្តេ អាគម្ម** គឺ ទ្រង់អាស្រ័យ គឺ ទ្រង់ពឹងពាក់ ទ្រង់សំដៅយកព្រះ-មានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់អនុមោទនាដល់ព្រះឧបការៈក្រៃលែងៗ ឡើងទៅ ក្នុងព្រះឧបការៈទាំងពីរ ទើបត្រាស់ថា ប្រការ

នោះ ជាយ៉ាងនោះជាដើម ។

[១៨៤] បណ្ដាបទទាំងនោះ បទថា **យំ ហានន្ទ បុគ្គលោ បុគ្គលំ អាគម្ម** សេចក្ដីថា បុគ្គលជាអន្តេវាសិកអាស្រ័យបុគ្គលដែលជាអាចារ្យណា ។ បទថា **ឥមស្សានន្ទ បុគ្គលស្ស ឥមិនា បុគ្គលេន** សេចក្ដីថា បុគ្គលដែលជាអន្តេ-វាសិកនេះ តបស្នងចំពោះបុគ្គលដែលជាអាចារ្យនេះ ។ បទថា **ន សុប្បដិការំ វទាមិ** សេចក្ដីថា តថាគតមិនពោលការតបស្នងឧបការៈជាការធ្វើដោយល្អ ។ ក្នុងកម្មទាំងឡាយ មានការអភិវាទនៈជាដើម ការឃើញអាចារ្យហើយ ធ្វើការក្រាបថ្វាយបង្គំ ឈ្មោះថា **អភិវាទន** បានដល់ កាលនឹងសម្រេចឥរិយាបថទាំងឡាយ បែរមុខទៅកាន់ទិសាភាគដែលអាចារ្យនៅ ថ្វាយបង្គំហើយដើរ ថ្វាយបង្គំហើយឈរ ថ្វាយបង្គំហើយអង្គុយ ថ្វាយបង្គំហើយដេក ។ ចំណែកការឃើញអាចារ្យពីទីឆ្ងាយហើយ ក្រោកឡើងធ្វើការទទួល ឈ្មោះថា **បច្ចុដ្ឋាន** ។ ក៏កម្មនេះ គឺ ឃើញអាចារ្យហើយ ផ្គងអញ្ជលីទុកលើសីសៈ នមស្ការអាចារ្យ ឬសូម្បីបែរមុខទៅកាន់ទិសាភាគដែលអាចារ្យនោះនៅ នមស្ការយ៉ាងនោះឯង ដើរទៅក្ដី ឈរក្ដី អង្គុយក្ដី ដេកក្ដី ផ្គងអញ្ជលីហើយនមស្ការនោះឯង ឈ្មោះថា **អញ្ជ-លីកម្ម** ។ ការធ្វើកម្មដែលសមគួរ ឈ្មោះថា **សាមីចិកម្ម** ។ ក្នុងវត្ថុទាំងឡាយ

មានចីវរជាដើម កាលនឹងថ្វាយចីវរ មិនថ្វាយតាមមានតាមបាន ។ ថ្វាយចីវរដែលមានតម្លៃច្រើន មានតម្លៃ ១០០ ខ្លះ ៥០០ ខ្លះ ១,០០០ ខ្លះ ។ ក្នុងវត្ថុទាំងឡាយសូម្បីមានបិណ្ឌបាតជាដើម មានន័យនេះដូចគ្នា ។ ដោយបច្ច័យច្រើនយ៉ាងណា ។ សូម្បីកាលញុំាងចន្ទោះចក្រវាឡឲ្យពេញដោយបច្ច័យដ៏ប្រណីត ៤ កាន់យកកំពូលប៉ុនក្នុំសិនេរុថ្វាយ រមែងមិនអាចធ្វើកិរិយាដែលសមគួរដល់អាចារ្យឡើយ ។

**[១៨៥]** ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រារព្ធថា ក៏ទក្ខិណា ១៤ នេះឯង ។ សូត្រនេះ កើតឡើងប្រារព្ធទក្ខិណាជាបាដិបុគ្គលិក ។ ចំណែកព្រះអានន្ទត្ថេរ កាន់យកទក្ខិណាជាបាដិបុគ្គលិកតែម្យ៉ាងថា បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះមានព្រះភាគមេត្តាទទួល ដូច្នេះ ។ តែព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្តែងថា ទានដែលបុគ្គលឲ្យហើយក្នុងឋានៈ ១៤ ឈ្មោះថាជាបាដិបុគ្គលិក ។ បទថា **អយំ បឋមា** សេចក្តីថា ទក្ខិណានេះ ប្រការទី ១ ដោយអំណាចគុណខ្លះ ដោយអំណាចជាទក្ខិណាដ៏ប្រសើរខ្លះ ពិតហើយ ទក្ខិណាទី ១ នេះ គឺ ប្រសើរ បានដល់ ប្រសើរបំផុត ឈ្មោះថា ប្រមាណនៃទក្ខិណានេះមិនមាន ទក្ខិណាសូម្បីប្រការទី ២-៣ ជាទក្ខិណាក្រៃលែងនោះឯង ។ ទក្ខិណា

ដ៏សេសទាំងឡាយ រមែងមិនដល់ការបរិបូរនៃទក្ខិណាយ៉ាងក្រៃលែងដោយការៈ បាន ។ បទថា **ពាហិរកេ កាមេសុ វីតរាគេ** បានដល់ អ្នកកម្មវាទី អ្នកកិរិយ-វាទី អ្នកមានអភិញ្ញា ៥ ដែលជាលោកិយៈ ។ បទថា **បុថុជ្ជនសីលវន្តេ** សេចក្តីថា បុថុជ្ជនអ្នកមានសីល ដោយឈ្មោះ ជាអ្នកមានសីលជាផែនដី មិនអួតអាង មិនមានមាយា មិនបៀតបៀនអ្នកដទៃ សម្រេចជីវិតដោយកសិកម្ម ឬពាណិជ្ជ-កម្មដោយធម៌ ដោយប្រពៃ ។ បទថា **បុថុជ្ជនទុស្សីលេ** សេចក្តីថា បុគ្គលទាំងឡាយ មាននាយកេវដ្តៈ និងអ្នកចាប់ត្រីជាដើម ឈ្មោះថា បុថុជ្ជនអ្នកទ្រុស្តសីល ចិញ្ចឹមជីវិតដោយការបៀតបៀនសត្វដទៃ ។

**[១៨៦]** ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់កំណត់វិបាករបស់ទក្ខិណា ជាបាដបុគ្គលិក ទើបត្រាស់ថា **តត្រានន្ទ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **តិរច្ឆានគតេ** សេចក្តីថា ការឲ្យណាដែលបុគ្គលឲ្យហើយ ដើម្បីចិញ្ចឹមអំណាចនៃគុណ ដោយអំណាចនៃឧបការៈ ការឲ្យនេះមិនកាន់យក ។ ការឲ្យណាសូម្បីត្រឹមតែថា បាយមួយវែក ឬកន្ទះវែកដែលបុគ្គលឲ្យហើយ ការឲ្យនោះក៏មិនកាន់យក ។ ចំណែកការឲ្យណា ដែលបុគ្គលប្រាថ្នាផលហើយឲ្យតាមសេចក្តីត្រូវការដល់សត្វទាំងឡាយមានសុនខ ជ្រូក មាន់ និងក្អែកជាដើមណាមួយ ដែល

មកដល់ ទ្រង់សំដៅដល់ទាននេះ ទើបត្រាស់ថា ឲ្យទានក្នុងសត្វតិរច្ឆានដូច្នេះ ។ បទថា សតគុណា បានដល់ មានអានិសង្សមួយរយ ។ បទថា បាដិកង្ខិតព្វា គឺ គប្បីប្រាថ្នា ។ មានអធិប្បាយថា ទក្ខិណានេះ រមែងឲ្យអានិសង្ស ៥០០ គឺ អាយុមួយរយ វណ្ណៈមួយរយ សុខមួយរយ ពលៈមួយរយ បដិភាណមួយរយ ។ ទក្ខិណាឲ្យអាយុក្នុងរយអត្តភាព ឈ្មោះថា អាយុមួយរយ ឲ្យវណ្ណៈក្នុងមួយរយអត្តភាពឈ្មោះថា វណ្ណៈមួយរយ ឲ្យសុខក្នុងមួយរយអត្តភាព ឈ្មោះថា សុខមួយរយ ឲ្យពលៈក្នុងមួយរយអត្តភាព ឈ្មោះថា ពលៈមួយរយ ឲ្យបដិភាណធ្វើសេចក្តីមិនតក់ស្លុតក្នុងមួយរយអត្តភាព ឈ្មោះថា បដិភាណមួយរយ ។ សូម្បីក្នុងកពមួយរយ ដែលពោលហើយ ក៏មានសេចក្តីយ៉ាងនេះឯង ។ គប្បីជ្រាបន័យគ្រប់បទដោយទំនងនេះ ។ ក្នុងបទនេះថា អ្នកបដិបត្តិដើម្បីធ្វើឲ្យច្បាស់នូវសោតាបត្តិផល សូម្បីឧបាសកអ្នកដល់ត្រៃសរណៈ ដោយទីបំផុតខាងក្រោម ឈ្មោះថា បដិបត្តិដើម្បីធ្វើឲ្យច្បាស់នូវសោតាបត្តិផល ។ សូម្បីទានដែលឲ្យក្នុងឧបាសកអ្នកបដិបត្តិដើម្បីធ្វើឲ្យច្បាស់នូវសោតាបត្តិផលនោះ រាប់មិនបាន ប្រមាណមិនបាន ។ ចំណែកទានដែលឲ្យដល់បុគ្គលដែលតាំងនៅក្នុងសីល ៥ មានផលច្រើនជាងនោះ ។ ទានដែលឲ្យដល់បុគ្គលដែលតាំងនៅក្នុងសីល ១០

មានផលច្រើនជាងនោះទៀត ។ ទានដែលថ្វាយដល់សាមណេរដែលបួសក្នុង ថ្ងៃនោះ មានផលច្រើនជាងនោះ ទានដែលថ្វាយដល់ភិក្ខុដែលឧបសម្បទា មាន ផលច្រើនជាងនោះ ទានដែលថ្វាយដល់ភិក្ខុដែលឧបសម្បទានោះឯង អ្នកដល់ ព្រមដោយវត្ត មានផលច្រើនជាងនោះ ទានឲ្យដល់អ្នកប្រារព្ធវិបស្សនា មាន ផលច្រើនជាងនោះ ។ ក៏សម្រាប់បុគ្គលដល់ព្រមដោយមគ្គ ដោយទីបំផុតក្រៃ លែង អ្នកបដិបត្តិដើម្បីធ្វើឲ្យច្បាស់ដែលសោតាបត្តិផល ឈ្មោះថា បដិបត្តិ ហើយ ។ ទានដែលឲ្យដល់បុគ្គលនោះ មានផលច្រើនជាងនោះទៀត ។ សួរថា ក៏អាចដើម្បីឲ្យទានដល់ភិក្ខុអ្នកដល់ព្រមដោយមគ្គឬ ។ ឆ្លើយថា អើ! អាចដើម្បី ឲ្យ ។ ក៏ភិក្ខុដែលប្រារព្ធវិបស្សនា កាន់បាត្រ និងចីវរ ចូលស្រុកដើម្បីបិណ្ឌ- បាត្រ ។ កាលភិក្ខុអ្នកដល់ព្រមដោយមគ្គនោះ ឈរត្រង់ទ្វារផ្ទះ ជនទាំងឡាយ ទទួលបាត្រអំពីដៃ ក៏ដាក់ខាទនីយៈ និងភោជនីយៈ ។ ការចេញចាកមគ្គរបស់ ភិក្ខុរមែងមានក្នុងខណៈនោះ ។ ទាននេះឈ្មោះថា ជាការឲ្យហើយដល់ភិក្ខុអ្នក ដល់ព្រមដោយមគ្គ ។ ក៏ម្យ៉ាងទៀត ភិក្ខុនោះអង្គុយក្នុងរោងឆាន់ មនុស្សទាំង ឡាយទៅហើយដាក់ខាទនីយៈ ភោជនីយៈក្នុងបាត្រ ។ ការចេញចាកមគ្គរបស់ ភិក្ខុនោះរមែងមានក្នុងខណៈនោះ ។ ទានសូម្បីនេះ ឈ្មោះថា ឲ្យហើយដល់ភិក្ខុ

អ្នកដល់ព្រមដោយមគ្គ ។ម្យ៉ាងទៀត កាលភិក្ខុនោះអង្គុយក្នុងវិហារ ឬរោង ឆាន់ ឧបាសកទាំងឡាយកាន់បាត្រទៅផ្ទះរបស់ខ្លួន ហើយដាក់ខាទនីយៈ និង ភោជនីយៈ ការចេញចាកមគ្គរបស់ភិក្ខុនោះ រមែងមានក្នុងខណៈនោះ ។ ទាន សូម្បីនេះ ឈ្មោះថា ឲ្យហើយដល់ភិក្ខុអ្នកដល់ព្រមដោយមគ្គ ។ គប្បីជ្រាប សេចក្តីនូវទានដែលបុគ្គលឲ្យហើយ ដល់អ្នកបដិបត្តិដើម្បីធ្វើឲ្យច្បាស់សោតា-បត្តិផលនោះ ដូចទឹកក្នុងប្រឡាយមិនអាចរាប់បាន ដូច្នោះ ។ គប្បីជ្រាបសេចក្តី នូវទានដែលបុគ្គលឲ្យហើយក្នុងបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ដូចទឹកក្នុងមហាសមុទ្រនោះឯង ក្នុងបណ្តាមហានទីនោះៗ ជាការរាប់មិនបាន ។ គប្បីសម្តែងសេចក្តីនេះ សូម្បីដោយការធ្វើធូលីក្នុងស្ថានត្រឹមតែលានបោកស្រូវ នៃផែនដីជាដើម ដរាបដល់ធូលីទាំងផែនដី ដែលប្រមាណមិនបាន ។

**[១៨៧]** ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រារព្ធថា ក៏ទក្ខិណា ៧ យ៉ាងនេះ ។ ទ្រង់ប្រារព្ធទេសនានេះ ដែលត្រាស់ថា ម្នាលគោតមី ព្រះនាងចូរ ថ្វាយសង្ឃចុះ កាលថ្វាយសង្ឃហើយ ជាការដែលព្រះនាងបានបូជាទាំងតថាគត និងសង្ឃ ដើម្បីទ្រង់សម្តែងថា ទានដែលឲ្យក្នុងឋានៈ ៧ នោះ ឈ្មោះថា ថ្វាយ សង្ឃហើយ ។ បណ្តាបទទាំងនោះ បទថា **ពុទ្ធប្បមុខេ ឧភតោសង្ឃេ** សេចក្តី

ថា សង្ឃនេះ គឺ ភិក្ខុសង្ឃចំណែកមួយ ភិក្ខុនីសង្ឃចំណែកមួយ ព្រះសាស្តាប្រថាប់អង្គុយត្រង់កណ្តាល ឈ្មោះថា សង្ឃ ២ ចំណែក មានព្រះពុទ្ធជាប្រមុខ ។ បទថា **អយំ បឋមា** សេចក្តីថា ឈ្មោះថា ទក្ខិណាមានប្រមាណស្មើដោយទក្ខិណានេះមិនមាន ។ ក៏ទក្ខិណាទាំងឡាយ មានទក្ខិណាទីពីរជាដើម រមែងមិនដល់ទក្ខិណាសូម្បីនោះ ។ សួរថា ក៏កាលព្រះតថាគតបរិនិព្វានហើយ អាចថ្វាយទានចំពោះព្រះសង្ឃ ២ ចំណែក មានព្រះពុទ្ធជាប្រធានឬ ។ ឆ្លើយថា អាច ។ យ៉ាងណា ។ ក៏គប្បីតាំងព្រះពុទ្ធរូប មានព្រះធាតុជាដើម ក្នុងឋានៈប្រធានរបស់សង្ឃ ២ ចំណែកត្រង់អាសនៈដាក់តាំង ថ្វាយវត្ថុទាំងអស់ មានទក្ខិណោទកជាដើមចំពោះព្រះសាស្តាមុន ហើយថ្វាយចំពោះព្រះសង្ឃ ២ ចំណែក ។ ទានដែលឈ្មោះថា ថ្វាយសង្ឃ ២ ចំណែក មានព្រះពុទ្ធជាប្រធាន ដោយប្រការដូច្នេះ ។ សួរថា ក្នុងព្រះសង្ឃ ២ ចំណែកនោះ ទានណាថ្វាយព្រះសាស្តាទាននោះគប្បីធ្វើយ៉ាងណា ។ ឆ្លើយថា គប្បីថ្វាយភិក្ខុដែលដល់ព្រមដោយវត្តបដិបត្តិព្រះសាស្តា សេចក្តីថា ទ្រព្យដែលជារបស់បិតា រមែងសមគួរដល់បុត្រ ។ សូម្បីការថ្វាយទានដល់ភិក្ខុសង្ឃ ក៏គួរ ។ ក៏កាន់យកទឹកដោះថ្លា និងប្រេងគប្បីធ្វើប្រទីប សំពត់សាដក គប្បីលើកទង់បដា ។ បទថា **ភិក្ខុសង្ឃេ** បាន

ដល់ ភិក្ខុសង្ឃចំណែកច្រើនទៅមិនទាន់ដាច់ខែ្ស ។ សូម្បីក្នុងភិក្ខុនីសង្ឃ ក៏ន័យនេះដូចគ្នា ។

**[១៨៨]** បទថា **គោត្រភុនោ** បានដល់ ទទួលត្រឹមតែគោត្រប៉ុណ្ណោះ អធិប្បាយថា ជាសមណៈតែឈ្មោះ ។ បទថា **កាសាវកណ្ឋា** គឺ អ្នកមានឈ្មោះថា មានសំពត់កាសាវៈរុំក ។ បានឮថា ភិក្ខុទាំងនោះរុំសំពត់កាសាវៈមួយផ្ទាំងត្រង់ដៃ ឬត្រង់កត្រាច់ទៅតាមទ្វារផ្ទះ សូម្បីកម្ម មានបុត្រភរិយា កសិកម្ម និងពាណិជ្ជកម្មជាដើមទាំងឡាយរបស់ភិក្ខុដែលទ្រុស្តសីលទាំងនោះ ក៏នឹងមានជាប្រក្រតីនោះឯង ។ មិនបានត្រាស់ថា សង្ឃទ្រុស្តសីល ក្នុងបទនេះថា អ្នកទាំងឡាយនឹងថ្វាយទានចំពោះសង្ឃបានក្នុងពួកភិក្ខុទ្រុស្តសីលនោះ ពិតហើយ សង្ឃឈ្មោះថា ទ្រុស្តសីលមិនមាន តែឧបាសកទាំងឡាយឈ្មោះថា ទ្រុស្តសីល នឹងថ្វាយទានដោយគិតថា យើងនឹងថ្វាយចំពោះសង្ឃក្នុងពួកភិក្ខុទ្រុស្តសីលនោះ ។

សូម្បីទក្ខិណាដែលថ្វាយសង្ឃមានព្រះពុទ្ធជាប្រធាន ដែលព្រះមានព្រះ-ភាគត្រាស់ថា មានផលរាប់មិនបាន ដោយការរាប់គុណ ដោយប្រការដូច្នេះ ។ សូម្បីទក្ខិណាដែលឲ្យក្នុងសង្ឃ ដែលមានភិក្ខុមានសំពត់កាសាវៈរុំក ត្រាស់ថា មានផលរាប់មិនបាន ដោយការរាប់គុណដូចគ្នា ។ ក៏ទក្ខិណាដែលដល់សង្ឃ

រមែងមានដល់បុគ្គលដែលធ្វើសេចក្ដីកោតក្រែងក្នុងសង្ឃ ។ តែសេចក្ដីកោតក្រែងក្នុងសង្ឃ ធ្វើបានលំបាក ។ ក៏បុគ្គលណាត្រៀមទេយ្យធម៌ ដោយគិតថា យើងនឹងឲ្យទក្ខិណាដល់សង្ឃ ទៅវត្តហើយឆ្លើយប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ចូរឲ្យព្រះថេរៈមួយរូបពីសង្ឃ ។ លំដាប់នោះ បានសាមណេរអំពីសង្ឃ រមែងដល់ការៈជាយ៉ាងដទៃថា យើងបានសាមណេរហើយដូច្នេះ ។ ទក្ខិណារបស់បុគ្គលនោះ រមែងមិនដល់សង្ឃ ។ សូម្បីកាលបានព្រះមហាថេរៈ កើតសេចក្ដីសោមនស្សថា យើងបានមហាថេរៈហើយ ដូច្នេះ ទក្ខិណាក៏មិនដល់សង្ឃដូចគ្នា ។ ចំណែកបុគ្គលណាបានសាមណេរ ដែលឧបសម្បទាហើយ ភិក្ខុកម្លោះ ឬថេរៈ ជាពាល ឬបណ្ឌិត រូបណាមួយអំពីសង្ឃហើយ មិនសង្ស័យ រមែងធ្វើសេចក្ដីកោតក្រែងក្នុងសង្ឃថា យើងនឹងថ្វាយសង្ឃ ។ ទក្ខិណារបស់បុគ្គលនោះ ឈ្មោះថា ដល់សង្ឃហើយ ។ បានឮថា ពួកឧបាសកអ្នកនៅត្រើយសមុទ្រឯណោះ ធ្វើយ៉ាងនេះ ។ ក៏ក្នុងឧបាសកទាំងនោះ ម្នាក់ជាម្ចាស់វត្ត ជាកុដុម្ពី ចោះចំពោះសង្ឃថា យើងនឹងថ្វាយទក្ខិណាដល់សង្ឃទើបឆ្លើយប្រាប់ថា សូមលោកម្ចាស់ចូរឲ្យភិក្ខុមួយរូប ។ ឧបាសកនោះបានភិក្ខុទ្រុស្តសីលមួយរូប នាំទៅកាន់ទីលំនៅខ្លួន ក្រាលអាសនៈ ចងពិតានខាងលើ បូជាដោយគ្រឿងក្រអូប ធូប និងផ្កាឈើ លាងជើង លាបដោយប្រេង បានថ្វាយទេយ្យធម៌ដោយសេចក្ដីកោតក្រែងក្នុងសង្ឃ ដូចធ្វើសេចក្ដីនមស្ការចំពោះ

ព្រះពុទ្ធ ។ ភិក្ខុរូបនោះមកកាន់ទ្វារផ្ទះថា លោកចូរឲ្យចបដើម្បីប្រយោជន៍ដល់ការបដិបត្តិវត្តក្នុងខាងក្រោយកត្ត ។ ឧបាសកអង្គុយកៀសចបដោយជើង ហើយពោលថា ចូរទទួលទៅ ។ មនុស្សទាំងឡាយបានពោលនឹងគេនោះថា លោកបានធ្វើសក្ការៈដល់ភិក្ខុនេះពីព្រឹកព្រលឹមមក មិនអាចនឹងពោល ឥឡូវនេះ សូម្បីត្រឹមតែថា ឧបចារៈ (មារយាទ) ក៏មិនមាន នេះឈ្មោះថាអ្វី ដូច្នេះ ។ ឧបាសកពោលថា នែ៎! នាយ សេចក្តីកោតក្រែងនោះមានចំពោះសង្ឃ មិនមានដល់ភិក្ខុនោះ ។ សួរថា ក៏អ្នកណា រមែងញ៉ាំងទក្ខិណាដែលថ្វាយសង្ឃ ដែលមានភិក្ខុមានសំពត់កាសាវៈរុំកឲ្យបរិសុទ្ធិ ។ ឆ្លើយថា ព្រះមហាថេរៈ ៨០ រូប មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម រមែងឲ្យបរិសុទ្ធិបាន ។ មួយទៀតព្រះថេរៈទាំងឡាយបរិនិព្វានយូរហើយ ព្រះខីណាស្រពទាំងឡាយ ដែលនៅមានជីវិតរស់នៅ តាំងពីព្រះថេរៈជាដើម ដរាបដល់សព្វថ្ងៃនេះ រមែងឲ្យបរិសុទ្ធិដូចគ្នា ។

ក្នុងបទនេះថា ម្នាលអានន្ទ **តថាគតមិនដែលពោលបាដិបុគ្គលិកទានថាមានផលច្រើនជាងសង្ឃគតទក្ខិណាដោយបរិយាយណាៗ ឡើយ** សង្ឃមានព្រះពុទ្ធជាប្រធានមាន សង្ឃបច្ចុប្បន្ននេះមាន នៅសង្ឃដែលមានភិក្ខុមានសំពត់កាសាវៈរុំកក្នុងអនាគតក៏មាន ។ សង្ឃដែលមានព្រះពុទ្ធជាប្រធាន មិនគប្បីនាំចូលទៅនឹងសង្ឃក្នុងបច្ចុប្បន្ននេះ សង្ឃក្នុងបច្ចុប្បន្ននេះ ក៏មិនគប្បីនាំចូលទៅនឹងសង្ឃ

ដែលមានកិច្ចមានសំពត់កាសាវៈរុំកក្នុងអនាគត គប្បីពោលតាមសម័យនោះប៉ុណ្ណោះ ។ ក៏សមណបុថុជ្ជនដែលនាំទៅអំពីសង្ឃ និងបាដិបុគ្គលិកសោតាបន្នកាលបុគ្គលអាចធ្វើសេចក្តីកោតក្រែងក្នុងសង្ឃ ទានដែលឲ្យក្នុងសមណៈអ្នកបុថុជ្ជន មានផលច្រើនជាង ។

ក្នុងពាក្យសូម្បីមានជាដើមថា សោតាបន្នដែលទាយកកាន់យក (ពីសង្ឃ) និងបាដិបុគ្គលិកសទាគាមី ក៏មានន័យនេះដូចគ្នា ។ ពិតហើយ កាលបុគ្គលអាចធ្វើសេចក្តីកោតក្រែងក្នុងសង្ឃ ឲ្យទានសូម្បីក្នុងកិច្ចទ្រុស្តសីល មានផលច្រើនជាងទានដែលបុគ្គលថ្វាយក្នុងព្រះខីណាស្រពនោះឯង ។

**[១៨៩]** ក៏ពាក្យណាដែលពោលថា ម្នាលមហាបពិត្រ ទានដែលឲ្យដល់អ្នកមានសីលនោះឯងមានផលច្រើនជាង ទានដែលឲ្យក្នុងអ្នកទ្រុស្តសីលមិនមានផលច្រើនយ៉ាងនោះទេ ពាក្យនោះគប្បីលះបង់ន័យនេះ ហើយគប្បីឃើញក្នុងចតុក្កៈនេះថា ម្នាលអានន្ទ ក៏សេចក្តីបរិសុទ្ធិនៃទក្ខិណានេះមាន ៤ យ៉ាង ។

បទថា **ទាយកតោ វិសុជ្ឈតិ** សេចក្តីថា ទក្ខិណាខ្វះបរិសុទ្ធិដោយការមានផលច្រើន អធិប្បាយថា ជាទានមានផលច្រើន ។ បទថា **កល្យាណធម្មោ** បានដល់ មានធម៌ល្អ ។

បទថា **បាបធម្មោ** គឺ មានធម៌អាក្រក់ ។ ក៏គប្បីសម្តែងព្រះវេស្សន្តរមហារាជ ក្នុងបទនេះថា ទក្ខិណាណាមួយបរិសុទ្ធិចំណែកទាយក ។ ក៏ព្រះវេ-

ស្បន្ទរមហាពជនោះ ទ្រង់ឲ្យព្រះឱរសព្រះធីតាដល់ព្រាហ្មណ៍ដូជកហើយ ញ៉ាំង ផែនដីឲ្យញាប់ញ័រ ។ គប្បីសម្ដែងនាយកេវដ្ដៈ អ្នកអាស្រ័យនៅត្រង់ទ្វារទឹក កល្យាណទី ក្នុងពាក្យនេះថា ទក្ខិណាណាមួយបរិសុទ្ធិចំណែកបដិគ្គាហកៈ ។ បានឮថា កេវដ្ដៈនោះ បានថ្វាយបិណ្ឌបាតដល់ព្រះទីឃសោមត្ថេរដល់ ៣ ដង ដេកលើគ្រែជាទីសម្រាប់ស្លាប់ បានពោលថា បិណ្ឌបាត្រដែលថ្វាយដល់លោក ម្ចាស់ទីឃសោមត្ថេរ រមែងលើកខ្ញុំឡើង ។ គប្បីសម្ដែងដល់ព្រានអ្នកនៅក្នុង វឌ្ឍមាន ក្នុងបទថា **នេវ ទាយកតោ** នេះ ។ បានឮថា នាយព្រាននោះ កាល ឲ្យទក្ខិណា ឧទ្ទិសដល់អ្នកស្លាប់ បានឲ្យដល់ភិក្ខុដែលទ្រុស្តសីលមួយរូបនោះ ឯងដល់ ៣ ដង ។ ក្នុងគ្រាទី ៣ អមនុស្សស្រែកឡើងថា អ្នកទ្រុស្តសីលប្លន់ខ្ញុំ ដូច្នេះ ។ ក្នុងវេលាដែលព្រាននោះ ថ្វាយដល់ភិក្ខុដែលមានសីលមួយរូបដែល មកដល់ ផលរបស់ទក្ខិណាក៏ដល់គេ ។ គប្បីសម្ដែងនៅក្នុងអសទិសទាន ក្នុង ពាក្យនេះថា ទក្ខិណាណាមួយបរិសុទ្ធិចំណែកទាយកប៉ុណ្ណោះ ។

ក្នុងពាក្យថា ទក្ខិណានោះបរិសុទ្ធិចំណែកទាយកនេះ គប្បីជ្រាបសេចក្ដី បរិសុទ្ធិនៃទានក្នុងបទទាំងពួង ដោយទំនងនេះថា អ្នកស្រែដែលឆ្លាត បានស្រែ សូម្បីមិនល្អ ក្តរនាំទូវមន្ទិលដោយការក្ដួរពាស់ក្នុងសម័យនោះ ដាំពូជដែលមាន ប្រយោជន៍ ថែរក្សារហូតអស់យប់ និងថ្ងៃ កាលមិនមានសេចក្ដីប្រមាទ រមែង បានស្រូវច្រើនជាងស្រែដែលមិនថែរក្សារបស់អ្នកដទៃ យ៉ាងណា អ្នកមានសីល

សូម្បីឲ្យទានដល់អ្នកទ្រុស្តសីល រមែងបានផលច្រើន ដូច្នោះ ។

ក្នុងបទថា **វីតរាគោ វីតរាគេសុ** នេះ ព្រះអនាគាមី ឈ្មោះថា ប្រាស ចាកអំពីរាគៈ ចំណែកព្រះអរហន្តជាអ្នកប្រាសចាករាគៈដោយសព្វគ្រប់នោះឯង ព្រោះដូច្នោះ ទានដែលព្រះអរហន្តឲ្យដល់ព្រះអរហន្តនោះឯង ជាទានដ៏ប្រសើរ ។ ព្រោះហេតុអ្វី ។ ព្រោះមិនមានសេចក្តីប្រាថ្នាកត របស់អ្នកអាល័យក្នុងភព ។ សួរថា ព្រះខីណាស្រពរមែងមិនជឿផលទានមែនឬ ។ ឆ្លើយថា បុគ្គលទាំងឡាយ ជឿផលទាន ដូចព្រះខីណាស្រពនោះ មិនមាន ក៏កម្មដែលព្រះខីណាស្រពធ្វើ ហើយ មិនមែនជាកុសល ឬអកុសល ព្រោះជាអ្នកប្រាសចាកឆន្ទរាគៈហើយ រមែងតាំងនៅក្នុងឋានកិរិយា ដោយហេតុនោះបណ្ឌិតទាំងឡាយ ទើបពោលថា ទានរបស់ព្រះខីណាស្រពនោះ មានផលដ៏ប្រសើរ ដូច្នេះ ។ សួរថា ក៏ទានដែល ព្រះសម្មាសម្ពុទ្ធទ្រង់ឲ្យដល់ព្រះសារីបុត្តត្ថេរ មានផលច្រើន ឬថា ទានដែល ព្រះសារីបុត្តត្ថេរថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ មានផលច្រើន ។ ឆ្លើយថា បណ្ឌិត ទាំងឡាយពោលថា ទានដែលព្រះសម្មាសម្ពុទ្ធទ្រង់ឲ្យដល់ព្រះសារីបុត្រ មាន ផលច្រើន ។ ព្រោះហេតុអ្វី ។ ព្រោះបុគ្គលដទៃវៀរព្រះសម្មាសម្ពុទ្ធ ឈ្មោះ ថា អាចឲ្យផលទានកើតឡើង មិនមាន ។ ពិតហើយ ទាន រមែងឲ្យផលដល់ អ្នកអាចធ្វើដោយសម្បទា ៤ ក្នុងអត្តភាពនោះឯង ។ សម្បទាក្នុងសូត្រនេះ មានដូច្នេះ គឺ ការកើតឡើងនូវទេយ្យធម៌ដែលមិនបៀតបៀនអ្នកដទៃ បានដោយ

ធម៌ ដោយប្រពៃ , ចេតនា ដោយអំណាចនៃបុព្វចេតនាជាដើម មានចេតនាធំ , ជាអ្នកមានគុណដ៏ប្រសើរក្រៃលែង ដោយការៈជាព្រះខីណាស្រព ។ សេចក្តីដល់ព្រមដោយវត្ថុ គឺ ជាអ្នកចេញពីនិរោធក្នុងថ្ងៃនោះ ដូច្នេះ ។

ចប់អដ្ឋកថា ទក្ខិណាវិភង្គសូត្រទី ១២

## ចប់វិភង្គវគ្គ វគ្គទី ៤

## ក្នុងវគ្គនេះរួមមាន ១២ សូត្រ


១-ភទ្ទេករត្តសូត្រ
២-អានន្ទភទ្ទេករត្តសូត្រ
៣-មហាកច្ចានភទ្ទេករត្តសូត្រ
៤-លោមសង្គិយសូត្រ
៥-ចូឡកម្មវិភង្គសូត្រ
៦-មហាកម្មវិភង្គសូត្រ
៧-សឡាយតនវិភង្គសូត្រ
៨-ឧទ្ទេសវិភង្គសូត្រ
៩-អរណវិភង្គសូត្រ
១០-ធាតុវិភង្គសូត្រ
១១-សច្ចវិភង្គសូត្រ
១២-ទក្ខិណាវិភង្គសូត្រ

# សឡាយតនវគ្គ

## អ ដ្ឋ ក ថា

## អនាថបិណ្ឌិកោវាទសូត្រទី ១

**[១៩៥]** *អនាថបិណ្ឌិកោវាទសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

*ក្នុងបទទាំងនោះ ពាក្យថា* **មានជម្ងឺធ្ងន់** *គឺ ឈឺហួសប្រមាណ ដរាបដល់ការដេករង់ចាំសេចក្ដីស្លាប់ ។ ពាក្យថា* **ហៅរកហើយ** *គឺ បានព្រួមកថា ដរាបណាដែលជើងរបស់គហបតីនៅនាំទៅបាន ដរាបនោះ គហបតីក៏បានធ្វើការទំនុកបម្រុងព្រះពុទ្ធមួយថ្ងៃមួយដង ពីរដង ឬបីដងមិនដាច់ និងលោកទំនុកបម្រុងព្រះសាស្ដាប៉ុនណា ក៏ទំនុកបម្រុងពួកព្រះមហាថេរៈប៉ុណ្ណោះដូចគ្នា ថ្ងៃនេះ លោកចូលដល់ការដេកដែលមិនមានការក្រោកឡើងទៀត ព្រោះជើងដើរមិនបាន ចង់បញ្ជូនដំណឹងទៅ ទើបហៅរកបុរសអ្នកបម្រើម្នាក់មក ។ ពាក្យថា* **លុះចូលទៅហើយ** *គឺ គ្រាទូលលាព្រះមានព្រះភាគហើយ ក៏ចូលទៅរក (ព្រះសារីបុត្ត) ក្នុងវេលាព្រះអាទិត្យលិច ។*

**[១៩៧]** ពាក្យថា *ស្រាកស្រាន្ត* គឺ ធូរស្រាលចុះ ។ ពាក្យថា **ធ្ងន់ឡើង** គឺ ចម្រើនក្រៃលែង បានដល់ ខ្លាំងឡើង គឺ ជាវេទនាដ៏ខ្លាំងក្លា ។ ពាក្យថា **មានតែសេចក្ដីចម្រើនឡើងប្រាកដ មិនមានការធូរថយចុះ** គឺ ក្នុងសម័យដែលកើតវេទនា ដែលមានសេចក្ដីស្លាប់ជាទីបំផុតឡើងមកនោះ ដូចខ្យល់បក់ភ្លើងដែលឆេះសន្ធោសន្ធៅរហូតអស់វេលាដែលចំហាយក្ដៅមិនទាន់រលត់ ទោះជាញ៉ាំងព្យាយាមជំកម្រិតណា ក៏មិនអាចធ្វើឲ្យវេទនានោះរម្ងាប់ទៅបាន តែនឹងរម្ងាប់ទៅបាន ក៏ទាល់តែកំដៅរលត់ទៅហើយ ។ ពេលនោះ ព្រះសារីបុត្រគិតថា វេទនារបស់មហាសេដ្ឋី ជាប្រភេទនាវេទនាមានសេចក្ដីស្លាប់ជាទីបំផុត មិនមានអ្នកណាអាចហាមបាន ពាក្យដ៏សេសញ៉ាំងប្រយោជន៍មិនបាន យើងនឹងពោលធម្មកថាដល់មហាសេដ្ឋីនោះ ។

**[២០២]** ឯការពោលធម្មកថានោះ ចំពោះគហបតីនោះ ទើបពោលឡើងថា **ព្រោះហេតុនោះ ក្នុងករណីនេះ** ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ព្រោះដូច្នោះ** គឺ ដែលឈ្មោះថា អ្នកដែលកាន់យកចក្ខុ ដោយការកាន់យកទាំងបីយ៉ាង អាចការពារវេទនាដែលមានសេចក្ដីស្លាប់ជាទីបំផុត ដែលកើតឡើងហើយមិនមាន ។ ពាក្យថា **នឹងមិនប្រកាន់មាំក្នុងចក្ខុ** គឺ នឹងមិនប្រកាន់ចក្ខុ ដោយការប្រកាន់ទាំង

បីយ៉ាង ។ ពាក្យថា **និងសេចក្ដីដឹងច្បាស់ដែលអាស្រ័យចក្ខុរបស់យើង ក៏មិនមាន** គឺ និងសេចក្ដីដឹងច្បាស់ដែលអាស្រ័យចក្ខុរបស់យើងក៏នឹងមិនមាន ។

**[២០៣]** ក្នុងអាយតនៈរូប លោកបានសម្ដែងក្នុងខាងក្រោយហើយថា **រូប ក៏មិនមាន** ។ ក្នុងទីនេះ កាលនឹងសម្ដែងសុញ្ញរូបក្នុងកាមភពទាំងអស់ លោកទើបពោលយ៉ាងនេះ ។

**[២១០]** ពាក្យថា **លោកនេះក៏មិនមាន** សេចក្ដីថា មិនថានឹងជាទីនៅអាស្រ័យ ឬអាហារការបរិភោគរហូតដល់គ្រឿងស្លៀកដណ្ដប់ ខ្ញុំមិនប្រកាន់ទាំងអស់ ។ ក៏ឯពាក្យនេះ លោកសម្ដែងដើម្បីការមិនមានសេចក្ដីតក់ស្លុតក្នុងបច្ច័យទាំងឡាយ ។ ចំណែកក្នុងពាក្យថា **លោកខាងមុខក៏មិនមាននេះ** សំដៅសេចក្ដីថា វៀរមនុស្សលោកចេញហើយ ដ៏សេស ឈ្មោះថា លោកខាងមុខ ឬលោកដទៃ ពាក្យនេះ លោកពោលដើម្បីការលះបង់សេចក្ដីតក់ស្លុតនេះថា យើងកាលកើតក្នុងទេវលោកឯណោះហើយ នឹងកើតក្នុងឋានៈឈ្មោះឯណោះ យើងនឹងទំពារ នឹងបរិភោគ នឹងស្លៀក នឹងដណ្ដប់វត្ថុឈ្មោះនេះ ។ ព្រះថេរៈដោះចេញអំពីសេចក្ដីប្រកាន់ទាំង ៣ យ៉ាងនេះថា សុញ្ញវត្ថុនោះ ខ្ញុំក៏នឹងមិនប្រកាន់ និងសេចក្ដីដឹងច្បាស់ដែលអាស្រ័យនោះ ក៏នឹងមិនមានដល់ខ្ញុំផង ហើយ

ទើបបញ្ចប់ធម្មទេសនាឲ្យដល់កំពូល គឺ ព្រះអរហត្ត ។

**[២១២]** ពាក្យថា **លិចចុះ** គឺ លោកបានឃើញសម្បត្តិរបស់ខ្លួនហើយ រមែងកើត រមែងលិចជោគជាំក្នុងអារម្មណ៍ទាំងឡាយ ។ កាលព្រះអានន្ទពោលថា ដូចដែលពោលមកនេះហើយ ក៏សម្គាល់ថា ដូចគហបតីនេះ ដែលមានសេចក្តីជឿ សេចក្តីជ្រះថ្លាយ៉ាងនេះ នៅខ្លាចស្លាប់ហើយ អ្នកដទៃអ្នកណាហ្ន៎ នឹងមិនខ្លាច កាលនឹងធ្វើឲ្យចិត្តតម្កល់មាំ ហើយឲ្យឱវាទដល់គហបតីនោះ ទើបបានពោលយ៉ាងនេះ ។ ពាក្យថា **ធម្មកថាមានសភាពដូច្នេះ** ខ្ញុំមិនដែលធ្លាប់បានស្តាប់ឡើយ គឺ ឧបាសកនេះពោលថា ធម្មកថាបែបនេះ សូម្បីក្នុងសម្នាក់ព្រះសាស្តា ខ្ញុំក៏មិនធ្លាប់បានស្តាប់ឡើយ ។ សួរថា ព្រះសាស្តាទ្រង់មិនសម្តែងពាក្យដែលល្អិតល្អន់ជ្រាលជ្រៅបែបនេះឬ ។

ឆ្លើយថា ទ្រង់មិនសម្តែងក៏ទេ ។ តែថា ពាក្យដែលទ្រង់សម្តែងដល់អាយតនៈខាងក្នុង ៦ អាយតនៈខាងក្រៅ ៦ ពួកវិញ្ញាណ ៦ ពួកផស្សៈ ៦ ពួកវេទនា ៦ ធាតុ ៦ ខន្ធ ៥ អរូប ៤ លោកនេះ និងលោកខាងមុខ ហើយត្រាស់ដាក់ទុកឲ្យដល់ភាពជាព្រះអរហន្ត ដោយអំណាចរូបដែលភ្នែកបានឃើញហើយ សំឡេងដែលត្រចៀកបានឮហើយ ក្លិន រស ផោដ្ឋព្វៈដែល ប្រមុះ អណ្តាត

កាយបានជ្រាបហើយ និងធម្មារម្មណ៍ដែលចិត្តបានដឹងច្បាស់ហើយ គហបតីនេះ មិនធ្លាប់បានស្តាប់ ។ ព្រោះដូច្នោះ ទើបពោលយ៉ាងនោះ ។

ម្យ៉ាងទៀត ឧបាសកនេះ ត្រេកអរក្រៃលែងក្នុងទាន កាលនឹងទៅសម្នាក់ព្រះពុទ្ធ ទើបមិនធ្លាប់ទៅដៃទទេ កាលនឹងទៅក្នុងវេលាមុនឆាន់ ក៏ឲ្យមនុស្សយកបបរ និងរបស់ទំពារស៊ីជាដើមហើយទើបទៅ កាលនឹងទៅក្នុងវេលាក្រោយឆាន់ហើយ ក៏ឲ្យយកទឹកដោះថ្លា ទឹកឃ្មុំ និងទឹកអំពៅជាដើមហើយទើបទៅ កាលមិនមានវត្ថុនោះ ក៏ឲ្យរែកខ្សាច់យកទៅចាក់រោយក្នុងបរិវេណព្រះគន្ធកុដិ កាលឲ្យទាន រក្សាសីលស្រេចហើយ ទើបត្រឡប់ទៅកាន់ផ្ទះ ។ បានឮមកថា ឧបាសកនេះ មានគតិបែបពោធិសត្វ ដូច្នោះ រហូតអស់វេលា ២៤ ឆ្នាំ ដោយច្រើនព្រះមានព្រះភាគ ត្រាស់តែទានកថាប៉ុណ្ណោះ ដល់ឧបាសកថា ឧបាសកធម្មតាថា ទាននេះជាផ្លូវដំណើររបស់ពួកពោធិសត្វ ជាផ្លូវដំណើររបស់តថាគតផង តថាគតបានឲ្យទានមកវេលា ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប អ្នកក៏ឈ្មោះថា ដើរតាមផ្លូវដែលតថាគតបានដើរមកហើយដោយពិត ។ សូម្បីព្រះមហាសាវក មានព្រះធម្មសេនាបតីជាដើម ។ ក្នុងវេលាដែលឧបាសកមកកាន់សម្នាក់របស់លោកៗ ក៏សម្តែងតែទានកថាដល់គាត់ដូចគ្នា ព្រោះហេតុនោះ

ឯង លោកទើបពោលថា គហបតី ធម្មកថាបែបនេះ រមែងមិនប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀកដណ្តប់សឡើយ ។ មានពាក្យដែលលោកអធិប្បាយទុកយ៉ាងនេះថា គហបតី សម្រាប់ពួកគ្រហស្ថមានសេចក្តីជាប់ជំពាក់ទាក់ទិនយ៉ាងស្អិតតែក្នុងស្រែ ចំការ ប្រាក់ មាស អ្នកបម្រើស្រី ប្រុស បុត្រ និងភរិយាជាដើម មានតែសេចក្តីពេញចិត្ត និងសេចក្តីអាល័យយ៉ាងខ្លាំង ពាក្យថា **កុំធ្វើសេចក្តីអាល័យជាប់ចិត្តក្នុងវត្ថុទាំងនេះ** កុំទៅធ្វើសេចក្តីពេញចិត្ត ដូច្នេះ ទើបមិនប្រាកដ គឺ រមែងមិនពេញចិត្តក្នុងគ្រហស្ថទាំងនោះ ដោយប្រការដូច្នេះ ។

**[២១៣]** ពាក្យថា ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ សេចក្តីថា ហេតុដូចម្តេចទើបចូលទៅគាល់ ។ បានឮមកថា ពេលគហបតីនោះ កើតក្នុងជាន់តុសិតប៉ុណ្ណោះ ក៏ឃើញអត្តភាពប្រមាណបីគាវុត រុងរឿងដូចគំនរមាស និងសម្បត្តិ មានឧទ្យាន និងវិមានជាដើម ទើបពិចារណាមើលថា សម្បត្តិរបស់យើងនេះក្រៃលែងអស្ចារ្យ យើងបានធ្វើអ្វីទុកក្នុងឋានមនុស្សហ្ន៎ ឃើញការធ្វើយ៉ាងក្រៃលែងក្នុងព្រះត្រៃរតន៍ ទើបគិតថា ភាពជាទេវតានេះ ជាទីតាំងនៃសេចក្តីប្រមាទ ព្រោះថា កាលយើងរស់នៅក្នុងសម្បត្តិនេះ ក៏នឹងត្រូវមានសេចក្តីវង្វេងភ្លេចសតិខ្លះក៏បាន ណ្ហើយចុះយើង នឹងទៅពោលសរសើរវត្តជេតពនរបស់

យើង ព្រះភិក្ខុសង្ឃ ព្រះតថាគត អរិយសាវក និងព្រះសារីបុត្តត្ថេរ បន្ទាប់ពីនោះហើយ ទើបយើងសោយសម្បត្តិ ។ ទេវបុត្រនោះ ទើបបានធ្វើយ៉ាងនោះ ។ ដើម្បីសម្តែងសេចក្តីនោះ លោកទើបពោលពាក្យថា **គ្រានោះឯងអនាថបិណ្ឌិកៈ** ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដែលពួកឥសីនៅអាស្រ័យជានិច្ច** បានដល់ ដែលពួកភិក្ខុអាស្រ័យហើយ ។

កាលពោលសរសើរវត្តជេតពនដោយគាថាដំបូងយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងពោលសរសើរអរិយមគ្គ ទើបបានពោលពាក្យថា **កម្ម និងវិជ្ជា** ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **កម្ម** បានដល់ មគ្គចេតនា ។ ពាក្យថា **វិជ្ជា** បានដល់ មគ្គប្បញ្ញា ។ ពាក្យថា **ធម៌** បានដល់ ធម៌ដែលជាចំណែកនៃសមាធិ ។ លោកសម្តែងថា ជីវិតរបស់អ្នកតាំងនៅក្នុងសីលថា **ជាជីវិតដ៏ឧត្តម** ដោយពាក្យថា **សីលំ ជីវិតមុត្តមំ** ។

មួយ៉ាងទៀត ការឃើញត្រូវ និងសេចក្តីត្រិះរិះ ឈ្មោះថា **វិជ្ជា** ។ សេចក្តីព្យាយាម សេចក្តីរលឹក និងសេចក្តីតាំងចិត្តមាំ ឈ្មោះថា **ធម៌** ។ ការនិយាយការងារ និងការចិញ្ចឹមជីវិត ឈ្មោះថា **សីល** ។ ជីវិតរបស់អ្នកតាំងនៅក្នុងសីលនេះ ជាជីវិតដ៏ខ្ពស់បំផុត ឈ្មោះថា **ជីវិតឧត្តម** ។ ពាក្យថា **ពួកសត្វ**

រមែងបរិសុទ្ធិដោយវត្ថុនេះ គឺ ពួកសត្វ រមែងបរិសុទ្ធិដោយមគ្គ ដែលប្រកប ដោយអង្គ ៨ នេះ ។

ពាក្យថា **ព្រោះហេតុនោះ** គឺ ព្រោះហេតុដែលបរិសុទ្ធិដោយមគ្គ មិនមែនព្រោះដោយគោត្រ ឬទ្រព្យ ។ បាទគាថាថា **គប្បីពិចារណាធម៌ដោយឧបាយនៃប្រាជ្ញា** គឺ គប្បីពិចារណាធម៌ដែលជាផ្នែកនៃសមាធិយ៉ាងល្អិតល្អន់ ។ បាទគាថាថា **យ៉ាងនេះ ទើបនឹងបរិសុទ្ធិក្នុងធម៌នោះ** គឺ ដោយលក្ខណៈដូច្នេះ ទើបនឹងបរិសុទ្ធិក្នុងអរិយមគ្គនោះ ។ម្យ៉ាងទៀត បាទគាថាថា **គប្បីពិចារណាធម៌ដោយឧបាយនៃប្រាជ្ញា** គឺ គប្បីពិចារណាធម៌ គឺ ខន្ធ ៥ យ៉ាងល្អិតល្អន់ ។ បាទគាថាថា **យ៉ាងនេះ ទើបនឹងបរិសុទ្ធិក្នុងធម៌នោះ** គឺ យ៉ាងនេះទើបបរិសុទ្ធិក្នុងសច្ចៈទាំង ៤ ប្រការនោះ ។

ឥឡូវនេះ អនាថបិណ្ឌិកទេវបុត្រ កាលនឹងពោលសរសើរព្រះសារីបុត្តត្ថេរ ទើបបានពោលថា **ព្រះសារីបុត្រនុ៎ះឯងជាដើម** ។ ក្នុងបទទាំងនោះ ពាក្យថា **ព្រះសារីបុត្រនុ៎ះឯង** ជាពាក្យអវធារណៈ (ហាមសេចក្តីដទៃ) អនាថបិណ្ឌិកទេវបុត្រ រមែងពោលថា ព្រះសារីបុត្រប៉ុណ្ណោះ ជាអ្នកកំពូលលើសដោយបញ្ញាជាដើមនេះឯង ។ ពាក្យថា **ដោយសេចក្តីស្ងប់រម្ងាប់** គឺ ដោយការ

ចូលទៅស្ងប់កិលេស ។ ពាក្យថា **ដល់ត្រើយ** គឺ ដល់ព្រះនិព្វាន ។ អនាថ-បិណ្ឌិកទេវបុត្រ រមែងពោលថា ភិក្ខុណាមួយសម្រេចព្រះនិព្វាន ភិក្ខុនោះយ៉ាងច្រើនក៏ត្រឹមតែប៉ុណ្ណោះ មិនមានអ្នកណាដែលប្រសើរហួសពីព្រះថេរៈទៅបាន ។ ដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា អនាថបិណ្ឌិកោវាទសូត្រ ទី ១

# អ ដ្ឋ ក ថា

## ឆន្នោវាទសូត្រទី ២

[២១៦] ឆន្នោវាទសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖

ក្នុងពាក្យទាំងនោះ ពាក្យថា **ឆន្នោ** បានដល់ ព្រះថេរៈមានឈ្មោះយ៉ាងនោះ មិនមែនជាព្រះថេរៈដែលចេញទៅជាមួយនឹងព្រះពោធិសត្វ ពេលចេញអភិនេស្រ្កមណ៍ ។

[២១៧] ពាក្យថា **ចេញចាកទីពួនសម្ងំ** គឺ ចេញពីផលសមាបត្តិ ។ ពាក្យថា **បានសួរដល់ជម្ងឺ** បានដល់ ការទំនុកបម្រុងភិក្ខុឈឺ ដែលព្រះពុទ្ធទ្រង់សរសើរ ទ្រង់ពណ៌នាទុក ព្រោះដូច្នោះ លោកទើបពោលយ៉ាងនោះ ។

[២២១] ពាក្យថា **សស្រ្តា** បានដល់ សស្រ្តាដែលសម្រាប់ប្រហារជីវិត ។ ពាក្យថា **មិនប្រាថ្នា** គឺ មិនចង់ ។

[២២៣] ពាក្យថា **មិនចូលទៅដល់** គឺ មិនកើត មិនមានបដិសន្ធិ ។

[២២៤] ពាក្យថា **នោះរបស់យើងជាដើម** លោកពោលទុកដោយអំណាច

សេចក្តីប្រកាន់ដោយតណ្ហា មានះ និងទិដ្ឋិ ។

[២២៥] ពាក្យថា **ឃើញការរលត់** គឺ ដឹងការអស់ទៅ និងការសាបសូន្យទៅ ។ ពាក្យថា **ខ្ញុំពិចារណាឃើញថា** នោះមិនមែនរបស់យើង នោះមិនមែនជាយើង នោះមិនមែនខ្លួនរបស់យើង គឺ ខ្ញុំពិចារណាឃើញថា មិនទៀងជាទុក្ខ មិនមែនតួខ្លួន ។

[២២៦] ពាក្យថា **ព្រោះហេតុនោះ** គឺ ព្រោះហេតុដែលព្រះថេរៈពោលថា កាលខ្ញុំអត់ទ្រាំចំពោះវេទនាដែលមានសេចក្តីស្លាប់ជាទីបំផុតមិនបាន ទើបបាននាំយកសស្ត្រានោះមក លោកជាបុថុជ្ជន ទើបបង្ហាញថា ព្រោះដូច្នោះ លោកចូរធ្វើទុកក្នុងចិត្តសូម្បីសេចក្តីនេះ ។ ពាក្យថា **រហូតអស់កាលជាប់ជានិច្ច** គឺ និច្ចកាល ។ ពាក្យថា **ដែលអាស្រ័យហើយ** គឺ តណ្ហា និងទិដ្ឋិអាស្រ័យហើយ ។ ពាក្យថា **ញាប់ញ័រ** បានដល់ ជារបស់អន្ទះសារ ។ ពាក្យថា **សេចក្តីស្ងប់** គឺ សេចក្តីស្ងប់កាយស្ងប់ចិត្ត អធិប្បាយថា សូម្បីការស្ងប់កិលេសក៏រមែងគួរ ។ ពាក្យថា **នតិ** បានដល់ តណ្ហា ។ ពាក្យថា **នតិយា អសតិ** គឺ កាលមិនមានសេចក្តីអាល័យ ព្រោះសេចក្តីអាល័យប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ភព ។ ពាក្យថា **មិនមានការមក និងការទៅ** គឺ ឈ្មោះថា ការមកដោយ

អំណាចបដិសន្ធិ រមែងមិនមាន ឈ្មោះថា ការទៅដោយអំណាចចុតិ ក៏រមែង មិនមាន ។ ពាក្យថា **ចុតិ និងឧប្បត្តិ** គឺ ឈ្មោះថា ចុតិដោយអំណាចការឃ្លាត ឈ្មោះថា ឧប្បត្តិ ដោយអំណាចការកើតឡើង ។ ពាក្យថា **មិនមានក្នុងលោក នេះ មិនមានក្នុងលោកមុខ មិនមានក្នុងចន្លោះលោកទាំងពីរ** គឺ ក្នុងលោកនេះ ក៏មិនមាន ក្នុងលោកមុខក៏មិនមាន ក្នុងលោកទាំងពីរក៏មិនមាន ។ ពាក្យថា **នេះជាទីបំផុតរបស់ទុក្ខ** គឺ នេះប៉ុណ្ណោះជាទីបំផុតរបស់វដ្តទុក្ខ និងកិលេសទុក្ខ នេះជាការកំណត់ដោយជុំវិញ ជាផ្លូវដោយជុំវិញ ។ ព្រោះនេះប៉ុណ្ណោះ ជា សេចក្តីបំណងក្នុងសេចក្តីនេះ ។ សម្រាប់លោកអ្នកណាកាន់យកពាក្យថា មិន មានដោយចន្លោះលោកទាំងពីរ ហើយត្រូវការចន្លោះភព ពាក្យដែលក្រែលែង ទៅសម្រាប់លោកទាំងនោះ ក៏ពោលក្នុងខាងក្រោយហើយនោះឯង ។

**[២២៧]** ពាក្យថា **នាំសស្ត្រាមកហើយ** គឺ យកសស្ត្រាសម្រាប់ផ្តាច់ ជីវិតមកហើយ កាត់បំពង់កហើយ ។

ក៏ខណៈនោះ សេចក្តីខ្លាចស្លាប់របស់លោកក៏ឈានចុះ គតិនិមិត្តប្រាកដ ឡើង ។ លោកដឹងខ្លួនថានៅជាបុថុជ្ជន កើតការតក់ស្លុត តាំងវិបស្សនា ពិចា- រណាសង្ខារ សម្រេចជាព្រះអរហន្ត ជាសមសីសី ហើយក៏បរិនិព្វាន ។ ពាក្យ

ថា **ទ្រង់ព្យាករណ៍ការមិនកើតចំពោះមុខនោះឯង** គឺ សូម្បីថា ការព្យាករណ៍នេះ មានក្នុងវេលាដែលព្រះថេរៈនៅជាបុថុជ្ជនក៏ពិត សូម្បីយ៉ាងនោះ ការបរិនិព្វានដែលមិនមានអ្វីមកជ្រៀតបានរបស់លោក ក៏បានមានតាមពាក្យព្យាករណ៍នេះ ។ ហេតុនោះ ព្រះមានព្រះភាគ ទ្រង់ទើបកាន់យកពាក្យព្យាករណ៍នោះឯងមកត្រាស់ ។ ពាក្យថា **ត្រកូលដែលគប្បីចូលទៅ** គឺ ត្រកូលដែលគួរចូលទៅ ដោយពាក្យថា ត្រកូលដែលគប្បីចូលទៅនេះ ព្រះថេរៈ រមែងទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន កាលនៅមានពួកឧបដ្ឋាក និងពួកឧបដ្ឋាយិកា នៅយ៉ាងនេះ ភិក្ខុនោះ នឹងបរិនិព្វានក្នុងព្រះសាសនារបស់ព្រះអង្គឬ ។

**[២២៨]** គ្រានោះ កាលព្រះមានព្រះភាគទ្រង់នឹងសម្តែងដល់ភិក្ខុនោះមិនមានការប្រេបួកប្រេបល់ក្នុងត្រកូលទាំងឡាយ ទើបត្រាស់ពាក្យថា **សារីបុត្រ សេចក្តីនេះរមែងមាន** ដូច្នេះជាដើម ។ បានឮមកថា ក្នុងឋានៈនេះ ការមិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយរបស់ព្រះថេរៈ បានកើតប្រាកដហើយ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា ឆន្នោវាទសូត្រទី ២

# អ ដ្ឋ ក ថា

## បុណ្ណោវាទសូត្រទី ៣

**[២២៩]** បុណ្ណោវាទសូត្រ មានបទផ្ដើមឡើងថា ឯវម្មេ សុតំ ខ្ញុំបាន ស្ដាប់មកហើយយ៉ាងនេះ ៖

ក្នុងព្រះសូត្រនោះ សេចក្ដីថា **ការនៅអ្នកតែម្នាក់ឯង** ឈ្មោះថា ការពួនសម្ងំ ។

**[២៣០]** ពាក្យថា **ប្រសិនបើថា នោះ** បានដល់ ភ្នែក និងរូបនោះ ។ ពាក្យថា **ព្រោះសេចក្ដីត្រេកត្រអាលកើតឡើង ទុក្ខទើបកើតឡើង** គឺ ការរួមយកទុក្ខក្នុងខន្ធ ៥ រមែងមានដោយការរួមយកសេចក្ដីត្រេកត្រអាល ដែលបានដល់តណ្ហាមកជាមួយផង ។ ដោយប្រការដូច្នេះ ក៏គឺ ទ្រង់ធ្វើឲ្យវដ្ដៈដល់ទីបំផុតដោយអំណាចនៃសច្ចៈទាំង ២ គឺ ទុក្ខ ហេតុឲ្យកើតទុក្ខ ក្នុងទ្វារទាំង ៦ ហើយទើបទ្រង់សម្ដែង ។

**[២៣១]** ក្នុងន័យទី ២ ទ្រង់ធ្វើវិវដ្ដៈឲ្យដល់ទីបំផុតដោយអំណាចសច្ចៈ ២ ប្រការ គឺ និរោធ និងមគ្គ ហើយទើបទ្រង់សម្ដែង ។ អនុសន្ធិដែលចែកទុក

ដោយចំពោះ គឺ ពាក្យថា **និងដោយអាការយ៉ាងនេះ បុណ្ណៈ** ។ លុះទ្រង់ដាក់ទេសនាដោយអំណាចវដ្តៈ និងវិវដ្តៈក្នុងព្រះអរហត្តយ៉ាងនេះមុនហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ឲ្យព្រះបុណ្ណត្ថេរបន្លឺសីហនាទក្នុងឋានទាំង ៧ ទើបបានត្រាស់ពាក្យថា **និងដោយអាការយ៉ាងនេះ** ដូច្នេះជាដើម ។

**[២៣២]** ពាក្យថា **កាច** គឺ ប្រទូសរ៉ាយ កាចសាហាវ ។ ពាក្យថា **រឹងរូស** គឺ កាចយង់ឃ្នង ។ ពាក្យថា **រមែងជេរ** គឺ រមែងជេរដោយរឿងសម្រាប់ជេរ ១០ យ៉ាង ។ ពាក្យថា **រមែងគម្រាម** គឺ រមែងគម្រាមកំហែងថា លោកជាសមណៈបានយ៉ាងណា យើងនឹងរករឿងលោក យ៉ាងនេះ និងយ៉ាងនេះ ។ ពាក្យថា **យ៉ាងនេះ ក្នុងករណីនេះ** គឺ វត្ថុយ៉ាងនេះ ក្នុងករណីនេះ នឹងមានដល់ខ្ញុំព្រះករុណា ។

**[២៣៤]** ពាក្យថា **ដោយដំបងព្រនង់** គឺ ដោយដំបងព្រនង់ប្រវែង ៤ ហត្ថ និងដោយកំណាត់ឈើ ។

**[២៣៥]** ពាក្យថា **ដោយសស្ត្រា** គឺ ដោយអាវុធដែលមានមុខតែម្ខាងជាដើម ។

**[២៣៧]** ពាក្យថា **តែងស្វែងរកនូវគ្រឿងសស្ត្រាជាគ្រឿងកម្ចាត់បង់នូវ**

ជីវិត គឺ ស្វែងរកសស្ត្រាគ្រឿងផ្តាច់បង់នូវជីវិត ។ សេចក្តីនេះ ព្រះថេរៈពោលសំដៅដល់ពួកភិក្ខុដែលស្តាប់រឿងក្នុងអសុភកថា ក្នុងវត្ថុនៃបារាជិកត្រង់សិក្ខាបទទី ៣ កើតសេចក្តីរង្កៀសក្នុងរាងកាយ ហើយស្វែងរកគ្រឿងផ្តាច់បង់នូវជីវិត គឺ សស្ត្រា ។

**[២៣៨]** ពាក្យថា **ទូន្មានចិត្ត** ក្នុងពាក្យថា ការទូន្មានចិត្ត និងការរម្ងាប់ចិត្តនេះ ជាឈ្មោះនៃការសង្រួមឥន្ទ្រិយជាដើម ។ ពិតហើយ ការសង្រួមឥន្ទ្រិយ ក្នុងពាក្យថា ទូន្មានហើយដោយសច្ចៈ ចូលដល់ការទូន្មានចិត្តដល់ទីបំផុតនៃវេទ ជាអ្នកសម្រេចនូវព្រហ្មចរិយហើយ នេះ លោកពោលថា ជាការទូន្មានចិត្ត ។ បញ្ញាក្នុងពាក្យថា **បើនៅមានអ្វីដ៏ក្រៃលែងជាងសច្ចៈ ចាគៈ ខន្តិក្នុងករណីនេះ** នេះ លោកពោលថា ជាការទូន្មានចិត្ត ។ ឧបោសថកម្ម ពាក្យថា **ដោយទាន ដោយសញ្ញមៈ ដោយការពោលពាក្យពិត** នេះ លោកពោលថា ជាការទូន្មានចិត្ត ។ តែក្នុងព្រះសូត្រនេះ គប្បីជ្រាបថា សេចក្តីអត់ធន់ គឺ ការទូន្មានចិត្ត ។ ពាក្យថា **ការចូលទៅរម្ងាប់ចិត្ត** ជាពាក្យប្រើជំនួសពាក្យថា ការទូន្មានចិត្តនោះឯង ។

ពាក្យថា **គ្រានោះឯង ព្រះបុណ្ណៈមានអាយុ** សេចក្តីថា ចង់ដឹងថា ក៏

ព្រះបុណ្ណៈនេះជាអ្នកណា និងហេតុដូចម្ដេចទើបប្រាថ្នាទៅកាន់ទីនោះ ។ ភិក្ខុរូបនេះ ក៏គឺ អ្នកស្រុកសុនាបរន្តៈនុ៎ះឯង ។ ក៏លោកកំណត់ថា ក្នុងក្រុងសាវត្ថីនៅមិនសប្បាយ ទើបប្រាថ្នានឹងទៅស្រុកសុនាបរន្តៈនោះ ។ តទៅនេះជាលំដាប់ពាក្យក្នុងរឿងនោះ ។

បានឮមកថា ក្នុងដែនសុនាបរន្តៈ មានបងប្អូនពីរនាក់ក្នុងពួកឈ្មួញមួយកន្លែង ក្នុងពីរបងប្អូននោះ ពេលខ្លះបងប្រុសក៏នាំរទេះ ៥០០ ទៅជនបទ ហើយក៏ផ្ទុកទំនិញមក ។ ពេលខ្លះក៏ប្អូនប្រុស ។ ចំណែកក្នុងពេលនេះ បងប្រុសឲ្យប្អូនប្រុសនៅចាំស្រុក ហើយខ្លួនឯងក៏នាំយករទេះ ៥០០ ត្រាច់ទៅកាន់ក្រុងមកដល់ក្រុងសាវត្ថីដោយលំដាប់ សម្រាកពួករទេះនៅជិតៗ វត្តជេតពន បរិភោគអាហារពេលព្រឹកហើយ ព្រមជាមួយអ្នកទៅជាមួយគ្នាអង្គុយជួបជុំ សម្រាកតាមសប្បាយ ។

ឯសម័យនោះ អ្នកក្រុងសាវត្ថីបរិភោគអាហារពេលព្រឹកហើយ អធិដ្ឋានអង្គឧបោសថ ស្លៀកដណ្ដប់សំពត់ កាន់គ្រឿងក្រអូប និងផ្កាឈើជាដើម បង្អោនចូលទៅបូជាកន្លែងដែលមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គង់នៅ ហើយនាំគ្នាចេញទៅតាមទិសខាងត្បូងទៅកាន់វត្តជេតពន ។ កាលគេឃើញអ្នកទាំងនោះ

ទើបសួរបុរសម្នាក់ថា តើមនុស្សទាំងនេះទៅណា ។ នែ! លោកមិនដឹងអ្វីទេ ឬ កែវ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតឡើងហើយក្នុងលោក ព្រោះហេតុនេះ មហាជននេះ ទើបនាំគ្នាទៅស្តាប់ធម្មកថាក្នុងសម្នាក់របស់ព្រះសាស្តា ។ ពាក្យថា ព្រះពុទ្ធ របស់បុរសនោះ ទម្លាយសម្បុរស្បែកជាដើម ចូលទៅទល់នឹងខួរឆ្អឹងតាំងនៅ ។ តមក គេបាននាំបរិវាររបស់ខ្លួនទៅកាន់វិហារជាមួយបរិស័ទនោះ គេឈរចុងបំផុតនៃបរិស័ទស្តាប់ធម៌របស់ព្រះសាស្តា ដែលកំពុងសម្តែងធម៌ដោយព្រះសូរសេងដ៏ពីរោះ ហើយកើតសេចក្តីប្រាថ្នានឹងបួស ។ កាលបរិស័ទដែលព្រះតថាគតទ្រង់ជ្រាបវេលាហើយ និងទ្រង់បញ្ជូនទៅហើយ គេក៏ចូលគាល់ព្រះសាស្តា ថ្វាយបង្គំ ហើយទូលអារាធនាព្រះអង្គដើម្បីសោយព្រះក្រយាហារក្នុងថ្ងៃស្អែក ក្នុងថ្ងៃទីពីរ គេឲ្យសាងបារាំ និងរៀបចំអាសនៈថ្វាយមហាទានចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ក្នុងទីបំផុតនៃភត្តកិច្ច ព្រះមានព្រះភាគទ្រង់អនុមោទនា ស្តេចត្រឡប់ គេក៏ទទួលទានអាហារព្រឹក ហើយអធិដ្ឋានអង្គឧបោសថ ហើយឲ្យហៅប្រធានគ្រប់គ្រងរបស់គេមក ប្រាប់វត្ថុគ្រប់យ៉ាងថា របស់ប៉ុណ្ណេះបានចំណាយទៅហើយ បានប្រគល់វត្ថុគ្រប់យ៉ាងថា ចូរឲ្យសម្បត្តិនេះដល់ប្អូនប្រុសខ្ញុំ ហើយក៏បួសក្នុងសម្នាក់ព្រះសាស្តា ផ្តើមចម្រើន

កម្មដ្ឋាន ។ គ្រានោះ កាលលោកមនសិការដល់កម្មដ្ឋាន កម្មដ្ឋានក៏មិនប្រាកដ ។

តមកលោកទើបគិតថា ជនបទនេះមិនសប្បាយដល់យើង យើងត្រូវទទួលកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ទៅកាន់ស្រុកដើមរបស់យើង ទើបកាលលោកត្រាច់បិណ្ឌបាតក្នុងពេលព្រឹក ហើយចេញចាកការពួនសម្ងំក្នុងពេលរសៀល ចូលគាល់ព្រះមានព្រះភាគ សូមឲ្យទ្រង់ប្រទានកម្មដ្ឋាន បានបន្លឺសីហនាទ ៧ យ៉ាង ហើយទើបចៀសទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះឯង ព្រះបុណ្ណៈ ។ល។ នៅ ដូច្នេះ ។

ក៏ព្រះបុណ្ណៈនេះ នៅទីណា ។ លោកនៅ ៤ កន្លែង ។ ពេលដំបូងលោកចូលកាន់ដែនសុនាបរន្តៈ ហើយចូលទៅកាន់អម្ពុដ្ឋបព៌ត ចូលទៅកាន់ស្រុកពួកឈ្មួញដើម្បីបិណ្ឌបាត ។ ក្នុងស្រុកនោះ ប្អូនប្រុសចំណាំលោកបានទើបថ្វាយអាហារ ហើយប្រាប់លោកថា លោកម្ចាស់ លោកមិនត្រូវទៅទីដទៃនិមន្តនៅទីនេះហើយ ឲ្យលោកទទួលពាក្យហើយ ក៏និមន្តឲ្យនៅក្នុងទីនោះឯង ។

តពីនោះ លោកបានទៅកាន់វត្តសមុទ្រគិរី ។ ក្នុងទីនោះ មានទីសម្រាប់ដើរចង្រ្កម ដែលគេកាត់យកផ្ទាំងថ្មដែលស៊ិកដែកទុកត្រង់ចុងមកធ្វើ ។ មិនមានអ្នកណាដើរជាន់ផ្ទាំងថ្មនោះបាន ។ ក្នុងទីនោះ រលកសមុទ្រមកប៉ះខ្ទប់នឹង

ផ្ទាំងថ្មដែលសឹកដែកត្រង់ចុង ឮសំឡេងខ្លាំងៗ ។ ព្រះថេរៈគិតថា នេះចូរជាទីនៅសប្បាយសម្រាប់អ្នកមនសិការដល់កម្មដ្ឋានចុះ ហើយក៏អធិដ្ឋានធ្វើឲ្យសមុទ្រស្ងប់សំឡេង ។

បន្ទាប់ពីនោះ លោកបានទៅកាន់មាតុលគិរី ។ ក្នុងទីនោះ មានពួកសត្វកុះករ មានសំឡេងគឹកកងទាំងយប់ទាំងថ្ងៃ ។ ព្រះថេរៈគិតថា ទីនេះមិនសប្បាយ តពីនោះក៏ទៅវត្តមកុឡការាម ។ វត្តនោះនៅមិនឆ្ងាយ មិនជិតស្រុករបស់ពួកឈ្មួញច្រើននាក់ ទៅមកសប្បាយ មិនមានសំឡេង ។ ព្រះថេរៈគិតថា ទីនេះសប្បាយ ទើបឲ្យសាងទីសម្រាកពេលយប់ និងពេលថ្ងៃ ព្រមទាំងទីចង្រ្កមជាដើម ហើយក៏ចូលវស្សាក្នុងទីនោះ ។ លោកនៅក្នុងទី ៤ កន្លែងដូចពោលមកនេះ ។

តមកទៀត ថ្ងៃមួយ ខាងក្នុងវស្សាទុំះឯង មានឈ្មួញ ៥០០ នាក់តាំងចិត្តថា ពួកយើងនឹងទៅសមុទ្រដទៃ ទើបយកទំនិញផ្ទុកក្នុងសំពៅ ក្នុងថ្ងៃចុះសំពៅ ប្អូនប្រុសរបស់ព្រះថេរៈទំនុកបម្រុងព្រះថេរៈហើយ ទទួលសិក្ខាបទក្នុងសម្នាក់ព្រះថេរៈ ថ្វាយបង្គំហើយ កាលនឹងទៅ បានប្រាប់លោកថា លោកម្ចាស់ ដែលឈ្មោះថា មហាសមុទ្រ មានអន្តរាយច្រើនណាស់ អាចធ្វើឲ្យវិនាស

នូវប្រយោជន៍បាន សូមឲ្យលោកម្ចាស់ជួយបំភ្លឺដល់ពួកខ្ញុំព្រះករុណាផង ហើយក៏ចុះសំពៅ ។ សំពៅក៏គ្រាច់ទៅយ៉ាងរហ័សរហូតដល់កោះមួយ ។ ពួកគេគិតថា ពួកយើងបរិភោគអាហារព្រឹកហើយចាំ នាំគ្នាឡើងកោះ ។ លើកោះនោះអ្វីៗ យ៉ាងដទៃមិនមានទេ មានតែព្រៃចន្ទន៍ទាំងនោះ ។ ពេលនោះបុរសម្នាក់យកកាំបិតចាំងដើមឈើ ក៏ដឹងថា ជាដើមចន្ទន៍ក្រហម ទើបពោលថា នេះនៃ៎ ពួកយើងទៅកាន់សមុទ្រដទៃដើម្បីប្រយោជន៍ដល់លាភ ដែលឈ្មោះថា លាភដ៏ក្រៃលែងជាងនេះមិនមានទៀតឡើយ កំណាត់ឈើប្រវែង ៤ ធ្នាប់ ក៏មានតម្លៃទាំងសែនហើយ យើងយកតែរបស់ដែលគួរយក ហើយក៏នាំគ្នាយកឈើចន្ទន៍-ក្រហមផ្ទុកពេញសំពៅ ។ ពួកគេក៏ធ្វើយ៉ាងនោះ ។ ពួកអមនុស្សដែលអាស្រ័យក្នុងព្រៃចន្ទន៍ក្រហមក៏ក្រោធ នាំគ្នាគិតថា មនុស្សទាំងនេះវាធ្វើព្រៃចន្ទន៍ក្រហមរបស់ពួកយើងឲ្យវិនាសហើយ ពួកយើងនឹងសម្លាប់ពួកវា ហើយនិយាយថា កាលពួកវាត្រូវសម្លាប់ក្នុងទីនេះ ព្រៃទាំងអស់ក៏នឹងក្លាយទៅជាព្រៃសាកសពដោយពិត ពួកយើងនឹងឲ្យសំពៅរបស់វាលិចកណ្ដាលសមុទ្រ ហើយតមកក្នុងវេលាដែលអ្នកទាំងនោះឡើងសំពៅ ហើយគ្រាច់ទៅបានតែមួយក្អែកប៉ុណ្ណោះ ក៏ធ្វើឲ្យកើតព្យុះយ៉ាងខ្លាំង ពួកអមនុស្សទាំងនោះឯង ក៏នាំគ្នាសម្ដែងរូបដែល

គួរឲ្យខ្លាចផ្សេងៗ ។ ពួកអ្នកសំពៅទាំងនោះខ្លាច នាំគ្នាសំពះទេវតារៀងៗខ្លួន ។ ចូឡបុណ្ណកុដុម្ពី ប្អូនប្រុសព្រះថេរៈគិតថា សូមឲ្យបងប្រុសរបស់ខ្ញុំចូរជាទីពឹងផងចុះ ហើយក៏ឈររឭកដល់ព្រះថេរៈ ។

បានឮថា ក្នុងខណៈនោះឯង ព្រះថេរៈពិចារណាមើលក៏បានជ្រាបថា ពួកគេកំពុងធ្លាក់នៅក្នុងសេចក្តីវិនាស ទើបហោះឡើងកាន់អាកាស មកឈរត្រង់មុខ ។ ពួកអមនុស្សឃើញព្រះថេរៈ ក៏និយាយថា លោកម្ចាស់បុណ្ណត្ថេរៈមកហើយ នាំគ្នាចៀសទៅ ។ ព្យុះក៏ស្ងប់ក្លាម ។ ព្រះថេរៈលួងលោមអ្នកទាំងនោះថា មិនត្រូវខ្លាច ហើយសួរថា ពួកអ្នកប្រាថ្នានឹងទៅណា ។ "ករុណា ពួកខ្ញុំព្រះករុណានឹងទៅកន្លែងដើមរបស់ខ្លួនឯងនុ៎ះឯង លោកម្ចាស់" ។ ព្រះថេរៈជាន់ផ្ទៃសំពៅ ហើយអធិដ្ឋានថា ចូរទៅកាន់ទីដែលអ្នកទាំងនេះត្រូវការ ។ ពួកឈ្មួញកាលទៅដល់កន្លែងរបស់ខ្លួនហើយ ក៏ដំណាលរឿងនោះ ឲ្យកូនប្រពន្ធស្តាប់ ហើយបបួលគ្នាថា មកចុះពួកយើង ចូរដល់ព្រះថេរៈជាទីពឹងចុះ ទើបនាំគ្នាទាំង ៥០០ នាក់ ព្រមទាំងពួកមេស្រុករបស់ខ្លួន ៥០០ នាក់ទៀត តាំងនៅក្នុងត្រៃសរណៈ ប្រកាសខ្លួនជាឧបាសក ។ តពីនោះក៏ឲ្យជញ្ជូនទំនិញចុះអំពីសំពៅ បែងចែកថ្វាយព្រះថេរៈមួយចំណែក ហើយប្រាប់លោកថា លោក

ម្ចាស់ នេះជាចំណែករបស់លោកម្ចាស់ ។ ព្រះថេរៈឆ្លើយថា អាត្មាមិនមានកិច្ច ដោយចំណែកនេះទេ តែពួកអ្នកធ្លាប់ឃើញព្រះសាស្តាហើយឬ ។ មិនទាន់ធ្លាប់ ឃើញទេលោកម្ចាស់ ។ បើដូច្នោះ សូមឲ្យអ្នកគយកចំណែកនេះទៅសាងបារាំ ថ្វាយព្រះសាស្តា ហើយពួកអ្នកនឹងបានឃើញ ព្រះសាស្តាដោយអាការយ៉ាងនេះ ។ អ្នកទាំងនោះក៏ទទួលថា ល្អហើយ លោកម្ចាស់ ហើយក៏ផ្តើមសាងបារាំ ដោយចំណែកនោះ និងដោយចំណែករបស់ខ្លួនជាច្រើនទៀត ។

បានឮមកថា សូម្បីព្រះសាស្តា ក៏ទ្រង់បានប្រើប្រាសតាំងពីវេលាផ្តើមកសាង ។ ពួកអ្នកយាមបានឃើញពន្លឺក្នុងវេលាពេលយប់ ក៏យល់ថា មានទេវតាសក្តិធំ ។ ពួកឧបាសកជួយគ្នាសាងបារាំ និងសេនាសនៈសម្រាប់ភិក្ខុសង្ឃរហូតស្រេច ត្រៀមគ្រឿងទាន ហើយក្រាបទូលព្រះថេរៈថា លោកម្ចាស់ពួកខ្ញុំបានធ្វើកិច្ចស្រេចហើយ សូមឲ្យលោកម្ចាស់មេត្តាទូលព្រះសាស្តាចុះ ។ ពេលរសៀល ព្រះថេរៈទៅដល់ក្រុងសាវត្ថីដោយឫទ្ធិ ហើយក្រាបទូលអង្វរព្រះមានព្រះភាគថា ពួកឈ្មួញក្នុងស្រុកឯណោះប្រាថ្នាគាល់ព្រះអង្គ សូមព្រះអង្គមេត្តាអនុគ្រោះដល់ពួកគេចុះ ។ ព្រះមានព្រះភាគទ្រង់ទទួលហើយ ។ ព្រះថេរៈជ្រាបថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏ត្រឡប់ទៅកាន់អាវាសរបស់ខ្លួន

វិញ ។

សូម្បីព្រះមានព្រះភាគ ក៏ត្រាស់ហៅព្រះអានន្ទត្ថេរមកបង្គាប់ថា អានន្ទ ស្អែកនេះពួកយើងនឹងត្រាច់បិណ្ឌបាត ត្រង់ស្រុករបស់ពួកឈ្មួញក្នុងដែនសុនាបរន្តៈ អ្នកចូរឲ្យស្លាកដល់ភិក្ខុ ៤៩៩ រូប ។ ព្រះថេរៈទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ប្រាប់រឿងនោះដល់ភិក្ខុសង្ឃ ហើយនិយាយថា សូមឲ្យពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាតចូរកុំចាប់ស្លាក ។ ក្នុងថ្ងៃនោះ ព្រះកុណ្ឌធានត្ថេរចាប់ស្លាកបានមុនគេ ។ ចំណែកពួកស្រុកឈ្មួញជ្រាបថា ថ្ងៃស្អែកនេះ ព្រះសាស្តាស្តេចនឹងមកដល់ ទើបសាងបារាំកណ្តាលស្រុក ត្រៀមរបស់ថ្វាយដ៏ប្រណីត ។ ព្រះមានព្រះភាគទ្រង់ធ្វើការបដិបត្តិព្រះសរីរៈតាំងពីព្រឹក ស្តេចចូលព្រះគន្ធកុដិ ប្រថាប់គង់ចូលផលសមាបត្តិ ។

បណ្ឌុកម្ពលសិលាសនៈរបស់ព្រះឥន្ទក៏ក្តៅឡើង ។ ស្តេចសក្កៈនោះទ្រង់ពិចារណាថា អ្វីនេះ ទ្រង់ឃើញថា ព្រះសាស្តាស្តេចនឹងទៅដែនសុនាបរន្តៈ ទើបត្រាស់ហៅវិស្សុកម្មទេវបុត្តមក បង្គាប់ថា បា! ថ្ងៃនេះ ព្រះមានព្រះភាគស្តេចនឹងត្រាច់បិណ្ឌបាតរយៈផ្លូវឆ្ងាយប្រមាណបីរយយោជន៍ (១ កម្ពុជៈ បីពាន់យោជន៍) បា! ចូរនិម្មិតផ្ទះកំពូលទុក ៥០០ ខ្នង ធ្វើការត្រៀមវាងផ្លូវត្រង់ចុង

បំផុតខាងទ្វារវត្តជេតពនឲ្យហើយស្រេច ។ វិស្សកម្មទេវបុត្តនោះ បានធ្វើយ៉ាងនោះឯង ។ ផ្ទះកំពូលសម្រាប់ព្រះមានព្រះភាគមានមុខបួន ។ របស់ព្រះអគ្គសាវកទាំងពីរមានមុខពីរ ។ ដ៏សេសមានមុខតែមួយ ។ ព្រះសាស្តាស្តេចចេញចាកព្រះគន្ធកុដិ ទ្រង់ចូលកាន់ផ្ទះកំពូលដ៏ប្រសើរក្នុងពួកផ្ទះកំពូល ដែលតាំងទុកតាមលំដាប់ ។ ពួកភិក្ខុ ៤៩៩ រូប តាំងពីព្រះអគ្គសាវកទាំងពីរ ក៏ទៅកាន់ផ្ទះកំពូល ៤៩៩ ខ្នង ។ មានផ្ទះកំពូលនៅខាងក្រោយមួយខ្នង ។ ផ្ទះកំពូលទាំង ៥០០ ខ្នង អណ្តែតទៅក្នុងអាកាស ។

ព្រះសាស្តាស្តេចដល់ភ្នំឈ្មោះ សច្ចពន្ធ ហើយទ្រង់បញ្ឈប់ផ្ទះកំពូលទុកក្នុងអាកាស ។ ត្រង់ភ្នំនោះ មានតាបសមិច្ឆាទិដ្ឋិ ឈ្មោះថា សច្ចពន្ធ ធ្វើឲ្យមហាជនកាន់យកសេចក្តីឃើញខុស ជាអ្នកមានលាភច្រើន និងមានយសច្រើន ។ តាបសនោះមានឧបនិស្ស័យនៃព្រះអរហត្ត រុងរឿងដូចប្រទីប ។ លុះទ្រង់ឃើញតាបសនោះហើយ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងធម៌ដល់គេទើបស្តេចទៅដើម្បីសម្តែងធម៌ ។ កាលទ្រង់ទេសនាចប់ តាបសក៏សម្រេចជាព្រះអរហន្ត ។ អភិញ្ញារបស់តាបសក៏មកជាមួយមគ្គនោះឯង ។ លោកជាឯហិភិក្ខុ ទ្រទ្រង់បាត្រចីវរដែលសម្រេចព្រោះឫទ្ធិ ហើយចូលកាន់ផ្ទះកំពូល ។

ព្រះមានព្រះភាគស្តេចទៅដល់ស្រុករបស់ពួកឈ្មួញព្រមទាំងភិក្ខុ ៥០០ រូប ទាំងផ្ទះកំពូល ទ្រង់ធ្វើឲ្យនរណាៗ មើលមិនឃើញផ្ទះកំពូល ហើយស្តេចទៅកាន់ស្រុកពួកឈ្មួញ ។ ពួកឈ្មួញបានថ្វាយមហាទានដល់ពួកភិក្ខុដែលមានព្រះពុទ្ធទ្រង់ជាប្រធាន ហើយទូលអារាធនាព្រះសាស្តាស្តេចទៅកាន់មកុឡការាម ។ ព្រះសាស្តាទ្រង់ចូលកាន់បារាំ ។ មហាជនរង់ចាំវេលា ដរាបព្រះសាស្តាស្ងប់សេចក្តីខ្វល់ខ្វាយជាប់ទាក់ទងនឹងអាហារ ក៏មនុស្សទាំងឡាយទទួលទានអាហារពេលព្រឹកស្រេចហើយ សមាទានអដ្ឋឧបោសថ កាន់គ្រឿងក្រអូប និងផ្កាឈើជាច្រើនត្រឡប់មកវត្ត ដើម្បីស្តាប់ធម៌ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ ។ ការរួចផុតពីកិលេសជាគ្រឿងចងកើតដល់មហាជនហើយ ។ ភាពកោលាហលជាប់ទាក់ទងនឹងព្រះពុទ្ធ ក៏បានមានហើយ ។ ដើម្បីសង្គ្រោះមហាជន ព្រះសាស្តាប្រថាប់ ២-៣ ថ្ងៃក្នុងទីនោះឯង ។ និងទ្រង់ក៏ញុំាងអរុណឲ្យតាំងឡើងក្នុងព្រះមហាគន្ធកុដិនុ៎ះឯង ។ កាលប្រថាប់ក្នុងទីនោះ ២-៣ ថ្ងៃហើយ ស្តេចក៏ត្រាច់បិណ្ឌបាតក្នុងស្រុករបស់ពួកឈ្មួញ ហើយត្រាស់ឲ្យព្រះបុណ្ណត្ថេរថា អ្នកចូរនៅក្នុងទីនេះចុះ ក្នុងចន្លោះផ្លូវ មានស្ទឹងឈ្មោះ និម្មទា ស្តេចបានទៅដល់ត្រើយនៃស្ទឹងនោះ ។ និម្មទានាគរាជ ធ្វើការទទួលព្រះសាស្តា អារាធនាព្រះអង្គចូល

កាន់ពិភពនាគ បានធ្វើសក្ការៈព្រះរតនត្រ័យហើយ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់នាគរាជនោះ ហើយក៏ស្តេចចេញចាកពិភពនាគ ។ នាគរាជនោះក្រាបទូលសូមថា សូមព្រះអង្គមេត្តា ប្រទានវត្ថុដែលគប្បីបម្រើដល់ខ្ញុំព្រះអង្គផងចុះព្រះអង្គ ។ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងចេតិយបទ ស្នាមព្រះបាទទុកត្រង់ត្រើយស្ទឹងនិម្មទា ។ ស្នាមព្រះបាទនោះ កាលរលកបោកមកក៏បិទ កាលរលករសាយទៅក៏បើក ។ ក្លាយជាស្នាមព្រះបាទដែលដល់សក្ការៈយ៉ាងធំ ។ កាលព្រះសាស្តាទ្រង់ចេញចាកទីនោះហើយ ស្តេចក៏មកដល់ភ្នំសច្ចពន្ធ ត្រាស់នឹងសច្ចពន្ធភិក្ខុថា មហាជនត្រូវអ្នកធ្វើឲ្យលិចចុះក្នុងផ្លូវអបាយ អ្នកត្រូវនៅក្នុងទីនេះឯង ដោះស្រាយលទ្ធិរបស់ពួកអ្នកទាំងនេះចេញ ហើយឲ្យពួកគេតាំងនៅក្នុងផ្លូវព្រះនិព្វាន ។ សូម្បីព្រះសច្ចពន្ធនោះ ក៏ទូលសូមវត្ថុដែលនឹងត្រូវរក្សា ។ ព្រះសាស្តា ទ្រង់ក៏សម្តែងស្នាមព្រះបាទទុកលើផ្ទាំងថ្មតាន់ ដូចប្រថាប់ត្រាទុកលើដុំដីស្អិតស្រស់ៗ ដូច្នោះ ។ បន្ទាប់ពីនោះ ស្តេចក៏យាងទៅវត្តជេតពននោះឯង ។ លោកសំដៅយកសេចក្តីនេះ ទើបពោលពាក្យជាដើមថា ខាងក្នុងវស្សានោះឯង ដូច្នេះ ។

ពាក្យថា **បរិនិព្វានហើយ** គឺ បរិនិព្វានហើយ ដោយអនុបាទិសេស-

*និព្វានធាតុ ។ មហាជនធ្វើការបូជាសរីរៈរបស់ព្រះថេរៈរហូតអស់ ៧ ថ្ងៃ ហើយយកឈើក្រអូបជាច្រើនមកបូជាព្រះសរីរៈ រក្សាធាតុ (ឆ្អឹង) ហើយសាងចេតិយបញ្ចុះ ។ ពាក្យថា* **ភិក្ខុច្រើន** *គឺ ពួកភិក្ខុដែលនៅក្នុងទីឈាបនកិច្ចសាកសពរបស់ព្រះថេរៈ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយស្រួលយល់ទាំងអស់នោះឯង ។*

ចប់អដ្ឋកថា បុណ្ណោវាទសូត្រទី ៣

# អ ដ្ឋ ក ថា

## នន្ទកោវាទសូត្រទី ៤

[២៤១] នន្ទកោវាទសូត្រ មានពាក្យជាដើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖

ក្នុងសូត្រនោះ ពាក្យថា **ក៏ដោយសម័យនោះឯង** សេចក្តីថា កាលព្រះមានព្រះភាគ ទ្រង់បានទទួលការសូមអង្វរអំពីព្រះមហាបជាបតីគោតមីហើយ ទ្រង់ក៏បញ្ជូនភិក្ខុនីសង្ឃទៅ ហើយត្រាស់ឲ្យភិក្ខុសង្ឃចូលប្រជុំ ទ្រង់ធ្វើការៈដល់សង្ឃថា ភិក្ខុទាំងឡាយដែលជាថេរៈចូរផ្លាស់វេនគ្នា ទូន្មានពួកភិក្ខុនី ព្រះអានន្ទពោលសំដៅយកសេចក្តីនោះ ទើបពោលពាក្យនេះ ។ ក្នុងសូត្រនោះ ពាក្យថា **បរិយាយេន** សំដៅដល់ដោយវារៈ ។

ពាក្យថា **មិនប្រាថ្នា** គឺ កាលដល់វេនរបស់ខ្លួនហើយ ភិក្ខុជាអ្នកទូន្មានភិក្ខុនីនឹងទៅស្រុកឆ្ងាយ ឬរវល់ធ្វើចីវរកម្មជាដើម ហើយត្រូវជាវេននៃការឲ្យឱវាទរបស់ភិក្ខុនន្ទកៈនេះ តែការផ្លាស់វេនគ្នាទូន្មាននេះ ព្រះមានព្រះភាគទ្រង់បានធ្វើការៈ ព្រោះហេតុនៃព្រះនន្ទកត្ថេរប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ព្រោះកាល

ពួកភិក្ខុនីទាំងនេះ បានឃើញព្រះថេរៈហើយ ចិត្តក៏នឹងជ្រះថ្លាតម្កល់មាំ ។ ព្រោះហេតុនោះ ពួកនាងភិក្ខុនីទាំងនោះ ទើបប្រាថ្នាទទួលពាក្យទូន្មានរបស់លោក ប្រាថ្នានឹងស្តាប់ធម្មកថា ដូច្នោះ ព្រះមានព្រះភាគទើបទ្រង់ដាក់វារៈនៃការឲ្យឱវាទ កាលដល់វេនរបស់ខ្លួនហើយ នន្ទកភិក្ខុនឹងសម្តែងឱវាទ នឹងពោលធម្មកថា ចំណែកព្រះថេរៈមិនព្រមធ្វើតាមវេនរបស់ខ្លួន ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយថា ន័យថា ភិក្ខុនីទាំងនោះ កាលព្រះថេរៈសោយរាជសម្បត្តិក្នុងជម្ពូទ្វីបអំពីជាតិមុន នាងជាស្រីស្នំ ។ ព្រះថេរៈបានជ្រាបហេតុការណ៍នោះដោយបុព្វេនិវាសញ្ញាណ ទើបគិតថា ភិក្ខុដទៃដែលបានបុព្វេនិវាសញ្ញាណ កាលបានឃើញយើងអង្គុយកណ្តាលភិក្ខុនីសង្ឃនេះ នាំយកសេចក្តីប្រៀបធៀប និងហេតុការណ៍ផ្សេងៗ មកពោលធម៌ ក៏នឹងគប្បីមើលហេតុការណ៍នេះ ហើយសម្គាល់ពាក្យដែលនឹងគប្បីពោលថា នន្ទកភិក្ខុមិនព្រមលះបង់ពួកស្រីស្នំរហូតដល់ថ្ងៃនេះ ព្រះនន្ទកភិក្ខុ ដែលមាននាងស្រីស្នំហែហមនេះ មិនល្អឡើយ ។ កាលពិចារណាឃើញសេចក្តីនេះ ព្រះថេរៈទើបមិនព្រមធ្វើតាមវេនរបស់ខ្លួន ។ បានឮមកថា ព្រះមានព្រះភាគទ្រង់ជ្រាបថា ធម៌ទេសនារបស់ព្រះថេរៈប៉ុណ្ណោះ ទើបជាទីសប្បាយដល់ភិក្ខុនីទាំងនេះ ទើបត្រាស់ហៅព្រះនន្ទកភិក្ខុមកក្នុងគ្រា

នោះឯង ។ ដើម្បីដឹងថា ភិក្ខុនីទាំងនោះ កាលជាតិមុនជានាងស្រីស្នំរបស់ព្រះថេរៈ ទើបមានរឿងដូចតទៅនេះ ៖

បានឮមកថា កាលមុនក្រុងពារាណសី មានពួកអ្នកធ្វើការងារដោយស្នូល ១,០០០ នាក់ គឺ ទាសៈ ៥០០ នាក់ ទាសី ៥០០ នាក់ ធ្វើការងាររួមគ្នា សម្រាកក្នុងទីជាមួយគ្នា ។ ព្រះនន្ទកត្ថេរនេះ ជាប្រធាននៃទាសៈក្នុងវេលានោះ ព្រះនាងគោតមី ជាប្រធាននៃទាសី នាងជាកិរិយាដ៏ឆ្លាតវាងវៃរបស់ប្រធាននៃទាសៈ ។ សូម្បីពួកអ្នកធ្វើការដោយស្នូល ទាំង ១,០០០ នាក់ កាលនឹងធ្វើបុញ្ញកម្ម ក៏ធ្វើរួមគ្នា ។ តមក វេលាចូលវស្សា មានព្រះបច្ចេកពុទ្ធ ៥ អង្គ ចេញចាកញកភ្នំនន្ទមូលកៈ មកចុះត្រង់ព្រៃឥសិបតនៈ ត្រាច់បិណ្ឌបាតក្នុងក្រុងហើយ ក៏ទៅកាន់ព្រៃឥសិបតនៈនុ៎ះឯង គិតថា ពួកយើងនឹងសូមហត្ថកម្មដើម្បីប្រយោជន៍ដល់កុដិនៅចាំវស្សា ស្លៀកដណ្តប់ចីវរ ចូលទៅកាន់ក្រុងក្នុងពេលល្ងាច ឈរត្រង់ទ្វារផ្ទះសេដ្ឋី ។ នាងប្រធាននៃទាសី កណ្តៀតឆ្នាំងទឹកទៅកំពង់ទឹក បានឃើញព្រះបច្ចេកពុទ្ធដែលកំពុងចូលកាន់ក្រុង ។ សេដ្ឋីបានស្តាប់ហេតុការណ៍ដែលព្រះបច្ចេកពុទ្ធទាំងនោះមក ក៏និយាយថា ពួកយើងមិនមានពេលទំនេរ សូមលោកម្ចាស់និមន្តទៅចុះ ។ គ្រានោះ នាងប្រធាននៃទាសី កំពុងទូលឆ្នាំងទឹក

ចូលទៅ ក៏ឃើញពួកព្រះបច្ចេកពុទ្ធទាំងនោះកំពុងចេញមកពីក្រុង ទើបដាក់ឆ្នាំងទឹកចុះ បង្អោនសំពះ ហើយទូលសួរថា លោកម្ចាស់ត្រឹមតែចូលកាន់ក្រុងហើយក៏ចេញមក តើមានហេតុអ្វីហ្ន៎ ។

បច្ចេក : ពួកអាត្មា មកដើម្បីសូមហត្ថកម្មនៃកុដិសម្រាប់ចាំវស្សា

ទាសី : បានឬទេ លោកម្ចាស់

បច្ចេក : មិនបានទេ ឧបាសិកា

ទាសី : ក៏ឯកុដិនោះ ពួកមនុស្សបាស់ ព្រឹទ្ធាចារ្យប៉ុណ្ណោះ ទើបនឹងធ្វើបាន ឬសូម្បីតែពួកអ្នកក្រលំបាកក៏ធ្វើបាន

បច្ចេក : អ្នកណាមួយក៏អាចធ្វើបាន

ទាសី : ប្រសើរណាស់ លោកម្ចាស់ ពួកខ្ញុំម្ចាស់នឹងធ្វើថ្វាយ ស្អែកនេះសូមនិមន្តទទួលភិក្ខារបស់ខ្ញុំម្ចាស់ និមន្តទុកហើយ ក៏កណ្ដៀតឆ្នាំងទឹកមកឈរត្រង់កំពង់ទឹកទៀត និយាយនឹងពួកទាសីដ៏សេសដែលនាំគ្នាមកថា ពួកនាងទាំងឡាយឈប់សិន ក្នុងវេលាដែលគេគ្រប់គ្នាមកហើយ ក៏និយាយថា នែ៎ពួកនាងនឹងធ្វើការងារជាខ្ញុំអ្នកដទៃរហូតទៅឬ ឬចង់រួចផុតពីភាពជាខ្ញុំគេ ។ ពួកទាសីឆ្លើយថា ចង់រួចផុតក្នុងថ្ងៃនេះឯង អ្នកមេម្ចាស់ ។ នាងទើបពោលថា បើដូច្នោះ

ស្អែកនេះខ្ញុំបាននិមន្តព្រះបច្ចេកពុទ្ធទាំង ៥ អង្គ ដែលមិនបានហត្ថកម្មមកឆាន់ សូមឲ្យពួកនាង ប្រាប់ពួកស្វាមីរបស់ពួកនាងឲ្យហត្ថកម្មត្រឹមតែថ្ងៃនេះចុះ ។ ពួកនាងទាំងនោះក៏ទទួលថា បាន ហើយក៏ប្រាប់ដល់ស្វាមីក្នុងវេលាដែលមកអំពីព្រៃក្នុងពេលល្ងាច ។ ពួកគេក៏ទទួលថា ប្រសើរហើយនាង ហើយក៏នាំគ្នាទៅប្រជុំត្រង់ទ្វារផ្ទះរបស់ប្រធាននៃទាសៈ ។ លំដាប់នោះ នាងប្រធានទាសីពោលនឹងពួកគេទាំងនោះថា បា!ទាំងឡាយ ស្អែកនេះសូមឲ្យពួកអ្នកចូរឲ្យហត្ថកម្មដល់ព្រះបច្ចេកពុទ្ធទាំងឡាយចុះណ៎ះ ហើយក៏ប្រាប់អានិសង្ស ណែនាំអ្នកដែលរឹងរូស ដែលមិនចង់ធ្វើដោយឱវាទ ។ ថ្ងៃស្អែក នាងបានថ្វាយអាហារចំពោះព្រះបច្ចេកពុទ្ធ ហើយឲ្យសញ្ញាដល់ពួកកូនទាសៈគ្រប់គ្នា ។ ភ្លាមនោះ ពួកកូនទាសៈទាំងនោះ ក៏ចូលព្រៃប្រមូលយកគ្រឿងឈើ សាងកុដិមួយខ្នងៗ មានបរិវារ គឺ ទីចង្រ្កមជាដើម កុដិមួយខ្នងៗ មានកន្លែងដាក់គ្រែ តាំងទឹកឆាន់ និងភាជនៈសម្រាប់ដាក់របស់ដែលត្រូវឆាន់ជាដើម សូមឲ្យពួកព្រះបច្ចេកពុទ្ធធ្វើបដិញ្ញាដើម្បីប្រយោជន៍នៅក្នុងកុដិនោះរហូតអស់បីខែ ហើយតាំងវេនគ្នាថ្វាយអាហារ ។ ក្នុងថ្ងៃវេនរបស់ខ្លួន អ្នកណាមិនអាចថ្វាយទានបាន នាងប្រធាននៃទាសីក៏នាំយកអាហារអំពីផ្ទះរបស់ខ្លួនឯង មកថ្វាយជំនួសអ្នកនោះ ។ កាលនាងប្រធាន

នៃទាសីប្រណិបត្តិរហូតអស់បីខែយ៉ាងនេះស្រេចហើយ ក៏ឲ្យទាសៈម្នាក់លះបង់សំពត់ម្នាក់មួយផ្ទាំង បានសំពត់សាច់គ្រោតគ្រាត ៥០០ ផ្ទាំង ហើយឲ្យគេយកសំពត់ទាំងនោះ ធ្វើជាត្រៃចីវរថ្វាយព្រះបច្ចេកពុទ្ធទាំង ៥ អង្គ ។ ព្រះបច្ចេកពុទ្ធទាំងឡាយក៏ចៀសចេញទៅតាមសប្បាយ ។ សូម្បីអ្នកធ្វើការងារដោយស្មងទាំងពាន់នាក់នោះ បានធ្វើកុសលមកជាមួយគ្នា ស្លាប់ហើយក៏កើតក្នុងទេវលោក ។ ស្ត្រីទាំង ៥០០ នាក់នោះ ពេលខ្លះក៏ជាភរិយា របស់បុរសទាំង ៥០០ នាក់នោះ ។ ពេលខ្លះសូម្បីទាំងអស់ ក៏ជាភរិយារបស់ប្រធាននៃទាសៈប៉ុណ្ណោះ ។ តមក ក្នុងកាលមួយប្រធាននៃទាសៈ ចុតិចាកទេវលោកមកកើតក្នុងរាជត្រកូល ។ សូម្បីទេវកញ្ញាទាំង ៥០០ នោះ ក៏មកកើតក្នុងត្រកូលដែលមានសម្បត្តិច្រើន កាលប្រធាននៃទាសៈនោះបានសោយរាជ្យ ក៏ទៅកាន់ព្រះរាជវាំង ជាស្រីស្នំ ។ កាលពួកនាងត្រាច់អន្ទោលនៅដោយទំនងនេះ ក្នុងកាលនៃព្រះមានព្រះភាគរបស់ពួកយើង ក៏មកកើតក្នុងត្រកូលក្សត្រិយ៍ក្នុងកោលិយនគរខ្លះ ក្នុងទេវទហនគរខ្លះ ។

សូម្បីព្រះនន្ទកនោះ កាលបួសហើយ ក៏បានសម្រេចជាព្រះអរហន្ត ។ ឯប្រធាននៃទាសី ចម្រើនវ័យហើយ ក៏តាំងនៅក្នុងតំណែងអគ្គមហេសីរបស់

ព្រះបាទសុទ្ធោទនមហារាជ ។ សូម្បីស្រីក្រៅពីនេះ ក៏ទៅកាន់ព្រះរាជវាំង (គឺជាព្រះជាយា ) របស់រាជបុត្រទាំងនោះ ។ ព្រះរាជបុត្តទាំង ៥០០ អង្គ ដែលជាព្រះស្វាមីរបស់ពួកព្រះនាងទាំងនោះ ទ្រង់បានស្តាប់ព្រះធម៌ទេសនា របស់ព្រះសាស្តាក្នុងការឈ្លោះគ្នាជាប់ទាក់ទងនឹងការដណ្តើមទឹក ហើយក៏ទ្រង់ព្រះផ្នួស ។ ពួកព្រះជាយា ក៏ទ្រង់បញ្ជូនរាជសាសន៍ដើម្បីឲ្យពួកព្រះស្វាមីទាំងនោះអផ្សុក ។ ព្រះមានព្រះភាគទ្រង់នាំពួកភិក្ខុដែលអផ្សុកទាំងនោះទៅស្រះតាវ៉ៅ ហើយទ្រង់ឲ្យតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃប្រជុំធំ ក៏ទ្រង់ឲ្យតាំងនៅក្នុងភាពជាព្រះអរហន្ត ។ សូម្បីព្រះជាយាទាំង ៥០០ អង្គនោះ ក៏នាំគ្នាចេញទៅបួសក្នុងសម្នាក់ព្រះមហាប្រជាបតគោតមី ។

គប្បីសម្តែងរឿងនេះ យ៉ាងនេះថា ប្រធាននៃទាសៈនេះ គឺ ព្រះនន្ទកៈ នាងទាសីទាំងនេះ គឺ ភិក្ខុនីទាំងនោះ ដូច្នេះ ។

**[២៥៦]** ពាក្យថា *រាជការាមោ* បានដល់ វត្តដែលព្រះបាទបសេនទិ-កោសល ទ្រង់សាងទុកក្នុងស្ថានទីស្រដៀងថូបារាម ស្ថិតនៅក្នុងទិសខាងត្បូងនៃព្រះនគរ ។

**[២៥៨]** ពាក្យថា *សម្មប្បញ្ញាយ សុទិដ្ឋំ* គឺ ឃើញតាមហេតុ តាមបច្ច័យ

ដោយវិបស្សនាបញ្ញា គឺ តាមសេចក្តីពិត ។

[២៦២] ពាក្យថា **តជ្ជំ តជ្ជំ** គឺ មានបច្ច័យនោះជាហេតុ មានបច្ច័យនោះជាសមុដ្ឋាន ។ មានពាក្យអធិប្បាយថា ក៏ឯវេទនានោះៗ ព្រោះអាស្រ័យបច្ច័យនោះៗ ទើបកើតឡើង ។ ពាក្យថា **បគេវស្ស ឆាយា** សេចក្តីថា ដើមឈើដែលចម្រើនឡើង ព្រោះអាស្រ័យឫសជាដើម ក៏មិនទៀង តាំងពីដុះដំបូងនោះឯង ។

[២៦៥] ពាក្យថា **អនុបហច្ច** គឺ មិនចូលទៅប្រហារ បុគ្គលធ្វើសាច់ឲ្យជាដុំៗ ហើយនាំយកស្បែកមកខាងក្រៅ ឈ្មោះថា រមែងចូលទៅកម្ចាត់កាយ គឺ សាច់ ក្នុងពាក្យថា មិនចូលទៅកម្ចាត់នោះ បុគ្គលធ្វើស្បែកឲ្យជាប់គ្នាជាផ្ទាំង ហើយនាំយកសាច់ទាំងឡាយមកខាងក្រៅ ឈ្មោះថា រមែងចូលទៅកម្ចាត់កាយ គឺ ស្បែក តែគេមិនធ្វើយ៉ាងនោះ ។

[២៦៦] ពាក្យថា **វិលិមំសនហារុ ពន្ធនំ** បានដល់ សាច់ដែលជាប់ត្រង់ស្បែកទាំងអស់នុ៎ះឯង ។ លោកពោលសំដៅយកកិលេសក្នុងចន្លោះគ្រប់យ៉ាងនុ៎ះឯងថា មានគ្រឿងចង គឺ សញ្ញោជនៈក្នុងចន្លោះ ដូច្នេះ ។

សួរថា ហេតុដូចម្តេច លោកទើបពោលពាក្យថា ៧ យ៉ាងទាំងនេះឯង ។

ឆ្លើយថា ព្រោះបញ្ញាណាដែលលោកពោលថា បញ្ញានេះ រមែងកម្ចាត់កិលេសទាំងឡាយបាន បញ្ញានោះខ្លួនឯងតែម្យ៉ាងពិតៗ មិនអាចកម្ចាត់បានដោយធម្មតារបស់ខ្លួន ។ ដូចជា ពូថៅ ដោយធម្មតារបស់ខ្លួនហើយ នឹងកាត់វត្ថុដែលត្រូវកាត់ឲ្យដាច់មិនបាន តែកាលត្រូវអាស្រ័យសេចក្តីព្យាយាមដែលកើតអំពីបុរសហើយ ទើបនឹងកាត់បានយ៉ាងណា បញ្ញា បើវៀរចាកពោជ្ឈង្គប្រការ ៦ ទៀតហើយ បញ្ញានោះ ក៏មិនអាចនឹងកម្ចាត់កិលេសទាំងឡាយបានដូច្នោះដែរ ។ ព្រោះដូច្នោះ លោកទើបពោលយ៉ាងនោះ ។ ពាក្យថា **បើដូច្នោះ** សេចក្តីថា លោកសម្តែងអាយតនៈខាងក្នុង ៦ ខាងក្រៅ ៦ កងវិញ្ញាណ ៦ ការប្រៀបធៀបប្រទីបដើមឈើ និងគោ ហើយបញ្ចប់ទេសនាដោយការអស់ទៅនៃអាសវៈដោយពោជ្ឈង្គៈ ៧ យ៉ាង ព្រោះហេតុណា ព្រោះហេតុនោះ សូម្បីស្អែកនេះ អ្នកក៏គប្បីប្រៀនប្រដៅពួកភិក្ខុនីទាំងនោះ ដោយឱវាទនោះឯង ។

**[២៦៩]** ពាក្យថា *សា សោតាបន្នា* សេចក្តីថា ភិក្ខុនីដែលទាបបំផុតក៏ជាសោតាបន្ន ។ ដ៏សេសក៏ជាសកទាគាមិនី អនាគាមិនី និងខីណាស្រព ។ សួរថា បើដូច្នោះ នឹងមានសេចក្តីត្រិះរិះបរិបូណ៌បានយ៉ាងណា ។ ឆ្លើយថា នឹងមានសេចក្តីត្រិះរិះបរិបូណ៌បាន ដោយសេចក្តីបរិបូណ៌នៃអជ្ឈាស្រ័យ ។ ពិត

ហើយ ភិក្ខុនីរូបណាមានសេចក្តីគិតយ៉ាងនេះថា កាលណាហ្ន៎ យើងកំពុងស្តាប់ធម្មទេសនារបស់លោកម្ចាស់ននូក: គប្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលក្នុងអាសនៈនុ៎ះឯង ។ ភិក្ខុនីនោះ ក៏បានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ភិក្ខុនីរូបណាមានសេចក្តីគិតថា សកទាគាមិផល អនាគាមិផល អរហត្តផល នាងភិក្ខុនីរូបនោះ ក៏ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហន្ត ។ ព្រោះហេតុនោះ ព្រះ-មានព្រះភាគទើបត្រាស់ថា ជាអ្នកវីកកាយ និងមានសេចក្តីត្រិះរិះដែលបរិបូណ៌ហើយនោះឯង ។

ចប់អដ្ឋកថា ឆន្នោវាទសូត្រទី ៤

# អ ដ្ឋ ក ថា

## ចូឡរាហុលោវាទសូត្រទី ៥

[២៧០] *រាហុលោវាទសូត្រ* មានពាក្យជាដើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្ដាប់មកហើយយ៉ាងនេះ ៖

*ក្នុងព្រះសូត្រនោះ ពាក្យថា* **ធ្វើវិមុត្តិឲ្យចាស់ក្លា** *មានវិគ្រោះថា ដែលឈ្មោះថា ធ្វើវិមុត្តិឲ្យចាស់ក្លា ក៏ព្រោះធ្វើវិមុត្តិឲ្យទុំជោរ ។ ពាក្យថា ធម៌បានដល់ ធម៌ ១៥ យ៉ាង ។ ធម៌ទាំងនោះ គប្បីជ្រាបសេចក្ដីបរិសុទ្ធិនៃឥន្ទ្រិយមានសទ្ធិន្ទ្រិយជាដើម ។ សមពិតដូចពាក្យដែលលោកពោលទុកថា*

***សទ្ធិន្ទ្រិយ រមែងបរិសុទ្ធិដោយអាការ ៣ យ៉ាងទាំងនេះ គឺ ៖***

*-វៀរបុគ្គលដែលមិនមានសទ្ធា*

*-សេពគប់ ចូលអង្គុយជិតបុគ្គលដែលមានសទ្ធា*

*-ពិចារណាសូត្រដែលជាហេតុឲ្យកើតសេចក្ដីជ្រះថ្លា*

***វីរិយិន្ទ្រិយ រមែងបរិសុទ្ធិដោយអាការ ៣ យ៉ាងទាំងនេះ គឺ ៖***

*-វៀរបុគ្គលខ្ជិលច្រអូស*

-សេពគប់ ចូលអន្តុយជិតបុគ្គលដែលប្រារព្ធសេចក្តីព្យាយាម

-ពិចារណាដល់សេចក្តីព្យាយាមដោយប្រពៃ

**សតិន្ទ្រិយ រមែងបរិសុទ្ធិដោយអាការ ៣ យ៉ាងទាំងនេះ គឺ ៖**

-វៀរបុគ្គលដែលមិនមានសតិ

-សេពគប់ ចូលអន្តុយជិតបុគ្គលដែលមានសតិតាំងមាំ

-ពិចារណាទីតាំងនៃសតិ (សតិប្បដ្ឋាន)

**សមាធិន្ទ្រិយ រមែងបរិសុទ្ធិដោយអាការ ៣ យ៉ាងទាំងនេះ គឺ ៖**

-វៀរបុគ្គលដែលមិនមានសមាធិ

-សេពគប់ ចូលអន្តុយជិតបុគ្គលដែលមាមសមាធិ

-ពិចារណាឈានទិងវិមោក្ខ

**បញ្ញិន្ទ្រិយ រមែងបរិសុទ្ធិដោយអាការ ៣ យ៉ាង ទាំងនេះ គឺ ៖**

-វៀរបុគ្គលដែលមិនមានបញ្ញា

-សេពគប់ ចូលអន្តុយជិតបុគ្គលដែលមានបញ្ញា

-ពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ

កាលវៀរបុគ្គល ៥ ពួក សេពគប់ ចូលអន្តុយជិតបុគ្គល ៥ ពួក ពិចា-

វណាសូត្រទាំង ៥ សូត្រ ដូចពោលមកនេះ ដោយអាការ ១៥ យ៉ាង ឥន្ទ្រិយទាំង ៥ ក៏រមែងបរិសុទ្ធិ ។ នៅមានធម៌សម្រាប់ធ្វើនូវវិមុត្តឲ្យចាស់ក្លា ១៥ យ៉ាងទៀត គឺ មានសទ្ធិន្ទ្រិយជាដើម សេចក្ដីសម្គាល់ ដែលជាចំណែកនៃការចាក់ធ្លុះ (និព្វេធភាគិយសញ្ញា) ៥ យ៉ាងទាំងនេះគឺ សេចក្ដីសម្គាល់ថា មិនទៀង សេចក្ដីសម្គាល់ថា ជាទុក្ខក្នុងវត្ថុដែលមិនទៀង សេចក្ដីសម្គាល់ថា មិនមែនតួខ្លួនក្នុងវត្ថុដែលជាទុក្ខ សេចក្ដីសម្គាល់ក្នុងការលះ សេចក្ដីសម្គាល់ក្នុងវិរាគៈ និងធម៌ ៥ យ៉ាងដទៃទៀត មានភាពជាអ្នកមានមិត្តល្អជាដើម ដែលត្រាស់ដល់ព្រះមេឃិយត្ថេរ ។

សួរថា ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះក្នុងវេលាណាហ្ន៎ ។

ឆ្លើយថា កាលព្រះអង្គទ្រង់ពិចារណាមើលលោក ក្នុងសម័យជិតភ្លឺ ក៏ទ្រង់មានព្រះតម្រិះយ៉ាងនេះ ។

**[២៧៦]** ពាក្យថា ***ទេវតាច្រើនពាន់អង្គ*** សេចក្ដីថា ព្រះរាហុលតាំងសេចក្ដីប្រាថ្នាទុកទៀបបាទមូលរបស់ព្រះមានព្រះភាគទ្រង់ព្រះនាមថា បទុមុត្តរៈ ក្នុងអត្តភាពជាស្ដេចនាគឈ្មោះ បាលិត ព្រមទាំងទេវតា ដែលតាំងសេចក្ដីប្រាថ្នាទុកដូចគ្នា ។ ក៏ឯបណ្ដាទេវតាទាំងនោះ ពួកខ្លះក៏ជាទេវតានៅលើផែនដី ។

ពួកខ្លះក៏កើតក្នុងអាកាស ។ ពួកខ្លះក៏នៅចាតុម្មហារាជិកា ។ ពួកខ្លះក៏នៅក្នុងទេវលោក ។ ពួកខ្លះក៏កើតក្នុងព្រហ្មលោក ។ តែក្នុងថ្ងៃនេះ ទេវតាទាំងអស់នោះ មកប្រជុំគ្នាក្នុងព្រៃអន្ធវ័នទន្ទឹះឯង ក្នុងទីតែមួយជាមួយគ្នា ។ ពាក្យថា **ធម្មចក្ខុ** សេចក្តីថា បឋមមគ្គ (សោតាបត្តិមគ្គ) លោកហៅថា ធម្មចក្ខុ ក្នុងឧបាលិ-ឱវាទសូត្រ និងទីឃនខសូត្រ ។ ផលទាំងបី លោកហៅថា **ធម្មចក្ខុ** ។ ក្នុងព្រហ្មាយុសូត្រ ។ ក្នុងសូត្រនេះ មគ្គ ៤ ផល ៤ គប្បីជ្រាបថា **ជាធម្មចក្ខុ** ។ ក៏ឯក្នុងបណ្តាទេវតាទាំងនោះ ទេវតាពួកខ្លះបានជាព្រះសោតាបន្ន ។ ពួកខ្លះជាព្រះសកទាគាមី ពួកខ្លះជាអនាគាមី ពួកខ្លះជាព្រះខីណាស្រព ។ ក៏ជាការកំណត់ដោយអំណាចរាប់ចំនួនទេវតាទាំងនោះថា ប៉ុណ្ណោះ ប៉ុណ្ណេះមិនមាន ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា រាហុលោវាទសូត្រ ទី ៩

# អ ដ្ឋ ក ថា

## ឆឆក្កសុត្រទី ៦

**[២៨៥]** ឆឆក្កសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មក ហើយយ៉ាងនេះ ៖

បណ្ដាពាក្យទាំងនោះ ពាក្យថា **អាទិកល្យាណំ** សេចក្ដីថា តថាគត នឹងធ្វើឲ្យពីរោះ គឺ ឲ្យប្រាសចាកទោស ឲ្យល្អក្នុងខាងដើម ហើយសម្ដែង ។ សូម្បីពីរោះក្នុងបទកណ្ដាល និងបទខាងចុង ក៏មានទំនងដូចគ្នានេះ ។ ព្រះ-មានព្រះភាគទ្រង់សរសើរអរិយវង្សសូត្រដោយ ៩ បទ មហាសតិប្បដ្ឋានសូត្រ ដោយ ៧ បទ មហាអស្សបុរសូត្រដោយ ៧ បទ ដូចគ្នា ដោយប្រការដូច្នេះ ។ ចំណែកព្រះសូត្រនេះ ទ្រង់សរសើរដោយ ៩ បទ ។

**[២៨៦]** ពាក្យថា **វេទិតព្វានិ** គឺ គប្បីជ្រាបដោយមគ្គព្រមទាំងវិប-ស្សនា ។ ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិបីប៉ុណ្ណោះ ទ្រង់សម្ដែងដោយមនាយ-តនៈ ។ និងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ខាងក្រៅ ទ្រង់សម្ដែងដោយធម្មា-យតនៈ ។ វៀរលែងតែទ្វិបញ្ចវិញ្ញាណ (វិញ្ញាណ ៥ គូ រួម ១០ ដួង) លោកិយ-

វិបាកចិត្ត ២០ ដួងដ៏សេស ទ្រង់សម្តែងដោយមនោវិញ្ញាណ ។ ផស្សៈ និង វេទនា ជាធម៌ដែលសម្បយុត្តដោយវិបាកវិញ្ញាណ តាមដែលពោលទុកហើយ ។ ពាក្យថា **តណ្ហា** បានដល់ តណ្ហាដែលកើតឡើងក្នុងខណៈនៃជវនៈ ដែលមាន វិបាកវេទនាជាបច្ច័យ ។

**[២៩៣]** ពាក្យថា **ចក្ខុជាត្តខ្លួន** មានពាក្យជាប់បន្តជាផ្នែកមួយដោយ ចំពោះ ។ ក៏ដើម្បីសម្តែងសេចក្តីដែលសច្ចៈ ២ ប្រការដែលត្រាស់ទុកក្នុង កាលជាខាងក្រោយមិនមែនជាត្តខ្លួន ទើបទ្រង់ផ្តើមទេសនានេះ ។ ក្នុងបទទាំង នោះ បទថា **ឧប្បជ្ជន្តិ** បានដល់ មិនសមគួរ ។ ពាក្យថា **សាបសូន្យទៅ** គឺ ប្រាសទៅ រលត់ទៅ ។

**[២៩៥]** ពាក្យថា **អយំ ខោ បន ភិក្ខវេ** គឺ សូម្បីនេះក៏ជាពាក្យជាប់ត ដែលជាផ្នែកមួយដោយចំពោះ ។ ពិតហើយ គឺដើម្បីទ្រង់សម្តែងវដ្តៈ ដោយ អំណាចសេចក្តីប្រកាន់មាំ ៣ យ៉ាង ព្រះមានព្រះភាគទើបទ្រង់ផ្តើមទេសនា នេះ ។ ពេលខ្លះពោលថា ដើម្បីទ្រង់សម្តែងវដ្តៈដោយសច្ចៈ ២ ប្រការ គឺ ទុក្ខ និងសមុទ័យ ដូច្នេះក៏មានដូចគ្នា ។ ក្នុងពាក្យថា **នោះរបស់យើងជាដើម** គប្បីជ្រាបសេចក្តីប្រកាន់មាំដោយតណ្ហា មានះ និងទិដ្ឋិ ទុំះឯង ។

ពាក្យថា **រមែងសម្លឹងឃើញ** គឺ រមែងឃើញដោយអំណាចនៃសេចក្តីប្រកាន់មាំទាំង ៣ យ៉ាង ។

**[២៩៦]** លុះទ្រង់សម្តែងវដ្តៈយ៉ាងនេះហើយ គ្រានេះ ដើម្បីទ្រង់សម្តែងវិវដ្តៈដោយអំណាចបដិបក្ខចំពោះសេចក្តីប្រកាន់មាំទាំង ៣ យ៉ាង ឬដើម្បីទ្រង់សម្តែងវិវដ្តៈ ដោយអំណាចសច្ចៈ ២ ប្រការ គឺ និរោធ និងមគ្គ ទើបត្រាស់ថា **អយំ ខោ បន** ដូច្នេះជាដើម ។

ពាក្យថា **នោះមិនមែនរបស់យើង** ជាដើម ជាពាក្យបដិសេធតណ្ហាជាដើម ។ ពាក្យថា **រមែងសម្លឹងឃើញ** គឺ រមែងឃើញថា ជារបស់មិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ។

**[២៩៧]** លុះទ្រង់សម្តែងវិវដ្តៈយ៉ាងនេះហើយ គ្រានេះដើម្បីទ្រង់នឹងសម្តែងវដ្តៈដោយអំណាចអនុស័យទាំងបីយ៉ាងទៀត ទើបត្រាស់ពាក្យជាដើមថា **ចក្ខុញ្ច ភិក្ខវេ** ។

ក្នុងពាក្យទាំងនោះ ពាក្យជាដើមថា **រមែងត្រេកត្រអាល** ព្រះមានព្រះភាគត្រាស់ដោយអំណាចតណ្ហា និងទិដ្ឋិប៉ុណ្ណោះ ។ ពាក្យថា **ដេកត្រាំ** គឺ នៅលះមិនបាន ។ ពាក្យថា **នៃទុក្ខ** បានដល់ នៃវដ្តទុក្ខ និងកិលេសទុក្ខ ។

[២៩៨] លុះទ្រង់សម្តែងវដ្តៈដោយអំណាចអនុស័យបីយ៉ាង យ៉ាងនេះហើយ គ្រានេះកាលទ្រង់នឹងសម្តែងវិវដ្តៈ ដោយអំណាចនៃន័យដែលផ្ទុយគ្នានឹងអនុស័យទាំងបីយ៉ាងនោះ ទើបត្រាស់ពាក្យជាដើមថា **ចក្ខុញ្ច** ម្តងទៀត ។ ពាក្យថា **អវិជ្ជា បហាយ** គឺ លះសេចក្តីមិនដឹង ដែលជាឫសគល់របស់វដ្តៈបានហើយ ។ ពាក្យថា **ញ៉ាំងវិជ្ជា** គឺ ញ៉ាំងសេចក្តីដឹង គឺ អរហត្តមគ្គឲ្យកើតឡើងហើយ ។

ពាក្យថា **នោះ រមែងជាឋានៈដែលមានបាន** គឺ ដោយកថាមគ្គត្រឹមតែប៉ុណ្ណេះឯង ព្រះអង្គក៏ទ្រង់ទេសនាដោយអំណាចវដ្តៈ និងវិវដ្តៈឲ្យដល់កំពូលបានហើយ កាលទ្រង់នឹងរួបរួមព្រះធម៌ទេសនានោះឯង ក៏បានត្រាស់ពាក្យជាដើមថា **ឯវំ បស្សំ ភិក្ខវេ** ម្តងទៀត ។

[២៩៩] ក្នុងពាក្យថា **ភិក្ខុប្រមាណ ៦០ រូប** នេះ នោះមិនគួរអស្ចារ្យឡើយ ដែលកាលព្រះតថាគតទ្រង់សម្តែងដោយព្រះអង្គឯងពិតៗ ភិក្ខុ ៦០ រូបបានសម្រេចជាព្រះអរហន្ត ។ ព្រោះថា សូម្បីកាលព្រះធម្មសេនាបតីសម្តែងសូត្រនេះ ក៏មានភិក្ខុ ៦០ រូប សម្រេចជាព្រះអរហន្ត សូម្បីព្រះមហាមោគ្គល្លានសម្តែងក្តី ព្រះមហាថេរៈ ៨០ រូប សម្តែងក្តី ក៏មានភិក្ខុ ៦០ រូប សម្រេចដូច

គ្នានោះឯង សូម្បីប្រការនេះ ក៏មិនគួរអស្ចារ្យ ។ ព្រោះព្រះសាវកទាំងនោះ លោកសម្រេចអភិញ្ញាធំ (ទាំងអស់គ្នា) ។

ក៏ក្នុងវេលាជាខាងក្រោយ ព្រះមាលេយ្យទេវត្ថេរក្នុងកោះលង្កា ក៏បានសម្ដែងព្រះសូត្រនេះខាងក្រោមលោហប្រាសាទ ។ សូម្បីគ្រានោះ ក៏មានភិក្ខុ ៦០ រូប សម្រេចជាព្រះអរហន្ត ។ ហើយព្រះថេរៈក៏សម្ដែងព្រះសូត្រនេះក្នុងមហាមណ្ឌប ដូចព្រះមាលេយទេវត្ថេរៈសម្ដែងក្នុងលោហប្រាសាទដូចគ្នា ។ ព្រះថេរៈ កាលចេញចាកមហាវិហារហើយ ក៏ទៅចេតិយបព៌ត ក្នុងទីនោះលោកក៏សម្ដែងដូចគ្នា ។ បន្ទាប់ពីនោះ លោកក៏ទៅសម្ដែងនៅវត្តសាកិយវង្ស នៅវត្តកូដាសី នៅអន្តរសោព្ភ នៅមុត្តង្គណៈ នៅបាតកបព៌ត នៅបាចីឃរកៈ (ផ្ទះខាងកើត) នៅទីឃវាបិយ (បឹងវែង) នៅញកក្នុំ នៅស្រុក និងទីកន្លែងចិញ្ចឹមពពែ ។

សូម្បីក្នុងទីទាំងនោះ ក៏មានភិក្ខុ ៦០ រូបៗ សម្រេចជាព្រះអរហន្ត ដូចគ្នា ។ កាលចេញចាកទីនោះហើយ ព្រះថេរៈក៏ទៅកាន់ចិត្តលបព៌ត ។ គ្រានោះនៅវត្តចិត្តលបព៌ត មានព្រះមហាថេរៈមានវស្សាជាង ៦០ ។ ជិតស្រះឈូកធំមានកំពង់ជ្រៅ ឈ្មោះថា កំពង់កុរុវកៈ ។ នៅឯកំពង់នោះ ព្រះថេរៈគិតថា យើងនឹងងូតទឹក ទើបចុះទៅ ។ ព្រះទេវត្ថេរទៅរកលោក ហើយឆ្លើយប្រាប់ថា

ខ្ញុំករុណានឹងដងទឹកស្រង់ ប្រគេនលោកម្ចាស់ ។ ដោយការបដិសណ្ឋារៈនុ៎ះឯង ព្រះថេរៈក៏ជ្រាបបានថា ពួកគេនិយាយថា មានព្រះមហាថេរៈឈ្មោះ មាលេ-យ្យទេវៈ ក៏ប្រហែលជារូបលោកនេះឯង ទើបសួរថា លោកម្ចាស់ជាទេវៈឬ ។ ករុណាលោកម្ចាស់ ។ លោកម្ចាស់មិនមានអ្នកណា ដែលប្រើដៃដុសខ្នងរបស់យើង ៦០ ឆ្នាំហើយ តែលោកនឹងងូតទឹកឲ្យយើង ហើយក៏ឡើងទៅអង្គុយលើមាត់ប្រាំង ។ ព្រះថេរៈក៏ធ្វើបរិកម្មដៃ និងជើងដរាបទូទៅហើយ ក៏ស្រង់ទឹកប្រគេនព្រះមហាថេរៈ ។ និងថ្ងៃនោះ ជាថ្ងៃស្តាប់ធម៌ ។ ពេលនោះ ព្រះមហាថេរៈទើបពោលថា ម្នាលទេវ លោកគួរឲ្យធម្មទានដល់យើងទាំងឡាយ ។ ព្រះថេរៈទទួលថា ករុណា យល់ព្រមលោកម្ចាស់ ។ កាលព្រះអាទិត្យលិចហើយ ពួកមនុស្សក៏ទៅអំពាវនាវប្រាប់គ្នាដើម្បីស្តាប់ធម៌ ។ ពួកព្រះមហាថេរៈ ៦០ រូប សុទ្ធតែមានវស្សាលើស ៦០ ទាំងអស់ បាននាំគ្នាមកស្តាប់ធម៌ ។ ព្រះទេវ-ត្ថេរ ។ ក៏ផ្តើមសូត្រនេះរហូតចប់ ។ កាលចប់ព្រះសូត្រហើយ ព្រះមហាថេរៈ ៦០ រូប ក៏បានសម្រេចជាព្រះអរហន្ត ។ បន្ទាប់ពីនោះ លោកក៏ទៅសម្តែងក្នុងតិស្សមហាវិហារ ។ សូម្បីក្នុងវត្តនោះក៏មានព្រះថេរៈ ៦០ រូប ( បានសម្រេចជាព្រះអរហន្ត ) ។ តពីនោះ ក៏សម្តែងឯនាគមហាវិហារ ជិតស្រុកកលកច្ឆៈ ។ សូម្បីក្នុងទីនោះ ក៏មានព្រះថេរៈ ៦០ រូប ( បានសម្រេចជាព្រះអរហន្ត ) ។

តពីនោះ ក៏ទៅវត្តកល្យាណី ក្នុងវត្តនោះ លោកក៏សំដែងខាងក្រោមប្រាសាទ ក្នុងថ្ងៃទី ១៤ រោច ។ សូម្បីក្នុងទីនោះក៏មានព្រះថេរៈ ៦០ រូប ( បានសម្រេចជាព្រះអរហន្ត ) ។

ក្នុងថ្ងៃឧបោសថ ក៏សំដែងលើប្រាសាទ ។ ឯលើប្រាសាទនោះ ក៏មានព្រះថេរៈ ៦០ រូប ( សម្រេចជាព្រះអរហន្តដូចគ្នា ) កាលព្រះទេវត្ថេរនុ៎ះឯងសំដែងព្រះសូត្រនេះ យ៉ាងនេះ ក្នុងទី ៦០ កន្លែង ក៏មានអ្នកសម្រេចជាព្រះ-អរហន្តក្នុងកន្លែងនីមួយៗ ៦០ រូប ដោយប្រការដូច្នេះ ។

តែកាលព្រះចូឡនាគត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក សំដែងព្រះសូត្រនេះក្នុងវត្តអម្ពិលកាឡកវិហារ មានបរិស័ទបីគាវុត ។ បរិស័ទទេវតាមួយយោជន៍ ។ កាលចប់ព្រះសូត្រ មានភិក្ខុមួយពាន់រូបបានជាព្រះអរហន្ត ។ ចំណែកក្នុងពួកទេវតាអំពីចំនួននោះៗ មួយចំនួនៗ មានបុថុជ្ជនត្រឹមតែចំនួន ១ អង្គ ប៉ុណ្ណោះឯង ។

ចប់អដ្ឋកថា ឆឆក្កសូត្រទី ៦

# អ ដ្ឋ ក ថា

## មហាសឡាយតនសូត្រទី ៧[1]

[៣០០] *មហាសឡាយតនសូត្រ មានបទជាដើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖*

*ក្នុងព្រះសូត្រនោះ ពាក្យថា* **មហាសឡាយតនិកំ** *ជាធម្មបរិយាយបំភ្លឺដល់អាយតនៈធំទាំង ៦ យ៉ាង ។*

[៣០១] *ពាក្យថា* **កាលមិនដឹង** *គឺ មិនដឹងដោយមគ្គ ព្រមទាំងវិបស្សនា ។*

[៣០២] *ពាក្យថា* **ដល់សេចក្តីកពូន** *គឺ រមែងដល់សេចក្តីចម្រើន សំដៅសេចក្តីថា រមែងដល់សេចក្តីស្ទាត់ជំនាញ ។ ពាក្យថា* **ប្រព្រឹត្តទៅក្នុងកាយ** *បានដល់ សេចក្តីរសាប់រសល់ក្នុងទ្វារទាំង ៥ ។ ពាក្យថា* **ប្រព្រឹត្តទៅក្នុងចិត្ត** *បានដល់ សេចក្តីរសាប់រសល់ផ្លូវមនោទ្វារ ។ សូម្បីក្នុងពាក្យថា* **សេចក្តីក្តៅក្រហាយ** *ជាដើម ក៏ទំនងនេះដូចគ្នា ។*

---

១-បាលីជា សឡាយតនវិភង្គសូត្រ ។

[៣០៣] បទថា **សុខផ្លូវកាយ** បានដល់ សេចក្ដីសុខប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ។ ពាក្យថា **សុខផ្លូវចិត្ត** បានដល់ សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត ។ និងក្នុងពាក្យថា សុខផ្លូវចិត្តនេះ មិនមានការចូល ឬការចេញដោយជវនៈតាមទ្វារទាំង ៥ ។ គឺ សេចក្ដីសុខផ្លូវចិត្តនេះ ត្រឹមតែកើតឡើងប៉ុណ្ណោះឯង ។ គ្រប់យ៉ាង រមែងប្រព្រឹត្តទៅតាមមនោទ្វារ ។ ឯវិបស្សនាដែលមានកម្លាំងនេះ រមែងជាបច្ច័យដល់មគ្គវុដ្ឋាន ។ វិបស្សនាដែលមានកម្លាំងនោះ ទើបប្រព្រឹត្តទៅបានតាមផ្លូវមនោទ្វារដូចគ្នា ។

ពាក្យថា **តថាភូតស្ស** គឺ ជាអ្នកដល់ព្រមដោយសេចក្ដីសុខផ្លូវចិត្តដែលប្រកបព្រមដោយកុសល ។ ពាក្យថា **បុព្វេ ខោ បនស្ស** គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈរបស់ភិក្ខុនោះ ឈ្មោះថា ស្អាតមកអំពីមុនហើយ គឺ ជាធម៌បរិសុទ្ធតាំងពីខាងដើម ចំណែកអង្គ ៥ ទៀត គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ឈ្មោះថា ជាអង្គដែលឧបការៈដល់ធម៌ទាំងពួង ។ ដោយប្រការដូច្នេះ លោកុត្តរមគ្គ ទើបមានអង្គ ៨ ឬអង្គ ៧ ក៏បាន ។ ចំណែកពួកវិតណ្ឌវាទី ចាប់យកខ្លឹមសារព្រះសូត្រនេះឯងថា ការឃើញរបស់ភិក្ខុជាយ៉ាងនោះ ហើយពោលថា លោកុត្តរមគ្គមានអង្គ ៥ ក៏មិន

មាន ។ គប្បីជំទាស់នឹងពួកអាចារ្យវិតណ្ឌវាទីនោះ ដោយពាក្យនិយាយសឹក ក្នុងចន្លោះនេះថា អរិយមគ្គប្រកបដោយអង្គ ៨ របស់ភិក្ខុនេះ រមែងដល់សេចក្តីបរិបូណ៌នៃការអប់រំ ដោយអាការយ៉ាងនេះ ។ គប្បីជ្រាបយ៉ាងនេះ ។ ដែលឈ្មោះថា លោកុត្តរមគ្គនោះ មានអង្គ ៥ មិនមានទេ ចំណែកអង្គដែលឧបការៈដល់ធម៌ទាំងពួងនេះ រមែងឲ្យពេញដោយអំណាចវិរតិចេតសិក ក្នុងខណៈនៃមគ្គ ។ ព្រោះថា វិរតិចេតសិកក្នុងវិរតិចេតសិក ដែលពោលយ៉ាងនេះថា ការវៀរចាកវចីទុច្ចរិតទាំង ៤ ឯណា រមែងលះការនិយាយខុស ធ្វើការនិយាយត្រូវឲ្យចម្រើន ។ កាលអប់រំសម្មាវាចាយ៉ាងនេះ អង្គទាំង ៥ ក៏មិនពេញលេញ រមែងបរិបូណ៌ ព្រមទាំងការវៀរចាកនុ៎ះឯង ។ សូម្បីក្នុងសម្មាកម្មន្តៈ និងសម្មាអាជីវៈ ក៏ទំនងនេះឯង ។ ដោយប្រការដូច្នេះ វចីកម្មជាដើម ក៏ជាធម៌បរិសុទ្ធតាំងអំពីខាងដើមនោះឯង ។

ចំណែកអង្គដែលឧបការៈដល់ធម៌ទាំង ៥ នេះ រមែងបរិបូណ៌ដោយអំណាចវិរតិចេតសិក ទើបពោលថា មគ្គដែលមានអង្គ ៥ មិនមាន ។ សូម្បីក្នុងសុភទ្ទសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា សុភទ្ទៈ ក្នុងធម្មវិន័យណា មានអរិយមគ្គប្រកបដោយអង្គ ៨ ។ និងព្រះសូត្រដទៃទាំងឡាយរយសូត្រ

ក៏មកហើយដោយមគ្គដែលមានអង្គ ៨ ប៉ុណ្ណោះ ។

**[៣០៤]** ពាក្យថា ***សតិប្បដ្ឋានសូម្បី ៤ យ៉ាង*** គឺ សតិប្បដ្ឋាន ៤ ដែលប្រកបព្រមដោយមគ្គនុ៎ះឯង ។ សូម្បីក្នុងសម្មាវាយាមៈជាដើម ក៏ទំនង ដូចគ្នានេះឯង ។ ពាក្យថា ***យុគនទ្ធា*** គឺ ជាធម៌គូទឹងគ្នា ដែលប្រកបក្នុង ខណៈជាមួយគ្នា ។ ធម៌ទាំងនោះ សូម្បីទឹងមានខណៈផ្សេងគ្នាយ៉ាងនេះ គឺ ក្នុងខណៈមួយជាសមាបត្តិ ក្នុងខណៈមួយជាវិបស្សនា ។ តែក្នុងអរិយមគ្គ ធម៌ទាំងនោះប្រកបក្នុងខណៈតែមួយ ។

**[៣០៦]** ពាក្យថា ***វិជ្ជា*** និង ***វិមុត្តិ*** បានដល់ វិជ្ជាក្នុងអរហត្តមគ្គ និង ផលវិមុត្តិ ។ ពាក្យដ៏សេសគ្រប់កន្លែង ងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា មហាសឡាយតនសូត្រទី ៧

# អ ដ្ឋ ក ថា

## នករវិន្ទេយ្យសូត្រទី ៨

[៣០៧] នគរវិន្ទេយ្យសូត្រ មានពាក្យជាដើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្តាប់មកហើយយ៉ាងនេះ ៖

ក្នុងសូត្រនោះ ពាក្យថា **សមវិសមំ ចរន្តិ** បានដល់ គ្រាខ្លះក៏ប្រព្រឹត្ត រៀបរយ គ្រាខ្លះក៏មិនរៀបរយ ។ ពាក្យថា **សមចរិយំបិ ហេតំ** កាត់បទជា **សមចរិយំបិ ហិ ឯតំ** ប្រែថា ក៏សូម្បីនេះ ក៏ជាការប្រព្រឹត្តរៀបរយ ។

[៣១០] ពាក្យថា **អាការពួកណា** គឺ ហេតុពួកណា ។ ពាក្យថា **កេ អន្វយា** ប្រែថា អ្វីដែលគប្បីតាមដឹង ។ ហេតុដូចម្តេចលោកទើបពោលថា ក៏ឯក្នុងព្រៃនោះមិនមានឡើយ កាមគុណ ៥ មានរូបជាដើម ដែលជាទីពេញ ចិត្តយ៉ាងក្រៃលែង ដោយអំណាចស្មៅពណ៌ខៀវ និងព្រៃចម្បាជាដើម ក៏មាន នៅក្នុងព្រៃនោះ មិនមែនឬ ។ មិនមែនមិនមាន ។ តែពាក្យនេះ លោកមិន បានសម្តែងដោយព្រៃ ។ តែលោកសំដៅយករូបស្ត្រីជាដើម ទើបពោលពាក្យ នេះ ។ ក៏រូបរបស់អ្នកស្ត្រីជាដើមទាំងនោះ គ្របសង្កត់ចិត្តរបស់បុរសហើយ

តាំងនៅ ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញរូបយ៉ាងដទៃ សូម្បីត្រឹមតែរូបមួយ ដែលគ្របសង្កត់ចិត្តបុរសហើយតាំងនៅយ៉ាងនេះ ដូចរូបស្ត្រីនេះឡើយ ម្នាលភិក្ខុទាំងឡាយ រូបស្ត្រីនេះ គ្របសង្កត់ចិត្តបុរសហើយតាំងនៅ គប្បីពង្រីកឲ្យពិស្តារ ។ ពាក្យដ៏សេសគ្រប់កន្លែង ងាយយល់ទាំងអស់ ។

ចប់អដ្ឋកថា នគរវិន្ទេយ្យសូត្រទី ៨

# អ ដ្ឋ ក ថា

## បិណ្ឌបាតបារិសុទ្ធិសូត្រទី ៩

**[៣១២]** *បិណ្ឌបាតបារិសុទ្ធិសូត្រ មានពាក្យជាដើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖*

*ក្នុងបទទាំងនោះ ពាក្យថា* ***ចេញចាកការពួនសម្ងំ*** *គឺ ចេញចាកផល-សមាបត្តិ ។ ពាក្យថា* ***ឥន្ទ្រិយរបស់អ្នកថ្លាផូរផង់*** *ទ្រង់ត្រាស់ដោយអំណាចឱកាស ។ ពិតហើយ ភិក្ខុដែលចេញចាកផលសមាបត្តិ មានឱកាសត្រង់បសាទទាំង ៥ តាំងនៅថ្លាផូរផង់ ពណ៌សម្បុរផូរផង់ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនោះ ។ ពាក្យថា* ***ដោយសុញ្ញតវិហារធម៌*** *គឺ ដោយធម៌ជាគ្រឿងនៅ គឺ ផលសមាបត្តិ ដែលមានសភាពសូន្យទទេជាអារម្មណ៍ ។*

**[៣១៣]** *ពាក្យថា* ***មហាបុរិសវិហារ*** *បានដល់ ធម៌ជាគ្រឿងនៅរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះមហាសាវករបស់ព្រះតថាគតជាមហាបុរស ។ ក្នុងពាក្យជាដើមថា* ***យេន ចាហំ មគ្គេន*** *បានដល់ ផ្លូវដែលចាប់តាំងពីវត្តទៅដរាបដល់សសរខឿននៃស្រុក នេះឈ្មោះថា ផ្លូវចូល ។ ប្រទេសដែលចូល*

ទៅខាងក្នុងស្រុក ត្រាច់ទៅតាមលំដាប់ផ្ទះ ដរាបដល់ផ្លូវចេញត្រង់ទ្វារក្រុង នេះឈ្មោះថា ប្រទេសដែលគប្បីត្រាច់ទៅ ។ តាំងពីក្រៅសសរខឿនមក រហូតដល់វត្ត នេះឈ្មោះថា ផ្លូវត្រឡប់ ។ ពាក្យថា **ក៏បដិឃៈ** គឺ សេចក្ដីទាំងថ្នាក់នៃចិត្ត សេចក្ដីថា អ្វីៗ ដែលកើតអំពីកិលេសជាហេតុឲ្យថ្នាំងថ្នាក់ចិត្ត មានឬមិនមាន ។ ពាក្យថា **ត្រូវសិក្សារឿយៗ ក្នុងកុសលធម៌ ទាំងពេលថ្ងៃ និងពេលយប់** គឺ ត្រូវតាមសិក្សារហូតទាំងថ្ងៃទាំងយប់ ។

**[៣១៥]** ក្នុងពាក្យជាដើមថា **យើងលះកាមគុណ ៥ ហើយឬហ្ន៎** សេចក្ដីថា ការពិចារណារបស់ភិក្ខុមួយរូប ក៏ផ្សេងគ្នាទៅ ។ ការពិចារណារបស់ភិក្ខុដទៃៗ ក៏មិនដូចគ្នា ។ យ៉ាងណា ។ ពិតហើយ ភិក្ខុមួយរូប ត្រឡប់មកពីបិណ្ឌបាតក្នុងបច្ឆាភត្ត រក្សាបាត្រចីវរ មកអង្គុយក្នុងឱកាសដែលស្ងៀមស្ងាត់ ហើយពិចារណាថា យើងបានលះកាមគុណ ៥ ហើយឬហ្ន៎ ។ លោកជ្រាបថា នៅមិនទាន់លះបង់បាន ទើបផ្គងសេចក្ដីព្យាយាមដកកាគៈដែលជាប់ទាក់ទងនឹងកាមគុណ ៥ ដោយអនាគាមិមគ្គ ចេញចាកទីនោះហើយ ក៏ពិចារណាផលបន្ទាប់អំពីមគ្គ ពិចារណាមគ្គបន្ទាប់អំពីផល ដឹងច្បាស់ថា លះបានហើយ ។ សូម្បីក្នុងនីវរណៈជាដើម ក៏ន័យដូចគ្នានេះឯង ។ តែការលះនីវរណៈទាំងនេះ

ជាដើម រមែងមានដោយអរហត្តមគ្គ ។ ការពិចារណាផ្សេងៗ របស់ភិក្ខុមួយរូប រមែងមានដោយវិធីនេះ ។ ឯក្នុងការពិចារណាទាំងនេះ ភិក្ខុរូបដទៃ រមែងពិចារណាគោលកម្មដ្ឋានសម្រាប់ពិចារណា ភិក្ខុរូបខ្លះក៏ពិចារណាកម្មដ្ឋានដទៃ ដូចពោលមកនេះ ។

ការពិចារណាផ្សេងៗ របស់ភិក្ខុផ្សេងគ្នា រមែងមានដោយប្រការដូច្នេះ ។ ពាក្យដ៏សេសគ្រប់ទីកន្លែង ងាយស្រួលយល់នោះឯង ។

ចប់អដ្ឋកថា បិណ្ឌបាតបារិសុទ្ធិសូត្រទី៩

# អ ដ្ឋ ក ថា

## ឥន្ទ្រិយភាវនាសូត្រទី ១០

**[៣២៨]** *ឥន្ទ្រិយភាវនាសូត្រ* មានពាក្យជាដើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្តាប់មកយ៉ាងនេះ ៖

ក្នុងព្រះសូត្រនោះ ពាក្យថា ក្នុង **ជង្គលា**[១] គឺ ក្នុងនិគមមានឈ្មោះ យ៉ាងនោះ ។

ពាក្យថា **ក្នុងព្រៃឫស្សី** បានដល់ ដើមឈើមួយប្រភេទឈ្មោះ វេឡុ ( គឺដើមឫស្សី ) ។ មានជង់ព្រៃធំ ដែលមានដើមឫស្សីទាំងនោះបិទបាំងហើយ ព្រះមានព្រះភាគប្រថាប់នៅក្នុងជង់ព្រៃនោះ ។

**[៣២៩]** ពាក្យថា **មិនឃើញរូបដោយចក្ខុ មិនឮសំឡេងដោយសោតៈ** លោកពោលអធិប្បាយថា ព្រះមានព្រះភាគ ទ្រង់សម្តែងយ៉ាងនេះថា មិនគប្បី មើលរូបដោយភ្នែក មិនគប្បីស្តាប់សំឡេងដោយត្រចៀក ។

**[៣៣០]** ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងការអប់រំឥន្ទ្រិយ ដែលមិន

---

១- បាលីជា កជង្គលា ។

មិនដូចក្នុងសាសនារបស់ព្រះអង្គ ទើបបានទ្រង់អាស្រ័យដោយបទនេះថា ក្នុងវិន័យរបស់ព្រះអរិយៈជាយ៉ាងដទៃ ។ ព្រះអានន្ទគិតថា ព្រះសាស្ដាទ្រង់អាស្រ័យដោយបទនេះ ណ្ហើយចុះ យើងនឹងទូលអារាធនាឲ្យទ្រង់សម្ដែងធម៌ជាប់ទាក់ទងនឹងការអប់រំឥន្ទ្រិយដល់ពួកភិក្ខុក្នុងបរិស័ទនេះ កាលនឹងទូលសូមអារាធនាដល់ព្រះសាស្ដា ទើបបានពោលពាក្យជាដើមថា **ឯតស្ស ភគវា** ។ លំដាប់នោះ កាលព្រះមានព្រះភាគ ទ្រង់នឹងសម្ដែងការអប់រំឥន្ទ្រិយដល់ភិក្ខុទាំងឡាយ ទើបត្រាស់ពាក្យជាដើមថា **បើដូច្នោះ អានន្ទ** ។

**[៣៣១]** ក្នុងព្រះសូត្រនោះ ពាក្យថា **នេះ គឺ ឧបេក្ខា** គឺ ឈ្មោះថាវិបស្សនូបេក្ខានេះឯង វិបស្សនូបេក្ខានេះស្ងប់ វិបស្សនូបបេក្ខានេះប្រណីត អធិប្បាយថា មិនធ្វើឲ្យក្ដៅក្រហាយ ។ ភិក្ខុនេះ មិនឲ្យចិត្តពេញចិត្តក្នុងអារម្មណ៍ដែលគួរប្រាថ្នាក្នុងរូបារម្មណ៍ ក្នុងចក្ខុទ្វារ មិនពេញចិត្តក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា និងពេញចិត្ត និងមិនពេញចិត្តក្នុងអារម្មណ៍កណ្ដាលៗ មិនឲ្យមានតម្រេក មិនប្រទូសរ៉ាយ ឬវង្វេងដល់ចិត្តនោះ កំណត់យកហើយ ផ្ដើមវិបស្សនាក្នុងភាពជាកណ្ដាល ។ ពាក្យថា **អ្នកមានភ្នែក** គឺ មានចក្ខុបរិបូណ៌ប្រាសចាកភាពងងឹត ។ ពិតហើយ អ្នកដែលឈឺភ្នែក នឹងបិទភ្នែក ឬបើកភ្នែក

ទៅខាងលើមិនបាន ។ ព្រោះដូច្នោះ ទើបមិនកាន់យកបុគ្គលនោះ ។

[៣៣៣] ពាក្យថា *ឰសកបោណេ* គឺ បានដល់តំណក់ទឹកដែលស្ថិតនៅខាងលើស្លឹកឈូក ។

[៣៣៨] ក្នុងពាក្យថា *ជាអ្នកសម្គាល់ក្នុងវត្ថុគួរខ្ពើម ថាជាវត្ថុមិនគួរខ្ពើម* ដោយការផ្សាយមេត្តា ឬដោយការយកជាតុមកប្រៀបផ្ទឹមគ្នា ក្នុងវត្ថុដែលគួរខ្ពើម ក៏រមែងជាអ្នកមានសេចក្ដីសម្គាល់ថា មិនគួរខ្ពើមបាន ។ ដោយការដោយចម្រើននូវអសុភ ឬដោយការបង្អោនចូលទៅ ដោយសភាពជារបស់មិនទៀង ក្នុងវត្ថុដែលមិនគួរខ្ពើម ក៏នឹងជាអ្នកមានសេចក្ដីសម្គាល់ថា គួរខ្ពើមបាន ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។ កាលវៀវត្ថុទាំងពីរចំណែកនោះបានដាច់ស្រឡះយ៉ាងនេះហើយ ជាអ្នកដាក់ខ្លួនជាកណ្ដាល តើប្រាថ្នាដើម្បីនឹងនៅធ្វើអ្វី ។ កាលវត្ថុគួរប្រាថ្នា និងវត្ថុមិនគួរប្រាថ្នាមកកាន់គន្លង ក៏នឹងក្លាយជាអ្នកមិនត្រេកអរ មិនប្រទូស្ដរ៉ាយ ។ សមពិតដូចព្រះពុទ្ធតម្រាស់ដែលត្រាស់ថា ភិក្ខុដែលមានសេចក្ដីសម្គាល់ក្នុងវត្ថុដែលគួរខ្ពើម ថាមិនគួរខ្ពើម តើដូចម្ដេច គឺ ភិក្ខុរមែងផ្សាយមេត្តា ឬបង្អោនចូលទៅដោយសភាពជាធាតុ ក្នុងវត្ថុដែលមិនគួរប្រាថ្នា ភិក្ខុ រមែងជាអ្នកមានសេចក្ដីសម្គាល់ក្នុងវត្ថុដែលគួរខ្ពើមថា មិនគួរខ្ពើមយ៉ាងនេះ ។ ភិក្ខុ មានសេចក្ដីសម្គាល់ក្នុងវត្ថុដែលមិនគួរខ្ពើម ថាគួរ

ខ្ពើម តើដូចម្តេច គឺ ភិក្ខុផ្សាយទៅនូវអសុភ ឬបង្អោនទាំចូលទៅដោយសភាព មិនទៀង ក្នុងវត្ថុដែលគួរប្រាថ្នា ភិក្ខុ រមែងមានសេចក្តីសម្គាល់ក្នុងវត្ថុដែលមិនគួរខ្ពើម ថាគួរខ្ពើមយ៉ាងនេះ ។ ភិក្ខុ ជាអ្នកមានសេចក្តីសម្គាល់ទាំងក្នុងវត្ថុដែលគួរខ្ពើម និងមិនគួរខ្ពើមថា មិនគួរខ្ពើម តើដូចម្តេច គឺ ភិក្ខុ រមែងផ្សាយមេត្តាទៅ ឬបង្អោនចូលទៅដោយសភាពជាធាតុ ទាំងក្នុងវត្ថុដែលមិនគួរប្រាថ្នា និងគួរប្រាថ្នា យ៉ាងនេះឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុដែលគួរខ្ពើម និងមិនគួរខ្ពើម ថាមិនគួរខ្ពើម ។ យ៉ាងណា ភិក្ខុឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុដែលមិនគួរខ្ពើម និងគួរខ្ពើម ថាគួរខ្ពើម គឺ ភិក្ខុផ្សាយអសុភទៅ ឬបង្អោនចូលទៅដោយសភាពជារបស់មិនទៀង ក្នុងវត្ថុដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា យ៉ាងនេះឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុមិនគួរខ្ពើម និងគួរខ្ពើម ថាគួរខ្ពើម ។ យ៉ាងណាឈ្មោះថា ភិក្ខុជាអ្នកព្រងើយ មានសតិសម្បជញ្ញៈ វៀរវត្ថុដែលគួរខ្ពើម មិនគួរខ្ពើម និងវត្ថុទាំងពីរយ៉ាងនោះបានយ៉ាងដាច់ស្រឡះ ។ គឺ ភិក្ខុក្នុងធម្មវិន័យនេះ ឃើញរូបដោយភ្នែកមិនត្រេកអរ មិនប្រទូសរ៉ាយ ជាអ្នកព្រងើយៗ មានសតិសម្បជញ្ញៈ ។ល។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត ក៏មិនត្រេកអរ មិនប្រទូសរ៉ាយទីងវត្ថុទាំងពីរយ៉ាងនោះ បានដាច់ស្រឡះ ជាអ្នកព្រងើយៗ មានសតិសម្បជញ្ញៈ ។

ក៏ឯសេចក្ដីសៅហ្មង គឺ សេចក្ដីពេញចិត្ត មិនពេញចិត្ត ទាំងពេញចិត្ត និងមិនពេញចិត្ត រមែងប្រើបានក្នុងន័យដំបូង ក្នុងបណ្ដាន័យទាំង ៣ នេះ ។ សេចក្ដីមិនសៅហ្មងក៏រមែងប្រើបាន ។

ក្នុងន័យទី ២ សន្និលេស រមែងប្រើបាន ។ ក្នុងន័យទី ៣ សេចក្ដីសៅហ្មង រមែងប្រើបាន ។ មានពាក្យដែលលោកពោលទុកទៀតថា សេចក្ដីសៅហ្មងទីមួយរមែងប្រើបាន សេចក្ដីសៅហ្មង និងសេចក្ដីមិនសៅហ្មងទីពីរក៏ប្រើបាន សេចក្ដីមិនសៅហ្មងទីបីប៉ុណ្ណោះ ទើបប្រើបាន ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា ឥន្ទ្រិយភាវនាសូត្រទី ១០

ចប់វគ្គទី ៥

រួមអដ្ឋកថាក្នុងសឡាយតនវគ្គនេះ

១-អនាថបិណ្ឌិកោវាទសូត្រ
២-ឆន្នោវាទសូត្រ
៣-បុណ្ណោវាទសូត្រ
៤-នន្ទកោវាទសូត្រ
៥-ចូឡរាហុលោវាទសូត្រ
៦-ឆឆក្កសូត្រ
៧-សឡាយតនវិភង្គ
៨-នគរវិន្ទេយ្យសូត្រ
៩-បិណ្ឌបាតបារិសុទ្ធិសូត្រ
១០-ឥន្ទ្រិយភាវនាសូត្រ

## ចប់អដ្ឋកថា ឧបរិបណ្ណាសកៈសូត្រ

ក្នុងអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះ បបញ្ចសូទនី

ចប់ទិបណ្ណាសកសុត្តន្តសង្គហដ្ឋកថា ដែលប្រដាប់ដោយ ៥ វគ្គ ។

*ក៏មជ្ឈិមនិកាយដែលហៅថា ឈ្មោះថា* ***មហាវិបស្សនា*** *នេះ មានលម្អ ៣ យ៉ាង គឺ ឈ្មោះថា មានលម្អក្នុងខាងដើម ព្រោះទ្រង់ផ្ដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងបរិយាយនូវឫសគល់របស់ធម៌ទាំងពួង ដល់អ្នកទាំងឡាយ , ក្នុងកណ្ដាល ឈ្មោះថា មានលម្អត្រង់កណ្ដាល ព្រោះពាក្យថា សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ , ឈ្មោះថា លម្អក្នុងខាងចុង ព្រោះពាក្យថា ព្រះអរិយៈអ្នកមានឥន្ទ្រិយដែលអប់រំហើយ ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងហើយនេះណា មជ្ឈិមនិកាយនោះ ជាការចប់បរិបូរណ៍ដោយអំណាចការពន្រឹកសេចក្ដីហើយ ។*

*ម្យ៉ាងទៀត ក៏ពាក្យពេចន៍មានប្រមាណប៉ុណ្ណេះ ខ្ញុំម្ចាស់ ដែលព្រះពុទ្ធមិត្តត្ថេរអ្នកមានបញ្ញាល្អហើយ ធ្លាប់នៅរួមគ្នាមកត្រង់កំពង់មយូរៈ សូមអារាធនាហើយ បានផ្ដើមធ្វើអដ្ឋកថា ឈ្មោះ* ***បបញ្ចសូទនីនៃមជ្ឈិមនិកាយ*** *ដ៏ប្រសើរ ជាការកម្ចាត់វាទៈរបស់អ្នកដទៃ ក៏ឯបបញ្ចសូទនីនោះ កាន់យកសារៈអំពីមហា-*

អដ្ឋកថា ចប់ស្រេចហើយ ។

ក៏អដ្ឋកថាឈ្មោះថា បបញ្ចសូទនីនោះ ចប់ស្រេចហើយដោយភាណវារៈទាំងឡាយ នៃបាលីប្រមាណ ១០៧ ។ សូម្បីវិសុទ្ធិមគ្គដែលមានប្រមាណ ៥៩ ដែលខ្ញុំរចនាគម្ពីរទុក ក៏ដើម្បីប្រយោជន៍នៃការប្រកាសសេចក្តីដោយភាណ-វារៈទាំងឡាយ ព្រោះហេតុនោះ អដ្ឋកថានេះ ព្រមទាំងវិសុទ្ធិមគ្គនោះ ដោយន័យនៃការរាប់គាថា គប្បីជ្រាបថា មាន ១៦៦ គាថា ពោលអំពីភាណវារៈ មានប្រមាណ ១៦៦ ភាណវារៈ ដោយប្រការដូច្នេះ ។ ខ្ញុំកាន់យកសារៈក្នុងមូល-អដ្ឋកថា ដែលប្រកាសលទ្ធិនៃព្រះថេរៈអ្នកនៅក្នុងមហាវិហារ រចនាអដ្ឋកថានេះ បានសម្រេចនូវបុណ្យណា ដោយអំណាចនៃបុណ្យនោះ សូមសត្វលោកបាននូវសេចក្តីសុខគ្រប់កាលចុះ ។ អដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះ **បបញ្ចសូទនី** នេះ ដែលព្រះថេរៈអ្នកប្រដាប់ដោយសទ្ធា បញ្ញា និងវីរិយៈដ៏បរិសុទ្ធិយ៉ាងក្រៃលែង ជាហេតុឲ្យកើតឡើងនៃគុណ មានសីល អាចារៈ សេចក្តីទៀងត្រង់ និងសេចក្តីទន់ភ្លន់ជាដើម ឲ្យកើតឡើងព្រមហើយ ជាអ្នកញាំងកំពង់ គឺ លទ្ធិរបស់ខ្លួន និងលទ្ធិរបស់អ្នកដទៃ អ្នកប្រកបដោយសេចក្តីដឹងជាក់ច្បាស់ និងសេចក្តីឆ្លាតឈ្លាស អ្នកមានសេចក្តីដឹង ដែលមិនមានអ្វីៗ ឬអ្នកណាមកជំទាស់

បាន ក្នុងសាសនារបស់ព្រះសាស្តា ព្រមទាំងអដ្ឋកថា ជាអ្នកច្លាតឈ្លាសដោយការរៀនសូត្របិដកទាំងបី ជាអ្នកឈ្លាសក្នុងមហាវេយ្យាករណ៍ ជាអ្នកប្រកបដោយសេចក្តីស្រស់បំព្រងនៃពាក្យនិយាយ ដែលមានពាក្យពេចន៍ដ៏ពីរោះ ឲ្យកើតសេចក្តីសុខដែលដល់ព្រមនៃការធ្វើ អ្នកមានវាទៈដែលពោលយ៉ាងត្រឹមត្រូវ ជាអ្នកប្រសើរជាងពួកអ្នកនិយាយ ជាមហាកវី ជាអ្នកប្រដាប់វង្សនៃភិក្ខុមហាវិហារ ជាត្ថេរៈ ជាអ្នកបំភ្លឺនៃថេរវង្សអ្នកមានសេចក្តីដឹងតាំងមាំល្អហើយ ក្នុងឧត្តរិមនុស្សធម៌ ដែលប្រដាប់ដោយគុណផ្សេងៗ មានអភិញ្ញា ៦ ជាដើម មានបញ្ញាជាគ្រឿងបែកធ្លាយ ដែលមានការបែកធ្លាយហើយជាបរិវារ អ្នកមានបញ្ញាបរិសុទ្ធិធំទូលាយ ជាអ្នកមាននាមធេយ្យៈ ដែលពួកគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោសៈ** បានធ្វើ (តែង) ទុកហើយ ។

សូម្បីព្រះនាមថា **ពុទ្ធៈ** របស់ព្រះពុទ្ធអ្នកមានព្រះហឫទ័យ
ស្អាត ជាតាទិបុគ្គល ជាអ្នកបម្រើនបំផុតក្នុងលោក អ្នកស្វែង
រកគុណដ៏ធំក្រៃលែង ប្រព្រឹត្តទៅក្នុងលោក នៅដរាបណា
សូមបបញ្ចសូទនីនេះ សម្តែងន័យនៃសេចក្តីបរិសុទ្ធិ នៃការ
ឃើញរបស់ពួកកុលបុត្រអ្នកស្វែងរកគុណ ជាគ្រឿងនាំចេញ

*ចាកលោក ចូរតាំងនៅក្នុងលោកដ៏ពេញនោះ ។*

*សូមអដ្ឋកថា ឈ្មោះ **បបញ្ចសូទនី** នេះ ចូលដល់ស្ថានដែលបរិសុទ្ធិប្រាសចាកអន្តរាយ សូមសេចក្តីត្រិះរិះទាំងឡាយដែលអាស្រ័យធម៌របស់ពួកសត្វចូរសម្រេចយ៉ាងនោះចុះហោង ។*

ចប់អដ្ឋកថា មជ្ឈិមនិកាយ ឈ្មោះ បបញ្ចសូទនី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងរ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់ | $ 700 US |
| -ម៉ៅ ម៉ារ៉ា និងស្មៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត | |
| -ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមស្មៀង | |
| -ម៉ៅ ប៊ុនសន្ថា ក្លួយស្រី ធន់ សន្ថានី | |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម គឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គីម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -ឧបាសិកា តាំង ផល្លា ព្រមទាំងស្វាមី និងបុត្ត | $ 10 US |
| -ឧបាសក តាំង សុខឡាយ ភរិយា និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផាអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈួ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

## តាមរយៈភិក្ខុចិត្តរក្សិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ភិក្ខុ ចៅ សៀប " អូស្ត្រាលី " | 100 AUS |
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលបិន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -ឧបសិកា គង់ សារឿម | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -ឧបាសិកា កូវ សារី | 100 AUS |
| -ឧបាសិកា ឈ គិមស៊ិន និងបុត្ត សំ ថានី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឌី មុយ ឧបាសិកា តែ ចាន់ណារ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាបួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ាន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉ោគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃឹម វីឡាត់ | 50 AUS |
| -ឧបាសក តូ សវ៉ើន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គីម លាភ (មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |

| | |
|---|---|
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គឹម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភាវ ឧបាសិកា កាំង គឹមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារីម | 15 AUS |
| -ចៃស៊ីម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ្គិច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា ស៊ា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អ៊ុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងីមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វ៉ាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |

